# ប្រវត្តិពុទ្ធឧបាសិកា

# ភាគទី ២



ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា
អាត្មាភាព **យង់ សុផាត**

# ប្រវត្តិពុទ្ធឧបាសិកា

# ភាគទី ២

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា

អាត្មាភាព **យង់ សុផាត**

សម្រាប់ជាធម្មទាន

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ
លេខ : ២២៥ សរ៧

រាជធានីភ្នំពេញ,ថ្ងៃទី...០៤...ខែ...កុម្ភៈ...ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា
## ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**<u>កម្មវត្ថុ</u>** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ។

**<u>យោង</u>** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្ដីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្ដាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***<u>ចម្លងជូន</u>*** :
- ទីស្ដីការគណៈរដ្ឋមន្ត្រី
"<u>ដើម្បីជូនជ្រាប</u>"
- សាលាខេត្តបាត់ដំបង
"<u>ដើម្បីមុខការ</u>"
-ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

សៀវភៅប្រវត្តិពុទ្ធឧបាសិកា ឬប្រវត្តិរបស់ឧបាសិកា **ភាគ ២ នេះ** មានប្រវត្តិរបស់ឧបាសិកាជាឯតទគ្គៈក៏មាន មិនមែនជាឯតទគ្គៈក៏មានដែរ មានខ្លឹមសារជាប្រវត្តិរឿងរ៉ាវរបស់ឧបាសិកា នាសម័យពុទ្ធកាល ដែលបានទទួលតំណែងជាឯតទគ្គៈ ហើយមានឈ្មោះល្បីល្បាញ នាសម័យនោះ ថែមទាំងជាអ្នកជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ឲ្យបានរុងរឿងចម្រើន ដល់ពុទ្ធបរិស័ទ នៅក្នុងសម័យនោះផងដែរ ។

ក្នុងសម័យនោះ ពុទ្ធបរិស័ទដ៏ច្រើន សុទ្ធតែបានស្គាល់តំណែង ឬភាពអស្ចារ្យ នៃឧបាសិកាទាំងអស់នោះ ដោយថា អ្នកខ្លះ បានស្ដាប់ព្រះធម៌របស់ឧបាសិកា អ្នកខ្លះបានធ្វើធម្មសាកច្ឆាជាដើម ។ ប៉ុន្តែ ឥឡូវនេះ ភាពអស្ចារ្យរបស់ឧបាសិកាខ្លះៗ ពុទ្ធបរិស័ទក្នុងសម័យនេះ ស្ទើរតែលែងស្គាល់អស់ទៅហើយ ដោយសារហេតុនេះ សៀវភៅនេះនឹងបានជាពន្លឺជំនួយឲ្យដល់ពុទ្ធបរិស័ទ បានស្គាល់ច្បាស់នូវភាពអស្ចារ្យ តួនាទី ចរិយាអធ្យាស្រ័យ វត្តបដិបត្តិ និងការសម្ដែងព្រះធម៌ផ្សេងៗ របស់ឧបាសិកាទាំងអស់នោះ ដែលមានសម្ដែងទុកនៅក្នុង **គម្ពីរព្រះត្រៃបិដក** និងក្នុង

**អដ្ឋកថា** ជាដើម ព្រោះថា ព្រះពុទ្ធសាសនា ដែលចម្រើនរុងរឿងនោះ ក៏អាស្រ័យមានអ្នកចងចាំ បដិបត្តិតាម និងចេះសម្តែងព្រះធម៌ ឲ្យដល់អ្នកដទៃបានស្តាប់ មិនមែនដោយប្រការដទៃទេ ដូច្នេះ ឧបាសិកាទាំងអស់នោះ ជាសក្ខីភាព បញ្ជាក់ឲ្យដឹងបានថា ព្រះពុទ្ធសាសនា ដែលរុងរឿងនៅក្នុងសម័យនោះ ក៏ដោយសារឧបាសិកាផងដែរ ទើបខ្ញុំព្រះករុណាអាត្មាភាព ខំប្រឹងប្រែងស្វែងរកក្បួនច្បាប់មកចងក្រង ទុកជាពន្លឺដល់ពុទ្ធបរិស័ទក្នុងសម័យនេះ ។

សៀវភៅនេះ ខ្ញុំមិនអាចដាក់កាសាបាលីផងបានទេ ព្រោះថាមានសេចក្តីពិស្តារពេក បើអ្នកសិក្សាត្រូវការភាសាបាលី ចូរតាមរកមើលក្នុង **គម្ពីរព្រះត្រៃបិដក** និង **អដ្ឋកថា** ក្នុងចំណុចដែលលើកឡើងមកនីមួយៗ ចុះ ព្រោះគ្រប់ចំណុច ដែលលើកឡើងមកនោះ សុទ្ធតែបានប្រាប់ពី **គម្ពីរ** ឬច្បាប់ដើម ជាមូលដ្ឋានរួចអស់ហើយ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែង ក៏ប្រសើរជាងអត់ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត

ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់នៅមានខុសមិនខាន ជួនដោយចេះមិនដល់ ជួនដោយការភ្លេចភ្លាំង ជាពិសេសនោះគឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិតជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

**សូមអស់មិត្តអ្នកអាន** បានទទួលនូវការចេះដឹង ជាគ្រឿងរំឭកផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់ព្រះនិព្វាន ដែលជាបរិយោសាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណាអាត្មាភាព បានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤**

**សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ ៦៤៥ ដុល្លារសហរដ្ឋអាមេរិក ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទនៅប្រមាណ ៦៥ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ១០ ព្រះអង្គផងដែរ** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស** *ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅ* **ថ្វាយបង្គំបាន ៥១ កន្លែង** *បានការឧបត្ថម្ភអំពីឧបាសក* **ឡាយ សុខុម** *និងឧបាសិកា* **ឌិម លក្ខណា** *នៅក្នុង* **ព.ស. ២៥៥០** *( ១០.០២.២០០៧ ) ។*

## **នឹកឃើញស្រុកព្រះ**

*នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា*
*សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា*
*ជ្រះថ្លាក្រៃលែង ។*
*៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង*
*នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក*
*ក្នុង ព.ស. ២៥៥០ ។*

*នៅមានបុណ្យកុសលនៅក្នុង* **ព.ស. ២៥៥១** *ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង* **ព.ស. ២៥៥០** *ដែរ ដោយសរុបប្រាក់នៅក្នុង* **ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល** *(* **១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល** *)* *និង* **ប្រាក់ដុល្លារ ៤៥ ដុល្លារ ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសស្រីលង្កា** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស** *ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **១២១ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ៤ ព្រះអង្គផងដែរ** *ដោយទៅថ្វាយបង្គំបាន* **១៩ កន្លែង** *បានការឧបត្ថម្ភមកអំពីឧបាសក* **ឡាយ សុខុម** *និងឧបាសក* **សោម រតនៈ** *ឧបាសិកា* **ស៊ិម ចណ្ណា** *នៅក្នុង* **ព.ស. ២៥៥១** *( ០៤.០៤.២០០៨ ) ។*

## នឹកឃើញលង្កា

*នឹកឃើញលង្កា នឹកឃើញកាលណា ជ្រះថ្លាក្រៃលែង*
*នៅពុទ្ធស្ថាន ១៩ កន្លែង ដែលខ្ញុំបានស្វែង*
*ទៅថ្វាយបង្គំ ។*

១២១ អង្គា គាល់ព្រះបាទា នាស្ថានមនោរម
លើសុមនកូដ ជេស្ដាឧត្ដម ជាកំពូលភ្នំ
ក្នុងប្រវត្តិពុទ្ធ ។
ទឹកដីលង្កា ទឹកដីអស្ចារ្យ ពេញពោរដោយឫទ្ធិ
នឹកឃើញកាលណា ជ្រះថ្លាក្រៃពិត ធម្មយាត្រាប្រណីត
ក្នុង ព.ស. ២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥១ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល (២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាលើកទី ២** ដែលមានលោកគ្រូអគ្គបណ្ឌិត **ម៉ិត សាខឡ** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥**

ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក យឹត ស្វូណោត ឧបាសិកា ហ៊្វន ម៉ាវ៉ាវនី M. SU SOKUNORA et MmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា អ៊ុំ រិទ្ធារី ឧបាសិកា ស្ងួន គល្យាណ ឧបាសិកា ស្ងួន ចរណៃ នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសកកាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នាទមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាលើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុខុផារត** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

៣៦ នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ៣ ព្រះអង្គផងដែរ បាន ការឧបត្ថម្ភមកអំពីឧបាសក ឆាយ អ៊ីចស៊ាង ឧបាសិកា ហុង គឹមសែ ក្រោមការជ្រោមជ្រែងរបស់ឧបាសក យន្ត សួន នៅក្នុង ព.ស. ២៥៥២ ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៣ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥២ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៣ ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( ១៣ លាន ០ សែន ៨ ម៉ឺន) និងប្រាក់ដុល្លារ ២០៨ ដុល្លារ ។នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌាលើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៦ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៣ ( ២៥.០១.២០១០ ) ។

## ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងៀមស្ងាត់អស្ចារ្យ
ឱះឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គ ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាលើកទី ៤** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥** ព្រះអង្គផងដែរ ដោយទៅ

ថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

## គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាន
ប្រៀបបានព្រៃស្ងាត់ ។

២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៥ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥៤ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៥ ប្រាក់ខ្មែរបាន ៣៥,២៨២០០០ រៀល ( ៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់រៀល ) និងប្រាក់ដុល្លារ ២៧៥៨ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំ

នៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាលើកទី ៥** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅ ប្រមាណ **៦៨ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **១៤ កន្លែងធំៗ** បានការជ្រោមជ្រែងមកពីឧបាសិកា **អ៊ឹង រិទ្ធារី** នៅក្នុង ព.ស. **២៥៥៥** ( ០២.០២.២០១២ ) ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១៤០ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ១៥** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩ កន្លែងធំៗ** បានការឧបត្ថម្ភមកអំពីឧបាសិកា **អ៊ឹង រិទ្ធារី** នៅក្នុង **ព.ស.២៥៥៥** ( ២៧.០៣.២០១២ ) ។

ឋ

# បានយល់ស្រុកព្រះ

| | | |
|---|---|---|
| ជ្រះថ្លាខ្លាំងណាស់ | បានយល់ស្រុកព្រះ | ជាតិភូមិសាស្ដា |
| ១៤ កន្លែង | ៦៨ អង្គា | បានក្រាបវន្ទា |
| | បូជាគ្រប់ប្រាណ ។ | |
| សិរីលង្កា | ១៤០ អង្គា | ៩ ពុទ្ធស្ថាន |
| ជ្រះថ្លាខ្លាំងណាស់ | ដែលពួកខ្ញុំបាន | នមស្ការពុទ្ធស្ថាន |
| | ក្នុងពុទ្ធសករាជ ២៥៥៥ ។ | |

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិស មហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យង់ សួង** ( ស្លាប់ ) និងញោមស្រី **ឈឹម ហាយ** ( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុង សង្សារវដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូន ចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីច** ជាដើម សូមឲ្យបាននូវ

ចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគតកុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណាទីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១ ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាល្អួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គឹម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ម៉ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន ចន្ទ្រនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វៃយ៉ា ជាទីប្រឹក្សាក្នុងកិច្ចការផារជម្មទាន

ឧបាសក សន ឈៀត ជួយប្រែ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ប្ដូ ស៊ីដ្ឋ ជួយពិនិត្យអក្ខរាវិរុទ្ធ

លោកគ្រូធម្មាចារ្យ គាំ អ៊ីច ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឌិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រឹម សុមេធ ជួយពិនិត្យអក្ខរាវិរុទ្ធ

# សមាជិកសមាគមធម្មទានអរិយវង្សយ៉េស្វផាត

*សម្តេចព្រះសង្ឃរាជគណមហានិកាយ* **នន្ទ ង៉ែត** *ជាប្រធានកិត្តិយស*

*ភិក្ខុ អគ្គបណ្ឌិតោ* **យ៉េ ស្វផាត** *ជាប្រធានសមាគម*

*លោកអភិបាលស្រុក* **ស្រេង ស្រ៊ាង** *ជាទីប្រឹក្សាសមាគម*

*ឧបាសក* **អ៊ឹម វ៉ៃយ៉ោ** *ជាអនុប្រធានសមាគម*

*ឧបាសិកា* **ង៉ែត យូអេង** *ជាអនុប្រធានសមាគម*

*សាមណេរ* **ម៉ី សាល្វួន** *ជាលេខាធិការ*

*ឧបាសក* **ឡាន ស្វុខុម** *ជាលេខាធិការរង*

*ឧបាសិកា* **តាំង ម៉េងជីង** *ជាហេរញ្ញិក*

*ឧបាសិកា* **ជា នាង** *ជាបេឡា*

*លោកគ្រូធម្មបណ្ឌិត* **អឿ សៅ** *សមាជិកកិត្តិយស និងឧបការគុណ*

*ឧបាសក* **ឡាយ ស្វុខុម** *សមាជិកកិត្តិយស និងឧបការគុណ*

*ឧបាសិកា* **អ៊ុង រិទ្ធារី** *សមាជិកកិត្តិយស និងឧបការគុណ*

*ឧបាសិកា* **ហោ ភាព** *សមាជិកកិត្តិយស និងឧបការគុណ*

*ឧបាសិកា* **គួ ប៊ុនគាង** *សមាជិកកិត្តិយស និងឧបការគុណ*

*ឧបាសិកា* **ឈុំ គីមហួយ** *សមាជិកកិត្តិយស និងឧបការគុណ*

ឧបាសិកា ម៉ែន រមណីយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឌិម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ុង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មាស ម៉ូនីតា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឡឹត ពេញចិត្ត សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា សៀត ឆាយគីម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក បញ្ញា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា តែង ភល្យណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហួង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហួង សុវណ្ណារ៉ែត ជាសមាជិកសកម្ម

# មាតិការឿង

ល.រ ទំព័រ


១- ឈ្មោះរបស់ឧបាសិកា ............................................ ទ

២- ជីវប្រវត្តិរបស់ឧបាសិកាខុជ្ជុត្តរា ................................ ១

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកចេះដឹងច្រើន

៣- ជីវប្រវត្តិរបស់ព្រះនាងសាមាវតី ................................ ២៣

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកនៅដោយមេត្តា

៤- ជីវប្រវត្តិរបស់ឧបាសិកាឧត្តរានន្ទមាតា ...................... ១៦៧

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកត្រេកអរក្នុងឈាន

៥- ជីវប្រវត្តិរបស់នាងសុប្បវាសាកោលិយធីតា ............. ២១៨

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកឲ្យទានផ្ចិតផ្ចង់

៦

# ជីវប្រវត្តិពុទ្ធឧបាសិកា ឬជីវប្រវត្តិរបស់ឧបាសិកា

មានឈ្មោះ ឧបាសិកា សុជាតា និងឧបាសិកា វិសាខា ជាដើម សុទ្ធសឹងតែជាឧបាសិកាដែលមានជំនាញឯកទេស ដែលគ្មានអ្នកដទៃប្រដូចបាន បាលីហៅថា **ឯតទគ្គៈ** គឺបានដល់ភាពប្រសើររបស់ឧបាសិកាម្នាក់ៗ ដូចជាឧបាសិកា សុជាតា ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងអ្នកដល់សរណៈជាបឋម ឧបាសិកា វិសាខា ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងការឲ្យទានដូច្នេះជាដើម ។

ដូច្នេះ ពុទ្ធឧបាសិការបស់ព្រះបរមគ្រូនៃយើងនេះ មានឈ្មោះរបស់លោកដូចខាងក្រោមនេះ គឺ

១- ឧបាសិកា សុជាតា
២- ឧបាសិកា វិសាខា
៣- ឧបាសិកា ខុជ្ជុត្តរា
៤- ឧបាសិកា ឧត្តរា
៥- ឧបាសិកា សុប្បវាសា
៦- ឧបាសិកា សុប្បិយា
៧- ឧបាសិកា កាតិយានី
៨- ឧបាសិកា កុលមាតាគហបតានី

៩- ឧបាសិកា កាឡី

១០- ឧបាសិកា មល្លិកាទេវី

១១-ឧបាសិកា សាមាវតី

១២- ឧបាសិកា ចុន្ទីរាជកុមារី

១៣- ឧបាសិកា រោហិណី

១៤- ឧបាសិកា សុមនារាជកុមារី

១៥- ឧបាសិកា ចូឡសុភទ្ទា

១៦- ឧបាសិកា បតិបូជិកា

១៧- ឧបាសិកា បុណ្ណទាសី

១៨- ឧបាសិកា បេសការធិតា

១៩- ឧបាសិកា បេសការី

២០- ឧបាសិកា មល្លិកា

២១- ឧបាសិកា មាតិកមាតា

២២- ឧបាសិកា សុត្តរ

២៣- ឧបាសិកា រជ្ជុមាលា

២៤- ឧបាសិកា លខុមា

២៥- ឧបាសិកា លតា

២៦- ឧបាសិកា សារីព្រាហ្មណី

២៧- ឧបាសិកា សិរិមា

២៨- ឧបាសិកា សុជាតា

២៩- ឧបាសិកា សុនន្ទា

៣០- ឧបាសិកា សុភទ្ទា

៣១- ឧបាសិកា សេសវតី

# ✍ ជីវប្រវត្តិរបស់ឧបាសិកាខុជ្ជុត្តរា ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកចេះដឹងច្រើន "

*ឧបាសិកាខុជ្ជុត្តរា ជាអ្នកមានបញ្ញាវាងវៃ ហើយក៏ជាអច្ឆរិយបុគ្គល ថែមទាំងជាអ្នកបានទទួលការលើកតម្កើង ឲ្យជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងពហូសូត ( ពហុស្សុត ) ជាអ្នករៀនសូត្រច្រើន ជាអ្នកមានភាពអង់អាចធ្វើខ្លួនឲ្យជាទីគោរពរបស់ស្ត្រីទាំងឡាយ មានព្រះនាងសាមាវតីជាដើម ។*

*ជីវប្រវត្តិរបស់ឧបាសិកាខុជ្ជុត្តរា មានសម្ដែងនៅក្នុង* ***អដ្ឋកថាមនោរថបូរណី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលី គម្ពីរ* ***អង្គុត្តរនិកាយ ឯកនិបាត*** *ដូចមានសេចក្ដីថា ៖*

*ឧបាសិកាខុជ្ជុត្តរា មានជីវប្រវត្តិអតីតជាតិពោលរួមជាមួយនឹងព្រះនាងសាមាវតីថា មានបុគ្គលទាំងឡាយពីរនាក់ បានមកចុះចាប់បដិសន្ធិ នៅក្នុងផ្ទះរបស់អ្នកមានធនធានម្នាក់ នៅក្នុងក្រុងហង្សវតី*

ដែលកើតឡើងនៅក្នុងជាតិនោះ គឺត្រូវនឹងពុទ្ធកាលរបស់ព្រះបទុមុត្តរសម្មាសម្ពុទ្ធ ។ លុះក្រោយមក ក្នុងបណ្តាកុលធីតាទាំងពីរនាក់នោះ ឧបាសិកាខុជ្ជុត្តរា បានឃើញព្រះបទុមុត្តរសម្ពុទ្ធ ព្រះអង្គទ្រង់ប្រកាសតែងតាំងឧបាសិកាម្នាក់ ទុកក្នុងតំណែងដ៏ប្រសើរជាងឧបាសិកាទាំងឡាយផ្នែកខាងជាអ្នកចេះដឹងច្រើន ( ពហូសូត ) ។ ក្នុងពេលនោះ នាងកុលធីតាខុជ្ជុត្តរា កាលបើឃើញដូច្នោះហើយ ក៏កើតមានការពេញចិត្តនៅក្នុងតំណែងនោះ ទើបបានធ្វើបុណ្យកុសលផ្សេងៗ ហើយបានតាំងចិត្តប្រាថ្នានៅក្នុងតំណែងនោះ ជាពិសេសនោះ នាងបានធ្វើបុណ្យកុសលតជាប់មក រហូតដល់អស់ជីវិតរបស់ខ្លួន ។ កាលនាងកុលធីតាអស់ជីវិតទៅហើយបានទៅកើតនៅក្នុងទេវលោកហើយដោយបុណ្យកុសលទាំងនោះ បានធ្វើឲ្យនាងស្លាប់កើតក្នុងកំណើតជាមនុស្ស និងទេវតាប៉ុណ្ណោះអស់មួយសែនកប្ប ( គឺរាប់ថយក្រោយពីកទ្រកប្បនេះ ) ។ លុះមកដល់ពុទ្ធកាលព្រះសមណគោតមបរមគ្រូនៃយើងនេះ នាងខុជ្ជុត្តរាទេពធីតាបានចុតិចាកទេវលោកមកបដិសន្ធិ នៅក្នុងគភ៌នៃមេនំ ក្នុងផ្ទះរបស់

ឃោសកសេដ្ឋី នៅក្នុងក្រុងកោសម្ពី ។ តែនាងជាអ្នកមានរាងកាយមិនប្រក្រតីដូចមនុស្សទូទៅ គឺនាងជាអ្នកមានរាងកាយជា **ខុជ្ជា** ប្រែថា **គម** បានដល់ ពេលដែលនាងកើតមក នាងមានរាងកាយខុសប្រក្រតីធម្មតា គឺនាងមានខ្នងគម ដោយអាស្រ័យហេតុនេះ ពពួកញាតិបានដាក់ឈ្មោះឲ្យនាងថា **នាងខុជ្ជុត្តរា** ។

ជីវប្រវត្តិរបស់នាងខុជ្ជុត្តរា វគ្គតទៅនេះ ក្រៅអំពីមានពោលនៅក្នុង **អដ្ឋកថាមនោរថបូរណី** ហើយ មានសម្ដែងនៅក្នុង **អដ្ឋកថាគម្ពីរធម្មបទ** ក្នុង **អប្បមាទវគ្គ** នៅក្នុង **រឿងរបស់ព្រះនាងសាមាវតី** ដូចមានសេចក្ដីថា ៖

នាងខុជ្ជុត្តរា កាលបើចម្រើនវ័យធំដឹងក្ដីហើយ នាងបានជាស្រីបម្រើរបស់ព្រះនាងសាមាវតី ក្នុងជំណើរដែលព្រះនាងសាមាវតីបានជាបុត្រីចិញ្ចឹមរបស់ឃោសកសេដ្ឋី ព្រមដោយស្រីដែលជាបរិវារប្រមាណ ៥០០ នាក់ ។ នាងខុជ្ជុត្តរាបានទទួលនាទីជាអ្នកទិញផ្កាពីផ្ទះរបស់នាយសុមនមាលាការ ហើយនាំយកទៅថ្វាយដល់ព្រះនាងសាមាវតីជាប្រចាំ

រៀងរាល់ថ្ងៃ ។ ចំណែកព្រះបាទឧទេនបានព្រះរាជទាន ព្រះរាជទ្រព្យមួយថ្ងៃៗ ៨កហាបណៈ ឲ្យជាតម្លៃផ្កាដល់ព្រះនាងសាមាវតីរៀងរាល់ថ្ងៃ ។ ថ្ងៃមួយ នាងខុជ្ជុត្តរាបានកាន់ប្រាក់ ៨ កហាបណៈ ទៅកាន់ផ្ទះរបស់នាយសុមនមាលាការដើម្បីទិញផ្កា តាមប្រក្រតីដែលខ្លួនធ្លាប់ធ្វើមកហើយជាប្រចាំរៀងរាល់ថ្ងៃ ។ ថៃដន្យថ្ងៃនោះ នាយសុមនមាលាការបានក្រាបទូលនិមន្តព្រះមានព្រះភាគ ព្រមដោយភិក្ខុសង្ឃឲ្យមកទទួលភត្តាហារនៅក្នុងផ្ទះរបស់ខ្លួន ។ លុះនាយសុមនមាលាការ បានក្រឡេកឃើញនាងខុជ្ជុត្តរាហើយ ទើបនិយាយប្រាប់នាងថា នាងខុជ្ជុត្តរា ថ្ងៃនេះខ្ញុំមិនមានពេលវេលាធ្វើកម្រងផ្កាឲ្យដល់នាងទេ ព្រោះខ្ញុំកំពុងតែបាត់ចែងរៀបចំភត្តាហារថ្វាយដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាព្រះប្រធាន សូមនាងទៅចូលរួមនៅក្នុងកម្មវិធីបុណ្យនោះផង ដែលមានការអង្គាសចង្ហាន់ថ្វាយដល់ភិក្ខុសង្ឃ និងស្តាប់ព្រះធម៌សិនចុះ នាងនឹងបានរួចផុតពីភាពជាអ្នកបម្រើរបស់អ្នកដទៃ ដោយការជួយធ្វើកិច្ចការបម្រើព្រះភិក្ខុសង្ឃ នាងនឹងបានទទួលយកកម្រងផ្កាក្រោយអំពីកិច្ចការងារនេះ

ហើយ ។ នាងខុជ្ជុត្តរាកាល បើឮដូច្នេះ នាងក៏បានជួយធ្វើការខ្វល់ខ្វាយនៅក្នុងផ្ទះបាយ និងបានបរិភោគអាហារនៅទីនោះផងដែរ ចំណែកនាយសុមនមាលាការ បានអង្គាសបច្ច័យប្រគេនថ្វាយដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាព្រះប្រធានរួចហើយ ទើបទទួលបាត្រមកដើម្បីជាប្រយោជន៍ក្នុងការធ្វើអនុមោទនា ។ គ្រានោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ក៏បានផ្ដើមសម្ដែងព្រះធម៌ទេសនា ជាការអនុមោទនា ។ ក្នុងពេលនោះដែរ នាងខុជ្ជុត្តរាក៏បានស្ដាប់នូវធម្មកថារបស់ព្រះលោកនាថ ថែមទាំងបានចាំនូវធម្មកថាទាំងអស់នោះទៀតផង ហើយជាពិសេសនោះ នាងបានតាំងនៅក្នុងសោតាបត្តិផល ដែលហៅថាព្រះសោតាបន្ន ។ ក្នុងថ្ងៃមុនៗ មក នាងខុជ្ជុត្តរាតែងតែបានកិបយកប្រាក់ទុកក្នុងមួយថ្ងៃៗ ៤ កហាបណៈ ដោយនាងបានទិញផ្កាក្នុងមួយថ្ងៃៗ តែ ៤ កហាបណៈប៉ុណ្ណោះ ។ ប៉ុន្តែក្នុងថ្ងៃដែលនាងបានសម្រេចជាព្រះសោតាបន្នហើយ នាងក៏បានទិញផ្កានោះដោយប្រាក់ទាំង ៨ កហាបណៈ ព្រោះនាងមិនមានចិត្តគិតបង់បានទ្រព្យរបស់អ្នកដទៃ ដោយហេតុដែលខ្លួនបានឃើញអរិយសច្ចៈ ទើបយកប្រាក់

ទាំងអស់នោះទៅទិញផ្កា ក៏ធ្វើឲ្យបានផ្កាពេញកំប្រោង ឬកន្ត្រក ហើយ នាងនាំយកទៅកាន់សម្នាក់របស់នាងសាមាវតី ។ គ្រានោះ ព្រះនាង សាមាវតី ទើបត្រាស់សួរនាងខុជ្ជុត្តរាថា នែនាងខុជ្ជុត្តរា ក្នុងថ្ងៃមុនៗ នាងមិនបាននាំយកផ្កាដ៏ច្រើនយ៉ាងនេះមកទេ តែក្នុងថ្ងៃនេះ នាងបាន នាំយកផ្កាយ៉ាងច្រើនមក ព្រះរាជាព្រះរាជទានតម្លៃផ្កាដល់យើងបន្ថែម ឡើងស្មើពីរដងឬ ? ពេលនោះ នាងខុជ្ជុត្តរាត្រូវក្រាបបង្គំទូលសេចក្តីពិត ទាំងអស់ ដោយមិនបិទបាំង ប្រាប់ឲ្យយល់នូវអំពើដែលខ្លួនធ្វើមិនល្អ មកហើយក្នុងកាលមុន ព្រោះខ្លួនមិនគួរពោលពាក្យកុហក ទើបក្រាបបង្គំ ទូលថា ព្រះពរម្ចាស់ សូមព្រះនាងទ្រង់ជ្រាបនូវសេចក្តីនេះ ។ ព្រះនាង សាមាវតីត្រាស់សួរថា នែនាងខុជ្ជុត្តរា កាលបើដូចនេះ ព្រោះហេតុអ្វី នាងទើបបានផ្កាមកច្រើនយ៉ាងនេះ ? នាងខុជ្ជុត្តរាក្រាបបង្គំទូលតបថា បពិត្រព្រះនាងម្ចាស់ ក្នុងថ្ងៃមុនៗ រួចមកហើយ ខ្ញុំម្ចាស់បានកិបយក កហាបណៈទុកជារបស់ខ្លួនមួយថ្ងៃៗ ៤ កហាបណៈ ហើយទិញផ្កា មកមួយថ្ងៃៗ ត្រឹមតែ ៤ កហាបណៈប៉ុណ្ណោះ ព្រះពរម្ចាស់ ។

គ្រានោះ ព្រះនាងសាមាវតីត្រាស់សួរទៀតថា ព្រោះហេតុអ្វី ក្នុងថ្ងៃនេះ បានជានាងមិនកិបយកកហាបណៈនោះទុកទៀត ? នាងខុជ្ជុត្តរាក្រាបទូលតបថា បពិត្រព្រះនាងម្ចាស់ ព្រោះហេតុដែលខ្ញុំម្ចាស់បានស្តាប់នូវធម្មកថារបស់ព្រះសាស្តា ហើយបានសម្រេចអមតធម៌ ទើបខ្ញុំម្ចាស់មិនបិទបាំង ប្រាប់ឲ្យយល់នូវសេចក្តីពិតទាំងនោះ ឲ្យព្រះនាងម្ចាស់បានជ្រាប ។ ព្រះនាងសាមាវតី មិនបានត្រាស់ព្រះវាចាគំរាមនាងខុជ្ជុត្តរាថា វ៉ឺយ នាងទាសីអាក្រក់ នាងចូរយកកហាបណៈ ដែលនាងកិបយកទុកពីមុនៗ យកមកឲ្យយើងវិញទេ តែព្រះនាងត្រឡប់ជាមានព្រះតម្រាស់ថា នែនាងខុជ្ជុត្តរា នាងចូរឲ្យយើងបានផឹកនូវទឹកអម្រឹត គឺអមតធម៌ តាមដែលនាងបានផឹកហើយនោះផងដែរ ។ នាងខុជ្ជុត្តរាក្រាបបង្គំទូលថា បពិត្រព្រះនាងម្ចាស់ ខ្ញុំម្ចាស់មិនអាចក្រាបបង្គំទូលថ្វាយដោយអាការយ៉ាងនេះបានទេ តែថា ខ្ញុំម្ចាស់នឹងសម្តែងធម៌ថ្វាយ តាមដែលព្រះសាស្តាទ្រង់សម្តែងហើយ ។ ព្រះនាងសាមាវតីទើបត្រាស់ថា នែនាងខុជ្ជុត្តរា បើដូច្នោះ នាងចូរសម្តែងធម៌ឲ្យយើងបានស្តាប់ផង ។

នាងខុជ្ជុត្តរាទើបក្រាបបង្គំទូលថា បពិត្រព្រះនាងម្ចាស់ ប្រសិនបើយ៉ាង នោះ សូមព្រះនាងម្ចាស់ទ្រង់អនុញ្ញាតឲ្យខ្ញុំម្ចាស់បានងូតទឹកជាមុនសិន ជាពិសេសនោះ គឺត្រូវអង្គុយលើអាសនៈខ្ពស់ជាងព្រះនាង ។ ព្រះនាងសមាវតីមានព្រះសវនីយ៍ឲ្យងូតទឹកដល់នាងខុជ្ជុត្តរា ដោយទឹកក្រអូប ១៦ ធ្នាំង ហើយប្រទានសំពត់សាដកសាច់ម៉ដ្ឋពីរផ្ទាំង ថែមទាំងឲ្យក្រាលអាសនៈឲ្យខ្ពស់ជាងខ្លួនដល់នាងខុជ្ជុត្តរា ។ ចំណែកនាងខុជ្ជុត្តរាដែលជាអ្នកតាំងនៅក្នុងសេក្ខប្បដិបទា បានស្លៀកសំពត់សាដកមួយផ្ទាំង មួយផ្ទាំងទៀតជណ្ដប់ ឲ្យយកផ្ចិតមួយមកផង ហើយឡើងអង្គុយលើអាសនៈ បានចាប់ផ្ចិតដ៏វិចិត្រ ហៅស្ត្រីទាំង ៥០០ នាក់មកអង្គុយលើអាសនៈដែលទាបជាងខ្លួន ហើយបានសម្តែងធម៌ឲ្យដល់ស្ត្រីទាំងនោះ ដោយទំនងដូចដែលព្រះមហាមុនីទ្រង់សម្តែងហើយនោះឯង ។ ស្ត្រីទាំងនោះមានព្រះនាងសាមាវតីជាប្រធាន កាលបើបានស្តាប់ធម្មកថារបស់នាងខុជ្ជុត្តរាហើយ ក៏បានសម្រេចជាព្រះសោតាបន្ន ហើយស្ត្រីទាំងនោះបានសំពះនាងខុជ្ជុត្តរា ថែមទាំងពោលថា បពិត្រនាងខុជ្ជុត្តរា

ចាប់អំពីថ្ងៃនេះទៅ នាងមិនត្រូវធ្វើការងារបម្រើតទៅទៀតទេ នាងចូរតាំងនៅក្នុងឋានៈជាមាតា និងតាំងនៅក្នុងឋានៈជាអាចារ្យនៃពួកយើងចុះ សូមនាងចូលទៅកាន់សម្នាក់ព្រះសម្ពុទ្ធ ស្តាប់ព្រះធម៌ដែលព្រះភគវាទ្រង់សម្តែងហើយៗ នាងនាំមកពោលឲ្យពួកយើងបានស្តាប់ផង ។ នាងខុជ្ជុត្តរាបានធ្វើយ៉ាងនោះ ដោយរាប់តាំងអំពីថ្ងៃនោះទៅ កាលបើនាងបានធ្វើយ៉ាងនោះជាប្រចាំរៀងមក ក្នុងកាលតមក នាងបានជាអ្នកទ្រទ្រង់ចេះចាំព្រះត្រៃបិដកទាំង ៣ ។

ការដែលនាងខុជ្ជុត្តរាជាអ្នកចេះដឹងបែកធ្លាយក្នុងព្រះត្រៃបិដក និងមានភាពអង់អាចក្នុងការពោលធម៌ ឲ្យដល់អ្នកដទៃស្តាប់បានផង ទើបបានទទួលការលើកតម្កើងថា ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយផ្នែកខាងជាធម្មកថិក ដែលមានសម្តែងនៅក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **អប្បមាទវគ្គ** ក្នុង **រឿងនាងសាមាវតី** ថា ៖

ក្រោយមក ព្រះសាស្តា ទ្រង់ប្រកាសតែងតាំងនាងខុជ្ជុត្តរាទុកក្នុងភាពជាអ្នកប្រសើរថា ម្នាលភិក្ខុទាំងឡាយ ឧបាសិកាអ្នកចេះដឹងច្រើន

ស្រេចនឹងនាងខុជ្ជុត្តរា ដែលជាសាវិការបស់តថាគត អ្នកជាធម្មកថិក ( អ្នកសម្តែងធម៌ ) ។

រឿងរបស់នាងខុជ្ជុត្តរា ដែលមានពោលនៅក្នុង **អដ្ឋកថាគម្ពីរមនោរថបូរណី** និងក្នុង **អដ្ឋកថាគម្ពីរធម្មបទ** ក្នុងរឿងព្រះនាងសាមាវតី ដូចមានសេចក្តីថា ៖

ចំណែកស្ត្រីទាំង ៥០០ នាក់នោះ បានពោលនឹងនាងខុជ្ជុត្តរាថា បពិត្រនាងខុជ្ជុត្តរា ពួកខ្ញុំត្រូវការដើម្បីនឹងចូលទៅគាល់ព្រះមានជោគ សូមនាងជួយឲ្យពួកយើងបានឃើញព្រះទសពល ពួកខ្ញុំនឹងបានបូជាព្រះវិជិតមារដោយគ្រឿងសក្ការៈ មានផ្កា និងគ្រឿងក្រអូបជាដើម ។ ពេលនោះ នាងខុជ្ជុត្តរាពោលពន្យល់ថា បពិត្រនាងទាំងឡាយ ការពិតរាជត្រកូលជារឿងដែលកម្រលំបាកណាស់ ខ្ញុំមិនអាចនឹងនាំពួកនាងទាំងឡាយទៅខាងក្រៅបាន ព្រោះព្រះរាជាទ្រង់នៅមិនទាន់មានសទ្ធា ។ ពួកស្ត្រីទាំងនោះ បាននាំគ្នាពោលអង្វរថា បពិត្រនាងខុជ្ជុត្តរា សូមនាងកុំឲ្យពួកខ្ញុំវិនាសឡើយ សូមនាងអារាធនាព្រះសក្យមុនីឲ្យពួកខ្ញុំបាន

ឃើញផងចុះ ។ នាងខុជ្ជុត្តរាពោលណែនាំស្ត្រីទាំងនោះថា នែនាងទាំងឡាយ ប្រសិនបើដូច្នោះ ពួកនាងទាំងឡាយអាចនឹងក្រឡេកឃើញព្រះសម្ពុទ្ធបានដោយប្រហោងប៉ុនណា ពួកនាងចូរបោះប្រហោងប្រមាណប៉ុណ្ណោះ ត្រង់ជញ្ជាំងបន្ទប់ ដែលជាទីលំនៅរបស់ពួកនាងចុះ ចូរនាំយកគ្រឿងក្រអូប និងកម្រងផ្កាជាដើមមក ហើយឈរនៅទីនោះ រួចចូរសម្លឹងមើល ចូរលើកដៃទាំងពីរឡើងថ្វាយបង្គំ និងចូរបូជាព្រះមុនី ព្រោះព្រះអង្គទ្រង់ចារិកទៅកាន់ផ្ទះលោកសេដ្ឋីទាំងបីនាក់ ។ ស្ត្រីទាំងនោះបានធ្វើតាមដែលនាងខុជ្ជុត្តរាពោលណែនាំ ក៏បានក្រឡេកឃើញព្រះសាស្តាទ្រង់ចារិកទៅចារិកមក ទើបថ្វាយបង្គំ និងបូជាដោយគ្រឿងក្រអូបនិងផ្កាឈើ ។ ថ្ងៃមួយ ព្រះនាងមាគន្ទិយា ដែលជាអគ្គមហេសីមួយព្រះអង្គទៀត របស់ព្រះបាទឧទេន ព្រះនាងបានយាងចុះចាកប្រាសាទរបស់ព្រះនាងទៅកាន់លំនៅរបស់ពួកស្ត្រីទាំងនោះ បានទតឃើញប្រហោងនៃបន្ទប់ទាំងឡាយហើយ ទើបត្រាស់សួរថា នេះប្រហោងអ្វី ? ពួកស្ត្រីទាំងនោះមិនបានដឹងថា ព្រះនាងមាគន្ទិយា ទ្រង់បានចងអាឃាតចំពោះ

ព្រះបរមគ្រូ ទើបក្រាបទូលទៅតាមសេចក្ដីពិតថា បពិត្រព្រះនាងម្ចាស់ ព្រះបរមសាស្ដា ស្ដេចយាងមកដល់ក្រុងនេះហើយ ពួកខ្ញុំព្រះអង្គឈរនៅក្នុងបន្ទប់នេះ តែងតែក្រឡេកមើលព្រះមានព្រះភាគ ថ្វាយបង្គំ និងបូជាព្រះសម្មាសម្ពុទ្ធបានដែរ ព្រះពរនាងម្ចាស់ ។ ព្រះនាងមាគន្ទិយាទ្រង់ត្រិះរិះថា ព្រះសមណគោតមស្ដេចយាងមកកាន់ក្រុងនេះ ឥឡូវនេះយើងនឹងធ្វើកម្មដែលគួរធ្វើដល់ព្រះសមណគោតម យើងនឹងដាក់ទោសដល់ពួកស្ដ្រីទាំងនេះឲ្យបាន ហើយព្រះនាងទើបទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ ស្ដ្រី៥០០នាក់ រួមទាំងព្រះនាងសាមាវតីផង បានប្រព្រឹត្តនូវអំពើក្បត់នឹងព្រះអង្គ ពួកស្ដ្រីទាំងនោះ នឹងដាក់ព្រះជន្មព្រះអង្គក្នុងកាលមិនយូរឡើយ ព្រះពរម្ចាស់ព្រះអង្គ ។ ព្រះរាជាទ្រង់មិនជឿ ដោយទ្រង់ត្រិះរិះថា ពួកស្ដ្រីទាំងនោះ នឹងមិនធ្វើយ៉ាងនោះឡើយ ។ សូម្បីព្រះនាងមាគន្ទិយា ទ្រង់បានក្រាបទូលដដែលៗ ទៀត តែព្រះរាជាក៏ទ្រង់មិនជឿ មិនយកចិត្តទុកដាក់ទៀតផង ។ លុះព្រះនាងមាគន្ទិយាទ្រង់ពិចារណាឃើញថា ព្រះនាងក្រាបទូលសូម្បីបីដងហើយ ព្រះរាជា

ក៏ទ្រង់មិនជឿ ទើបក្រាបទូលថាប្រសិនបើព្រះអង្គទ្រង់ពុំជឿខ្ញុំម្ចាស់ទេ សូមព្រះអង្គ ទ្រង់យាងទៅលំនៅរបស់ពួក ស្ត្រីទាំងអស់នោះហើយ ទ្រង់ពិចារណាមើលចុះ ព្រះពរព្រះអង្គ ។ព្រះរាជាទើបស្តេចយាងទៅទត ក៏បានឃើញប្រហោងនៅតាមបន្ទប់ទាំងឡាយ ទើបត្រាស់សួរថា នេះប្រហោងអ្វី ? ពួកស្ត្រីទាំងអស់នោះ បានក្រាបបង្គំទូលសេចក្តីនោះ ឲ្យទ្រង់ជ្រាបដោយសព្វគ្រប់ប្រការ ។ព្រះរាជាទ្រង់មិនពិរោធចំពោះស្ត្រី ទាំងនោះឡើយ ទាំងមិនបានត្រាស់ថាអ្វីសោះទៀត មានព្រះរាជបញ្ជា ឲ្យបើកចន្លោះទាំងឡាយ ហើយឲ្យធ្វើបង្អួចតាមបន្ទប់ទាំងអស់ ។ បានឮថា បង្អួច ដែលមានប្រហោងតូចៗ ទាំងឡាយ បានកើតឡើង ក្នុងគ្រានោះឯង ។

រឿងទាក់ទងបុព្វកម្មរបស់នាងខុជ្ជុត្តរា បានមានភិក្ខុទាំងឡាយ ចាប់អារម្មណ៍ក្រាបទូលសួរព្រះទសពលថា បពិត្រព្រះអង្គដ៏ចម្រើន នាងខុជ្ជុត្តរាកើតមកជាស្រីខ្នងគម ព្រោះបាបកម្មអ្វី ហើយនាងជាអ្នក មានបញ្ញានោះ ព្រោះបានធ្វើកម្មអ្វី ថែមទាំងជាអ្នកបានសម្រេចជា

ព្រះសោតាបន្ន ព្រោះបានធ្វើកម្មអ្វី ចំណែកការកើតជាស្រីបម្រើរបស់អ្នកដទៃ តើនាងបានធ្វើកម្មអ្វី ព្រះអង្គ ? ពេលនោះ ព្រះសម្ពុទ្ធ ទើបត្រាស់តបថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលនៅមិនទាន់មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក មានព្រះបាទពារាណសីគ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងពារាណសី ។ គ្រានោះ មានព្រះបច្ចេកពុទ្ធមួយព្រះអង្គមានខ្នងគម ជាអ្នកមានការស្និទ្ធស្នាលជាមួយនឹងព្រះបាទពារាណសី ។ នាងខុជ្ជុត្តរានេះ បានកើតនៅក្នុងវាំងព្រះបាទពារាណសី នាងបានជាឧបដ្ឋាយិកាម្នាក់ នាងបានដណ្តប់សំពត់កម្ពល ក្នុងគ្រានោះ នាងបានក្រឡេកឃើញព្រះបច្ចេកពុទ្ធ ដែលមានខ្នងគមនិមន្តដើរមក នាងក៏បានសម្តែងអាការដើរទៅដូចព្រះបច្ចេកពុទ្ធរូបនោះ ។ ដោយបាននិយាយជាមួយនឹងស្ត្រីទាំងឡាយ ដែលនៅរួមជាមួយនឹងខ្លួនថា ព្រះបច្ចេកពុទ្ធរបស់ពួកយើងតែងតែដើរទៅយ៉ាងនេះៗ ។ ព្រោះផលនៃកម្មអាក្រក់ដែលខ្លួនធ្វើទុកក្នុងកាលមុន ទើបបានធ្វើឲ្យនាងជាស្ត្រីមានខ្នងគមក្នុងបច្ចុប្បន្នជាតិនេះ មួយទៀត ព្រះបាទពារាណសី ទ្រង់និមន្តព្រះបច្ចេកពុទ្ធ

៨ រូប ឲ្យគង់នៅក្នុងព្រះរាជវាំង ទើបត្រាស់ឲ្យរាជបុរសទទួលបាត្រមក កាលទ្រង់ដាក់បាយបាយាសពេញបាត្រហើយ បានឲ្យយកបាត្រទៅ ថ្វាយព្រះបច្ចេកពុទ្ធទាំងអស់នោះ ។ ព្រះបច្ចេកពុទ្ធទាំងអស់នោះ ក៏បាន ទទួលយកបាត្រ ដែលដាក់ពេញដោយបាយបាយាសកំពុងតែក្តៅគគុក ក៏ផ្លាស់ប្តូរដៃចុះឡើងៗ ជារឿយៗ ។ គ្រានោះ នាងខុជ្ជុត្តរា កាលបាន ឃើញព្រះបច្ចេកពុទ្ធធ្វើយ៉ាងនោះហើយ ទើបបានថ្វាយកងដៃភ្លុក ៨ វង់ ( កន្លែងខ្លះថា កងដៃមាស ) ដែលជារបស់ខ្លួន ព្រមទាំងពោលថា សូមលោកម្ចាស់ដាក់បាត្រនៅលើកងដៃនេះ ហើយកាន់យកទៅចុះ លោកម្ចាស់ ។ ពេលនោះ ព្រះបច្ចេកពុទ្ធទាំងនោះ បានទទួលយកហើយ បាននិមន្តទៅកាន់ជ្រោយភ្នំនន្ទមូល ។ ព្រោះផលដែលប្រាកដចេញមក នៃកម្មល្អនោះ ក្នុងកាលឥឡូវនេះ នាងទើបបានជាអ្នកទ្រទ្រង់ព្រះ ត្រៃបិដក មានបញ្ញាច្រើន ព្រោះផលដែលហូរចេញពីការឧបដ្ឋាក ដែលនាងបានធ្វើដល់ព្រះបច្ចេកពុទ្ធទាំងនោះ នាងទើបបានសម្រេចជា ព្រះសោតាបន្ន នេះជាបុព្វកម្មក្នុងសម័យមួយពុទ្ធន្តររបស់នាង ។ ក្នុង

ពុទ្ធកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ធីតារបស់សេដ្ឋីម្នាក់នៅក្នុងក្រុងពារាណសី កាន់កញ្ចក់កំពុងតែអង្គុយម្នាក់ឯង នៅក្នុងវេលារសៀល ។ ក្នុងខណៈនោះ ភិក្ខុនីមួយរូបជាព្រះខីណាស្រព ដែលជាអ្នកធ្លាប់ស្និទ្ធស្នាលនឹងនាងបានទៅរកនាងដើម្បីសួរសុខទុក្ខដល់នាង ។ សូម្បីភិក្ខុនីជាព្រះខីណាស្រព ក៏មានសេចក្តីប្រាថ្នាដើម្បីនឹងឃើញត្រកូលឧបដ្ឋាកក្នុងវេលាល្ងាច ។ ចៃដន្យក្នុងពេលដែលភិក្ខុនីទៅដល់នោះស្រីបម្រើណានីមួយក្នុងសម្នាក់របស់សេដ្ឋីធីតា មិនមាននរណាម្នាក់នៅឡើយ សេដ្ឋីធីតាទើបពោលថា ខ្ញុំសូមថ្វាយបង្គំព្រះនាងម្ចាស់ សូមចាប់យកកំប្រោងគ្រឿងប្រដាប់នោះឲ្យដល់ខ្ញុំបន្តិច ។ គ្រានោះភិក្ខុនីគិតពិចារណាថា បើយើងមិនចាប់ហុចកំប្រោងគ្រឿងប្រដាប់នេះឲ្យនាងទេ នាងនឹងធ្វើអាឃាតចំពោះយើង ហើយនាងនឹងទៅកើតក្នុងនរក តែថា ប្រសិនបើយើងចាប់ហុចឲ្យ នាងនឹងកើតជាស្រីបម្រើអ្នកដទៃ ប៉ុន្តែត្រឹមតែការបម្រើអ្នកដទៃ នៅល្អជាងការទៅឆេះក្នុងនរក ព្រះថេរីអាស្រ័យការអាណិត ទើបបានចាប់យកកំប្រោងគ្រឿងប្រដាប់នោះហុចទៅឲ្យ ។ ព្រោះ

កម្មអាក្រក់ក្នុងអតីត បានបណ្តាលផលមិនល្អឲ្យនាង ទើបបានឲ្យនាងមកកើតជាអ្នកបម្រើបុគ្គលដទៃទៅ ។

ការស្លាប់របស់យើងមិនថានៅក្នុងឋានៈបែបណា នៅក្នុងវណ្ណៈណាក៏ដោយ រមែងមានការកើតឡើងគ្រប់ពេលវេលា ដូចជាព្រះនាងសាមាវតី ព្រមដោយស្ត្រីបរិវារទាំងអស់ ដែលសំដៅដល់នាងខុជ្ជុត្តរាផង ត្រូវបានព្រះនាងមាគន្ទិយា ប្រើឲ្យយកភ្លើងទៅដុតទាំងរស់រហូតស្លាប់នៅក្នុងប្រាសាទរបស់ព្រះនាង ។ អំណើះពីនោះមក ព្រះនាងសាមាវតី ព្រមដោយស្ត្រីបរិវារទាំងអស់ ត្រូវបានភ្លើងឆេះស្លាប់ទៅ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងសាលាធម្មសភាថា នៃអាវុសោទាំងឡាយ ការស្លាប់ដូចនេះ របស់ឧបាសិកាអ្នកដល់ព្រមដោយសទ្ធាច្រើនយ៉ាងនេះ រាប់ថាជាការមិនសមគួរសោះឡើយ ។ ព្រះលោកនាថស្តេចយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តើពួកអ្នកអង្គុយសន្ទនាគ្នាអំពីរឿងអ្វី ? ភិក្ខុទាំងឡាយ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយសន្ទនាគ្នាអំពីរឿងការធ្វើ

មរណកាលរបស់ឧបាសិកាទាំងនោះ ដែលរាប់ថាជាការធ្វើមរណកាល ដែលមិនសមគួរ ព្រះអង្គ ។ គ្រានោះ ព្រះមហាមុនី ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការធ្វើមរណកាពរបស់ស្ត្រីទាំងនោះ ដែលមាន ព្រះនាងសមាវតីជាប្រធាន មិនសមគួរចំពោះក្នុងអត្តភាពនេះ តែថា ការធ្វើមរណភាពនៃស្ត្រីទាំងនោះ បានទទួលហើយ សមគួរនឹងបាបកម្ម ដែលគេបានធ្វើទុកក្នុងជាតិមុនៗ ។ ពេលនោះ ភិក្ខុទាំងឡាយ មាន សេចក្តីត្រូវការដើម្បីឲ្យដឹងរឿងក្នុងអតីតជាតិរបស់ស្ត្រីទាំងនោះ ទើប ក្រាបបង្គំទូលអារាធនាព្រះភគវា បពិត្រព្រះអង្គដ៏ចម្រើន បាបកម្មអ្វី ដែលស្ត្រីទាំងនោះធ្វើទុកមកហើយក្នុងជាតិមុនៗ ព្រះអង្គ ? សូមព្រះអង្គ ទ្រង់មេត្តាសម្តែងប្រាប់ ឲ្យដល់ខ្ញុំព្រះអង្គបានជ្រាបផង ! លំដាប់នោះ ព្រះពុទ្ធអង្គ ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា ក្នុងអតីតកាល គឺ ក្នុងសម័យដែល ព្រះបាទព្រហ្មទត្ត ទ្រង់គ្រប់គ្រងរាជសម្បត្តិនៅក្នុង ក្រុងពារាណសី ក្នុងគ្រានោះ មានព្រះបច្ចេកពុទ្ធ ៨ រូប និមន្តមក ទទួលចង្ហាន់ នៅក្នុងព្រះរាជវាំងជាប្រចាំ ។ ចំណែកស្ត្រីទាំង ៥០០

នាក់ ( ដែលនៅក្នុងព្រះរាជវាំងរបស់ព្រះបាទព្រហ្មទត្ត ) បាននាំគ្នាធ្វើការទំនុកបម្រុងព្រះបច្ចេកពុទ្ធទាំងនោះ ។ បណ្តាព្រះបច្ចេកពុទ្ធទាំង ៨ រូបនោះ ព្រះបច្ចេកពុទ្ធ ៧ រូប បានហោះទៅកាន់ហិមវន្តប្រទេសហើយ ។ ចំណែកព្រះបច្ចេកពុទ្ធមួយរូបទៀត មិនទាន់បាននិមន្តទៅទេ តែបានគង់ចូលឈានសមាបត្តិ នៅក្នុងទីមានស្មៅដុះស៊ុបទ្រុបនៅក្បែរស្ទឹងមួយ ។ តមកថ្ងៃមួយ កាលបើព្រះរាជាអស់កិច្ចជាប់ទាក់ទងនឹងព្រះបច្ចេកពុទ្ធទាំងឡាយហើយ ដោយព្រះបច្ចេកពុទ្ធនិមន្តត្រឡប់ទៅវិញ ព្រះអង្គទើបទ្រង់នាំស្ត្រីជាបរិវារទាំងនោះទៅ ដើម្បីទ្រង់លេងទឹកក្នុងស្ទឹង ( កន្លែងខ្លះថា ស្ទឹងគង្គា ) ។ ស្ត្រីទាំងនោះ បាននាំគ្នាលេងទឹកនៅក្នុងស្ទឹងនោះអស់មួយថ្ងៃ កាលពួកនាងឡើងមកពីទឹកវិញ ក៏មានភាពរងាណាស់ ត្រូវការនឹងអាំងភ្លើង ដើម្បីនឹងបំបាត់នូវភាពរងា ទើបពោលថា នាងទាំងឡាយចូរជ្រើសរើសមើលទីកន្លែងបង្កាត់ភ្លើង ហើយពួកនាងៗ ដើរទៅដើរមក ក៏បានឃើញទីកន្លែងដែលមានស្មៅស្ងួតមួយកន្លែង ទើបទៅឈរនៅព័ទ្ធជុំវិញហើយ បង្កាត់ភ្លើងឡើង ដោយ

យល់ថាជាគំនរស្មៅ ។

គ្រានោះ លុះស្មៅទាំងឡាយត្រូវភ្លើងឆេះហើយ ស្រកស្រុតទាបចុះ ស្ត្រីទាំងនោះបានឃើញព្រះបច្ចេកពុទ្ធ ទើបពោលថា ពួកយើងវិនាសហើយៗ ព្រះបច្ចេកពុទ្ធជាម្ចាស់របស់ព្រះរាជាត្រូវភ្លើងឆេះពេលៗ ប្រសិនបើព្រះរាជាទ្រង់ជ្រាប ទ្រង់នឹងដាក់ទោសឲ្យដល់ពួកយើងៗ នឹងវិនាសជាប្រាកដ ហេតុដូច្នេះពួកយើងចូរនាំគ្នាដុតលោកឲ្យឆេះអស់ទៅ ពួកស្ត្រីទាំងនោះបាននាំគ្នាទៅយកអុសមកដាក់ពីលើ ព្រះបច្ចេកពុទ្ធទៀត រហូតដល់ក្លាយជាពំនូកធំ ។តពីនោះស្ត្រីទាំងនោះបាននាំគ្នាដុតភ្លើងនៅត្រង់គំនរអុសនោះហើយ ក៏ចៀសចេញទៅដោយយល់ថា គ្រានេះនឹងឆេះអស់ ។ ការដុតភ្លើងក្នុងគ្រាមុន ពួកគេមិនមានចេតនា គឺការតាំងចិត្តនឹងដុត តែមកគ្រានេះ ពួកគេមានចេតនា គឺការតាំងចិត្តដុត ទើបត្រូវកម្មអាក្រក់នោះជាប់តាមឲ្យផលមកដល់ជាតិនេះ ។ ការពិត បុគ្គលទាំងឡាយសូម្បីយកអុសមួយពាន់រទេះមកគរដុត ក៏មិនអាចដើម្បីនឹងធ្វើឲ្យព្រះបច្ចេកពុទ្ធ អ្នកនៅក្នុងឈានសមាបត្តិ សូម្បីឲ្យកើតអាការក្តៅ

បានឡើយ ។ ព្រោះដូច្នោះ លុះដល់ថ្ងៃទី ៧ ព្រះបច្ចេកពុទ្ធរូបនោះ បានចេញពីសមាបត្តិ ក្រោកឡើងរលាស់ចីវររួចហើយ និមន្តចេញទៅ ។ ពួកស្ត្រីទាំងនោះ កាលបើអស់ជីវិតទៅហើយ ត្រូវទៅឆេះនៅក្នុងនរក អស់ច្រើនពាន់ឆ្នាំ ព្រោះការដែលពួកខ្លួនធ្វើបាបកម្មនោះទុកមកហើយ ទើបបានជាហេតុនាំឲ្យពួកស្ត្រីទាំងនោះ ឆេះនៅក្នុងផ្ទះទំនងនេះ ១០០ ជាតិមកហើយដែរ ដោយវិបាក ( ផលកម្មដែលបានធ្វើពីកាលមុន ) ដ៏សេស ។ នេះជាបុព្វកម្មរបស់ស្ត្រីទាំងនោះ ដែលធ្លាប់បានធ្វើបាប ក្នុងអតីតជាតិ ។

ជីវប្រវត្តិរបស់ឧបាសិកាខុជ្ជុត្តរា ដែលជាចំណែកល្អរាប់ជាបុណ្យ របស់នាងមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាមនោរថបូរណី** ថា ៖

ក្រោយពីការដែលបានសន្ទនាកើតឡើង ក្នុងកណ្តាលបរិស័ទ ទាំង ៤ ថា នាងខុជ្ជុត្តរាជាពហូសូត គឺអ្នកសិក្សារៀនសូត្រច្រើន ជាអ្នក មានភាពអង់អាចក្នុងការពោលធម៌ឲ្យស្ត្រី ៥០០ នាក់បានស្តាប់ រហូត ដល់បានសម្រេចសោតាបត្តិផល ដោយមហាជនបាននាំគ្នាពោល

សរសើរយ៉ាងនេះ ។

កិត្តិគុណ គឺសេចក្ដីល្អរបស់នាងខុជ្ជុត្តរា ជាឧបាសិកាម្នាក់ ផ្នែកខាងឧបាសិកា ដែលបានទទួលការលើកតម្កើង ឲ្យជាឯតទគ្គៈ តាមដែលមានពោលទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

គ្រាមួយ ព្រះមានព្រះភាគ ទ្រង់ប្រថាប់គង់នៅក្នុងវត្តជេតពន ទ្រង់បានត្រាស់ប្រារព្ធរឿងនាងខុជ្ជុត្តរាឧបាសិកាឲ្យជាដើមហេតុ ទើបទ្រង់ប្រកាសតែងតាំងនាងខុជ្ជុត្តរា ទុកក្នុងតំណែងជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងគេថា

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា** ម្នាលភិក្ខុទាំងឡាយ ពួកឧបាសិកាអ្នកចេះដឹងច្រើន ស្រេចនឹងនាងខុជ្ជុត្តរា អ្នកជាសាវិការបស់តថាគត ។

( ជីវប្រវត្តិរបស់នាងខុជ្ជុត្តរា ចប់ )

88888888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះនាងសាមាវតី ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកនៅដោយមេត្តា "

ព្រះនាងសាមាវតី ជាព្រះអរិយឧបាសិកា ជាអ្នកទ្រទ្រង់នូវគុណធម៌ផ្នែកខាងរស់នៅដោយមេត្តាចិត្ត ដែលរាប់ថា ជាគុណធម៌ប្រចាំជីវិតរបស់ព្រះនាង រហូតដល់បានទទួលការរាប់អានពីមហាជនទាំងឡាយថា អ្នកនៅដោយមេត្តាចិត្ត នេះជាលក្ខណៈរបស់ព្រះនាងដែលមានប្រចាំខ្លួន ។

ជីវប្រវត្តិរបស់ព្រះនាងសាមាវតី មានរឿងទាក់ទងនឹងឧបាសិកាខុជ្ជុត្តរាផងដែរ តាមដែលមានសម្តែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

ក្នុងអតីតជាតិ ឧបាសិកាទាំងពីរនាក់ គឺឧបាសិកាខុជ្ជុត្តរា និងឧបាសិកាសាមាវតី បានទៅកើតក្នុងត្រកូលអ្នកមានធនធានម្នាក់ នៅ

ក្នុងក្រុងហង្សវតី ត្រូវនឹងពុទ្ធកាលនៃព្រះបទុមុត្តរៈ ដោយរាប់ថយក្រោយ ពីភទ្ទកប្បនេះទៅបានមួយសែនកប្ប ។ កាលតមក កុលធីតាទាំងពីរនាក់នោះ ពេលដែលចម្រើនវ័យធំដឹងក្តីហើយ បាននាំគ្នាទៅកាន់វិហារ ដោយគិតថា ពួកយើងនឹងទៅស្តាប់ព្រះធម៌របស់ព្រះបទុមុត្តរៈជាម្ចាស់ ។ ក្នុងបណ្តាកុលធីតាទាំងពីរនាក់នោះ ឧបាសិកាខុជ្ជុត្តរា បានឃើញព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ប្រកាសតែងតាំងឧបាសិកាម្នាក់ ទុកក្នុងតំណែងជាឯតទគ្គៈ គឺផ្នែកខាងពហូសូត នាងឃើញដូច្នោះហើយ ទើបបានធ្វើកុសលផ្សេងៗ ហើយតាំងចិត្តប្រាថ្នានូវតំណែងនោះដែរ ។ ចំណែកឧបាសិកាសាមាវតី ក៏បានឃើញព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ប្រកាសតែងតាំងឧបាសិកាម្នាក់ ទុកក្នុងតំណែងជាឯតទគ្គៈ អ្នកមានប្រក្រតីនៅដោយមេត្តាចិត្ត កាលនាងឃើញដូច្នោះហើយ ទើបបានធ្វើកុសលផ្សេងៗ ហើយប្រាថ្នាឲ្យបានតំណែងនោះដែរ ។ ក្រោយពីកុលធីតាទាំងពីរនាក់នោះ បានតាំងសេចក្តីប្រាថ្នានូវមុខតំណែងនោះហើយ ក៏បានប្រឹងប្រែងធ្វើបុណ្យកុសលជាប់តគ្នារហូតដល់អស់ជីវិត លុះកុលធីតា

ទាំងពីរនាក់នោះអស់ជីវិតទៅហើយ បានទៅកើតក្នុងទេវលោកដោយសេចក្ដីល្អនោះ បានធ្វើឲ្យអ្នកទាំងពីរនាក់នោះ កើតជាមនុស្ស និងទេវតាតែម្យ៉ាងប៉ុណ្ណោះ អស់មួយសែនកប្ប ។ ក្នុងសម័យនេះ កុលធីតាទាំងពីរនាក់នោះ គឺនាងខុជ្ជុត្តរាចុតិអំពីទេវលោកមកបដិសន្ធិ នៅក្នុងគភ៌ស្ត្រីមេដោះ នៅក្នុងផ្ទះរបស់ឃោសកសេដ្ឋី នាងជា **ខុជ្ជា** គឺជាមនុស្សមានខ្នងគម ព្រោះដូច្នោះ ទើបពួកញាតិដាក់ឈ្មោះឲ្យនាង ថា **ខុជ្ជុត្តរា** ។ ចំណែកសាមាវតីទេពធីតា ក៏បានចុតិចាកទេវលោកមកបដិសន្ធិនៅក្នុងផ្ទះរបស់ភទ្ទវតីសេដ្ឋី ក្នុងដែនភទ្ទវតី ពួកញាតិបានដាក់ឈ្មោះឲ្យនាងថា **សាមា** ប្រែថា **មាស** ( យល់ថា នាងប្រហែលជាមានសម្បុរលឿង ) ទើបបានដាក់ឈ្មោះឲ្យដូច្នេះ ។

ជីវប្រវត្តិរបស់ព្រះនាងសាមាវតីតទៅនេះ ក្រៅពីមានសម្ដែងនៅក្នុង **អដ្ឋកថាមនោរថបូរណីហើយ** នៅមានសម្ដែងទុកនៅក្នុង **គម្ពីរអដ្ឋកថាធម្មបទ** នៃ **អប្បមាទវគ្គ** ក្នុងរឿងរបស់ព្រះនាងសាមាវតី ដូចមានសេចក្ដីថា ៖

ក្នុងគ្រានោះ **ភទ្ទវតីសេដ្ឋី** ដែលជាបិតារបស់នាងសាមាវតី បានជាមិត្រសម្លាញ់ជាមួយនឹងឃោសកសេដ្ឋី តែលោកទាំងពីរនាក់ ជាមិត្រមិនធ្លាប់ជួបគ្នាសោះ ។ មូលហេតុដែលសេដ្ឋីទាំងពីរនាក់នោះ បានជាមិត្រនឹងគ្នា មកពីឃោសកសេដ្ឋីបានស្តាប់ឮពីសម្បត្តិ និងវ័យ ថែមទាំងប្រទេសរបស់ភទ្ទវតីសេដ្ឋីពីពួកឈ្មួញ ដែលមកអំពីដែនភទ្ទវតី កាលមានបំណងចង់ធ្វើជាសម្លាញ់ជាមួយនឹងភទ្ទវតីសេដ្ឋីហើយ ទើប បញ្ជូនគ្រឿងបណ្ណាការទៅឲ្យ ។ ហើយក៏ធ្វើឲ្យសេដ្ឋីទាំងពីរនាក់នោះ បានជាសម្លាញ់នឹងគ្នា ដែលមិនធ្លាប់ឃើញមុខគ្នាឡើយ ក្រោយពីមាន បណ្ណាការ មានសារចងសម្ពន្ធមិត្រនឹងគ្នា ។ តពីនេះសូមនាំយករឿងរ៉ាវ របស់ឃោសកសេដ្ឋី មកសម្តែងទុកក្នុងពេលនេះសិន ព្រោះជាត្រកូល សេដ្ឋីដែលមានការទាក់ទងនឹងរឿងអនាគតរបស់នាងសាមាវតី ។ ក្នុង សម័យមុនពុទ្ធកាលព្រះពុទ្ធជាម្ចាស់នៃយើងនេះ ពេលទុព្ភិក្ខភ័យ គឺ ភ័យដែលកើតអំពីការអត់បាយ ឬការខ្វះអាហារនៅក្នុងស្រុកភូមិ ក្នុង ដែនអល្លកប្ប: ។ មានបុរសម្នាក់ ឈ្មោះថា **កោតុហលិក:** មិនអាច

នឹងរស់នៅតទៅទៀតបាន ក៏បាននាំកិរិយាដែលមានកូនខ្ចីឈ្មោះថា នាងកាឡី ហើយបានកាន់យកស្បៀងសម្រាប់ដើរផ្លូវចេញទៅ ដោយបំណងថា នឹងទៅរស់នៅក្នុងក្រុងកោសម្ពី អាចារ្យពួកខ្លះពោលបានថា បុរសឈ្មោះកោតុហលិកចេញទៅហើយ ក្នុងកាលមហាជនកំពុងតែស្លាប់ដោយអហិវាតករោគ (រោគខ្យល់មានពិស ដូចជាពិសនៃពស់) ដែលនៅក្នុងផ្ទះមួយៗ មានមនុស្សស្លាប់ព្រមគ្នា ១០ នាក់ក៏មាន ២០ នាក់ក៏មាន ៣០ នាក់ ក៏មាន ។ តែក៏មានអ្នកដែលរួចជីវិត គឺអ្នកដែលគេចចេញអំពីដែនអល្លកប្បៈទៅ ។ កាលបើពីរនាក់ប្តីប្រពន្ធបានធ្វើដំណើរទៅមិនយូរប៉ុន្មានស្បៀងក៏អស់ ហើយត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ មិនអាចនឹងនាំយកកូនរបស់ខ្លួនទៅបាន ។ គ្រានោះ បុរសដែលជាប្តីបាន និយាយជាមួយនឹងភរិយាថា ម្នាលនាងដ៏ចម្រើន កាលបើយើងទាំងពីរនាក់នៅមានជីវិត កូនក៏អាចមានទៀតបាន ដូច្នេះ ចោលកូននេះទៅ ហើយពួកយើងនឹងធ្វើដំណើរទៅ ធម្មតាទឹកចិត្តរបស់មាតាជាធម្មជាតិដ៏ស្រទន់ ព្រោះហេតុនោះ ទើបនាងនិយាយថា ខ្ញុំមិនអាច

ចោលកូន ដែលនៅមានជីវិតនេះបានទេ ។ ស្វាមីបានពោលថា បើដូច្នោះ យើងនឹងធ្វើដូចម្តេច ? ភរិយាឆ្លើយថា ពួកយើងផ្លាស់ប្តូរវេនគ្នា.ពម្តង ម្នាក់ ។ មាតាលើកកូនឡើង.ព ដូចជាលើកកម្រងផ្កាឡើងដូច្នោះដែរ ពមិនបានយូរប៉ុន្មាន ហើយក៏ឲ្យដល់បិតាម្តង ។ទុក្ខវេទនាដ៏ខ្លាំងក្លាជាង សេចក្តីស្រេកឃ្លាន បានកើតឡើងដល់បុរសដែលជាស្វាមីនោះ ក្នុងកាល ដែលខ្លួនទទួលយកកូនមក.ពហើយដាក់ចុះ បុរសដែលជាស្វាមីនិយាយ នឹងភរិយានោះរឿយៗ ថា ម្នាលនាងដ៏ចម្រើន យើងបើនៅមានជីវិត កូនយើងអាចមានទៀតបាន ចូរចោលកូននេះទៅចុះ សូម្បីភរិយា កាលបើ បានឮដូច្នោះហើយ ក៏បានពោលហាមបុរសដែលជាស្វាមីនោះជារឿយៗ បុរសដែលជាស្វាមី កាលបើភរិយាពោលហាមដូច្នោះ ក៏នៅស្ងៀម មិនឆ្លើយអ្វីៗ ទាំងអស់ ។ កូននោះត្រូវមាតា និងបិតាផ្លាស់ប្តូរវេនគ្នា.ព ទៅតាមវារៈដែលខ្លួននឿយហត់ កាលដល់វារៈបិតា.ពក៏ដេកលក់ក្នុងដៃ របស់បិតា បុរសដែលជាស្វាមី កាលបានដឹងថាកូនរបស់ខ្លួនដេកលក់ ហើយ ក៏បានបណ្តោយឲ្យភរិយាដើរទៅមុខ ហើយខ្លួនឯងយកកូនដែល

ដេកលក់នោះ ដាក់ទៅលើកម្រាលស្លឹកឈើមួយ នៅក្រោមគុម្ពឈើមួយគុម្ព រួចហើយក៏ដើរទៅតាមក្រោយ ក្នុងគ្រានោះ មាតាត្រឡប់បែរមកមើលខាងក្រោយមិនឃើញកូនក៏សួរថា បពិត្រអ្នកជាស្វាមី កូនរបស់យើងទៅណា ? បុរសដែលជាស្វាមីឆ្លើយថា ខ្ញុំបានដាក់ឲ្យកូនដេកនៅលើកម្រាលស្លឹកឈើមួយ នៅក្រោមគុម្ពោតឈើមួយគុម្ពឯណោះ ភរិយាកាលបើឮដូច្នោះ ក៏យកដៃគក់ទ្រូង យំខ្សឹកខ្សួល ដោយពោលថា បពិត្រអ្នកជាស្វាមី លោកកុំធ្វើឲ្យខ្ញុំវិនាសឡើយ ខ្ញុំបើវៀរចាកកូនហើយ ខ្ញុំមិនអាចនឹងរស់នៅបានតទៅទៀតទេ សូមលោកទៅនាំយកកូននោះមកឲ្យដល់ខ្ញុំវិញមក ហើយកូននោះត្រូវបិតាធ្វើដូច្នោះជារឿយៗ ទៅ ក៏បានស្លាប់តាមផ្លូវទៅ ។ នាយកោតុហលិកៈ បានចោលកូនដូច្នោះទៅមកៗ រហូតដល់ ៧ ដង ។ ដែលឈ្មោះថា បាបកម្មបុគ្គលមិនគួរមើលងាយថា មានប្រមាណតិចតួចប៉ុណ្ណោះ មិនឲ្យផលឡើយ ពីរនាក់ប្ដីប្រពន្ធ បានធ្វើដំណើរទៅៗ ក៏បានទៅដល់ត្រកូលនៃអ្នករក្សាគោមួយ ។

ក្នុងថ្ងៃនោះ មានពិធីមង្គលដើម្បីមេគោរបស់នាយគោបាល ។ ព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដែលតែងតែមកឆាន់នៅក្នុងផ្ទះរបស់នាយគោបាលជានិច្ច ។ នាយគោបាលបាននិមន្តព្រះបច្ចេកពុទ្ធឲ្យឆាន់ស្រេចហើយ ទើបបានធ្វើនូវពិធីមង្គល ។ បាយបាយាសជាច្រើន ដែលនាយគោបាលបានតាក់តែងនោះ ហើយនាយគោបាលបានឃើញពីរនាក់ប្តីប្រពន្ធនោះមកដល់ហើយ ក៏បានសួរថា អ្នកមកអំពីទីណា ? កាលបានសួរដឹងរឿងរ៉ាវនោះហើយ ក៏ធ្វើសេចក្តីអនុគ្រោះប្តីប្រពន្ធទាំងពីរនាក់នោះ គឺបានរៀបចំនូវបាយបាយាស និងទឹកដោះថ្លាជាច្រើនឲ្យដល់ពីរនាក់ប្តីប្រពន្ធនោះ ។ ប្រពន្ធបានពោលនឹងប្តីថា បពិត្រអ្នកជាម្ចាស់ កាលលោកនៅមានជីវិត ខ្ញុំក៏ឈ្មោះថា នៅមានជីវិតដែរ លោកជាអ្នកមានពោះផត អស់កាលជាយូរមកហើយ ចូរបរិភោគតាមសេចក្តីត្រូវការចុះ ពោលដូច្នោះហើយ ក៏ដាក់បាយាស និងសប្បិចំពោះមុខប្តី ចំណែកឯខ្លួនក៏បានបរិភោគនូវសប្បិតែបន្តិចបន្តួចប៉ុណ្ណោះ ។ ចំណែកនាយកោតុហលិកៈ បរិភោគមធុបាយាសច្រើនហួសប្រមាណ បាយាស

ដែលនៅក្នុងពោះនោះ មិនអាចនឹងរលួយបាន ព្រោះខ្លួនបរិភោគច្រើនពេក ដោយស្រេកឃ្លានអស់ ៧-៨ ថ្ងៃមកហើយ ។ នាយគោបាល លុះបាន រៀបចំបាយបាយាសឲ្យដល់ប្ដីប្រពន្ធពីរនាក់នោះហើយ ខ្លួនឯងទើប បរិភោគជាខាងក្រោយ ។ នាយកោតុហលិកៈ បានអង្គុយមើលនាយ គោបាលបរិភោគអាហារ ហើយបានឃើញដុំនៃបាយាសដែលនាយ គោបាលពូតឲ្យដល់មេឆ្កែដែលដេកនៅខាងក្រោមតុ ទើបគិតថា យីអើ! មេឆ្កែនេះមានបុណ្យច្រើនណាស់ហ្ន៎ បានស៊ីអាហារបែបនេះជានិច្ច ។ នាយកោតុហលិកៈនោះ មិនអាចនឹងញ៉ាំងបាយាសឲ្យរលួយបាន ព្រោះ តែការបរិភោគច្រើនពេក ទើបធ្វើកាលកិរិយាក្នុងពេលរាត្រីនោះ ហើយ បានទៅកើតក្នុងពោះនៃមេឆ្កែនោះ ។ គ្រានោះ ភរិយារបស់គាត់បាន ចាត់ចែងធ្វើសរីរកិច្ចរួចហើយ ក៏នៅធ្វើការស៊ីឈ្នួលក្នុងផ្ទះរបស់នាយ គោបាលនោះឯង បានអង្ករមួយនាឡិ ហើយយកទៅចាត់ចែងដាំបាយ ដាក់បាត្រថ្វាយព្រះបច្ចេកពុទ្ធ ហើយពោលថា បពិត្រលោកម្ចាស់ ដ៏ចម្រើន សូមកុសលនេះមានដល់ស្វាមីរបស់ខ្ញុំម្ចាស់ចុះ ហើយនាង

គិតថា យើងគួរនឹងរស់នៅក្នុងទីនេះឯង ព្រោះលោកម្ចាស់ដ៏ចម្រើន តែងតែមកកាន់ទីនេះជានិច្ច ទេយ្យធម៌មានក្តី មិនមានក្តី មិនជាបញ្ហា យើងថ្វាយបង្គំហើយ នឹងធ្វើការខ្វល់ខ្វាយ ឬញុំាងចិត្តឲ្យជ្រះថ្លារាល់ៗថ្ងៃ ក៏បានបុណ្យដែរ នាងគិតឃើញដូច្នេះហើយ ទើបនាងរស់នៅធ្វើជាទាសីនៅក្នុងផ្ទះរបស់នាយគោបាល ។ក្នុងខែទី ៦-៧ មេឆ្កែនោះក៏កើតកូនឈ្មោលមួយ ។ នាយគោបាលក៏បញ្ជាឲ្យគេយកនូវទឹកដោះស្រស់ឲ្យដល់កូនឆ្កែនោះផឹក មិនយូរប៉ុន្មានកូនឆ្កែនោះក៏ធំធាត់ឡើង ។ គ្រានោះព្រះបច្ចេកពុទ្ធ កាលដែលឆាន់រួចហើយ តែងតែឲ្យដុំបាយមួយដុំដល់កូនឆ្កែនោះជានិច្ច ។ ព្រោះអាស្រ័យដុំបាយកូនឆ្កែនោះ ក៏កើតមានចិត្តស្រឡាញ់ចំពោះព្រះបច្ចេកពុទ្ធ ។ នាយគោបាលតែងតែទៅកន្លែងព្រះបច្ចេកពុទ្ធ ដើម្បីបម្រើមួយថ្ងៃ ២-៣ ដងជានិច្ច ។ នាយគោបាលកាលដើរទៅតែងស្រែក ឬយកដំបងវាយបង្អើល ទៅតាមគុម្ពោតឈើទាំងឡាយ ដែលនៅតាមផ្លូវ ក្រែងមានសត្វសាហាវ ស្រែក ២-៣ ដងដើម្បីឲ្យសត្វសាហាវទាំងឡាយរត់ចេញទៅ ឯកូនឆ្កែតែងតែទៅជាមួយ

នាយគោបាលនោះដែរ ។ នៅសម័យថ្ងៃមួយ នាយគោបាលក៏បានពោល ជាមួយនឹងព្រះបច្ចេកពុទ្ធថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលណា ខ្ញុំព្រះករុណា មិនមានឱកាសទំនេរ ក្នុងកាលនោះ ខ្ញុំម្ចាស់នឹងបញ្ជូន កូនឆ្កែនេះមក សូមលោកម្ចាស់គប្បីមកតាមសញ្ញានៃកូនឆ្កែ ដែលខ្ញុំ ម្ចាស់បញ្ជូនមកហើយ ។តាំងពីកាលនោះមក ក្នុងថ្ងៃដែលមិនមានឱកាស នាយគោបាល ក៏បានបញ្ជូនកូនឆ្កែទៅថា នែបា ឯងចូរទៅនិមន្តលោក ម្ចាស់មក ដោយពាក្យត្រឹម តែមួយម៉ាត់ប៉ុណ្ណោះ កូនឆ្កែក៏ស្ទុះរត់ទៅ កាលទៅដល់ទីកន្លែង មានគុម្ពោតឈើ ក៏ស្រែកព្រុសឡើង ២-៣ដង បានដឹងថា សត្វសាហាវរត់គេចបាត់ទៅហើយ ដោយសារឮសំឡេង ព្រុសរបស់ខ្លួននោះហើយ ក៏រត់សំដៅទៅកាន់លំនៅរបស់ព្រះបច្ចេកពុទ្ធ កាលទៅដល់បណ្ណសាលាហើយព្រុសឡើងបីដង ឲ្យលោកដឹងថា ខ្លួនមកដល់ហើយ ក៏ដេកក្រាបនៅក្នុងទីដ៏សមគួរមួយរង់ចាំ ។ កាល ព្រះបច្ចេកពុទ្ធកំណត់ពេលវេលាចេញទៅ កូនឆ្កែក៏បានដើរបណ្តើរ ព្រុសបណ្តើរអំពីខាងមុខៗ ព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធ កាលនឹង

ចង់សាកល្បងមើលកូនក្ដែ ក៏ធ្វើជានិមន្ដទៅកាន់ផ្លូវដទៃ ពេលនោះ កូនក្ដែឃើញដូច្នោះហើយ ក៏រត់ទៅឈរព្រុសស្ទាក់ខាងមុខព្រះបច្ចេកពុទ្ធ ហើយនាំលោកមកកាន់ផ្លូវដើមវិញ ។ ក្នុងថ្ងៃមួយនោះ ព្រះបច្ចេកពុទ្ធ កាលនឹងសាកល្បងមើលកូនក្ដែនោះ ទើបនិមន្ដទៅកាន់ផ្លូវផ្សេងទៀត សូម្បីកូនក្ដែនោះ កាលបើឃើញដូច្នោះហើយ ក៏រត់ទៅព្រុសស្ទាក់ នៅពីមុខព្រះបច្ចេកពុទ្ធៗ ក៏មិនត្រឡប់មក ដោយព្រះបច្ចេកពុទ្ធយក ជើងរុញកូនក្ដែឲ្យចេញផុតពីផ្លូវ ហើយនិមន្ដតទៅទៀត កូនក្ដែដឹងថា ព្រះ បច្ចេកពុទ្ធលោកមិននិមន្ដត្រឡប់វិញទេ ក៏ទៅខាំជាយស្បង់ ឬជាយចីវរ ទាញនាំព្រះបច្ចេកពុទ្ធមកកាន់ផ្លូវដើមវិញ ។ កូនក្ដែនោះ មានសេចក្ដី ស្រឡាញ់ចំពោះព្រះបច្ចេកពុទ្ធនោះយ៉ាងខ្លាំងក្លា ដោយអាការយ៉ាងនេះ ។

ក្នុងកាលជាខាងក្រោយមក ចីវរព្រះបច្ចេកពុទ្ធបានចាស់គ្រាំគ្រា ។ គ្រានោះ នាយគោបាល បានប្រគេនសំពត់សម្រាប់ធ្វើចីវរដល់ព្រះ បច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធ បានពោលទៅនឹងនាយគោបាលថា នៃអ្នក ដ៏ចម្រើន ការធ្វើចីវរដែលបុគ្គលធ្វើម្នាក់ឯងបានដោយលំបាក អាត្មា

នឹងទៅកាន់ទីដែលជាទីសប្បាយហើយនឹងធ្វើចីវរ ។ នាយគោបាល បានពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន និមន្តធ្វើនៅក្នុងទីនេះចុះ ព្រះករុណាម្ចាស់ ។ ព្រះបច្ចេកពុទ្ធតបថា នែអ្នកដ៏ចម្រើន អាត្មា មិនអាចធ្វើចីវរក្នុងទីនេះបានទេ ។ នាយគោបាលបានពោលថា បពិត្រ លោកម្ចាស់ដ៏ចម្រើន បើដូច្នោះ លោកម្ចាស់កុំទៅកាន់ទីកន្លែងដទៃ យូរពេក ។ កូនក្អែបានស្ដាប់ឮពាក្យរបស់ព្រះបច្ចេកពុទ្ធ និងនាយគោបាល នោះ ។ ព្រះបច្ចេកពុទ្ធពោលនឹងនាយគោបាលនោះថា នែឧបាសក ចូរទៅចុះ នាយគោបាលក៏ត្រឡប់ទៅវិញ ហើយព្រះបច្ចេកពុទ្ធ ក៏បាន ហោះឆ្ពោះទៅកាន់ភ្នំគន្ធមាទន៍ទៅ ហើយកូនក្អែបានសម្លឹងមើលព្រះ បច្ចេកពុទ្ធដែលហោះទៅកាន់ភ្នំគន្ធមាទន៍ កាលបើមើលទៅលែងឃើញ ព្រះបច្ចេកពុទ្ធហើយ ហឫទ័យក៏បែកស្លាប់ ។ ដែលឈ្មោះថា សត្វតិរច្ឆាន ទាំងឡាយ រមែងមានចិត្តស្មោះត្រង់ ចំណែកមនុស្សមានចិត្តគិតផ្សេងៗ មាត់និយាយផ្សេងមិនដូចគ្នា ព្រោះហេតុនោះឯង បុត្ររបស់នាយបង្ហាត់ដំរី ឈ្មោះបេស្សៈពោលថា បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយ

រមែងមានចិត្តស្រឡាញ់ មានចិត្តធូន់ ចំណែកសត្វចិញ្ចឹម (បសុសត្វ) ទាំងឡាយ រមែងមានចិត្តស្រោល ព្រះករុណាព្រះអង្គ ។ កូនឆ្កែនោះ កាលបើស្លាប់ទៅហើយ ក៏បានទៅកើតក្នុងស្ថានតាវត្តិង្ស មានស្រីទេពអប្សរ ១០០០ ចោមរោមជាបរិវារ និងបានសោយមហាសម្បត្តិដ៏ធំ ក៏ព្រោះជាសត្វមានការឃើញដ៏ត្រឹមត្រូវ និងមិនមានការវៀចវេរ ។ កាលទេវបុត្រនោះ ខ្សឹបនៅជិតនៃត្រចៀក របស់បុគ្គលណាៗ ហើយ សំឡេងរមែងឮឆ្ងាយទៅបាន ១៦ យោជន៍ ចំណែកសំឡេង ដែលនិយាយជាធម្មតាវិញ រមែងឮចេញទៅឆ្ងាយប្រមាណមួយម៉ឺនយោជន៍ ។ ព្រោះហេតុនោះឯង ទេវបុត្រនោះមានទាមថា **ឃោសកទេវបុត្រ** ។ នេះជាផលនៃកម្មអ្វី ? ជាផលនៃការព្រុសជូនដំណើរព្រះបច្ចេកពុទ្ធ ដោយសេចក្ដីស្រឡាញ់ ។ឃោសកទេវបុត្រនោះ តាំងនៅក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស មិនយូរប៉ុន្មានក៏ចុតិមកវិញ ។ ហេតុដែលធ្វើឲ្យទេវបុត្រចុតិមាន៤ប្រការ ពិតណាស់ ទេវបុត្រទាំងឡាយ រមែងចុតិចាកទេវលោកដោយហេតុ ៤ យ៉ាងនេះគឺ ១-ដោយការអស់អាយុ ២-ដោយការ

អស់បុណ្យ ៣- ដោយការអត់អាហារ ៤- ដោយសេចក្ដីក្រោធ ។ ក្នុងបណ្ដាហេតុទាំង ៤ យ៉ាងនោះ ទេវបុត្រអង្គណាបានធ្វើបុញ្ញកម្មទុកជាច្រើន ទេវបុត្រអង្គនោះ បាននៅក្នុងទេវលោកជរាបដល់អស់អាយុហើយ ក៏បានទៅកើតក្នុងទេវលោកជាន់ខ្ពស់ៗ ឡើងទៅទៀត យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអស់អាយុ ។ ទេវបុត្រអង្គណាធ្វើបុណ្យទុកបានតិច បុណ្យនោះរមែងអស់ទៅក្នុងចន្លោះ ដូចជាធញ្ញជាតិដែលបុគ្គលទុកដាក់នៅ ក្នុងជង្រុកជំប្រមាណត្រឹមតែ ៤-៥ នាឡិដូច្នេះ យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអស់បុណ្យ ។ ទេវបុត្រអង្គខ្លះ រវល់តែបរិភោគកាមគុណ រហូតភ្លេចបរិភោគអាហារ ព្រោះតែការវង្វេងភ្លេចសតិ មានការនឿយហត់ហើយ ក៏ចុតិទៅ យ៉ាងនេះឈ្មោះថា ចុតិដោយការអត់អាហារ ។ ទេវបុត្រអង្គខ្លះ អត់ទ្រាំមិនបានចំពោះសេចក្ដីក្រោធ ហើយក៏ចុតិ យ៉ាងនេះឈ្មោះថា ចុតិដោយសេចក្ដីក្រោធ ។ ចំណែក ឃោសកទេវបុត្រអង្គនេះ រវល់តែបរិភោគកាមគុណ វង្វេងភ្លេចសតិ ទើបចុតិដោយការអត់អាហារ ។ លុះចុតិមកហើយ ក៏បាន

ទៅបដិសន្ធិ នៅក្នុងផ្ទៃនៃស្ត្រីលម្អនគរ នៅក្នុងក្រុងកោសម្ពី ។ ក្នុងថ្ងៃសម្រាលមក នាងបានសួរទាសីថា កូនប្រុស ឬកូនស្រី កាលនាងទាសីឆ្លើយថា បពិត្រអ្នកនាងម្ចាស់ កូនប្រុស ទើបប្រាប់ឲ្យនាងទាសីយកទៅបោះចោលដោយពាក្យថា នាងចូរយកទារកនេះទៅដាក់ក្នុងចង្អេរចាស់ ហើយយកទៅបោះចោលលើគំនរសំរាមចុះ ពិតណាស់ស្រីលម្អក្រុងទាំងឡាយ រមែងចិញ្ចឹមតែកូនស្រី មិនត្រូវការចិញ្ចឹមកូនប្រុសទេ ដ្បិតប្រពៃណីរបស់ពួកគេមានការចិញ្ចឹមតែកូនស្រីប៉ុណ្ណោះដើម្បីបន្តវេនរបស់ពួកគេ ។ កាលយកទារកនោះទៅចោលលើគំនរសំរាមហើយ សុម្បីក្អែក ឬសុនខត្រឹមតែមួយមិនអាចចូលទៅជិតទារកបានទាំងនេះជាផលនៃការព្រួសដែលកើតមកអំពីសេចក្តីស្រឡាញ់ ចំពោះព្រះបច្ចេកពុទ្ធ ។ ក្នុងខណៈនោះ មានមនុស្សចេញទៅក្រៅផ្ទះ ក៏បានឃើញក្អែកចោមរោម ក៏គិតថា មានហេតុអ្វីហ្ន៎ ទើបដើរទៅមើលក្នុងទីនោះ បានឃើញទារកនោះភ្លាម ក៏កើតមានសេចក្តីស្រឡាញ់ ចំពោះទារកនោះ ដូចជាកូនរបស់ខ្លួន ទើបនាំទារកនោះទៅកាន់ផ្ទះ ដោយ

សេចក្តីសប្បាយចិត្តថា យើងបានកូនប្រុសមួយហើយ ។

គ្រានោះសេដ្ឋីអ្នកនៅក្នុងក្រុងកោសម្ពីបានទៅកាន់រាជត្រកូល បានជួបជាមួយនឹងបុរោហិត ដែលដើរមកពីរាជវាំងក៏សួរថា បពិត្រលោកអាចារ្យ ថ្ងៃនេះ លោកបានពិចារណាមើលផ្កាយនៃនក្ខត្តឫក្ស ដែលជាហេតុនៃគ្រោះល្អ ឬអាក្រក់ហើយឬ ? បុរោហិតពោលតបថា អើ មហាសេដ្ឋី កិច្ចអ្វីដទៃរបស់យើងមិនមាន ។ លោកសេដ្ឋីបានពោលថា បពិត្រលោកអាចារ្យ មានរឿងអ្វីកើតដល់អ្នកជនបទឬ ? រាជបុរោហិតពោលតបថា អ្វីយ៉ាងដទៃមិនមានទេ ប៉ុន្តែទារកដែលកើតនៅក្នុងថ្ងៃនេះ នឹងបានមកជាសេដ្ឋីដ៏ប្រសើរនៅក្នុងក្រុងនេះ ។ ពេលនោះ ភរិយារបស់លោកសេដ្ឋីដែលមានគភ៌គ្រប់ខែហើយ ព្រោះ ហេតុនោះ លោកសេដ្ឋី ក៏បានបញ្ជាប្រើអ្នកបម្រើឲ្យទៅកាន់ផ្ទះយ៉ាងឆាប់ ដោយពោលថា នែបា ឯងចូរទៅមើលភរិយារបស់អញថា សម្រាលកូនហើយ ឬនៅទេ ? លុះដឹងថា មិនទាន់សម្រាល កាលបានគាល់ព្រះរាជារួចហើយ ប្រញាប់ត្រឡប់ទៅផ្ទះយ៉ាងឆាប់រហ័ស ហៅទាសីម្នាក់ឈ្មោះថា កាឡី

មកហើយ ឲ្យយកទ្រព្យ ១០០០ កហាបណៈ ពោលថា នាងចូរទៅ រកមើលនៅក្នុងក្រុងនេះ មានទារកណាដែលកើតក្នុងថ្ងៃនេះ បើមាន ចូរនាងឲ្យទ្រព្យ ១០០០ កហាបណៈនេះដល់អាណាព្យាបាលហើយ ចូរនាំទារកនោះមក ។ គ្រានោះ នាងកាឡីបានដើរៗ ទៅ ក៏បានឃើញ ទារកនោះ ហើយទើបសាកសួរម្ចាស់ផ្ទះថា ក្មេងនេះកើតពីពេលណា ? ស្ត្រីជាម្ចាស់ផ្ទះនោះ ឆ្លើយថា កើតក្នុងថ្ងៃនេះឯង ទើបនិយាយថា ចូរឲ្យក្មេងនេះមកដល់ខ្ញុំៗ នឹងឲ្យតម្លៃតាំងពី ១០០ រហូតដល់ ១០០០ កហាបណៈ កាលបើយល់ព្រមហើយ ក៏នាំក្មេងនោះទៅឲ្យលោកសេដ្ឋី ។ លោកសេដ្ឋីគិតថា បើកូនរបស់យើងកើតមកជាស្រី យើងនឹងឲ្យគេ នៅរួមជាមួយនឹងកូនស្រីរបស់យើង ហើយនឹងតែងតាំងគេឲ្យជាសេដ្ឋី បើកូនរបស់យើងជាប្រុស យើងនឹងសម្លាប់វាចោល កាលគិតឃើញ ដូច្នេះហើយ ទើបទទួលយកក្មេងនោះទុក ថែរក្សានៅក្នុងផ្ទះរបស់ខ្លួន ។ ក្រោយមក កន្លងទៅបាន ២-៣ ថ្ងៃ ភរិយារបស់លោកសេដ្ឋីនោះ ក៏សម្រាលបុត្រមកបានកូនប្រុសមួយ ។ លោកសេដ្ឋីក៏គិតថា ប្រសិនបើ

មិនមានក្មេងនេះទេ កូនប្រុសរបស់យើងនឹងបានតំណែងជាសេដ្ឋីដូចនេះ យើងគួរតែសម្លាប់ក្មេងនេះចោល កាលលោកគិតឃើញដូច្នេះហើយ ក៏បានហៅទាសីមកប្រាប់ថា ពេលហ្វូងគោចេញពីក្រោល នាងចូរយកក្មេងនេះ ដាក់ឲ្យដេកនៅត្រង់ផ្លូវក្រោលគោ ពេលដែលគោទាំងឡាយចេញនឹងជាន់វាស្លាប់មិនខាន ប៉ុន្តែនាងត្រូវចាំឃ្លាំមើលសិនថា គោជាន់ឬមិនជាន់វា ហើយសឹមត្រឡប់មក ។ គ្រានោះ នាងទាសីក៏បានធ្វើតាមពាក្យបញ្ជារបស់លោកសេដ្ឋី ដោយយកក្មេងនោះ ទៅឲ្យដេកនៅត្រង់ទ្វារក្រោលគោចេញ ពេលដែលបើកទ្វារឲ្យគោចេញ គោឧសភៈដែលជាមេហ្វូង ក្នុងថ្ងៃមុនៗ ចេញពីក្រោល ក្រោយគេបង្អស់ ប៉ុន្តែក្នុងថ្ងៃនោះ បានចេញទៅមុនគោដទៃទាំងអស់ ថែមទាំងបានទៅឈរបាំងការពារទារកឲ្យនៅក្នុងចន្លោះជើងទាំង ៤ ទៀតផង ។ មេគោទាំងឡាយច្រើនរយបាននាំគ្នាដើរចេញទៅ ដោយដើរចៀសគោឧសភៈនោះ ។ សូម្បីនាយគោបាលក៏គិតថា គោឧសភៈ នេះក្នុងថ្ងៃមុនៗ បានចេញពីក្រោលក្រោយគេ តែក្នុងថ្ងៃនេះ បានចេញទៅមុនគេ ហើយឈប់នៅឈរ

ស្ទៀមត្រង់ទ្វារក្រោលនោះ មានហេតុអ្វីហ្ន៎ ទើបដើរទៅមើល ក៏បាន ឃើញកូនក្មេងនៅក្រោមពោះគោនោះ ហើយក៏កើតមានសេចក្ដីស្រឡាញ់ ចំពោះក្មេងនោះ ដូចជាកូនរបស់ខ្លួន រួចក៏បាននាំទៅផ្ទះ ដោយគិតថា យើងបានកូនប្រុសមួយហើយ ។ កាលនាងកាឡីឃើញដូច្នោះហើយ ក៏បានត្រឡប់ទៅផ្ទះវិញ តំណាលរឿងទាំងអស់នោះ ឲ្យលោកសេដ្ឋី បានជ្រាប បន្ទាប់ពីបានដឹងហើយ លោកសេដ្ឋីពោលថា នែនាងកាឡី នាងឯងចូរទៅ ហើយចូរឲ្យទ្រព្យ ១០០០ កហាបណៈដល់បុរសនោះ ហើយនាំវាត្រឡប់មកវិញ នាងកាឡីក៏បានធ្វើតាមបញ្ជារបស់លោកសេដ្ឋី គឺបានយកទ្រព្យ ១០០០ កហាបណៈឲ្យដល់បុរសនោះ ហើយនាំយក ទារកនោះត្រឡប់មកប្រគល់ឲ្យលោកសេដ្ឋីវិញ ។

គ្រានោះ លោកសេដ្ឋីបានពោលនឹងនាងកាឡីថា នែនាងកាឡី ក្នុងក្រុងនេះ មានពួកឈ្មួញរទេះ ៥០០ តែងក្រោកឡើងពីងងឹតៗ ធ្វើដំណើរទៅជួញ ។ ដូច្នេះ នាងចូរនាំក្មេងនេះទៅដាក់ឲ្យដេកក្នុងផ្លូវរទេះ គោទាំងឡាយៗនឹងជាន់វា ឬក៏រទេះទាំងឡាយនឹងកិនខ្លួនវាស្លាប់មិនខាន

ហើយនាងឯងចូរចាំឃ្លាំមើលដូចមុនសិន តើរទេះទាំងនោះ កិនវាដែរ ឬទេ ? នាងកាឡីក៏បាននាំក្មេងនោះទៅហើយ យកទៅដាក់ក្នុងផ្លូវរទេះ តាមបញ្ជារបស់លោកសេដ្ឋីមែន ។ ពេលនោះ ជន្មោររទេះបានទៅខាង មុខគេ ពេលទៅដល់ទីនោះហើយ គោទាំងឡាយក៏ឈប់ទ្រឹង មិនទៅ មុខទៀត ព្រមទាំងរលាស់នឹមចេញ ។ សូម្បីជន្មោររទេះចាប់ទាញនឹម ញយៗ ជង គោទាំងនោះ ក៏មិនព្រមដើរទៅមុខដែរ ។ កាលជន្មោនោះ ព្យាយាមធ្វើយ៉ាងនោះ រហូតដល់អរុណរះឡើង ដោយគោទាំងនោះ មិនព្រមទៅមុខ ។ទើបគាត់គិតថា គោនេះមិនទៅមុខ តើមានហេតុអ្វីហ្ន៎ ទើបពិនិត្យមើលផ្លូវ ក៏បានឃើញទារកដេកនៅលើផ្លូវនោះ ក៏គិតថា កម្មរបស់យើងធ្ងន់ណាស់ហ្ន៎ ក៏មានចិត្តត្រេកអរថា យើងបានកូនប្រុស ម្នាក់ហើយ ទើបនាំក្មេងនោះទៅកាន់ផ្ទះរបស់ខ្លួន កាលបើនាងកាឡី ឃើញហេតុការណ៍ដូច្នោះហើយ ក៏បានត្រឡប់ទៅផ្ទះវិញ សេដ្ឋីក៏បាន សួរពីរឿងនោះ នាងក៏បានប្រាប់លោកសេដ្ឋីឲ្យជ្រាប កាលបើលោកសេដ្ឋី បានជ្រាបហើយ ទើបពោលជាមួយនឹងនាងកាឡីថា នាងចូរយកទ្រព្យ

១០០០ កហាបណៈ ឲ្យដល់ជន្មៅរទេះនោះ ហើយនាំយកក្មេងនោះត្រឡប់មកវិញ នាងក៏បានធ្វើទៅតាមបញ្ជាទាំងនោះដូចមុន ។ពេលនោះ សេដ្ឋីបានពោលជាមួយនឹងនាងកាឡីនោះថា ឥឡូវនេះ នាងចូរនាំវាទៅកាន់ព្រៃស្មសាន ហើយដាក់ឲ្យវាដេកនៅក្នុងចន្លោះនៃគុម្ពឈើ វាប្រាកដជាត្រូវសត្វទាំងឡាយ មានឆ្កែព្រៃជាដើមខាំស៊ី ឬក៏ត្រូវអមនុស្សសម្លាប់វាឲ្យស្លាប់ក្នុងទីនោះមិនខាន ហើយនាងក៏ចាំឃ្លាំមើលសិនដែរដូចលើកមុនទៀត សឹមត្រឡប់មកវិញ នាងកាឡីក៏បាននាំក្មេងនោះទៅព្រៃស្មសាន ក៏បានធ្វើទៅតាមបញ្ជាលោកសេដ្ឋីដែលប្រាប់ ហើយក៏ឈរនៅក្នុងទីដ៏សមគួរ ចាំឃ្លាំមើលដូចលើកមុនៗ ទៀត ។ ឆ្កែក្តីក្អែកក្តី អមនុស្សក្តី មិនអាចចូលទៅជិតបាន ។មានពាក្យសួរថា បណ្តាជនទាំងឡាយ មានមាតាបិតា បងប្អូនជាដើម នរណាមួយឈ្មោះថា ជាអ្នកថែរក្សាក្មេងនោះ មិនមែនឬ តើនរណាជាអ្នករក្សាក្មេងនោះ ?ឆ្លើយថា បុណ្យ គឺការព្រួសដែលទារកនោះ កាលនៅជាសុនខបានព្រួសបង្អើលសត្វសាហាវ ដោយសេចក្តីស្រឡាញ់ចំពោះព្រះបច្ចេកពុទ្ធ ដោយបំណង

មិនឲ្យសត្វសាហាវទាំងឡាយបៀតបៀនព្រះបច្ចេកពុទ្ធ កម្មនេះឯងជាអ្នករក្សា ។ ពេលនោះឯង បុរសដែលជាអ្នករក្សាពពែម្នាក់ បានកៀងមេពពែជាច្រើនសែនក្បាល ទៅកាន់គោចរឯព្រៃស្មសាន មានមេពពែមួយបានដើរស៊ីស្លឹកឈើជាដើម បានចូលទៅកាន់គុម្ពឈើដែលទារកដេក ឃើញទារកនោះហើយ ទើបលុតជង្គង់ឲ្យទារកនោះបៅដោះ សូម្បីបុរសដែលជាអ្នក រក្សាពពែបានធ្វើសំឡេងហ៊ឺយៗ ក៏មិនចេញ បុរសនោះគិតថានឹងយករំពាត់វាយឲ្យចេញ ទើបដើរតម្រង់ទៅគុម្ពឈើនោះ ក៏បានឃើញមេពពែកំពុងតែលុតជង្គង់បំបៅទារកនោះ កាលឃើញដូច្នោះហើយក៏មានសេចក្ដីស្រឡាញ់ចំពោះទារកនោះថា ដូចជាកូនប្រុសរបស់ខ្លួនទើបនាំទារកនោះទៅដោយគិតថា យើងបានកូនប្រុសម្នាក់ហើយ នាងកាឡីកាលបើឃើញហេតុការណ៍ដូច្នោះហើយ ក៏ត្រឡប់ទៅផ្ទះវិញថែមទាំងបានជម្រាបរឿងរ៉ាវទាំងនោះ ឲ្យលោកសេដ្ឋីបានជ្រាប កាលបើលោកសេដ្ឋីបានជ្រាបហើយ បានពោលថា នាងចូរយកទ្រព្យ ១០០០ កហាបណៈឲ្យដល់បុរសនោះ ហើយនាំទារកនោះមកវិញ នាងកាឡី

ក៏បានធ្វើតាមពាក្យបញ្ជារបស់លោកសេដ្ឋី ។ គ្រានោះ លោកសេដ្ឋីបានពោលទឹងនាងកាឡីថា នែនាងកាឡីនាងឯង ចូរនាំយកទារកនេះឡើងទៅលើភ្នំ ដែលជាទីសម្រាប់ចោលចោររួចហើយ ចូរបោះវាទៅក្នុងជ្រោះ វានឹងប៉ះទង្គិចថ្មភ្នំ ឬដាច់ជាកំណាត់តូចៗ ធ្លាក់ចុះមកលើផែនដីនឹងស្លាប់មិនខាន ហើយនាងឯងនៅរង់ចាំឃ្លាំមើលវាសិនថា ស្លាប់ហើយឬក៏មិនទាន់ស្លាប់ សឹមត្រឡប់មក នាងកាឡីក៏បានធ្វើតាមពាក្យបញ្ជារបស់លោកសេដ្ឋីដែលបញ្ជានោះ ដោយបោះទារកនោះចូលទៅក្នុងជ្រោះមែន ។ ក៏ក្នុងជ្រោះនោះ មានគុម្ពឫស្សីមួយគុម្ពធំដែលមានគុម្ពទំពាំងបាយជូរដុះគ្របនៅពីលើគុម្ពឫស្សីធំនោះ កាលបោះទារកនោះធ្លាក់ចុះមក ក៏ធ្លាក់ទៅលើគុម្ពនៃវល្លិ៍ទំពាំងបាយជូរនោះ ហាក់បីដូចជាធ្លាក់ចុះទៅលើផ្ទាំងសំពត់រោមសត្វ ហើយក្នុងថ្ងៃនោះ នាយជាងផែងមានសេចក្តីត្រូវការនូវបន្ទះឫស្សី គាត់ក៏ទៅកាន់ព្រៃភ្នំជាមួយនឹងកូនរបស់គាត់ដើម្បីកាប់ឫស្សី ប្រុងនឹងកាប់គុម្ពឫស្សីនោះ នាកាលគុម្ពឫស្សីកម្រើកទារកនោះក៏បានស្រែកយំឡើង ។ ទើបគាត់និយាយថា ដូចជា

មានសំឡេងកូនក្មេងយំ ក៏ឡើងតាមចំហៀងនៃភ្នំទៅ ក៏បានឃើញទារកនោះ រួចក៏មានចិត្តរីករាយសប្បាយ ទើបនាំទៅផ្ទះរបស់ខ្លួន ដោយគិតថា យើងបានកូនប្រុសម្នាក់ហើយ ។ នាងកាឡីកាលបើឃើញដូច្នោះ ក៏បានយករឿងរ៉ាវទាំងអស់នោះ ទៅជម្រាបដល់លោកសេដ្ឋីវិញទៀត លោកសេដ្ឋី កាលបើជ្រាបដូច្នោះហើយ ក៏បានពោលថា នាងចូរយកទ្រព្យ ១០០០ កហាបណៈ ឲ្យជាងផែង ហើយយកទារកមកវិញ នាងកាឡី ក៏បានធ្វើតាមពាក្យរបស់លោកសេដ្ឋីដែលបានបញ្ជានោះទៅ ។

កាលលោកសេដ្ឋី បានគិតសម្លាប់ទារកនេះអស់កាលដ៏យូរ ទារកនោះក៏ចម្រើនឡើងដោយលំដាប់មក ជាពិសេសនោះ ទារកនោះមិនបានស្លាប់ដោយអំពើរបស់លោកសេដ្ឋីឡើយ ។ ទារកនោះមានឈ្មោះថា **ឃោសកៈ** ។ ឃោសកកុមារនោះ ដូចជាបន្លាក្នុងភ្នែករបស់លោកសេដ្ឋី ។ លោកសេដ្ឋីមិនអាចដើម្បីនឹងសម្លឹងមើលនូវឃោសកកុមារនោះត្រង់ៗ បាន លោកសេដ្ឋីបានរកឧបាយ ដើម្បីនឹងសម្លាប់នូវឃោសកកុមារនោះទៀត ទើបទៅកាន់សម្នាក់នៃនាយស្មូនឆ្នាំងដែលជា

សម្លាញ់របស់ខ្លួន ហើយសួរថា កាលណាលោកនឹងដុតឡ ? នាយស្ទូនផ្ទាំងឆ្លើយថា ខ្ញុំដុតក្នុងថ្ងៃស្អែកនេះ លោកសេដ្ឋីបានពោលថា បើដូច្នោះ លោកចូរទទួល ១០០០ កហាបណៈនេះចុះ ហើយចូរធ្វើនូវកិច្ចការងារមួយឲ្យខ្ញុំ ។ នាយស្ទូនផ្ទាំងសួរថា បពិត្រលោកសេដ្ឋីឲ្យខ្ញុំធ្វើកិច្ចការងារអ្វី ? លោកសេដ្ឋីប្រាប់ថា ខ្ញុំមានអវជាតបុត្រម្នាក់ ខ្ញុំនឹងបញ្ជូនវាមកសម្នាក់របស់លោក កាលបើវាមកដល់លោកចូរឲ្យវាចូលទៅក្នុងបន្ទប់ ហើយយកកាំបិតដ៏មុតកាប់វាឲ្យដាច់ជាកំណាត់តូច-ធំ ដាក់វាក្នុងពាង ហើយដុតក្នុងឡចុះ ទ្រព្យ ១០០០ កហាបណៈនេះជារង្វាន់របស់លោក ។ ថ្ងៃក្រោយខ្ញុំនឹងធ្វើអំពើដែលគួរធ្វើដល់លោកឲ្យក្រៃលែងជាងនេះទៅទៀត ។ នាយស្ទូនផ្ទាំងឆ្លើយថា បាន ។ លុះដល់ថ្ងៃស្អែកឡើង លោកសេដ្ឋីក៏បានហៅឃោសកកុមារមក ហើយបញ្ជូនទៅដោយពាក្យថា នែកូនកាលពីម្សិលមិញនេះបិតាបង្គាប់ឲ្យស្ទូនផ្ទាំងធ្វើកិច្ចការងារមួយឲ្យបិតា កូនឯងចូរទៅកាន់សម្នាក់របស់នាយស្ទូនផ្ទាំង ហើយពោលយ៉ាងនេះថា លោកបានធ្វើកិច្ចការងារ ដែលបិតារបស់

ខ្ញុំបង្គាប់ទុកកាលពីម្សិលមិញឲ្យស្រេចចុះ ឃោសកកុមារនោះទទួលថា បាទ ហើយក៏បានធ្វើដំណើរទៅមែន ។ ចំណែកកូនប្រុសរបស់លោកសេដ្ឋី កំពុងតែលេងអង្គញ់ជាមួយនឹងពួកក្មេងដទៃទៀត កាលឃើញឃោសក កុមារនោះដើរមក ក៏ហៅឃោសកកុមារនោះ ហើយសួរថា បង! បងឯង ទៅណា ? ឃោសកកុមារប្រាប់ថា បងនាំពាក្យបណ្តាំរបស់បិតាយើងទៅ កាន់សម្នាក់របស់ស្មូនឆ្នាំង ទើបនិយាយថា ខ្ញុំទៅទីនោះជំនួសបងវិញ ហើយឲ្យបងលេងជំនួសខ្ញុំឲ្យបានឈ្នះវិញឲ្យដល់ខ្ញុំផង ។ ឃោសក កុមារប្រាប់ប្អូនថា បងខ្លាចបិតាជាឲ្យដឹង ។ កូនសេដ្ឋីបានប្រាប់បងថា បងឯងកុំខ្លាចឡើយ ខ្ញុំជាអ្នកនាំយកបណ្តាំទៅដោយខ្លួនឯងវិញ ព្រោះ ពួកក្មេងទាំងនេះបានលេងឈ្នះខ្ញុំច្រើនណាស់ សូមបងលេងដណ្តើម យកឈ្នះឲ្យខ្ញុំវិញ ។ បានឮមកថា ឃោសកកុមារជាអ្នកឈ្លាសវៃក្នុងការ លេងអង្គញ់ ព្រោះហេតុនោះ កូនប្រុសរបស់លោកសេដ្ឋី ក៏បានទទួច អង្វរឃោសកកុមារយ៉ាងនោះទៅ ។ ចំណែកឃោសកៈ ក៏និយាយ នឹងកូនប្រុសរបស់លោកសេដ្ឋីនោះថា បើដូច្នោះ ប្អូនឯងចូរទៅប្រាប់

នាយស្នូនផ្ទាំងថា កាលពីថ្ងៃម្សិលមិញនេះ បិតារបស់ខ្ញុំបង្គាប់ឲ្យលោកធ្វើកិច្ចការងារមួយ លោកចូរធ្វើកិច្ចការងារនោះឲ្យសម្រេចទៅចុះ ដូច្នេះហើយ ក៏បញ្ជូនប្អូនប្រុសដែលត្រូវជាកូនរបស់ លោកសេដ្ឋីទៅកាន់សម្នាក់របស់នាយស្នូនផ្ទាំង ។ កូនប្រុសរបស់លោកសេដ្ឋីនោះ កាលបើទៅដល់សម្នាក់របស់នាយស្នូនផ្ទាំងនោះ ហើយក៏បានពោលតាមពាក្យបណ្តាំនោះ ។ កាលបើពោលតាមពាក្យបណ្តាំនោះហើយ គ្រានោះនាយស្នូនផ្ទាំងបានសម្លាប់កូនប្រុសរបស់លោកសេដ្ឋីនោះ ហើយបោះចូលទៅក្នុងឡ ។ ចំណែកឃោសកៈ លេងរហូតដល់រសៀល ក៏ត្រឡប់ទៅកាន់គេហដ្ឋានវិញ កាលលោកសេដ្ឋីឃើញឃោសកៈមកហើយសួរថា នែកូនសម្លាញ់ កូនឯងមិនបានទៅទេឬ ? ឃោសកៈក៏បានប្រាប់នូវហេតុដែលខ្លួនមិនបានទៅ និងហេតុដែលកូនប្រុសរបស់លោកសេដ្ឋីទៅជំនួសឲ្យបានជ្រាប លោកសេដ្ឋីបានឮដូច្នោះហើយ ក៏បានស្រែកនូវសំឡេងយ៉ាងខ្លាំងឡើងថា កុំសម្លាប់កូនយើងឡើយ ថែមទាំងផ្គងអញ្ជលីឡើងកន្ទក់កន្ទេញថា នែនាយស្នូនផ្ទាំងដ៏ចម្រើន លោកកុំធ្វើឲ្យ

យើងវិនាសឡើយ ពោលដូច្នេះហើយ ក៏បានរត់ទៅកាន់សម្នាក់របស់នាយស្មូនឆ្នាំងនោះ ។

គ្រានោះ នាយស្មូនឆ្នាំង កាលបើបានឃើញលោកសេដ្ឋីនោះមកដោយអាការយ៉ាងនោះហើយ ក៏និយាយថា បពិត្រលោកសេដ្ឋី លោកកុំធ្វើសំឡេងឮខ្លាំងពេក កិច្ចការងាររបស់លោកខ្ញុំបានធ្វើស្រេចហើយ ។ លោកសេដ្ឋីនោះបានត្រូវសេចក្តីសោកដ៏ធំ គ្របសង្កត់ហើយ ឬហាក់បីដូចជាត្រូវថ្មភ្នំដ៏ធំសង្កត់អ៊ីចឹង ឬក៏ដូចជាបុគ្គលអ្នកមានចិត្តប្រទូស្តបុគ្គល ដែលមិនគួរប្រទូស្តដូច្នោះ អ្នកប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្តតប រមែងដល់ឋានៈ ១០ យ៉ាង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលណាប្រទូស្តដោយអាជ្ញាចំពោះបុគ្គលទាំងឡាយដែលមិនមានអាជ្ញា ហើយមិនប្រទូស្តតបបុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡុកចិត្ត ( ឆ្កួត ) ១ រឹបជាន់អំពី

ស្តេច ១ ពោលពាក្យបង្អាច់ដ៏អាក្រក់ ១ អស់ញាតិវលីង ១ ពុកផុយ
កោគទ្រព្យទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ
១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយនេះទៅហើយ រមែង
ទៅកើតក្នុងនរក ។ សូម្បីមានសភាពយ៉ាងនោះហើយក៏ដោយ លោក
សេដ្ឋី ក៏មិនអាចសម្លឹងឃោសកៈនោះ ដោយត្រង់ៗ បានទៀត ទើបគិត
រកឧបាយថា ធ្វើយ៉ាងណាហ្ន៎ ទើបនឹងសម្លាប់គេបាន បានសម្លឹងឃើញ
ឧបាយថា យើងនឹងបញ្ជូនវាទៅកាន់សម្នាក់នៃអ្នកយកសួយ នៅក្នុង
ស្រុកសួយ ១០០ របស់យើងឲ្យវាស្លាប់នៅក្នុងទីនោះ កាលគិតឃើញ
ដូច្នេះហើយ ទើបសរសេរសំបុត្រផ្ញើទៅនាយស្មៀននោះថា បុគ្គលនេះ
ជាកូនថោកទាបរបស់យើង ដូច្នេះឯងចូរសម្លាប់វា ហើយបោះវាចូលទៅ
ក្នុងរណ្តៅអាចម៍ចុះ ។ កាលធ្វើយ៉ាងនេះស្រេចហើយ ខ្ញុំនឹងដឹងនូវអំពើ
ដែលគួរធ្វើដល់លោកក្នុងកាលជាខាងក្រោយ កាលសរសេរដូច្នេះហើយ
ទើបពោលថា នែកូនសម្លាញ់ នាយស្មៀនរបស់បិតា មាននៅឯស្រុក
សួយ ១០០ កូនឯងចូរនាំយកសំបុត្រមួយច្បាប់នេះទៅឲ្យគេ ដូច្នេះហើយ

ក៏យកសំបុត្រចងទុកនឹងជាយសំពត់របស់ឃោសកៈទៅ ។ នាយឃោសកៈនោះមិនចេះអក្សរទេ ព្រោះតាំងពីនៅក្មេង លោកសេដ្ឋីគិតតែរកឧបាយសម្លាប់ចោលជានិច្ច ប៉ុន្តែមិនអាចសម្លាប់បាន តើកុមារនោះ សិក្សាសាស្ត្របានដូចម្តេច នាយឃោសកៈនោះ ចងសំបុត្រសម្លាប់ខ្លួនឯងទុកនឹងជាយសំពត់ ដោយប្រការដូច្នេះ មុននឹងចេញធ្វើដំណើរទៅ ក៏បាននិយាយជាមួយនឹងលោកសេដ្ឋីថា បពិត្របិតា ខ្ញុំមិនមានស្បៀងសម្រាប់ធ្វើដំណើរទេ ។ លោកសេដ្ឋីពោលថា កូនឯងមិនចាំបាច់យកស្បៀងធ្វើដំណើរទេ ក្នុងស្រុកឯណោះ ក្នុងរវាងផ្លូវ សេដ្ឋីដែលជាសម្លាញ់របស់បិតាមានម្នាក់ដែរ កូនឯងចូរទៅបរិភោគអាហារពេលព្រឹក ឯផ្ទះរបស់លោកសេដ្ឋីនោះហើយ ចាំធ្វើដំណើរបន្តទៅមុខទៀតចុះ ។ នាយឃោសកៈនោះពោលទទួលថា បាទ ក៏បានសំពះលាបិតា ធ្វើដំណើរចេញទៅដល់ស្រុកនោះ ហើយបានសួររកផ្ទះសេដ្ឋីដើរៗ ទៅ ក៏បានទៅជួបនឹងកិរិយារបស់លោកសេដ្ឋី កាលកិរិយារបស់លោកសេដ្ឋីសួរថា ឯងមកអំពីទីណា ? ក៏ឆ្លើយថា មកអំពីក្រុង ។ កិរិយារបស់លោកសេដ្ឋី

សួរថា ឯងជាកូនចៅរបស់អ្នកណា ? នាយឃោសកៈឆ្លើយថា បពិត្រអ្នកស្រី ខ្ញុំជាកូនរបស់លោកសេដ្ឋីដែលជាសម្លាញ់របស់ស្វាមីអ្នកស្រី ។ ភរិយារបស់លោកសេដ្ឋីសួរទៀតថា ឯងឈ្មោះឃោសកៈមែនឬ ? ឃោសកៈ ឆ្លើយថា បាទ ពិតមែនហើយអ្នកស្រី ។

គ្រានោះ គ្រាន់តែឃើញភ្លាម សេចក្តីស្រឡាញ់ដូចជាកូនចំពោះឃោសកៈនោះ ក៏បានកើតភ្លាមដល់ភរិយារបស់លោកសេដ្ឋី ។ លោកសេដ្ឋីនោះ មានកូនស្រីម្នាក់ នាងមានអាយុប្រហែលជា ១៥ ឬ ១៦ ឆ្នាំហើយ នាងជាអ្នកមានរូបរាងស្រស់ស្អាត គួរឲ្យជាទីស្រឡាញ់ ។ លោកសេដ្ឋីបានប្រគល់ទាសីម្នាក់ ទុកដើម្បីឲ្យបម្រើនាងនៅក្នុងបន្ទប់ដ៏មានសិរីលើប្រាសាទជាន់ទី ៧ ក្នុងខណៈនោះ កូនស្រីរបស់លោកសេដ្ឋីបានប្រើនាងទាសីឲ្យទៅផ្សារដើម្បីទិញផ្កា ។ គ្រានោះ ភរិយារបស់លោកសេដ្ឋីឃើញនាងទាសីនោះហើយ សួរថា នាងឯងទៅណា ? នាងទាសីឆ្លើយថា បពិត្រអ្នកស្រីនាង ខ្ញុំធ្វើកិច្ចបម្រើកូនរបស់អ្នកស្រីក៏ពោលថា នាងចូរមកណេះសិន បន្ទន់នូវកិច្ចបម្រើនោះសិន ។ នាងឯង

ចូរចាត់ចែងលាងជើង និងលាបប្រេងឲ្យកូនប្រុសរបស់យើងសិន សឹមធ្វើកិច្ចការបម្រើកូនស្រីយើងជាខាងក្រោយ ។ពេលនោះ នាងបានធ្វើកិច្ចការតាមពាក្យបញ្ជារបស់កិរិយាលោកសេដ្ឋីស្រេចហើយក៏បានទៅទិញផ្កាមក ។គ្រានោះ កូនស្រីរបស់លោកសេដ្ឋីបានគំរាមថា ហេតុដូចម្តេចបានជានាងទៅយូរម្ល៉េះ ? ខណៈនោះ នាងទាសីនោះបានជម្រាបរឿងទាំងអស់នោះថា នាងម្ចាស់កុំខឹងនឹងខ្ញុំម្ចាស់អី ។បុត្រសេដ្ឋីឈ្មោះឃោសកៈបានមក នាងខ្ញុំធ្វើនូវកម្មនោះៗ ដល់បុត្រសេដ្ឋីនោះហើយទើបទៅផ្សារ គ្រាន់តែឮឈ្មោះថាឃោសកៈដែលជាបុត្ររបស់សេដ្ឋីនោះភ្លាម សេចក្តីស្រឡាញ់ក៏កាត់សម្បុរស្បែកមុតចូលទៅជ្រៅរហូតដល់ក្នុងឆ្អឹង ។ពិតណាស់ កូនស្រីក្រមុំរបស់លោកសេដ្ឋីនោះ ធ្លាប់បានជាភរិយារបស់នាយឃោសកៈនោះ ក្នុងកាលដែលនាយឃោសកៈមានឈ្មោះថា **នាយកោតុហលិកៈ** បានថ្វាយបាយាសមួយនាឡិដល់ព្រះបច្ចេកពុទ្ធ ដោយអានុភាពនៃការថ្វាយបាយាសមួយ នាឡិនោះបានធ្វើឲ្យនាងមកកើតក្នុងត្រកូលសេដ្ឋីនេះ ។ សេចក្តីស្រឡាញ់ក្នុង

កាលមុន បានគ្របសង្កត់ចិត្តកូនស្រីរបស់សេដ្ឋីនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះពុទ្ធអង្គត្រាស់ថា

សេចក្ដីស្រឡាញ់នោះ កើតឡើងដោយហេតុ ២ ប្រការ គឺ ដោយការនៅរួមជាមួយគ្នាក្នុងកាលមុន ១ ដោយការប្រព្រឹត្តនូវអំពើដែលជាប្រយោជន៍ ដល់គ្នានឹងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចផ្កាឧប្បលអាស្រ័យភក់ និងទឹក កើតក្នុងទឹកដូច្នោះ ។

គ្រានោះ សេដ្ឋីធីតាសួរនាងទាសីថា ឥឡូវនេះ គេនៅឯណា ? នាងទាសីបានប្រាប់ថា បពិត្រនាងម្ចាស់ គេនៅក្នុងបន្ទប់ ។ សេដ្ឋីធីតាបានសួរទៀតថា តើគេមានរបស់អ្វីក្នុងដៃដែរឬ ? នាងទាសី ឆ្លើយថា បពិត្រនាងម្ចាស់ មានសំបុត្រមួយច្បាប់ដែលចងជាប់នឹងជាយសំពត់របស់គេ ។ ពេលនោះ ឃោសកៈកំពុងតែដេកលក់ កាលមាតាបិតាមើលមិនឃើញ ឬព្រោះតែរវល់បញ្ជូនចិត្តទៅកាន់ទីដទៃ នាងក៏បានលបចូលទៅកាន់បន្ទប់ដំណេករបស់ឃោសកៈ ហើយស្រាយសំបុត្រនោះយកចូលទៅកាន់បន្ទប់របស់ខ្លួន បិទទ្វារ បើកបង្អួចហើយអាន

សំបុត្រនោះព្រោះនាងជាស្ត្រីឈ្លាសវៃក្នុងអក្សរសាស្ត្រ កាលបើអាន ទៅដឹងរឿងទាំងនោះ ទើបគិតថា ស្លាប់ហើយ មនុស្សល្ងង់ខ្លៅចង នូវសំបុត្រ ដែលជាគ្រឿងញុំាងខ្លួនឲ្យស្លាប់ទុកនឹងជាយសំពត់របស់ខ្លួន ហើយនាំយកទៅ ប្រសិនបើយើងមិនបានមើលសំបុត្រនេះទេ ជីវិត របស់គេនឹងត្រូវអស់មិនខាន ។ ហើយនាងបានហែកសំបុត្រនោះចោល សរសេរសំបុត្រមួយច្បាប់ផ្សេងទៀត តាមពាក្យរបស់សេដ្ឋីថា កូនប្រុស របស់ខ្ញុំនេះឈ្មោះថា ឃោសកៈ អ្នកទាំងឡាយ ចូរញុំាងបុគ្គលឲ្យនាំ នូវបណ្ណាការពីស្រុកសួយមួយរយ ធ្វើនូវមង្គលជាមួយកូនស្រីរបស់ លោកសេដ្ឋីនៅក្នុងជនបទនេះ ឲ្យសង់ផ្ទះពីរជាន់នៅត្រង់កណ្ដាលស្រុក សម្រាប់ជាលំនៅរបស់ពួកគេ ធ្វើការរក្សាឲ្យបានល្អ គឺការបិទបាំងកំពែង និងដោយគ្រឿងបិទបាំង គឺបុរសហើយ ចូរបញ្ជូនដំណឹងទៅប្រាប់ខ្ញុំថា កាលនេះផង កាលនោះផងខ្ញុំធ្វើស្រេចហើយ ។ កាលកម្មយ៉ាងនេះ លោកធ្វើហើយ ខ្ញុំនឹងដឹងនូវអំពើដែលគួរធ្វើតបស្នងសងគុណក្នុងកាល ជាខាងក្រោយវិញ លុះសរសេររួចហើយ បានយកទៅបត់ចងទុកនឹង

ជាយសំពត់របស់ឃោសកៈដូចដើមវិញ ។ នាយឃោសកៈបានដេកលក់ រហូតអស់មួយយប់ ក្រោកឡើងបរិភោគហើយចៀសចេញទៅ ។ លុះដល់ ថ្ងៃស្អែកឡើងគេបានទៅដល់ស្រុកនោះតាំងពីព្រលឹម គេបានឃើញ នាយស្មៀនកំពុងធ្វើការងារ ហើយអង្គុយក្នុងស្រុក ។ នាយស្មៀននោះ បានឃើញនាយឃោសកៈនោះមកហើយ សួរថា នែបា អ្នកឯងមកមាន ការអ្វី ? នាយឃោសកៈ ឆ្លើយថា បិតារបស់ខ្ញុំប្រើឲ្យនាំយកសំបុត្រ នេះមកជូនលោក កាលនាយស្មៀន ទទួលយកសំបុត្រមកអានហើយ ក៏មានចិត្តត្រេកអរ បានពោលជាមួយគហបតីទាំងឡាយថា នែអ្នក ដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយ ចូរមើលនូវសេចក្តីស្រឡាញ់ដែល នាយ មានចំពោះពួកយើង ដោយលោកសេដ្ឋីបញ្ជូនសំបុត្រមកឲ្យយើង ដោយប្រាប់ថា ចូរធ្វើមង្គលដល់បុត្រច្បងរបស់យើង ពួកលោកចូរ ប្រញាប់នាំយកឈើជាដើមមក ដូច្នេះហើយ ឲ្យគេសាងផ្ទះមានប្រការ ដូចពោលហើយ នៅក្នុងកណ្តាលស្រុក ឲ្យនាំយកគ្រឿងបណ្ណាការ មកអំពីស្រុកសួយមួយរយ នាំយកកូនស្រីលោកសេដ្ឋីនៅក្នុងជនបទ

មកធ្វើមង្គលស្រេចហើយ ក៏បញ្ជូនដំណឹងទៅប្រាប់លោកសេដ្ឋីថា កាលនេះ និងកាលនោះខ្ញុំបានធ្វើស្រេចហើយ ។ គ្រានោះ លោកសេដ្ឋី បានឮដំណឹងនោះភ្លាម ក៏ខូចចិត្តយ៉ាងខ្លាំង ហើយគិតថា យើងឲ្យធ្វើនូវ កិច្ចណា កិច្ចនោះមិនសម្រេចទាល់តែសោះ កិច្ចណា ដែលមិនឲ្យធ្វើ ក៏ត្រឡប់ជាធ្វើបានសម្រេចទៅវិញ ។ សេចក្តីសោកសៅបូកនឹង សេចក្តីសោកសៅដល់បុត្រដែលស្លាប់ទៅ ដូចគ្នានឹងញុំាងកម្តៅក្នុងពោះ ឲ្យកើតឡើង ក៏ក្អួតឈាមចេញមក ។ សូម្បីភរិយារបស់នាយឃោសកៈ ក៏ផ្តាំពួកមនុស្សថា ប្រសិនបើមាននរណាមកអំពីសម្នាក់របស់សេដ្ឋី ដែលជាឪពុកក្មេករបស់យើង បើមិនទាន់ប្រាប់យើងទេ កុំប្រាប់ដល់ ស្វាមីរបស់យើងមុនឲ្យសោះ សូម្បីលោកសេដ្ឋីក៏គិតថា ឥឡូវនេះ យើងនឹងមិនធ្វើកូនថោកទាបនេះ ឲ្យជាម្ចាស់នៃទ្រព្យរបស់យើងទេ គិតឃើញដូច្នេះហើយ ទើបប្រាប់នាយស្មៀនម្នាក់ថា នែនាយស្មៀន ខ្ញុំប្រាថ្នាចង់ជួបបុត្ររបស់ខ្ញុំ លោកចូរបញ្ជូនអ្នកបម្រើម្នាក់ ឲ្យទៅហៅ បុត្ររបស់ខ្ញុំមក នាយស្មៀននោះទទួលថា បាទ ឲ្យសំបុត្រហើយ បញ្ជូន

អ្នកបម្រើម្នាក់ទៅ ចំណែកកិរិយារបស់នាយឃោសកៈ បានឃើញបុរសនេះមកឈរនៅទៀបទ្វារជួច្ចេះហើយ ក៏ហៅបុរសនោះ មកសួរថា នែអ្នកដ៏ចម្រើន អ្នកមកមានការអ្វី ? អ្នកបម្រើឆ្លើយថា បពិត្រនាងម្ចាស់ លោកសេដ្ឋីដែលជាឪពុករបស់នាយឃោសកៈឈឺ បានប្រើខ្ញុំឲ្យមកហៅបុត្ររបស់គាត់ ។ សេដ្ឋីធីតាសួរថា នែអ្នកដ៏ចម្រើន តើលោកសេដ្ឋីនៅមានកម្លាំង ឬខ្សោយកម្លាំង ? អ្នកបម្រើឆ្លើយប្រាប់ថា បពិត្រនាងម្ចាស់នៅមានកម្លាំង ថែមទាំងនៅបរិភោគអាហារបានទៀតផង អ្នកនាងម្ចាស់ ។

គ្រានោះ សេដ្ឋីធីតាដែលជាកិរិយារបស់ឃោសកៈនោះ មិនបានឲ្យឃោសកៈដឹងក្នុងរឿងនោះទេ ហើយបានប្រាប់ឲ្យទៅសម្រាក ថែមទាំងបានរៀបចំស្បៀងឲ្យដល់អ្នកបម្រើនោះហើយ ពោលថា លោកនឹងទៅបាន ក្នុងកាលដែលខ្ញុំអនុញ្ញាតឲ្យទៅ លោកចូរស្នាក់នៅទីនេះសិនហើយ ។មហាសេដ្ឋីបានពោលជាមួយនឹងនាយស្មៀនទៀតថា នែនាយស្មៀន លោកមិនទាន់បានផ្ញើសំបុត្រទៅកាន់សម្នាក់បុត្ររបស់ខ្ញុំទេឬ ?

នាយស្មៀនឆ្លើយថា ខ្ញុំបានបញ្ជូនទៅហើយ ប៉ុន្តែអ្នកដែលទៅនោះ មិនទាន់ត្រឡប់មកវិញសោះ ។ លោកសេដ្ឋី កាលបើឮដូច្នោះហើយ បានពោលថា បើដូច្នោះ លោកចូរបញ្ជូនអ្នកដទៃឲ្យទៅម្តងទៀត នាយស្មៀននោះក៏បញ្ជូនមនុស្សទៅទៀតមែន ។ កិរិយារបស់ឃោសកៈ បានបដិបត្តិចំពោះបុរសនោះ ដូចជាបុរសដែលមកមុននោះដែរ ក្នុងកាលនោះរោគរបស់លោកសេដ្ឋី ក៏បានឈឺធ្ងន់ឡើងៗ កាជនៈត្រងឈាមមួយចូល កាជនៈមួយចេញ លោកសេដ្ឋីក៏បានសួរនាយស្មៀនទៀតថា នែនាយស្មៀន លោកមិនទាន់បានបញ្ជូនឲ្យមនុស្ស ទៅហៅបុត្ររបស់យើងមកទេឬ ? នាយស្មៀនប្រាប់ថា បពិត្រនាយ ខ្ញុំបានបញ្ជូនទៅហើយ ប៉ុន្តែអ្នកដែលទៅនោះ មិនទាន់ត្រឡប់មកវិញសោះទៅបាត់ៗ តើមានហេតុអ្វីហ្ន៎ ។ លោកសេដ្ឋីប្រាប់ថា បើដូច្នោះ លោកចូរបញ្ជូនអ្នកដទៃឲ្យទៅម្តងទៀត នាយស្មៀននោះក៏បានបញ្ជូនអ្នកដទៃទៅទៀតមែន កិរិយារបស់ឃោសកៈ សួរព្រឹត្តិការណ៍នោះ នឹងបុរសដែលមកក្នុងវារៈទី ៣ ទៀត បុរសនោះប្រាប់ថា បពិត្រនាងម្ចាស់ លោកសេដ្ឋីឈឺធ្ងន់ណាស់

ហើយ ថែមទាំងបរិភោគអាហារមិនបានទៀតផង មានតែសេចក្តីស្លាប់នៅខាងមុខ ព្រោះភាជនៈត្រងឈាមពេញមួយចេញ ភាជនៈមួយចូល កាលបើឮដូច្នោះហើយ ភរិយារបស់ឃោសកៈគិតថា ឥឡូវនេះជាកាលដែលនាយឃោសកៈគួរទៅបានហើយ ទើបនាងប្រាប់សេចក្តីនោះដល់នាយឃោសកៈថា បពិត្រនាយ បានឮថាបិតារបស់លោកឈឺធ្ងន់ហើយ ។ កាលឃោសកៈសួរថា នៃនាងដ៏ចម្រើន នាងនិយាយថា ដូចម្តេច ? នាង ក៏បានឆ្លើយទៀតថា បពិត្រនាយ ការមិនសប្បាយកើតមានដល់បិតារបស់លោកហើយ ។ នាយឃោសកៈពោលថា ឥឡូវនេះ ខ្ញុំគួរធ្វើយ៉ាងណា ? សេដ្ឋីធីតាបានពោលថា បពិត្រនាយ យើងនឹងយកគ្រឿងបណ្ណាការដែលកើតអំពីស្រុក ១០០ ស្រុក ទៅសួរសុខទុក្ខគាត់ ដោយនាយឃោសកៈទទួលយល់ព្រមថា ប្រពៃហើយៗ ក៏បានបញ្ជូនឲ្យមនុស្សទៅនាំយករទេះ មកផ្ទុកគ្រឿងបណ្ណាការទាំងនោះពេញហើយ បានធ្វើដំណើរចេញទៅ ។

គ្រានោះ ភរិយារបស់នាយឃោសកៈ បាននិយាយជាមួយនឹង

ឃោសកៈនោះថា បិតារបស់លោកមានកម្លាំងខ្សោយហើយ កាល
យើងកាន់យកគ្រឿងបណ្ណាការប៉ុណ្ណេះទៅ នឹងជាការយឺតយូរ ដូច្នេះ
សូមលោកបញ្ជាឲ្យគេនាំយកគ្រឿងបណ្ណាការនេះ ត្រឡប់ទៅវិញចុះ
កាលពោលដូច្នេះហើយ ក៏បញ្ជូនគ្រឿងបណ្ណាការនោះទាំងអស់ត្រឡប់
ទៅផ្ទះរបស់ខ្លួនវិញ ហើយនិយាយទៀតថា បពិត្រនាយ លោកគប្បី
ឈរនៅខាងចុងជើងបិតារបស់លោក ខ្ញុំនឹងឈរនៅខាងសិរសា កាល
ចូលទៅដល់ផ្ទះនោះហើយ នាងក៏បង្គាប់មនុស្សរបស់ខ្លួនថា ពួកលោក
ចូរកាន់យកការរក្សាទាំងខាងមុខផ្ទះ ទាំងខាងក្រោយផ្ទះ ក៏កាលដើរ
ចូលទៅរបស់សេដ្ឋីបុត្រ ក៏បានទៅឈរនៅចុងជើងរបស់បិតា រីឯកិរិយា
ក៏បានទៅឈរនៅខាងលើសិរសា ។ ក្នុងខណៈនោះ សេដ្ឋីដែលដេកផ្ងារ
នៅលើគ្រែ ចំណែកនាយស្មៀន កាលបើច្របាច់ជើងរបស់លោសេដ្ឋី
នោះក៏និយាយថា បពិត្រនាយ បុត្ររបស់លោកមកហើយ លោកសេដ្ឋី
សួរថា កូនប្រុសរបស់ខ្ញុំគេនៅឯណា ? នាយស្មៀនឆ្លើយថា គេនៅខាង
ចុងជើងរបស់លោក ។ ពេលនោះ សេដ្ឋីនោះបានឃើញកូនប្រុសនោះ

ហើយ ក៏ឲ្យហៅនាយស្មៀនមក ហើយសួរថា ក្នុងផ្ទះរបស់ខ្ញុំមានទ្រព្យប៉ុន្មាន ? នាយស្មៀនបានប្រាប់ថា បពិត្រនាយ មាន ៤០កោដិប៉ុណ្ណោះ គ្រឿងឧបភោគ និងបរិភោគ ឬស្រែចម្ការ សត្វជើង ២ សត្វជើង ៤ យាន វាហនៈ មានចំនួន ច្រើនប៉ុណ្ណោះៗ លោកសេដ្ឋីគិតនឹងនិយាយថា ខ្ញុំមិនឲ្យទ្រព្យដែលមានប្រមាណប៉ុណ្ណោះ ដល់ឃោសកៈកូនប្រុសរបស់ខ្ញុំទេ ត្រឡប់ជានិយាយថា ខ្ញុំឲ្យ ។ កូនស្រីរបស់លោកសេដ្ឋីបានឮពាក្យនោះ ហើយក៏គិតថា សេដ្ឋីនេះកាលពោលពាក្យម្ដងទៀត គប្បីពោលនូវពាក្យអ្វីមួយដទៃ ដូច្នេះហើយ ធ្វើអាការដូចជារពឹលរពាលដោយសេចក្ដីសោករំសាយសក់ស្រែកយំពោលថា បពិត្របិតា តើបិតាពោលពាក្យដូចម្ដេច ? ពួកខ្ញុំជាអ្នកមិនមានបុណ្យពិតមែន នាងពោលដូច្នេះហើយក៏ធ្វើជាដួលចុះ យកក្បាលបោកត្រង់ដើមទ្រូងរបស់លោកសេដ្ឋីមិនឲ្យនិយាយទៀតបាន ហើយសម្ដែងអាការតូចចិត្ត ទួញយំ រហូតទាល់តែលោកសេដ្ឋីនិយាយលែងបាន លោកសេដ្ឋីក៏បានធ្វើកាលកិរិយាក្នុងខណៈនោះឯង ជនទាំងឡាយបានឮថា លោកសេដ្ឋីធ្វើអនិច្ចកម្មហើយ ទើបទៅ

ក្រាបទូលព្រះបាទឧទេន ។ហើយព្រះបាទឧទេន ទ្រង់បញ្ជាឲ្យធ្វើឈាបនកិច្ចសរីរៈរបស់លោកសេដ្ឋីនោះ ហើយត្រាស់សួរថា បុត្រាបុត្រីរបស់លោកសេដ្ឋីនេះមានដែរឬទេ ? ជនទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព មានបុត្រប្រុសឈ្មោះឃោសកៈ បពិត្រព្រះសម្មតិទេព លោកសេដ្ឋីបានប្រគល់ទ្រព្យទាំងអស់ឲ្យដល់ឃោសកៈហើយដែរ ទើបធ្វើអនិច្ចកម្មទៅ ព្រះរាជាទ្រង់បញ្ជាឲ្យហៅសេដ្ឋីបុត្រនោះមកគាល់ គាប់ជួនថ្ងៃនោះ ភ្លៀងក៏បានបង្អុរចុះមកក្នុងទីព្រះលានហ្លួងមានទឹកដក់ សេដ្ឋីបុត្រទៅហើយ ដោយបំណងថានឹងគាល់ព្រះរាជា ។ព្រះរាជាទ្រង់បើកបង្អួចទតមើលនាយឃោសកៈដែលកំពុងតែដើរមក ទ្រង់បានទតឃើញនាយឃោសកៈលោតផ្លោះរំលងថ្លុកទឹក ដែលនៅតាមព្រះលានហ្លួងដើរចូរមក ទើបត្រាស់សួរនាយឃោសកៈដែលមកថ្វាយបង្គំ រួចឈរនៅក្នុងទីដ៏សមគួរ ហើយព្រះរាជាត្រាស់សួរថា នែអ្នកដ៏ចម្រើន អ្នកឯងឈ្មោះឃោសកៈឬ ? ឃោសកៈក៏ទូលថា ព្រះករុណាថ្លៃវិសេស ។ទ្រង់បានពោលលួងលោមថា អ្នកឯងកុំខូចចិត្ត បិតារបស់អ្នកធ្វើអនិច្ចកម្មហើយ យើង

នឹងប្រគល់ តំណែងជាសេដ្ឋី ដែលជារបស់បិតាឲ្យដល់អ្នកពោលដូច្នេះ ហើយ ទ្រង់បញ្ជូននាយឃោសកៈទៅថា នែអ្នកដ៏ចម្រើន អ្នកឯង ចូរទៅចុះ ហើយព្រះរាជាក៏បានឈរទតមើលនាយឃោសកៈ ដែលកំពុងតែដើរចេញទៅនោះ ។ នាយឃោសកៈ មិនបានលោតក្នុងទីដែលខ្លួនលោត ក្នុងពេលដែលខ្លួនដើរចូលមកគាល់ព្រះរាជានោះទេ ដោយបានដើរចុះ ទៅសន្សឹមៗ ក្នុងទឹក ។

គ្រានោះ ព្រះរាជាត្រាស់បញ្ជាឲ្យហៅនាយឃោសកៈនោះមកវិញ ហើយទ្រង់ត្រាស់សួរថា ព្រោះហេតុដូចម្តេច កាលអ្នកមកកាន់សម្នាក់របស់យើង អ្នកបានលោតផ្លោះកន្លងថ្លុកដែលមានទឹកដើរចូលមក កាលអ្នកចេញទៅវិញ អ្នកបានចុះដើរទៅសន្សឹមៗ ក្នុងទឹកនោះ ? ពេលនោះ នាយឃោសកៈទូលថា ព្រះករុណាថ្លៃវិសេស កាលនោះខ្ញុំព្រះអង្គនៅជាកុមារ ហើយជាអ្នកពេញចិត្តក្នុងការលេង ប៉ុន្តែឥឡូវនេះខ្ញុំព្រះអង្គបានទទួលដំណឹងអំពីព្រះអង្គហើយ ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គមិនត្រាច់ទៅដូចក្នុងពេលមុនទៀត ហើយដើរចុះទៅសន្សឹមៗ

ទើបគួរ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះ ហើយទ្រង់ត្រិះរិះថា បុរសនេះជាអ្នកមានបញ្ញា យើងនឹងប្រគល់តំណែងជាសេដ្ឋីដល់គេក្នុងកាលឥឡូវនេះចុះ គិតឃើញដូច្នេះហើយ ក៏ប្រគល់ភោគៈ ដែលបិតាមានហើយ បានប្រគល់តំណែងជាសេដ្ឋី ព្រមដោយវត្ថុទាំងពួងជាច្រើនមុខទៀត ។សរុបសេចក្តីថា នាយឃោសកៈនោះបានក្លាយមកជាឃោសកសេដ្ឋីនៃក្រុងកោសម្ពីហើយ ឡើងទៅឈរនៅលើរថ រួចបានធ្វើការប្រទក្សិណព្រះនគរ ដោយសភាពរីករាយក្រៃពេក ។ ក្នុងពេលនោះ កូនស្រីរបស់លោកសេដ្ឋី ក៏អង្គុយប្រឹក្សាជាមួយនឹងនាងទាសីថា នៃកាឡីដ៏ចម្រើន សម្បត្តិមានប្រមាណប៉ុណ្ណេះ ដែលសម្រេចដល់សេដ្ឋីបុត្ររបស់នាង ក៏បានមកដោយអាស្រ័យយើងផងដែរ ។ នាងកាឡីបានសួរថា បពិត្រនាងម្ចាស់ ព្រោះហេតុអ្វី ?សេដ្ឋីធីតាតបថា ព្រោះឃោសកៈសេដ្ឋីនេះ បានចងសំបុត្រ ដែលជាសំបុត្រសម្លាប់ខ្លួនឯង ចងជាប់នឹងជាយសំពត់ ហើយមកកាន់ផ្ទះរបស់យើង ។ គ្រានោះ ខ្ញុំបានហែកសំបុត្ររបស់គេនោះមើលក៏ដឹង ហើយហែកចោល រួចក៏បានសរសេរសំបុត្រ

មួយច្បាប់ថ្មីជំនួស ដើម្បីឲ្យរៀបមង្គលការគាត់ជាមួយនឹងខ្ញុំ ដោយហេតុយ៉ាងនេះឯង ។ នាងកាឡីពោលថា បពិត្រនាងម្ចាស់ នាងម្ចាស់ដឹងហេតុត្រឹមតែប៉ុណ្ណេះឬ ? ប៉ុន្តែលោកសេដ្ឋីព្យាយាមនឹងសម្លាប់ឃោសកៈនេះតាំងអំពីកាលគាត់នៅពីក្មេងមកម៉្លេះ តែមិនអាចសម្លាប់បាន ហើយលោកសេដ្ឋី គាត់ត្រូវចំណាយទ្រព្យទៅអស់យ៉ាងច្រើនសន្ធឹកសន្ធាប់ ព្រោះតែចង់សម្លាប់ឃោសកៈសេដ្ឋីនេះ ។ គ្រានោះ សេដ្ឋីធីតាបានឃើញនាយឃោសកៈ ដែលធ្វើការប្រទក្សិណព្រះនគររួចហើយ ចូលទៅកាន់ផ្ទះពេលដែលទៅដល់ក្នុងផ្ទះ នាងក៏បានសើចដោយគិតថា សម្បត្តិមានប្រមាណប៉ុណ្ណេះៗ សម្រេចហើយ ក៏ព្រោះអាស្រ័យយើងផងដែរ ។ ពេលនោះសេដ្ឋីបុត្រ បានឃើញអាការដូច្នេះហើយ ក៏សួរថា នាងសើចអ្វី ? សេដ្ឋីធីតាឆ្លើយថា ព្រោះអាស្រ័យហេតុម្យ៉ាង ។ សេដ្ឋីបុត្រសួរទៀតថា ចូរប្រាប់ហេតុនោះមក ? សេដ្ឋីធីតាមិនប្រាប់ ។ លំដាប់នោះ សេដ្ឋីបុត្រគំរាមថា ប្រសិនបើនាងមិនប្រាប់ខ្ញុំទេ ខ្ញុំនឹងកាត់នាងជាពីរកំណាត់ពោលដូច្នេះហើយ ក៏ទាញដាវចេញមក ។ សេដ្ឋីធីតាទើបប្រាប់នូវសេចក្តី

តាមការពិតថា ខ្ញុំសើចក៏ព្រោះគិតឃើញថា សម្បត្តិមានប្រមាណ ប៉ុណ្ណេះនេះ លោកបានហើយព្រោះអាស្រ័យខ្ញុំ ។ សេដ្ឋីបុត្រឆ្លើយថា ប្រសិនបើបិតារបស់ខ្ញុំ មិនប្រគល់មតកំរបស់លោកឲ្យដល់ខ្ញុំទេ ខ្ញុំ ក៏មិនបានដែរ ។ បានឮមកថា ឃោសកសេដ្ឋីនោះ មិនបានដឹងរឿងអ្វី ទាំងអស់ ចំពោះហេតុការណ៍ដែលកើតមកហើយ ។ ព្រោះហេតុនោះ ទើបមិនជឿតាមពាក្យរបស់សេដ្ឋីធីតានោះ។គ្រានោះសេដ្ឋីធីតា ក៏បាន តំណាលរឿងទាំងអស់នោះ ប្រាប់ដល់សេដ្ឋីបុត្រនោះថា បិតារបស់ លោកបានចងសំបុត្រជាប់នឹងជាយសំពត់របស់លោកនោះ ដើម្បីឲ្យគេ សម្លាប់លោកទេតើ ខ្ញុំបានឃើញដូច្នេះហើយ ក៏សរសេរសំបុត្រសា ជាថ្មីវិញ គឺក្នុងរឿងការរៀបមង្គលការនោះឯង ទោះបីនាងនិយាយ ដូច្នេះហើយក៏ដោយ សេដ្ឋីបុត្រនោះ ក៏នៅតែមិនជឿ ហើយនិយាយថា នាងនិយាយមិនពិត ទើបគិតថា យើងនឹងសួរនាងកាឡី ហើយបានសួរ នាងកាឡីថា នែនាងកាឡីយ៉ាងនោះ ពិតមែនឬ ? នាងកាឡីពោលថា ពិតមែន ។ ជាពិសេសគឺចាប់តាំងពីកាលលោកនៅក្មេងៗ មកម៉្លេះ

ដោយលោកសេដ្ឋីប្រាថ្នានឹងសម្លាប់លោកតែមិនអាចសម្លាប់បានគឺលោកបានរួចផុតអំពីសេចក្ដីស្លាប់ ៧ ដងមកហើយ ឥឡូវនេះ លោកវិលត្រឡប់មកអំពីស្រុកសួយ ហើយបានទទួលតំណែងជាសេដ្ឋី ព្រមដោយវត្ថុនៅក្នុងមួយមុខៗ ១០០ ។ឃោសកសេដ្ឋីបានស្ដាប់ពាក្យនោះហើយគិតថា យើងធ្វើកម្មធ្ងន់ណាស់ហ្ន៎ យើងរួចហើយអំពីសេចក្ដីស្លាប់បែបនេះ ជាអ្នកនៅដោយសេចក្ដីប្រមាទនោះមិនសមគួរទេ ដូច្នេះយើងនឹងជាអ្នកមិនប្រមាទ ហើយបានលះបង់ទ្រព្យសម្បត្តិក្នុងមួយថ្ងៃ ១០០០ កហាបណៈ ដើម្បីចែកទានដល់អ្នកដំណើរផ្លូវឆ្ងាយ និងមនុស្សកំព្រាជាដើម ។

គ្រានោះ កុដុម្ពិកឈ្មោះមិត្តៈ ជាអ្នកខ្វល់ខ្វាយក្នុងការឲ្យទានរបស់ឃោសកសេដ្ឋីនោះ ។ ក្នុងកាលនោះ សេដ្ឋីឈ្មោះកទូវតិយៈនៅក្នុងនគរឈ្មោះកទូវតិយៈ បានជាសម្លាញ់ មិនដែលស្គាល់គ្នាជាមួយនឹងឃោសកសេដ្ឋី ។ឃោសកសេដ្ឋីបានឮនូវដំណឹង នូវទ្រព្យសម្បត្តិផងនូវវ័យផង និងប្រទេសរបស់កទូវតិយសេដ្ឋីអំពីពួកឈ្មួញទាំងឡាយ

ដែលមកអំពីកទ្ទវតិយនគរ ឃោសកសេដ្ឋីព្រោះតែប្រាថ្នាភាពជាសម្លាញ់ជាមួយនឹងសេដ្ឋីនោះៗ ទើបបញ្ជូនគ្រឿងបណ្ណាការទៅឲ្យ ។ សូម្បីកទ្ទវតិយសេដ្ឋី ក៏បានស្តាប់ឮអំពីទ្រព្យសម្បត្តិ និងវ័យ ព្រមទាំងប្រទេសរបស់ឃោសកសេដ្ឋីអំពីពួកឈ្មួញ ដែលមកអំពីក្រុងកោសម្ពី ដោយប្រាថ្នាភាពជាសម្លាញ់នឹងសេដ្ឋីនោះ ទើបបញ្ជូនគ្រឿងបណ្ណាការទៅឲ្យសេដ្ឋីទាំងពីរនោះ បានជាសម្លាញ់នឹងគ្នាហើយយ៉ាងនេះឯង ។

ក្នុងកាលជាខាងក្រោយមក នៅក្នុងកទ្ទវតិយនគរ បានកើតអហិវាតករោគឡើង ហើយរុយក្បាលខៀវបានស្លាប់មុន តអំពីនោះ តុកកែ កណ្តុរ មាន់ ជ្រូក ឆ្កែ ឆ្មា គោ ទាសាទាសី រមែងស្លាប់ទៅដោយលំដាប់ ។ ពួកមនុស្សដែលជាម្ចាស់ផ្ទះស្លាប់ក្រោយសត្វទាំងនោះ ក្នុងបណ្តាជនទាំងនោះ ពួកជនណាទម្លាយនូវជញ្ជាំងរត់គេចចេញទៅ ពួកជនទាំងនោះមានជីវិតរស់នៅតទៀត សូម្បីក្នុងកាលនោះ សេដ្ឋីដែលជាសម្លាញ់របស់ឃោសកសេដ្ឋី ព្រមទាំងភរិយា និងកូនស្រី ក៏បានរត់គេចទៅដោយវិធីយ៉ាងនោះដែរ ដោយប្រាថ្នាចង់ឃើញឃោសកសេដ្ឋី ទើបធ្វើ

ដំណើរទៅកាន់ក្រុងកោសម្ពី ។ អ្នកទាំង ៣ នាក់នោះ មានស្បៀងអស់ហើយក្នុងរវាងផ្លូវ ក៏បានទទួលនូវការលំបាក ដែលកើតមកអំពីខ្យល់និងកម្តៅថ្ងៃ ជាពិសេសដោយការស្រេកឃ្លានយ៉ាងខ្លាំង បានធ្វើដំណើរទៅជាលំដាប់ ក៏បានទៅដល់ក្រុងកោសម្ពីយ៉ាងលំបាកជាទីបំផុត រួចក៏បានទៅងូតទឹកកន្លែងមួយ រួចហើយក៏បានចូលទៅកាន់សាលាមួយទៀបទ្វារក្រុង ។ ក្នុងកាលនោះលោកសេដ្ឋីពោលជាមួយនឹងភរិយាថា នែនាងដ៏ចម្រើន យើងមកដោយទំនងយ៉ាងនេះ រមែងមិនជាទីគាប់ចិត្តសូម្បីដល់មាតាបង្កើត ។ បានឮថា សេដ្ឋីដែលជាសម្លាញ់របស់យើងបានលះបង់ទ្រព្យមួយថ្ងៃ ១០០០ កហាបណៈ ឲ្យដល់អ្នកធ្វើដំណើរមានមនុស្សកំព្រាជាដើម យើងបញ្ជូនកូនស្រីរបស់យើងទៅកាន់ទីនោះឲ្យនាំយកអាហារមកបរិភោគទីនេះ ២-៣ ថ្ងៃសិន សឹមចូលទៅជួបជាមួយនឹងសម្លាញ់របស់យើង ភរិយាកទុវតិយសេដ្ឋីទទួលតបពាក្យរបស់ស្វាមីថា ប្រពៃហើយបង ។ ក៏បាននាំគ្នាសម្រាកនៅក្នុងសាលានោះឯង ។ លុះដល់ថ្ងៃស្អែកឡើង កាលអ្នកបម្រើមកប្រាប់ដល់ពេល

វេលា ដើម្បីឲ្យមនុស្សក្រមុំ្បត់ និងអ្នកធ្វើដំណើរជាដើមឲ្យទៅយកអាហារ កាលមនុស្សក្រមុំ្បត់និងអ្នកធ្វើដំណើរជាដើមកំពុងធ្វើដំណើរទៅ ដើម្បីទទួលយកអាហារពីលោកសេដ្ឋី និងភរិយានោះ ហើយខ្លួនឯង ក៏បានបញ្ជូនកូនស្រីទៅដោយពាក្យថា នែកូនស្រី កូនឯងចូរទៅទទួលយកអាហារពីលោកសេដ្ឋី និងភរិយានោះមកដើម្បីឲ្យឪពុកម្ដាយបរិភោគផង ។ ធីតានៃត្រកូលដែលជាអ្នកមានភោគៈច្រើន ជាអ្នកមានសេចក្ដីអៀនខ្មាសច្រើន ព្រោះភាវៈនៃខ្លួន ជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ប៉ុន្តែត្រូវមានវិបត្តិដូច្នោះហើយ ក៏កាត់សេចក្ដីអៀនខ្មាសទាំងនោះចេញ ហើយក៏កាន់យកភាជន៍ទៅ ដើម្បីត្រូវការអាហារទៅជាមួយពួកមនុស្សជាច្រើននោះ ។ពេលដែលនាងទៅដល់ហើយ មានអ្នកចាត់ចែងសួរថា នាងត្រូវការប៉ុន្មានចំណែក ? នាងក៏ប្រាប់ថា ៣ ចំណែក ។ គ្រានោះកុដុម្ពិកឈ្មោះមិត្តៈក៏បានឲ្យអាហារ ៣ ចំណែកដល់នាងមែន ។ កាលនាងនាំអាហារមកកន្លែងមាតាបិតាហើយ ទាំង ៣ នាក់ ក៏បានអង្គុយបរិភោគរួមគ្នាទៅ ។ ពេលនោះ មាតា និងកូនស្រី បានពោលទៅកាន់

ស្វាមីថា **វិបត្តិ** ( ការវេទនាទុក្ខលំបាក ) រមែងកើតឡើងដល់ត្រកូលធំៗ ទាំងឡាយ សូមលោកកុំគិតអ្វីឡើយ ចូរបរិភោគអាហារទៅ ។ បាន ពោលអង្វរដោយប្រការផ្សេងៗ ហើយសេដ្ឋីនោះ ក៏បានព្រមបរិភោគ អាហារនោះទៅ ។ កទុវតិយសេដ្ឋីបរិភោគអាហារហើយ មិនអាចធ្វើ ឲ្យអាហាររលួយទៅបាន ។ នាកាលអរុណរះឡើង ក៏បានធ្វើកាលកិរិយា ទៅ ។ ភរិយា និងកូនស្រី បានយំខ្សឹកខ្សួលរៀបរាប់ដោយប្រការផ្សេងៗ ។ លុះដល់ថ្ងៃស្អែកឡើង កូនស្រីនោះ បានដើរទៅយកអាហារបណ្តើរ យំបណ្តើរ នាយមិត្តកុដុម្ពិក បានឃើញដូច្នោះហើយ ក៏បានសួរនាងថា នែនាងដ៏ចម្រើន តើនាងត្រូវការអាហារប៉ុន្មានចំណែក នាងក៏បានឆ្លើយ ប្រាប់ថា ខ្ញុំត្រូវការតែអាហារពីរចំណែក មិត្តកុដុម្ពិកនោះ ក៏បានឲ្យ អាហារពីរចំណែកដល់នាងមែន ។ នាងក៏បានយកអាហារនោះដើរត្រឡប់ មកវិញបណ្តើរ យំបណ្តើរ យកមកឲ្យមាតាហើយ ក៏អង្គុយបរិភោគ រួមជាមួយមាតាទៅ ។ មាតាកាលដែលធីតារបស់ខ្លួនអង្វរឲ្យបរិភោគ ក៏បរិភោគទៅ ប៉ុន្តែអាហារដែលបរិភោគចូលទៅហើយនោះ មិនអាច

រលួយបាន ក៏បានធ្វើកាលកិរិយាទៅក្នុងថ្ងៃនោះឯង ។ នាងសាមាអស់ទីពឹង ក៏ដល់នូវសភាពលំបាកជាទីបំផុត គឺយំខ្សឹកខ្សួល អាឡោះអាល័យ ចំពោះមាតាបិតាដែលស្លាប់ ។ លុះដល់ថ្ងៃស្អែកឡើង នាងក៏បានដើរទៅ យកអាហារបណ្តើរ យំបណ្តើរទៀត ដោយទៅជាមួយនឹងពួកស្មូមយាចក មិត្តកុដុម្ពិកឃើញដូច្នោះហើយ សួរថា នាងត្រូវការអាហារប៉ុន្មានចំណែក? នាងប្រាប់ថា បពិត្រនាយ មួយចំណែកបានហើយ ? មិត្តកុដុម្ពិកចាំ នាងបានថា នាងនេះមកទទួលយកអាហារ ៣ ថ្ងៃមកហើយ ព្រោះ ហេតុនោះ ទើបពោលទៅកាន់នាងថា នែស្រីខូច នែស្រីចង្រៃ នាងឯង ចូរវិនាសទៅ ថ្ងៃនេះនាងឯងស្គាល់ប្រមាណផ្ទៃរបស់ខ្លួនឯងហើយឬ ? កុលធីតាដែលជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ហើយជាអ្នកបរិបូណ៌ដោយ ហិរិ និងឱត្តប្បៈ កាលបើឮដូច្នោះ ហាក់បីដូចត្រូវប្រហារដោយលំពែង នៅត្រង់ដើមទ្រូង ឬដូចជាត្រូវគេស្រោចដោយទឹកឈឺផ្សានៅត្រង់ដំបៅ នាងបានសួរថា បពិត្រនាយ ខ្ញុំមានកំហុសអ្វី ? មិត្តកុដុម្ពិកបានពោលថា ថ្ងៃមុននាងបានទទួលអាហារយកទៅ ៣ ចំណែកពីម្សិលមិញនេះ នាង

ទទួលយកទៅ ២ ចំណែក ថ្ងៃនេះ នាងទទួលយកតែ ១ ចំណែក ហើយនាងឯងស្គាល់ប្រមាណផ្ទៃរបស់ខ្លួនឯងហើយឬ ? នាងកុលធីតា បានពោលថា បពិត្រនាយ លោកកុំយល់ថា ខ្ញុំទទួលយកទៅដើម្បីតែខ្លួនឯងម្នាក់ឲ្យសោះឡើយ ។មិត្តកុដុម្ពិកសួរទៀតថា បើដូច្នោះ តើនាងឯងទទួលយកទៅ ៣ ចំណែកមានហេតុអ្វី ? នាងកុលធីតាឆ្លើយថា បពិត្រនាយ ក្នុងថ្ងៃមុនពួកខ្ញុំមានមនុស្ស ៣ នាក់ ពីម្សិលមិញនេះពួកខ្ញុំមាន មនុស្ស ២ នាក់ រីឯថ្ងៃនេះមានតែម្នាក់ឯងតែប៉ុណ្ណោះ ។

គ្រានោះ មិត្តកុដុម្ពិកក៏បានសួរទៀតថា មានហេតុអ្វី ? ក្រោយពីបានស្តាប់រឿងទាំងអស់ ដែលនាងតំណាលប្រាប់ហើយតាំងអំពីដើមមកក៏មិនអាចនឹងទប់ទឹកភ្នែកបាន ដោយទឹកភ្នែកក៏បានហូរចេញមកថែមទាំងបានពោលថា នែនាងដ៏ចម្រើន នាងកុំបារម្ភអី ចាប់ពីថ្ងៃនេះតទៅ នាងចូរជាធីតារបស់យើងចុះ ពោលដូច្នេះហើយ ក៏ចាប់ឱបថើបនាង រួចនាំយកទៅកាន់ផ្ទះរបស់ខ្លួន ដោយតាំងនាងទុកជាធីតាច្បងនៅក្នុងផ្ទះរបស់ខ្លួនទៅ ។ ពេលនោះ នាងសាមានោះបានឮសំឡេង

ទ្រហឹងអឺងកងនៅក្នុងរោងទានហើយ ទើបសួរថា បពិត្របិតា ព្រោះហេតុអ្វី ទើបបិតាមិនធ្វើជនទាំងនោះ ឲ្យជាអ្នកមានសំឡេងស្ងប់ស្ងាត់សិន ហើយសឹមឲ្យទាន ? មិត្តកុដុម្ពិកពោលថា នែកូន បិតាមិនអាចធ្វើបានទេ ។ នាងសាមាបានពោលថា បពិត្របិតា ខ្ញុំអាចធ្វើបាន ។ មិត្តកុដុម្ពិកសួរថា នែកូនស្រី តើកូនអាចធ្វើបានដូចម្តេច ? នាងសាមាឆ្លើយថា បពិត្របិតា សូមបិតាធ្វើរបងព័ទ្ធរោងទាន ដាក់ទ្វារពីរល្មមប្រមាណមនុស្សម្នាក់ចូលទៅបានហើយ ចូរប្រាប់ថា ពួកអ្នកទាំងអស់គ្នាចូលតាមទ្វារនេះ ចេញទៅតាមទ្វារនេះ ជនទាំងនោះ ប្រាកដជាមានសំឡេងស្ងប់ស្ងាត់ ហើយទទួលយកអាហារទៅ ។ មិត្តកុដុម្ពិកបានស្តាប់ពាក្យនោះហើយ ពោលថា នែកូនស្រី ឧបាយនេះល្អមែន ហើយក៏បញ្ជាឲ្យគេធ្វើដូច្នោះទៅ សេដ្ឋីធីតានោះ ក្នុងកាលមុនមានឈ្មោះថា **សាមា** តែព្រោះនាងធ្វើរបងព័ទ្ធជុំវិញរោងទាន ទើបនាងមានឈ្មោះថា **សាមាវតី** ចាប់តាំងអំពីពេលនោះមក ភាពកោលាហលក្នុងរោងទានក៏បាត់ទៅ ឃោសកសេដ្ឋី បានឮសំឡេងនោះ ក្នុងកាលមុន ក៏មានសភាពសប្បាយ

រីករាយថា សំឡេងនេះនៅក្នុងរោងទានរបស់យើង ប៉ុន្តែកាលមិនបានឮសំឡេងនោះ ២-៣ថ្ងៃ ក៏បានសួរមិត្តកុដុម្ពិកថា ទានដែលឲ្យដល់មនុស្សកំព្រា និងអ្នកធ្វើដំណើរជាដើម លោកនៅតែឲ្យឬ ? មិត្តកុដុម្ពិកឆ្លើយថា បពិត្រនាយ ខ្ញុំនៅតែឲ្យដដែលទេតើ ។ ឃោសកសេដ្ឋីបានសួរថា កាលបើឮដូច្នោះហើយ ព្រោះហេតុអ្វី បើលោកនៅតែឲ្យ ហេតុអ្វីក៏ខ្ញុំមិនបានឮសំឡេងអស់ ២-៣ ថ្ងៃមកហើយ ។ មិត្តកុដុម្ពិកបានប្រាប់ថា ខ្ញុំបានធ្វើឧបាយដោយអាការដែលពួកអ្នកមកយកអាហារទៅ ឲ្យមានសភាពស្ងប់ស្ងៀម ។ រីឯឃោសកសេដ្ឋីបានពោលដោយសេចក្ដីសង្ស័យថា បើដូច្នោះ ហេតុអ្វីក៏លោកមិនធ្វើមកពីមុន ទើបពេលនេះបានជាលោកធ្វើ ? មិត្តកុដុម្ពិកឆ្លើយថា ព្រោះខ្ញុំមិនដឹងលោកនាយ ។ ឃោសកសេដ្ឋីសួរថា ឥឡូវនេះ លោកដឹងបាន ដោយសារអ្វី ? មិត្តកុដុម្ពិកឆ្លើយថា បពិត្រលោកនាយ ដោយកូនស្រីរបស់ខ្ញុំជាអ្នកប្រាប់ ។ ឃោសកសេដ្ឋីសួរថា ក៏កូនស្រីរបស់អ្នកដែលខ្ញុំមិនស្គាល់មានដែរឬ ? មិត្តកុដុម្ពិកនោះ បានតំណាលរឿងរបស់កុទ្ទវតិយសេដ្ឋីទាំងអស់ ចាប់តាំងពីការ

កើតឡើងនៃអហិវាតរោគហើយ ក៏បានប្រាប់ដល់ការដែលខ្លួនតាំងធីតា របស់សេដ្ឋីនោះ ទុកក្នុងតំណែងជាកូនស្រីច្បងរបស់ខ្លួន ។ ឃោសកសេដ្ឋីបានពោលជាមួយនឹងមិត្តកុដុម្ពិកនោះថា កាលបើមានរឿងដូច្នេះ ហេតុអ្វីលោកក៏មិនប្រាប់ដល់ខ្ញុំផង ធីតានៃសម្លាញ់របស់ខ្ញុំ ក៏ឈ្មោះថា ជាធីតារបស់ខ្ញុំដែរ កាលបើពោលដូច្នោះហើយ ក៏បានប្រើអ្នកបម្រើឲ្យទៅហៅនាងសាមាវតីមកសួរថា នែនាងដ៏ចម្រើន នាងជាធីតារបស់សេដ្ឋីឬ ? នាងសាមាវតីឆ្លើយថា ចាសមែន ។ ឃោសកសេដ្ឋីពោលថា បើដូច្នោះ នាងកុំគិតឡើយ នាងចូរជាធីតារបស់ខ្ញុំចុះ ពោលដូច្នេះហើយ ក៏បើបក្បាលនាងសាមាវតី ថែមទាំងបានប្រគល់ស្ត្រី ៥០០ នាក់ឲ្យដល់នាងសាមាវតី ដើម្បីប្រយោជន៍ការៈជាបរិវារ ហើយតែងតាំងនាងសាមាវតីទុកក្នុងតំណែងជាធីតាច្បងរបស់ខ្លួនដែរ ។ ខាងក្រោយមក នៅក្នុងថ្ងៃមួយ នៅក្នុងព្រះនគរនោះ មានគេប្រកាសបុណ្យនក្ខត្តឫក្ស ក៏ក្នុងបុណ្យនោះសូម្បីធីតានៃត្រកូលទាំងឡាយ ដែលមិនធ្លាប់ចេញទៅខាងក្រៅ ក៏នាំគ្នាចេញទៅខាងក្រៅ ដោយធ្វើដំណើរទៅកាន់ស្ទឹងងូតទឹក

ជាមួយនឹងបរិវាររបស់ខ្លួនៗ ។ ក្នុងថ្ងៃនោះ សូម្បីនាងសាមាវតីដែលមានស្ត្រី ៥០០ នាក់ហែហមហើយ បាននាំគ្នាធ្វើដំណើរឆ្លងកាត់ខាងមុខព្រះរាជវាំង ដើម្បីទៅងូតទឹក ។ចំណែកព្រះបាទឧទេន ទ្រង់ប្រថាប់ឈរនៅនាសីហបញ្ជរ ទ្រង់ទតឃើញនាងសាមាវតីនោះ ទើបត្រាស់សួរថា ស្ត្រីទាំងនោះជាស្រីស្នំរបស់អ្នកណា ? រាជបុរសក្រាបទូលថា បពិត្រមហារាជ ស្ត្រីទាំងនោះមិនមែនជាស្ត្រីស្នំរបស់អ្នកណាទេ ។ ព្រះបាទឧទេនសួរទៀតថា បើដូច្នោះ នាងជាធីតារបស់អ្នកណា ? រាជបុរសក្រាបទូលថា បពិត្រមហារាជ នាងជាកូនស្រីរបស់ឃោសកសេដ្ឋីឈ្មោះនាងសាមាវតី ។ ព្រះបាទឧទេនគ្រាន់តែទតឃើញភ្លាម ក៏ទ្រង់កើតសេចក្តីស្នេហាភ្លាមដែរ ទើបបញ្ជាឲ្យបញ្ជូនសារទៅឲ្យសេដ្ឋីថា សូមលោកសេដ្ឋីបញ្ជូនធីតារបស់លោកមកឲ្យយើង ។ ឃោសកសេដ្ឋីក្រាបបង្គំទូលបដិសេធវិញថា បពិត្រមហារាជ ទូលព្រះបង្គំមិនមានធីតាជាទៃទៀតឡើយ ។ ព្រះបាទឧទេនបានបញ្ជូនសារទៅទៀតថា សូមលោកសេដ្ឋីកុំបដិសេធយ៉ាងនេះឡើយ ចូរបញ្ជូនធីតាលោកមកកុំខាន ។ ឃោសកសេដ្ឋី

បានបញ្ជូនសារតបទៅព្រះរាជាវិញទៀតថា បពិត្រមហារាជ ពួកខ្ញុំព្រះអង្គជាគហបតី មិនថ្វាយកុមារីដល់ព្រះអង្គទេ ព្រោះខ្លាចពីការវាយធ្វើបាប ហើយបណ្តេញនូវកុមារីទាំងឡាយអំពីរាជវាំង ។ ព្រះរាជាកាលបើឮដូច្នោះទ្រង់ក៏ខ្ញាល់ឡើង ទើបទ្រង់បញ្ជាឲ្យទៅចាប់សេដ្ឋីនិងភរិយារបស់លោកសេដ្ឋីអូសចេញទៅខាងក្រៅផ្ទះ ។ នាងសាមាវតីងូតទឹកហើយត្រឡប់មក កាលមិនបានឱកាសចូលទៅក្នុងផ្ទះ ក៏សួរថា បពិត្របិតាតើមានរឿងអ្វី ? លោកសេដ្ឋីឆ្លើយថា នែកូនសម្លាញ់ ព្រះរាជាទ្រង់បញ្ជូនសារមក ព្រោះហេតុនៃកូន ។ កាលពួកយើងពោលថា មិនថ្វាយ ក៏ទ្រង់ឲ្យគេចាប់ពួកយើងចេញមកខាងក្រៅផ្ទះ នាងសាមាវតីក៏ពោលថា បពិត្របិតា បិតាធ្វើកម្មនេះធ្ងន់ណាស់ ធម្មតាព្រះរាជា កាលបញ្ជូនសារមកហើយ មិនគួរទូលថា មិនថ្វាយ គួរតែទូលថា ប្រសិនបើព្រះអង្គទទួលធីតារបស់ខ្ញុំ ព្រមទាំងបរិវាររបស់គេ ខ្ញុំព្រះអង្គក៏នឹងថ្វាយ លោកសេដ្ឋីពោលថា នែកូនសម្លាញ់ ល្អហើយ ប្រសិនបើកូនយល់ព្រមយ៉ាងនេះ បិតាក៏យល់ព្រមដែរ ។ ព្រះរាជាទ្រង់នាំនាងសាមាវតី

ព្រមទាំងបរិវារនោះមក ទ្រង់បានអភិសេកជាមួយនាង ហើយតាំងនាងទុកនៅក្នុងតំណែងជាអគ្គមហេសី ។ ស្ត្រីដ៏សេសក៏បានធ្វើជាបរិវាររបស់នាងសាមាវតី ។

ព្រះបាទឧទេន បានមានព្រះអគ្គមហេសីមួយព្រះអង្គទៀត ព្រះនាងមានព្រះនាមថា **វាសុលទត្តា** ជាព្រះរាជធីតារបស់ព្រះបាទចណ្ឌប្បជ្ជោត ។មានរឿងតំណាលពិស្តារថា នៅក្នុងក្រុងឧជ្ជេនី មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមថា **ចណ្ឌប្បជ្ជោត** ។ ថ្ងៃមួយ ព្រះអង្គស្តេចយាងមកអំពីព្រះរាជឧទ្យាន ទ្រង់ទតមើលនូវសម្បត្តិរបស់ព្រះអង្គហើយត្រាស់ថា សម្បត្តិដូច្នេះរបស់អ្នកណាមានដែរឬហ្ន៎ ? នាកាលអាមាត្យក្រាបទូលថា សម្បត្តិរបស់ព្រះបាទឧទេន ដែលនៅក្នុងក្រុងកោសម្ពីមានច្រើនក្រៃលែងជាងសម្បត្តិរបស់ព្រះអង្គ ឆ្ងាយណាស់ ។

គ្រានោះ ព្រះបាទចណ្ឌប្បជ្ជោតទ្រង់បានត្រាស់ថា បើដូច្នោះ យើងនឹងទៅចាប់ព្រះរាជាអង្គនោះ ។ អាមាត្យក្រាបទូលថា បពិត្រមហារាជ អ្នកណាមួយក៏ដោយ ក៏មិនអាចចាប់ព្រះរាជាអង្គនោះបាន

ដែរ ។ ព្រះរាជាត្រាស់ថា យើងនឹងរកឧបាយចាប់ឲ្យទាល់តែបាន ។ អាមាត្យក្រាបទូលថា បពិត្រមហារាជ មិនអាចទេ ។ ព្រះរាជាបានត្រាស់ថា ព្រោះហេតុអ្វី ? អាមាត្យក្រាបទូលថា ព្រោះស្ដេចនេះចេះសិល្បៈ ឈ្មោះហត្ថិកន្តៈ ទ្រង់រាយនូវមន្តហើយ ដេញពិណឈ្មោះហត្ថិកន្តៈ ហើយញ៉ាំងដំរីឲ្យរត់ទៅក៏បាន និងចាប់យកក៏បាន បុគ្គលអ្នកដល់ព្រមដោយដំរីជាពាហនៈដូចព្រះរាជាអង្គនោះមិនមាន ។ ព្រះរាជាត្រាស់ថា យើងមិនអាចនឹងចាប់ព្រះរាជាអង្គនោះបានឬ ? អាមាត្យក្រាបទូលថា បពិត្រមហារាជ ប្រសិនបើព្រះអង្គមានបំណងក្នុងព្រះទ័យដូច្នេះហើយ បើដូច្នោះ សូមព្រះអង្គទ្រង់បញ្ជាឲ្យជាងធ្វើដំរីឈើឡើងហើយបញ្ជូនទៅជិតសម្នាក់ព្រះរាជាអង្គនោះ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដល់វាហនដំរី ស្ដេចយាងចេញមកឆ្ងាយពីពពួកពល ព្រះអង្គនឹងអាចចាប់ព្រះបាទឧទេន ដែលទ្រង់ស្ដេចយាងមកដោយអាការនោះបាន ។ គ្រានោះ ព្រះរាជាត្រាស់ថា ឧបាយនេះអាចប្រើការបាន រួចក៏បានបញ្ជាឲ្យគេធ្វើដំរីយន្តអំពីឈើ យកកំណាត់សំពត់រុំព័ទ្ធខាងក្រៅ ហើយទ្រង់

បញ្ជាឲ្យធ្វើដំរីយន្តនោះ ឲ្យមានចិត្តកម្មផ្សេងៗ បញ្ជាឲ្យរាជបុរសលែងដំរីនោះទៅក្បែរស្រះមួយ ដែលនៅជិតដែនដីរបស់ព្រះបាទឧទេន ។ ចំណែកដំរីយន្តនោះ អាចមានបុរស ៦០ នាក់ដើរទៅមកបានក្នុងពោះដំរីនោះ ពួកបុរសទាំងអស់នោះបាននាំគ្នាយកអាចម៍ដំរីមកទម្លាក់ចោលក្នុងទីនោះៗ ពេលនោះព្រានព្រៃម្នាក់បានឃើញដំរីនោះហើយ ក៏គិតថាដំរីនេះសមគួរដល់ស្ដេចដែនដីរបស់យើង គិតឃើញដូច្នោះហើយក៏បាននាំគ្នាមកក្រាបទូលព្រះបាទឧទេនថា បពិត្រមហារាជ ខ្ញុំព្រះអង្គបានឃើញដំរីដ៏ប្រសើរ ដែលមានអវយវៈសសុទ្ធ មានចំណែកប្រៀបដូចកំពូលនៃភ្នំកៃលាស សមគួរដល់ព្រះអង្គណាស់ ។ ពេលនោះព្រះបាទឧទេនទ្រង់ឲ្យព្រានព្រៃនោះឯង ជាអ្នកនាំផ្លូវទៅកន្លែងដំរីនោះព្រមដោយបរិវារជាច្រើន ពួកចារបុរសក៏បានដឹងអំពីការយាងមករបស់ព្រះបាទឧទេន ក៏ទៅក្រាបទូលដល់ព្រះបាទចណ្ឌប្បជ្ជោតឲ្យទ្រង់ជ្រាប ព្រះបាទចណ្ឌប្បជ្ជោតទ្រង់ជ្រាបហើយ ស្ដេចយាងមក ទ្រង់បានធ្វើនូវជីទំនេរទុកនៅត្រង់ទីកណ្ដាល បង្កប់នូវពួកពលទុកសងខាង ។ ព្រះបាទ

ឧទេនស្តេចមិនបានទ្រង់ជ្រាបដល់ការយាងមករបស់ព្រះបាទចណ្ឌប្បជ្ជោត ក៏នៅតែដេញទៅតាមដំរីនោះទៀត ។ មនុស្សដែលនៅខាងក្នុងដំរី ក៏ប្រញាប់នាំដំរីទៅដោយរហ័ស កាលព្រះរាជាទ្រង់រាយមន្តដេញពិណចាប់ដំរីឈើនោះៗ ធ្វើដូចមិនឮសំឡេងពិណ បេះតែរត់ទៅមុខ ។ ព្រះរាជាមិនអាចតាមទាន់ដំរីនោះស្តេចក៏ឡើងជិះលើសេះដេញទៅតាមរហូតឆ្ងាយអំពីកងពល ។ ពួកចារបុរសរបស់ព្រះបាទចណ្ឌប្បជ្ជោត ដែលដាក់កងទ័ពទុកក្នុងទីទាំងសងខាងផ្លូវ ក៏ចេញមកចាប់ព្រះបាទឧទេន យកទៅថ្វាយដល់ព្រះបាទចណ្ឌប្បជ្ជោតទៅ ។ គ្រានោះ ពួកពលរបស់ព្រះបាទឧទេនបានដឹងថា ព្រះរាជារបស់ខ្លួន ធ្លាក់ទៅក្នុងអំណាចនៃបុគ្គលដែលមិនមែនជាមិត្រហើយ ក៏បានសង់បន្ទាយនៅខាងៗ ព្រំដែនរង់ចាំ ។ ចំណែកព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បានបញ្ជាឲ្យយកព្រះបាទឧទេនទៅដាក់ឃុំ នៅក្នុងទីកន្លែងដែលដាក់ពួកចោរ ទ្រង់បញ្ជាឲ្យបិទទ្វារហើយទ្រង់បានសោយនូវទឹកជ័យ រហូតអស់ ៣ ថ្ងៃ ក្នុងថ្ងៃទី ៣ ព្រះបាទឧទេនសួរអ្នកយាមគុកថា នែអ្នកទាំងឡាយ ស្តេចផែនដីរបស់ពួកអ្នក

នៅឯណា ? អ្នកយាមគុកបានឆ្លើយថា ស្តេចផែនដីរបស់ពួកយើង ទ្រង់កំពុងតែសោយនូវទឹកជ័យ ( ទឹកដែលបុគ្គលផឹកក្នុងពេលដែលខ្លួនឈ្នះ ) ដោយទ្រង់ត្រេកអរថា បច្ចាមិត្រអញចាប់បានហើយ ។ ពេលនោះ ព្រះបាទឧទេនបានពោលថា ស្តេចផែនដីរបស់ពួកអ្នកឯងបែបនេះឬ ? ដែលចាប់ព្រះរាជាជាសត្រូវបានហើយ បើត្រូវសម្លាប់ក៏សម្លាប់មកចុះ ត្រឡប់ទៅជាគិតតែពីអង្គុយសោយទឹកជ័យទៅវិញ ហើយឲ្យយើងនៅក្នុងគុករងទុក្ខដូច្នេះ ។ អ្នកយាមគុកទាំងនោះ កាលបើឮព្រះបាទឧទេននិយាយយ៉ាងនេះហើយ ក៏បាននាំគ្នាទៅក្រាបទូលសេចក្តីនោះដល់ព្រះបាទចណ្ឌប្បជ្ជោតៗ ស្តេចយាងទៅត្រាស់សួរថា ព្រះអង្គត្រាស់យ៉ាងនោះ ពិតមែនឬ ? ព្រះបាទឧទេនតបថា ព្រះករុណាថ្លៃវិសេស ពិតមែនហើយ ។ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់ថា ពាក្យដែលព្រះអង្គពោលនោះប្រពៃហើយ ទូលបង្គំនឹងលែងព្រះអង្គបាន ប៉ុន្តែខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាអ្នកចេះមន្តចាប់ដំរី ហេតុដូច្នេះ សូមព្រះអង្គបង្រៀនមន្តនោះដល់ខ្ញុំព្រះអង្គសិន ។ ព្រះបាទឧទេនពោលថា ប្រពៃ

ហើយ ទូលបង្គំអាចបង្រៀនបាន ប៉ុន្តែសូមព្រះអង្គថ្វាយបង្គំខ្ញុំព្រះអង្គសិន ។ ព្រះបាទចណ្ឌប្បជ្ជោតពោលថា ទូលបង្គំមិនអាចថ្វាយបង្គំព្រះអង្គបានទេ ។ ព្រះបាទឧទេនពោលថា បើព្រះអង្គមិនអាចថ្វាយបង្គំខ្ញុំព្រះអង្គទេ មន្តនេះខ្ញុំមិនអាចបង្រៀនព្រះអង្គដែរ ។ ព្រះបាទចណ្ឌប្បជ្ជោតបានពោលថា ប្រសិនបើព្រះអង្គមិនថ្វាយមន្តនេះដល់ទូលបង្គំទេ ទូលបង្គំនឹងដាក់អាជ្ញាចំពោះព្រះអង្គ ។ ព្រះបាទឧទេនសើចថា ព្រះអង្គធ្វើយ៉ាងណាក៏ធ្វើចុះ ព្រោះពេលនេះព្រះអង្គជាធំ ចំពោះសរីរៈទូលបង្គំហើយ ប៉ុន្តែព្រះអង្គមិនជាធំលើចិត្តរបស់ទូលព្រះបង្គំទេ ។

គ្រានោះ ព្រះរាជាទ្រង់ព្រះសណ្តាប់នូវពាក្យអង់អាចក្លាហានរបស់ព្រះបាទឧទេននោះហើយ ក៏ទ្រង់ព្រះតម្រិះថា អញនឹងរៀនមន្តអំពីព្រះបាទឧទេននេះ បានដោយប្រការដូចម្តេចហ្ន៎ ។ ហើយទ្រង់ព្រះចិន្តាថា អញមិនអាចញុំាងអ្នកដទៃឲ្យចេះនូវមន្តនេះបានទេ អញនឹងឲ្យធីតារបស់អញទៅរៀន ជាមួយនឹងព្រះបាទឧទេន កាលរៀនចេះហើយសឹមអញរៀនយកពីធីតារបស់អញវិញ ទើបជាការល្អ ។ គ្រានោះ

ព្រះបាទចណ្ឌប្បជ្ជោត ក៏បានត្រាស់ទៅកាន់ព្រះបាទឧទេននោះថា តើព្រះអង្គអាចឲ្យអ្នកដទៃដែលមកថ្វាយបង្គំព្រះអង្គហើយ អាចរៀនយកមន្តនេះបានឬ?ព្រះបាទឧទេនតបថា ករុណាថ្ងៃវិសេស បានៗព្រះបាទចណ្ឌប្បជ្ជោតត្រាស់ថា បើដូច្នោះ នៅក្នុងសម្នាក់របស់ទូលបង្គំ មានស្ត្រីខ្នងគមម្នាក់ ព្រះអង្គចូលទៅនៅជិតខាងក្រៅវាំងននហើយ បង្រៀនមន្តដល់ស្ត្រីនោះ ដែលជាអ្នកអង្គុយនៅខាងក្នុងវាំងននោះចុះ ៗព្រះបាទឧទេនពោលថា បពិត្រមហារាជ ប្រពៃហើយ ស្ត្រីខ្នងគមក្តីស្រីខ្វាក់ខ្វិនក្តី ចូរលើកទុកសិនចុះ កាលនាងថ្វាយបង្គំទូលបង្គំហើយទូលបង្គំនឹងបង្រៀនមន្តឲ្យៗលំដាប់នោះ ព្រះបាទចណ្ឌប្បជ្ជោត ស្តេចបានយាងទៅត្រាស់ប្រាប់វាសុលទត្តារាជធីតាថា នែកូនស្រី មានបុរសកើតរោគឃ្លង់ម្នាក់ ចេះមន្តកាត់ថ្លៃពុំបាន បិតាមិនអាចនឹងឲ្យបុគ្គលដទៃចេះមន្តនោះបានទេ ហេតុដូច្នេះ កូនឯងចូលទៅអង្គុយខាងក្នុងវាំងននហើយថ្វាយបង្គំបុគ្គលនោះ រួចរៀនមន្ត ដោយបុគ្គលនោះឈរនៅខាងក្រៅវាំងននបង្រៀនមន្តដល់កូនឯង បន្ទាប់មក កាលបើកូនចេះ បិតា

នឹងរៀនពីកូនឯងវិញ ។ ព្រះបាទចណ្ឌប្បជ្ជោតនោះ ដែលត្រាស់ថា កូនស្រីរបស់ខ្លួនជាមនុស្សខ្វិនគម ហើយព្រះបាទឧទេនជាបុរសកើតរោគឃ្លង់យ៉ាងនេះ ព្រោះខ្លាចក្រែងអ្នកទាំងពីរនោះ ធ្វើនូវសន្ថវៈគ្នានឹងគ្នា ។ ព្រះបាទឧទេនបានស្ថិតនៅអំពីខាងក្រៅវាំងនន ទ្រង់បានបង្រៀនមន្តដល់ព្រះរាជធីតា ដែលបានថ្វាយបង្គំហើយ អង្គុយនៅខាងក្នុងវាំងនន ។ សម័យថ្ងៃមួយ ព្រះបាទឧទេនបានត្រាស់ទៅកាន់ព្រះនាងវាសុលទត្តា សូម្បីព្រះអង្គត្រាស់ប្រាប់ជារឿយៗ ក៏មិនអាចនឹងពោលនូវបទមន្តបានក៏ស្រែកសម្តុតថា នែស្រីខ្វិនគម មេស្រីចង្រៃ បបូរមាត់របស់នាងឯងក្រាស់ណាស់ ហាងឯងពោលយ៉ាងនេះក៏មិនកើត ពោលយ៉ាងនោះ ក៏មិនកើត ។ ពេលនោះ នាងវាសុលទត្តា ក៏ត្រាស់ទៅវិញថា យី អាបុរសឃ្លង់ ឯងនិយាយអ្វី ថាស្រីដូចយើងនេះជាស្រីខ្វិនគម ពោលដូច្នេះហើយទ្រង់ក៏សើយនូវជាយវាំងននលើកឡើងរួចព្រះបាទឧទេនត្រាស់សួរថា នាងជានរណា ? នាងក៏ត្រាស់ប្រាប់ថា ខ្ញុំឈ្មោះនាងវាសុលទត្តា ជាធីតានៃព្រះបាទចណ្ឌប្បជ្ជោត ។ គ្រានោះ ព្រះបាទ

ឧទេនបានពោលថា បិតារបស់នាងបាននិយាយប្រាប់ដល់ខ្ញុំថា នាងជាស្ត្រីខ្នងគម ។ នាងវាសុលទត្តាបានពោលដែរថា សូម្បីបិតារបស់ខ្ញុំព្រះអង្គ ក៏មានព្រះបន្ទូលអំពីព្រះអង្គដែរថា ជាមនុស្សកើតរោគឃ្លង់ដែរ ។ កាលអ្នកទាំងពីរនោះ ទ្រង់បានជ្រាបរឿងរ៉ាវទាំងអស់នោះហើយទ្រង់ព្រះចិន្តាថា ពាក្យនោះព្រះរាជាត្រាស់ហើយ ដោយការខ្លាចក្រែងយើងទាំងពីរនាក់ ធ្វើនូវសន្ថវៈគ្នានឹងគ្នា បន្ទាប់មក ទ្រង់ក៏បានធ្វើនូវសន្ថវៈគ្នានឹងគ្នា នៅខាងក្នុងវាំងននោះមែន ។ ចាប់ផ្តើមអំពីកាលនោះមក ការរៀនមន្ត ឬសិល្បៈក៏មិនមាន ចំណែកព្រះបាទចណ្ឌប្បជ្ជោតទ្រង់សួរព្រះរាជធីតាជារឿយៗ ថា នែកូនស្រី កូនឯងនៅតែរៀនមន្តនោះទៀតឬ ឬក៏រៀនចប់ហើយ ? ព្រះនាងវាសុលទត្តាត្រាស់ថា បពិត្រព្រះបិតា ខ្ញុំម្ចាស់កំពុងតែរៀនមិនទាន់ចប់ទេ ខាងក្រោយមក ក្នុងថ្ងៃមួយព្រះបាទឧទេនបានត្រាស់ទៅនឹងនាងវាសុលទត្តាថា នែនាងដ៏ចម្រើនឈ្មោះថា អំពើដែលស្វាមីគប្បីធ្វើ មាតាបិតា បងប្អូនប្រុស និងបងប្អូនស្រីមិនអាចដើម្បីនឹងធ្វើនូវអំពើនោះបានឡើយ ប្រសិនបើនាងនឹងឲ្យ

ជីវិតដល់ខ្ញុំៗ នឹងប្រគល់ស្ត្រី ៥០០ នាក់ឲ្យធ្វើជាបរិវាររបស់នាង ហើយ នឹងប្រទានតំណែងជាអគ្គមហេសីដល់នាងទៀតផង ។

គ្រានោះ ព្រះនាងវាសុលទត្តាត្រាស់ថា បើព្រះអង្គជាអ្នកតាំងនៅក្នុងតម្រាស់នេះមែន ខ្ញុំម្ចាស់នឹងថ្វាយនូវជីវិត គឺនឹងជួយដល់ព្រះអង្គឲ្យបាន ។ ព្រះបាទឧទេនត្រាស់តបថា នែនាងដ៏ចម្រើន ខ្ញុំអាចតាំងនៅក្នុងតម្រាស់នេះបាន ។ ព្រះនាងវាសុលទត្តា ទ្រង់ទទួលនូវព្រះតម្រាស់នោះថា ប្រពៃហើយ ពោលដូច្នេះហើយ ព្រះនាងយាងទៅកាន់សម្នាក់របស់បិតា ថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរ ។ ខណៈនោះ ព្រះបាទចណ្ឌប្បជ្ជោត ត្រាស់សួរព្រះនាងវាសុលទត្តាថា នែកូនស្រី កូនបានរៀនមន្តនោះចប់ហើយឬ ? នាងវាសុលទត្តាបានពោលថា បពិត្រព្រះបិតា នៅមិនទាន់ចប់ទេ ។ គ្រានោះ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់សួរព្រះនាងវាសុលទត្តាថា នែកូនស្រី ព្រោះហេតុអ្វីក៏រៀនក្រចប់ម្ល៉េះ ? នាងវាសុលទត្តាតបថា បពិត្រព្រះបិតា ខ្ញុំម្ចាស់គួរនឹងបានទ្វារ ១ និងពាហនៈ ១ ។ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់ថា

នៃកូនស្រី កម្មនេះតើដូចម្តេច ? ព្រះនាងតបថា បពិត្រព្រះបិតា មាន ឱសថមួយមុខ នឹងត្រូវកាន់យកក្នុងវេលារាត្រី ដោយសញ្ញាតាម ផ្កាយព្រឹក ដើម្បីជាប្រយោជន៍ឧបការៈដល់មន្ត ។ ព្រោះហេតុនោះ ក្នុងពេលដែលខ្ញុំម្ចាស់ទៅពេលណាក៏បាន ទ្វារគួរក៏មាន ពាហនៈគួរ ក៏មានដែរ ។ ព្រះរាជាទ្រង់ទទួលយល់ព្រមដោយព្រះរាជតម្រាស់ថា បាន ព្រះបាទឧទេន និងនាងវាសុលទត្តាបានកាន់យកទ្វារមួយដែល ខ្លួនពេញចិត្ត ទុកក្នុងអំណាចរបស់ខ្លួន ចំណែកឯពាហនៈ ៥ យ៉ាង របស់ព្រះបាទចណ្ឌប្បជ្ជោតនោះ គឺ ១- ដំរីញីមានឈ្មោះថា **ភទ្ទវតី** អាចដើរមួយថ្ងៃបាន ៥០ យោជន៍ ២- អ្នកបម្រើឈ្មោះថា **កាកៈ** អាចដើរមួយថ្ងៃបាន ៦០ យោជន៍ ៣- សេះ ២ គឺ សេះឈ្មោះថា **វេលកង្សិ** ១ និង **មញ្ជុកេសិ** ១ អាចដើរមួយថ្ងៃបានមួយរយយោជន៍ ៤- ដំរីនាឡាគិរី អាចដើរមួយថ្ងៃបាន ១២០ យោជន៍ ។ បានឮមកថា ព្រះរាជាអង្គនោះ កាលព្រះសម្មាសម្ពុទ្ធមិនទាន់ឧប្បត្តិឡើងក្នុងលោក បានជាអ្នកបម្រើនៃឥស្សរជនម្នាក់ ។ ថ្ងៃមួយ កាលឥស្សរជននោះ

ចេញទៅក្រៅព្រះនគរដើម្បីផ្ងូតទឹក ហើយត្រឡប់មកវិញ ។ គ្រានោះ មានព្រះបច្ចេកពុទ្ធមួយព្រះអង្គ និមន្តចូលទៅក្នុងព្រះនគរ ដើម្បីបិណ្ឌបាត ប៉ុន្តែមិនបានភិក្ខាសូម្បីត្រឹមតែមួយវែក ព្រោះអ្នកក្រុងទាំងអស់ ត្រូវមារបណ្ដាលចិត្តមិនឲ្យដាក់បាត្រ និមន្តចេញពីក្រុងមកវិញមានតែបាត្រទទេ ។ ពេលនោះ មារមានចិត្តបាបបានចូលទៅរកព្រះបច្ចេកពុទ្ធនោះ ដោយភេទដែលមិនមានបុគ្គលណាស្គាល់ ហើយសួរព្រះបច្ចេកពុទ្ធ ក្នុងខណៈដែលលោកនិមន្តដល់ទ្វារព្រះនគរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានវត្ថុអ្វីៗ ខ្លះដែរឬ ? ព្រះបច្ចេកពុទ្ធឆ្លើយថា ក៏អ្នកឯងធ្វើនូវអាការ គឺកិរិយាមិនបានឲ្យដល់អាត្មាហើយ មិនមែនឬ ? មារឆ្លើយថា បើដូច្នោះ សូមលោកម្ចាស់ត្រឡប់ទៅកាន់ក្រុងម្ដងទៀតចុះ លើកនេះខ្ញុំមិនធ្វើដូច្នោះទៀតទេ ។ ព្រះបច្ចេកពុទ្ធ សូម្បីមារពោលដូច្នោះ ក៏មិនបាននិមន្តចូលទៅកាន់ក្រុងម្ដងទៀតឡើយ ។ ត្បិតថា បើព្រះបច្ចេកពុទ្ធនោះនិមន្តចូលទៅកាន់ក្រុងម្ដងទៀត មារនោះនឹងបណ្ដាលឲ្យអ្នកក្រុងទាំងអស់ទះដៃ ធ្វើការសើចចំអក ព្រោះដូច្នោះ

ទើបព្រះបច្ចេកពុទ្ធមិននិមន្តចូលទៅកាន់ក្រុងម្តងទៀត មារក៏អន្តរធាន បាត់ទៅក្នុងទីនោះឯង ។ គ្រានោះ ឥស្សរជននោះ គ្រាន់តែឃើញ ព្រះបច្ចេកពុទ្ធដែលនិមន្តចេញមកអំពីក្រុងដោយបាត្រទទេ ក៏ថ្វាយបង្គំ សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានវត្ថុអ្វីខ្លះហើយ ឬ ? ព្រះបច្ចេកពុទ្ធឆ្លើយថា នែអ្នកដ៏ចម្រើន អាត្មាភាពត្រាច់ទៅហើយ ចេញមកវិញហើយ ឥស្សរជននោះគិតថា លោកម្ចាស់ដ៏ចម្រើននេះ មិនឆ្លើយនឹងសំណួរដែលយើងសួរ ត្រឡប់ជាពោលពាក្យដទៃមកវិញ លោកម្ចាស់នេះ ប្រាកដជាមិនបាននូវវត្ថុអ្វីៗ ខ្លះហើយមើលទៅ ។ ពេលនោះ ឥស្សរជននោះ ក៏បានដើរចូលទៅបើកបាត្រព្រះបច្ចេកពុទ្ធ មើល ក៏ឃើញតែបាត្រទទេ ក៏មានចិត្តឆ្ងល់ ប៉ុន្តែមិនអាចហ៊ានទទួល បាត្រ ព្រោះមិនដឹងថា ភត្តក្នុងផ្ទះរបស់ខ្លួនមាន ឬក៏មិនមាន ក៏បាន ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់រង់ចាំបន្តិច សិនចុះ ពោលដូច្នេះហើយ ក៏ប្រញាប់ដើរទៅផ្ទះ ហើយសួរអ្នកផ្ទះថា ភត្តនៅក្នុងផ្ទះរបស់យើងមាន ឬមិនមាន ? កាលអ្នកបម្រើឆ្លើយថា

មាន ក៏បានពោលថា នៃអ្នកដ៏ចម្រើន បុគ្គលដែលជាអ្នកមានកម្លាំងខ្លាំង ហើយរហ័សវិសេសជាងឯងមិនមាន ហេតុដូច្នេះ ឯងចូររត់ទៅរកលោកម្ចាស់នោះ ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ ឲ្យបាត្រលោកម្ចាស់ដល់ខ្ញុំព្រះករុណា ហើយទទួលយកមក អ្នកបម្រើនោះ ទទួលយកបាត្ររត់ត្រឡប់មកវិញយ៉ាងលឿន ៗ គ្រានោះឯង ឥស្សរជននោះ ក៏បានញុំាងបាត្រនោះឲ្យពេញដោយភោជនរបស់ខ្លួន ហើយពោលថា ឯងចូររត់យកបាត្រនេះទៅប្រគេនដល់លោកម្ចាស់វិញ យើងនឹងឲ្យចំណែកបុណ្យដែលកើតអំពីទាននេះដល់អ្នកឯងដែរ អ្នកបម្រើទទួលយកបាត្រនោះហើយ ក៏បានរត់យកទៅប្រគេនព្រះបច្ចេកពុទ្ធ ថែមទាំងបានថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយ ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ការរត់ទៅមកយ៉ាងលឿននេះ ដោយផលនៃសន្ទុះជើងរបស់ខ្ញុំម្ចាស់នេះ សូមពាហនៈទាំង ៥ ដែលអាចទៅបាន ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ សូមកើតមានដល់ខ្ញុំម្ចាស់ ៗ ម្យ៉ាងទៀត រាងកាយរបស់

ខ្ញុំម្ចាស់ កាលវត់ទៅមក ដែលបានត្រូវកម្ដៅនៃព្រះអាទិត្យដុតពេល ហើយនេះ សូមឲ្យអាផ្កាបេស់ខ្ញុំម្ចាស់ផ្សាយទៅ ដូចតេជះនៃព្រះអាទិត្យ ក្នុងទីដែលខ្ញុំម្ចាស់កើតហើយៗ ចំណែកបុណ្យក្នុងបិណ្ឌបាតនេះ ដែលម្ចាស់ទានបានឲ្យហើយដល់ខ្ញុំម្ចាស់ ដោយផលដែលហូរចេញអំពីចំណែកបុណ្យនេះ សូមឲ្យខ្ញុំម្ចាស់ជាអ្នកបានចំណែកនៃធម៌ ដែលលោកម្ចាស់បានហើយ ។ គ្រានោះ ព្រះបច្ចេកពុទ្ធពោលថា សូមឲ្យសេចក្ដីប្រាថ្នា ដែលអ្នកប្រាថ្នាហើយបានសម្រេច ហើយបានពោលធ្វើការអនុមោទនាថា

សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយតាំងចិត្តហើយ ចូរឲ្យសម្រេចដល់អ្នក ឲ្យបានឆាប់រួសរាន់ទាន់ចិត្ត ។ សូមតម្រិះត្រូវទាំងពួងចូរពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើតពុំនោះសោត ដូចកែវមណីមានរស្មីដ៏រុងរឿង ជាកែវវិសេសអាចញុំាងសេចក្ដីប្រាថ្នាទាំងពួងឲ្យសម្រេចបាន ។

បានឮថា គាថាទាំងពីរនេះឯង ជាគាថាសម្រាប់អនុមោទនា

របស់ព្រះបច្ចេកពុទ្ធគ្រប់ៗ ព្រះអង្គ ។ **រតនៈ** គឺកែវមណីដែលអាចឲ្យសម្រេចនូវសម្បត្តិទាំងពួងបាន ហៅថា **កែវមណីជោតិរស** ក្នុងគាថានេះ ជាការសម្ដែងឲ្យឃើញដល់បុញ្ញកម្មរបស់អ្នកបម្រើនោះ ។ គឺគេបានមកជាព្រះបាទចណ្ឌប្បជ្ជោតក្នុងកាលឥឡូវនេះ ។ ហើយផលដែលហូរចេញអំពីបុញ្ញកម្មនោះ ពាហនៈទាំង ៥ នោះឯង បានកើតដល់គេ ។ ថ្ងៃមួយ ព្រះរាជាស្ដេចយាងចេញទៅដើម្បីកម្សាន្តក្នុងឧទ្យាន ។ ព្រះបាទឧទេន ទ្រង់ព្រះចិន្ដាថា អញគប្បីរត់ចេញទៅ ក្នុងថ្ងៃនេះ ដាក់ប្រាក់មាសឲ្យពេញក្នុងការុង ដាក់នៅលើខ្នងដំរី ហើយនាំព្រះនាងវាសុលទត្តាចេញទៅជាមួយ ។ ទាហានដែលរក្សានៅខាងក្នុងនៃរាជវាំងទាំងឡាយ បានឃើញព្រះបាទឧទេនរត់ចេញទៅនោះ ក៏ទៅក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប គ្រានោះ ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បញ្ជូនពលទៅដោយព្រះតម្រាស់ថា ពួកឯងចូរទៅឲ្យលឿន ព្រះបាទឧទេនទ្រង់បានជ្រាបថា ទាហានរបស់ព្រះបាទចណ្ឌប្បជ្ជោតដេញមកតាមក្រោយហើយ ក៏ទ្រង់ស្រាយមាត់ការុងកហាបណៈទម្លាក់ចុះមក

ទាហានរបស់ព្រះបាទចណ្ឌប្បជ្ជោតឃើញដូច្នោះហើយ ក៏នាំគ្នារើស យកកហាបណៈឡើង ហើយក៏បានដេញតទៅទៀត ។ ចំណែកព្រះបាទ ឧទេនក៏ទ្រង់ស្រាយមាត់ការុងមាសទម្លាក់ទៀត កាលពួកទាហាននោះ រវល់តែនាំគ្នារើសយកមាស ដែលព្រះបាទឧទេនទម្លាក់ទៅនោះ ក៏ស្តេច យាងទៅដល់បន្ទាយរបស់ព្រះអង្គ ដែលតាំងនៅខាងៗ ព្រំដែននោះ ។ គ្រានោះ ពួកពលទាហានគ្រាន់តែបានឃើញស្តេចយាងមកដល់ភ្លាម ក៏ចោមរោមព្រះអង្គ ហើយយាងព្រះអង្គ ចូលទៅក្នុងព្រះនគររបស់ ខ្លួនវិញ ។ ព្រះបាទឧទេនព្រះអង្គគ្រាន់តែស្តេចយាងទៅដល់ព្រះនគរភ្លាម ក៏បានអភិសេកព្រះនាងវាសុលទត្តាជាអគ្គមហេសីភ្លាមដែរ ។មិនមែន តែប៉ុណ្ណោះព្រះនាងទេវីដទៃទៀត មានព្រះនាងមាគន្ទិយា ក៏បានទទួល តំណែងជាអគ្គមហេសី ដែលព្រះបាទឧទេនតែងតាំងដែរ ។

ព្រះបាទឧទេនមានអគ្គមហេសីមួយព្រះអង្គទៀត ព្រះនាមថា ព្រះនាងមាគន្ទិយា មានរឿងតំណាលទុកនៅក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **អប្បមាទវគ្គ** ក្នុងរឿងរបស់ព្រះនាងសាមាវតី និងក្នុង **អដ្ឋកថា**

មនោរថបូរណី ដូចមានសេចក្តីថា ៈ-

នាងមាគន្ទិយា ជាកូនស្រីរបស់ព្រាហ្មណ៍ ឈ្មោះមាគន្ទិយៈ ក្នុងដែនកុរុ ។ មាតារបស់នាងក៏ឈ្មោះមាគន្ទិយា និងឪពុកមារបស់នាង ក៏ឈ្មោះមាគន្ទិយៈដូចគ្នាដែរ ។ នាងជាស្ត្រីមានរូបស្រស់ស្អាតក្រៃលែង ប្រៀបដូចជាទេពអប្សរ ។ ក៏បិតារបស់នាង កាលរកនូវស្វាមី ដែលមិនបានសមគួរដល់នាង សូម្បីត្រកូលធំៗ ទាំងឡាយ មកស្តីដណ្តឹងហើយ ក៏បដិសេធ ហើយបញ្ជូនទៅវិញថា ពួកលោកមិនសមគួរដល់ធីតារបស់យើងទេ ។ ថ្ងៃមួយ ព្រះមានជោគ ទ្រង់ប្រមើលមើលនូវសត្វលោកក្នុងពេលជិតភ្លឺ ទ្រង់បានឃើញឧបនិស្ស័យនៃអនាគាមិផលរបស់មាគន្ទិយព្រាហ្មណ៍ ព្រមទាំងករិយា ទ្រង់ក៏បានប្រដាប់ដោយបាត្រនិងចីវរ ហើយស្តេចយាងទៅកាន់ទីបម្រើភ្លើង របស់ព្រាហ្មណ៍នោះ ដែលនៅខាងក្រៅនិគម ។ ព្រាហ្មណ៍នោះ បានឃើញព្រះវរកាយដ៏ប្រសើរ ដោយភាពស្អាតនៃព្រះរូបរបស់ព្រះតថាគតហើយ ក៏គិតដូច្នេះថា ក្នុងលោកនេះ បុរសដទៃស្មើដោយបុរសនេះមិនមាន បុរសនេះ

ជាអ្នកសមគួរដល់ធីតារបស់យើងហើយ យើងនឹងឲ្យធីតារបស់យើង ដល់បុរសនេះ ដើម្បីជាប្រយោជន៍ដល់ការចិញ្ចឹមរក្សាគ្នា ហើយទើប ពោលថា បពិត្រសមណៈ ខ្ញុំមានធីតាម្នាក់ ខ្ញុំមិនទាន់ឃើញនូវបុរស ដែលសមគួរដល់នាង រហូតអស់កាលដ៏យូរមកហើយ លោកជាអ្នក សមគួរដល់នាង ហើយនាងក៏ជាអ្នកសមគួរដល់លោកដែរ លោកគួរ បាននាងទុកជាស្ត្រីអ្នកបម្រើនៅក្បែរលោក ហើយនាងក៏គួរបានលោក ជាស្វាមីដែរ ខ្ញុំនឹងឲ្យធីតារបស់ខ្ញុំដល់លោក លោកចូររង់ចាំនៅទីនេះសិន ទម្រាំនឹងខ្ញុំត្រឡប់មកវិញ ។ ព្រះសាស្តា មិនត្រាស់នូវអ្វីៗ ទាំងអស់ ទ្រង់បាននៅស្ងៀម ។ ព្រាហ្មណ៍នោះ ក៏បានទៅផ្ទះយ៉ាងលឿន ហើយ ពោលទៅកាន់នាងព្រាហ្មណីថា នែនាងដ៏ចម្រើន ខ្ញុំបានឃើញបុរស ដែលសមគួរដល់កូនស្រីយើងហើយ នាងចូរតាក់តែងខ្លួនកូនស្រីរបស់ យើងឲ្យឆាប់ៗ ប្រើព្រាហ្មណីឲ្យតាក់តែងកូនស្រីរួចហើយ នាំទៅមួយ អន្លើដោយព្រាហ្មណី បានទៅកាន់សម្នាក់ព្រះលោកនាថ ។ អ្នកនគរ ទាំងមូលភ្ញាក់ផ្អើលថា ព្រាហ្មណ៍នេះមិនឲ្យកូនស្រីដល់អ្នកណាមួយ

ដោយសម្គាល់ថាបុរសដែលសមគួរដល់កូនស្រីរបស់គាត់មិនមានមក ជាយូរហើយ ។ បានឮថា គាត់ពោលថា ថ្ងៃនេះយើងបានជួបបុរស ដែលសមគួរដល់កូនស្រីរបស់គាត់ហើយ បុរសនោះជានរណាទៅហ្ន៎ ដូច្នេះ ពួកយើងនាំគ្នាទៅមើលបុរសនោះ ។ គ្រានោះ មានមហាជន ជាច្រើនបានដើរទៅមួយនឹងព្រាហ្មណ៍នោះដែរ ។ កាលព្រាហ្មណ៍នោះ នាំធីតាមក ព្រះសាស្តា មិនបានទ្រង់ស្ថិតនៅក្នុងទីដែលព្រាហ្មណ៍នោះ ពោលទេ ទ្រង់បានប្រាកដឲ្យឃើញព្រះចេតិយ គឺស្នាមព្រះបាទទុក នៅក្នុងទីនោះហើយ ស្តេចយាងទៅកាន់ទីដទៃ ។ពិតណាស់ ព្រះចេតិយ គឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលព្រះអង្គ ទ្រង់អធិដ្ឋានហើយ ប្រថាប់ស្នាមព្រះបាទ រមែងមិនប្រាកដក្នុងទីដទៃទេ មួយវិញទៀត ព្រះចេតិយ គឺស្នាមព្រះបាទជាវត្ថុដែលទ្រង់អធិដ្ឋានទុក ដើម្បីជាប្រយោជន៍ដល់ជនទាំងឡាយណា គឺមានតែជនទាំងឡាយនោះ ប៉ុណ្ណោះ អាចឃើញព្រះចេតិយ គឺស្នាមព្រះបាទនោះបាន សូម្បីមាន សត្វដំរីជាន់ក៏ដោយ មហាមេឃបង្អុរចុះមកក៏ដោយ ខ្យល់កំបុតត្បូង

ក៏ដោយ ដើម្បីនឹងមិនឲ្យបុគ្គលទាំងនោះមើលមិនឃើញ អ្វីមួយក៏មិនអាចដើម្បីលុបនូវព្រះចេតិយ គឺស្នាមព្រះបាទនោះបានឡើយ ។ពេលនោះ នាងព្រាហ្មណីពោលទៅកាន់ព្រាហ្មណ៍ថា ចុះបុរសនោះនៅទីណា? ព្រាហ្មណ៍បានតបថា យើងបាននិយាយជាមួយនឹងគេថា លោកចូរឈរចាំយើងក្នុងទីនេះសិន ឥឡូវនេះ គេទៅកាន់ទីណាហ្ន៎ ក៏បានរកមើលរួចក៏បានឃើញ ព្រះចេតិយ គឺស្នាមព្រះបាទ ហើយបានពោលថា នេះជាស្នាមជើងរបស់គេទេតើ នាងព្រាហ្មណីបាននឹកដល់មន្តមើលលក្ខណៈ ពិចារណាមើលលក្ខណៈនៃស្នាមព្រះបាទ ព្រោះភាពជាអ្នកស្ទាត់ជំនាញក្នុងវេទទាំង ៣ព្រមទាំងមន្តសម្រាប់ទាយលក្ខណៈហើយពោលថា បពិត្រព្រាហ្មណ៍ នេះមិនមែនជាស្នាមជើងរបស់បុគ្គល អ្នកមានប្រក្រតីបរិភោគកាមគុណទេ ហើយពោលគាថាដូច្នេះថា

**បុគ្គលមានរាគចរិត រមែងមានស្នាមជើងផតត្រង់កណ្ដាល បុគ្គលមានទោសចរិត រមែងមានស្នាមជើងធូន់ត្រង់កែង បុគ្គលមានមោហចរិតវិញ រមែងមានស្នាមជើងខ្ទាំត្រង់ចុងម្រាម បុគ្គលមានកិលេស**

គ្រឿងប្រក់ ឬដំបូលរបើកហើយ រមែងមានស្នាមជើង ដូចនេះឯង ។

គ្រានោះ ព្រាហ្មណ៍បានពោលទៅកាន់នាងព្រាហ្មណីថា នែនាងដ៏ចម្រើន នាងមានប្រក្រតីឃើញមន្ត ដូចជាការឃើញក្រពើក្នុងពាងទឹក ឬដូចជាការឃើញចោរដែលនៅក្នុងផ្ទះ នាងចូរនៅស្ងៀមចុះ ។ នាងព្រាហ្មណីពោលថា បពិត្រព្រាហ្មណ៍ លោកប្រាថ្នាដើម្បីនឹងពោលនូវពាក្យឯណា ចូរពោលនូវពាក្យនោះចុះ ប៉ុន្តែស្នាមជើង នេះមិនមែនជាស្នាមជើងរបស់មនុស្សដែលបរិភោគកាមគុណទេ ។ រីឯព្រាហ្មណ៍បានរកមើលខាងនេះ ខាងនោះ ហើយក៏បានឃើញព្រះសាស្តា ថែមទាំងពោលថា នុ៎ះ គឺបុរសនោះ រួចហើយក៏ដើរចូលទៅរក បានពោលដូច្នេះថា បពិត្រសមណៈ ខ្ញុំបាននាំធីតារបស់ខ្ញុំមកឲ្យលោក ដើម្បីជាប្រយោជន៍ដល់ការចិញ្ចឹមគ្នា ព្រះមានជោគមិនត្រាស់ថា តថាគតត្រូវការធីតារបស់អ្នក ឬក៏មិនត្រូវការ ទ្រង់បានត្រាស់ថា នែព្រាហ្មណ៍ តថាគតសូមត្រាស់ប្រាប់រឿងមួយដល់អ្នក កាលព្រាហ្មណ៍ពោលថា បពិត្រសមណៈ សូមត្រាស់ប្រាប់មកចុះ ។ ព្រះមានព្រះភាគ ទើប

ត្រាស់ដំណាលរឿង ដែលមារជាប់តាមព្រះអង្គតាំងអំពីស្តេចចេញសាង ព្រះផ្នួស រហូតដល់ព្រះអង្គគង់នៅក្រោមដើមអជ្ជបាលនិគ្រោធ ដោយ មានពពួកធីតារបស់មារមកល្បួងលួងលោម ដើម្បីរំងាប់នូវសេចក្តី សោករបស់មារនោះ អ្នកពោលពាលព្រោះសេចក្តីសោកថា ឥឡូវនេះ ព្រះសិទ្ធត្ថបានកន្លងផុតនូវនិស្ស័យរបស់យើងហើយ ដោយពួកធីតាមារ ទាំងនោះបាននិម្មិតនូវរូបនាងកុមារីជាច្រើន ដើម្បីល្បួងលួងលោម តថាគតជាដើម ព្រះពុទ្ធអង្គទ្រង់ត្រាស់ព្រះគាថាដូច្នេះថា

សេចក្តីប្រាថ្នាក្នុងមេថុនមិនមានដល់តថាគត ព្រោះឃើញនាង តណ្ហា នាងអរតី និងនាងរាគា ដែលជាធីតានៃមារសោះទៅហើយ ធ្វើ ដូចម្តេចឡើយ តថាគតនឹងមានសេចក្តីប្រាថ្នាក្នុងមេថុន ព្រោះឃើញរូប របស់ទារិកានៃអ្នក ដែលពោរពេញដោយមូត្រ និងករីសនេះ តថាគត មិនគួរត្រូវការដើម្បីប៉ះពាល់នូវធីតារបស់អ្នកនោះ សូម្បីតែដោយ ជើងឡើយ ។

ក្នុងពេលដែលព្រះសាស្តាត្រាស់ព្រះគាថានេះចប់ ព្រាហ្មណ៍

និងព្រាហ្មណីក៏បានតាំងនៅក្នុងអនាគាមិផល ។ចំណែកនាងមាគន្ទិយា ដែលជាធីតា បានចងគំនុំនឹងព្រះលោកនាថថា ប្រសិនបើព្រះសមណៈនេះ មិនត្រូវការយើង ក៏គួរពោលថា តថាគតមិនត្រូវការ ប៉ុន្តែសមណៈនេះ ត្រឡប់ទៅពោលថាឲ្យយើងថា ជាអ្នកពោរពេញដោយមូត្រ និងករីសទៅវិញ ណ្ហើយចុះ រឿងនោះលើកទុកសិនចុះ យើងអាស្រ័យការ ដល់ព្រម ដោយជាតិ ត្រកូល ភោគៈ យស និងវ័យ ដែលបានប្តី បែបនេះ ហើយយើងនឹងដឹងកម្មដែលយើងគួរធ្វើដល់សមណៈនេះ ។ សួរថា ព្រះសាស្តា ទ្រង់ជ្រាបនូវការកើតឡើងនៃអាឃាតចំពោះព្រះអង្គ ជាមួយនឹងនាងមាគន្ទិយាឬ ? ឬក៏ទ្រង់មិនជ្រាប ? ឆ្លើយថា ព្រះភគវា ព្រះអង្គទ្រង់ជ្រាបច្បាស់ណាស់ ។ សួរថា កាលព្រះអង្គទ្រង់ជ្រាបទៅ ហើយ ហេតុអ្វីទើបទ្រង់ត្រាស់ព្រះគាថានេះទៀត ? ឆ្លើយថា ព្រះអង្គទ្រង់ ត្រាស់ព្រះគាថានេះ ដើម្បីជាប្រយោជន៍ដល់ព្រាហ្មណ៍ និងនាងព្រាហ្មណី ទាំងពីរនាក់ប៉ុណ្ណោះ ។ ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មិនបានអើពើ ដល់អាឃាតទេ ទ្រង់បានសម្តែងព្រះធម៌ចំពោះបុគ្គល ដែលគួរបាន

សម្រេចមគ្គផលតែប៉ុណ្ណោះ ។ ព្រាហ្មណ៍ និងព្រាហ្មណី បាននាំនាងមាគន្ទិយានោះ ទៅផ្ញើនឹងចុល្លមាគន្ទិយៈដែលជាប្អូន ហើយខ្លួនឯងទាំងពីរនាក់បានទៅកាន់សម្នាក់ព្រះមហាវីរៈ ដើម្បីបួស កាលបួសហើយមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ។ ចំណែកចុល្លមាគន្ទិយៈបានគិតដូច្នេះថា ធីតារបស់យើងមិនសមគួរដល់បុគ្គលថោកទាបទេ គឺសមគួរដល់ព្រះរាជាតែមួយព្រះអង្គប៉ុណ្ណោះ ទើបនាំនាងទៅកាន់ក្រុងកោសម្ពី បានតាក់តែងដោយគ្រឿងអលង្ការទាំងពួង ហើយបានចូលទៅថ្វាយបង្គំព្រះបាទឧទេន ថែមទាំងពោលពាក្យថា ស្រីកែវនេះជារបស់សមគួរដល់មហាបពិត្រ ព្រះបាទឧទេនគ្រាន់តែឃើញនាងមាគន្ទិយានោះភ្លាម ក៏ទ្រង់កើតសេចក្តីប្រតិព័ទ្ធយ៉ាងខ្លាំងភ្លាមដែរ ទើបទ្រង់ប្រទាននូវការអភិសេក ថែមទាំងទ្រង់ធ្វើនូវស្រ្តី ៥០០ នាក់ឲ្យជាបរិវាររបស់នាងមាគន្ទិយានោះ ដោយទ្រង់តាំងនាងទុកក្នុងតំណែងជាអគ្គមហេសី ។ សរុបសេចក្តី ព្រះបាទឧទេននេះ មានអគ្គមហេសី ៣ ដែលមានស្រ្តី ១៥០០ នាក់ជាបរិវារ ។

ក្នុងសម័យនោះឯង នៅក្នុងក្រុងកោសម្ពី មានសេដ្ឋី ៣ នាក់ គឺឃោសកសេដ្ឋី ១ កុក្កុដសេដ្ឋី ១ បវារិកសេដ្ឋី ១ ។ សេដ្ឋីទាំង ៣ នាក់នេះ កាលវស្សូបនាយិកាជិតចូលមកដល់ហើយ បានឃើញតាបស ៥០០ រូប មកអំពីព្រៃហិមពាន្ត កំពុងតែត្រាច់ទៅដើម្បីភិក្ខានៅក្នុងក្រុង ក៏កើតមានសេចក្តីជ្រះថ្លា បាននិមន្តឲ្យគង់ឆាន់ហើយ ថែមទាំងបាន អារាធនាតាបសទាំងនោះ ឲ្យស្នាក់នៅក្នុងសម្នាក់របស់ខ្លួន រហូតអស់ ៤ ខែ បានញ៉ាំងតាបសទាំងនោះ ឲ្យប្តេជ្ញាដើម្បីជាប្រយោជន៍ដល់ការ មកទៀតក្នុងកាលដែលភូមិភាគជោកជាំដោយទឹកភ្លៀងហើយតាបស ទាំងនោះបានទៅកាន់ព្រៃហិមពាន្តវិញ ចាប់តាំងពីកាលនោះមក តាបស ទាំងនោះនៅក្នុងព្រៃហិមពាន្តអស់ ៨ ខែ នៅក្នុងសម្នាក់របស់លោក សេដ្ឋីទាំង ៣ នាក់ អស់ ៤ ខែ ។ តាបសទាំងនោះ កាលមកអំពី ព្រៃហិមពាន្ត ក្នុងពេលដទៃមួយ បានឃើញដើមជ្រៃធំមួយដើម ដែល នៅជិតព្រៃ ឬជាយព្រៃ ក៏គង់នៅក្បែរគល់ដើមជ្រៃធំនោះ ។ បណ្តា តាបសទាំងនោះ តាបសដែលជាប្រធានគេ ក៏គិតដូច្នេះថា ទេវតាដែល

អាស្រ័យនៅនាដើមឈើនេះ មិនមែនជាទេវតាតូចទាបទេ ដោយពិត ជាទេវតាមានស័ក្តធំ ដែលនៅដើមឈើនេះ ប្រសិនបើទេវតានេះ បានឲ្យ ទឹកផឹកដល់ពួកឥសី មិនដឹងថាជាការល្អ យ៉ាងណាទៅហ្ន៎ ទេវតានោះ ក៏បានថ្វាយទឹកផឹកដល់ពួកឥសីទាំងនោះ ទៅតាមការគិតរកទឹកផឹក របស់តាបសនោះមែន ។ ដោយបានប្រគេនទឹកសម្រាប់ស្រង់ដល់តាបស ទាំងនោះទៀតផង ។ គ្រានោះ តាបសដែលជាប្រធាន ក៏បានគិតដល់ អាហារទៀត ទេវតាក៏បានប្រគេនអាហារទៀតមែន ។ លំដាប់នោះ តាបសបានតម្រិះដូច្នេះទៀតថា ទេវតានេះបានឲ្យនូវវត្ថុគ្រប់យ៉ាងដែល យើងគិតហើយៗ អើហ្ន៎ យើងគប្បីបានឃើញទេវតានេះ ទេវតានោះ ក៏បានសម្តែងខ្លួនប្រាកដឲ្យដល់តាបសទាំងនោះឃើញទៀត ។ ពេលនោះ តាបសទាំងនោះសួរទេវតានោះថា បពិត្រទេវតា អ្នកមានសម្បត្តិធំ សម្បត្តិនេះ អ្នកបានហើយដោយអាស្រ័យកម្មអ្វី ? កាលពីមុនអ្នកបាន ធ្វើកម្មអ្វីទុក ទើបបានជាអ្នកបានសម្បត្តិបែបនេះ ? ទេវតាតបថា បពិត្រ លោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយ កុំសាកសួរខ្ញុំម្ចាស់

ធ្វើអ្វីក្នុងរឿងនេះ ។ តាបសបានពោលតទៅទៀតថា បពិត្រទេវតា សូមអ្នកប្រាប់មកចុះ ទេវតានោះមានការអៀនខ្មាសមិនហ៊ានពោល ប្រាប់ ព្រោះកម្មដែលខ្លួនធ្វើហើយនោះ ជាកម្មបន្តិចបន្តួច ប៉ុន្តែកាល ត្រូវតាបសទាំងនោះ ជជីកសួរជារឿយៗ ក៏ពោលថា បើដូច្នោះ សូម លោកម្ចាស់ទាំងឡាយ ស្តាប់ចុះ ខ្ញុំម្ចាស់នឹងពោលប្រាប់ ។ បានឮមកថា ទេវតានេះជាមនុស្សក្រម្នាក់ ជាអ្នកស្វែងរកការងារធ្វើដើម្បីចិញ្ចឹមជីវិត ហើយ បានធ្វើការងារនៅក្នុងសម្នាក់អនាថបិណ្ឌិកសេដ្ឋី ក៏អាស្រ័យ ការងារនោះចិញ្ចឹមជីវិតទៅ ។ ខាងក្រោយមក ថ្ងៃមួយ កាលដល់ថ្ងៃ ឧបោសថ អនាថបិណ្ឌិកសេដ្ឋីមកអំពីវិហារហើយ សួរថា ថ្ងៃនេះមាន អ្នកណាៗ បានប្រាប់ដល់បុរសដែលជាអ្នកធ្វើការងារស៊ីឈ្នួលនោះថា ថ្ងៃនេះ ជាថ្ងៃឧបោសថដែរឬទេ ? មនុស្សដែលនៅក្នុងផ្ទះនោះឆ្លើយថា បពិត្រលោកម្ចាស់ មិនទាន់មានអ្នកណាមួយប្រាប់ទេ អនាថបិណ្ឌិក ពោលដូច្នេះថា បើដូច្នោះ ពួកអ្នកឯង ចូរចម្អិននូវអាហារល្ងាចទុក សម្រាប់គេចុះ ។ គ្រានោះ ជនទាំងនោះក៏បាននាំគ្នាដាំបាយដោយអង្ករ

មួយនាឡិ ដើម្បីឲ្យបុរសអ្នកធ្វើការងារស៊ីឈ្នួលនោះ ។ បុរសនោះ បានធ្វើការងាររហូតដល់វេលាល្ងាច ក៏បានត្រឡប់មកផ្ទះវិញ ក្នុងពេលដែលគេជួសបាយឲ្យបុរសនោះៗ ក៏មិនទាន់បរិភោគភ្លាមទេ ដោយគិតថា ក្នុងថ្ងៃមុនៗ ភាពជ្រួលប្របល់មាននៅក្នុងផ្ទះនេះថា សូមលោកឲ្យបាយឲ្យសម្ល សូមលោកឲ្យម្ហូបជាដើម ប៉ុន្តែក្នុងថ្ងៃនេះ ជនដ៏សេសក៏ជាអ្នកមានសំឡេងស្ងប់ស្ងៀម ដេកលក់ទៅហើយ បានជួសបាយរៀបចំទុកសម្រាប់យើងតែម្នាក់ប៉ុណ្ណោះ តើមានហេតុអ្វីទៅហ្ន៎ ទើបសួរថា អ្នកទាំងឡាយបរិភោគអាហារហើយឬនៅ ? ជនទាំងនោះឆ្លើយថា នែអ្នកថ្ងៃនេះគេទាំងអស់គ្នាមិនបានបរិភោគអាហារក្នុងពេលល្ងាចទេ ។ បុរសនោះសួរទៀតថា ព្រោះហេតុអ្វី ? ជនទាំងនោះឆ្លើយថា ក្នុងផ្ទះនេះគេមិនបានបរិភោគអាហារក្នុងពេលល្ងាចទេ ព្រោះជាថ្ងៃឧបោសថ ដោយពួកយើងទាំងអស់គ្នាបានរក្សាឧបោសថ ដោយហោចទៅសូម្បីទារកដែលនៅបៅដោះជាប្រក្រតី លោកអនាថបិណ្ឌិកសេដ្ឋីឲ្យទារកនោះខ្ពុរមាត់ហើយ ប្រើបម្រើឲ្យដាក់វត្ថុមានរសផ្អែម ៤ មុខទៅក្នុងមាត់

ឲ្យរក្សាឧបោសថ ហើយកាលប្រទីបដែលបុគ្គលអុជហើយ ដោយប្រេងមានក្លិនក្រអូប បំភ្លឺទារកតូចធំទាំងអស់ នៅកន្លែងដេកហើយ បាននាំគ្នាស្វាធ្យាយអាការ ៣២ ប្រការ ប៉ុន្តែថា ពួកយើងមិនបានប្រាប់ដល់លោកថា ថ្ងៃនេះ ជាថ្ងៃឧបោសថ ព្រោះហេតុនោះ ទើបពួកយើងនាំគ្នាចម្អិនអាហារទុកសម្រាប់ឲ្យអ្នកតែម្នាក់ឯង ដូច្នេះ ចូរអ្នកទទួលទានចុះ ។ បុរសនោះ បានសួរថា ប្រសិនបើខ្ញុំរក្សាឧបោសថ ក្នុងកាលឥឡូវនេះ សមគួរឬទេ ? បើសមគួរ ខ្ញុំនឹងរក្សាឧបោសថដែរ ។ ជនទាំងនោះឆ្លើយថា ក្នុងសេចក្តីនេះ មានតែលោកអនាថបិណ្ឌិកសេដ្ឋីទេ ទើបអាចជ្រាបរឿងនេះបាន ។ បុរសនោះបានពោលថា បើដូច្នោះ សូមពួកអ្នកសួរសេចក្តីនេះ ចំពោះលោកនាយឲ្យខ្ញុំផង ។ ជនទាំងនោះ ក៏បានទៅសួរអនាថបិណ្ឌិកសេដ្ឋី ហើយអនាថបិណ្ឌិកសេដ្ឋីក៏ពោលយ៉ាងនេះថា បានទេតើ បើដូច្នោះ ចូរឲ្យបុរសនោះខ្ពុរមាត់ ហើយអធិដ្ឋានអង្គឧបោសថទៅ បានរក្សាឧបោសថពាក់កណ្តាលថ្ងៃដែរ ។ ចំណែកបុរសនោះ បានជ្រាបដូច្នេះហើយ បានធ្វើតាមការប្រាប់របស់អនាថបិណ្ឌិក

សេដ្ឋីមែន ។ កាលគេស្រេកឃ្លានខ្លាំង ព្រោះធ្វើការ រហូតអស់មួយថ្ងៃ ខ្យល់ក៏កម្រើកឡើង ក្នុងសរីរៈរបស់គេៗ បានយកខ្សែចងពោះ ចាប់ត្រង់ចុងខ្សែបម្រះនទៀលទៅមក ។ អនាថបិណ្ឌិកសេដ្ឋីបានជ្រាបព្រឹត្តិការណ៍ដូច្នេះហើយ បានប្រើអ្នកបម្រើឲ្យយកវត្ថុមានរសផ្អែម ៤ មុខ ទៅកាន់សម្នាក់បុរសនោះជាមួយលោក ហើយសួរថា នែអ្នកដ៏ចម្រើន អ្នកកើតអ្វី ? បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្យល់កម្រើកឡើងដល់ខ្ញុំ ។ លោកសេដ្ឋីបានពោលថា បើដូច្នោះ អ្នកឯង ចូរក្រោកឡើងផឹកនូវភេសជ្ជៈនេះចុះ ។ បុរសនោះសួរថា បពិត្រលោកនាយបុគ្គលដទៃគេទទួលទានហើយឬនៅ ? លោកសេដ្ឋីឆ្លើយថា មិនអីទេ គេអត់មានកើតអីទេ ចូរអ្នកផឹកទៅចុះ ។ បុរសនោះពោលថា បពិត្រលោកសេដ្ឋីកាលខ្ញុំរក្សាឧបោសថ មិនបានរក្សាឲ្យបានពេញមួយថ្ងៃ គឺបានត្រឹមតែពាក់កណ្ដាលថ្ងៃប៉ុណ្ណោះ ហេតុដូច្នេះ ខ្ញុំមិនផឹកនូវភេសជ្ជៈនេះទេ ។ បុរសនោះសូម្បីលោកសេដ្ឋីពោលថា នែអ្នកដ៏ចម្រើន អ្នកកុំធ្វើយ៉ាងនេះឡើយ សូម្បីលោកសេដ្ឋីពោលយ៉ាងនេះក៏ដោយ បុរសនោះក៏នៅតែមិនព្រម

ធ្វើតាម លុះដល់អរុណរះឡើង ក៏បានធ្វើកាលកិរិយាទៅ ហើយក៏បានទៅកើតជាទេវតានៅដើមជ្រៃនោះ ៗ ព្រោះហេតុនោះ ទេវតានោះ កាលបើបានពោលដូច្នេះហើយ ក៏បានពោលទៀតថា លោកសេដ្ឋីនោះជាអ្នករាប់អានព្រះពុទ្ធថា ជារបស់យើង រាប់អានព្រះធម៌ថា ជារបស់យើង រាប់អានព្រះសង្ឃថា ជារបស់យើង សម្បត្តិនេះខ្ញុំបានមកហើយដោយផល ដែលកើតមកអំពីកម្ម គឺការរក្សាឧបោសថ បានពាក់កណ្តាលថ្ងៃ ដែលខ្ញុំបានអាស្រ័យនឹងលោកសេដ្ឋីនោះជាអ្នកជួយខ្ញុំ ៗតាបស ៥០០ រូប កាលបានស្តាប់ពាក្យថា ព្រះពុទ្ធភ្លាម ក៏ក្រោកឡើងផ្គងនូវអញ្ជលីចំពោះទេវតា បានពោលថា លោកនិយាយថា ព្រះពុទ្ធដូច្នេះឬ ? រហូតសួរបញ្ជាក់ដល់ទេវតានោះ ៣ ដង ហើយទេវតានោះឆ្លើយថា ខ្ញុំបាននិយាយថាព្រះពុទ្ធមែន ហើយក៏បានបន្លឺឡើងនូវឧទានថា ពាក្យថាព្រះពុទ្ធនេះមិនងាយកើតមាននៅក្នុងលោកទេ គឺបុគ្គលរកបានដោយកម្រនៅក្នុងលោក ហើយពោលថា បពិត្រទេវតា ពួកយើងជាអ្នកដែលលោកឲ្យបានស្តាប់ឮនូវសំឡេង ដែលមិនធ្លាប់បានស្តាប់ឮមក ហើយ

អស់កាលជាសែនកប្ប ។ គ្រានោះតាបសដែលជាអន្តេវាសិកបានពោល ពាក្យនឹងអាចារ្យថា បើដូច្នោះ ពួកយើងនាំគ្នាទៅគាល់ព្រះសាស្តាចុះ អាចារ្យបានពោលថា នែអ្នកទាំងឡាយ សេដ្ឋី ៣ នាក់ ជាអ្នកមាន ឧបការៈច្រើនដល់យើង ថ្ងៃស្អែកនេះ ពួកយើងទទួលភិក្ខានៅក្នុងលំនៅ របស់សេដ្ឋីទាំងនោះ ដោយប្រាប់លាសេដ្ឋីទាំងនោះហើយ ចាំនាំគ្នាទៅ នែអ្នកទាំងឡាយ អ្នកទាំងឡាយចូរនាំគ្នាបង្អង់សិនចុះ តាបសដែលជា អន្តេវាសិកទាំងនោះ ក៏នាំគ្នាបង្អង់ទៅតាមពាក្យរបស់អាចារ្យ ។ លុះ ដល់ថ្ងៃស្អែកឡើង សេដ្ឋីទាំង ៣នាក់ បានត្រៀមនូវយាគូ និងភត្តហើយ ក្រាលអាសនៈទុក ដឹងថា ថ្ងៃនេះ លោកម្ចាស់ទាំងឡាយរបស់យើងមក ពេលដែលតាបសទាំងនោះមកដល់ ក៏បានធ្វើការក្រោកទទួល តាបស ទាំងនោះ ហើយបាននាំទៅកាន់លំនៅ និមន្តឲ្យគង់លើអាសនៈ រួចក៏ បានប្រគេនភិក្ខាដល់តាបសទាំងនោះ តាបសទាំងនោះ ធ្វើភត្តកិច្ចរួច ស្រេចហើយ បានពោលថា នែសេដ្ឋីដ៏ចម្រើនទាំងឡាយ ពួកយើងសូម លាអ្នកទៅសិនហើយ ។ សេដ្ឋីទាំងនោះសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន

ទាំងឡាយ លោកម្ចាស់ទាំងឡាយ បានប្តេជ្ញាជាមួយខ្ញុំម្ចាស់ទាំងឡាយថា នឹងនៅទីនេះ រហូតអស់ ៤ ខែ មិនមែនឬ ? ឥឡូវនេះ លោកម្ចាស់ទាំងឡាយទៅណាវិញ ? តាបសទាំងនោះ បានពោលឡើងថា ឥឡូវនេះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានកើតឡើងហើយក្នុងលោក ព្រោះហេតុនេះ បានជាយើងទាំងឡាយនាំគ្នាទៅគាល់ព្រះមានជោគ ។ សេដ្ឋីទាំងនោះ ក៏បានសួរថា តើការទៅគាល់ព្រះមុនីអង្គនោះ សមគួរដល់លោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ ? តាបសទាំងនោះឆ្លើយថា នែអ្នកដ៏ចម្រើន សូម្បីជនពួកដទៃក៏អាចទៅគាល់បានដែរ មិនមានហាម ។ សេដ្ឋីទាំងនោះបានពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយរង់ចាំពួកខ្ញុំបន្តិចសិន ពួកខ្ញុំម្ចាស់ទាំងឡាយនឹងរៀបចំស្បៀងរួចហើយ នឹងទៅជាមួយលោកម្ចាស់ទាំងឡាយដែរ ។ គ្រានោះ តាបសទាំងនោះពោលថា នែអ្នកទាំងឡាយ ការរៀបចំស្បៀងធ្វើដំណើរទៅយឺតយូរណាស់ ដូច្នេះ ពួកយើងទៅមុន ចូរពួកអ្នកទាំងឡាយទៅតាមក្រោយចុះ កាលពោលដូច្នេះហើយ ពួកតាបស

ទាំងនោះ ក៏បាននាំគ្នាទៅគាល់ព្រះពុទ្ធមុន លុះទៅដល់ហើយ ក៏បានចូលទៅថ្វាយបង្គំព្រះសាស្តា រួចក៏នាំគ្នាអង្គុយនៅក្នុងទីដ៏សមគួរ ។

គ្រានោះ កាលតាបសទាំងនោះ អង្គុយនៅក្នុងទីដ៏សមគួររួចហើយ ព្រះពុទ្ធអង្គទ្រង់ត្រាស់អនុបុព្វីកថា សម្តែងប្រោសដល់តាបសទាំងនោះ ។ ក្នុងកាលជាទីបំផុតនៃទេសនានោះ តាបសទាំង ៥០០ រូបនោះក៏បានសម្រេចព្រះអរហត្តផល មួយអន្លើដោយបដិសម្ភិទា ហើយទូលសូមបព្វជ្ជា ។ ព្រះសម្ពុទ្ធក៏ទ្រង់អនុញ្ញាតឲ្យសាងបព្វជ្ជាឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា គឺព្រះភគវាត្រាស់ថា អ្នកចូរមកជាភិក្ខុចុះ ។

សេដ្ឋីទាំង ៣ នាក់នោះ បានចាត់ចែងរៀបចំរទេះ ៥០០ ផ្ទុកដោយគ្រឿងឧបករណ៍នៃទាន មានសំពត់ស្បៀកដណ្តប់ ទឹកដោះថ្លា ទឹកឃ្មុំ និងទឹកអំពៅជាដើម កាលទៅដល់ក្រុងសាវត្ថីហើយ បាននាំគ្នាចូលទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះមហាមុនី ព្រះពុទ្ធអង្គទ្រង់ក៏បានសម្តែងនូវធម្មកថា ក្នុងទីបំផុតនៃធម្មកថានោះ សេដ្ឋីទាំងនោះក៏បានតាំងនៅក្នុងសោតាបត្តិផល រួចក៏បាននាំគ្នាថ្វាយទាននៅក្នុងសម្នាក់របស់ព្រះសាស្តា

អស់កន្ទះខែ ហើយទូលអារាធនាព្រះមានជោគ ដើម្បីឲ្យស្ដេចយាងទៅកាន់ក្រុងកោសម្ពី ជាប្រយោជន៍ដល់វេនេយ្យសត្វ ។ កាលព្រះជិនស្រីទ្រង់ប្រទានការប្ដេជ្ញា ទើបត្រាស់ថា នែគហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ តែងតែត្រេកអរនៅក្នុងទីកន្លែងដ៏ស្ងប់ស្ងាត់ ។ សេដ្ឋីទាំងនោះទើបនាំគ្នាពោលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីនេះពួកខ្ញុំព្រះអង្គយល់ហើយ ។ កាលពោលដូច្នេះហើយ ក៏បាននាំគ្នាទៅកាន់ក្រុងកោសម្ពីវិញ ដោយឲ្យជាងកសាងវិហារ ៣ គឺឃោសកសេដ្ឋីឲ្យកសាងឃោសិតារាម កុក្កុដសេដ្ឋីឲ្យកសាងកុក្កុដារាម បាវារិកសេដ្ឋីឲ្យកសាងបាវារិការាម ហើយបានបញ្ជូនដំណឹងទៅថ្វាយដល់ព្រះសក្យមុនី ដើម្បីឲ្យព្រះអង្គយាងមក ។ ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវដំណឹងរបស់សេដ្ឋីទាំងនោះ ដែលបានបញ្ជូនមក ហើយក៏ស្ដេចយាងទៅកាន់ទីនោះ ។ សេដ្ឋីទាំងនោះ បានក្រាបទូលអារាធនានិមន្តព្រះមុនីឲ្យស្ដេចចូលទៅខាងក្នុងវិហារហើយ បានវេរថ្វាយថា ខ្ញុំព្រះករុណាសូមវេរថ្វាយវិហារនេះដល់ភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ។

ព្រះមានជោគ ពេលដែលព្រះអង្គគង់នៅក្នុងវិហារនីមួយៗ មួយថ្ងៃ ទ្រង់គង់នៅក្នុងវិហាររបស់សេដ្ឋីណា ព្រះពុទ្ធអង្គទ្រង់ក៏បានត្រាច់ទៅបិណ្ឌបាតនៅផ្ទះរបស់សេដ្ឋីនោះឯង ។សេដ្ឋីទាំង ៣ នាក់នោះ មាននាយមាលាការ ឈ្មោះសុមនៈជាអ្នកឧបដ្ឋាក បានពោលនឹងសេដ្ឋីទាំងនោះយ៉ាងនេះថាខ្ញុំជាអ្នកធ្វើការបម្រើលោកទាំងឡាយមកអស់កាលដ៏យូរហើយ ហេតុដូច្នេះខ្ញុំសូមអារាធនាឲ្យព្រះសាស្ដាទ្រង់ទទួលចង្ហាន់របស់ខ្ញុំមួយថ្ងៃ ។ សេដ្ឋីទាំង ៣ នាក់នោះ បានពោលថា នែអ្នកដ៏ចម្រើន បើដូច្នោះ លោកចូរនិមន្តព្រះសម្ពុទ្ធ ឲ្យព្រះអង្គទទួលចង្ហាន់ក្នុងថ្ងៃស្អែកចុះ ។ ពេលនោះ នាយសុមនមាលាការទទួលពាក្យថា ល្អហើយនាយរួចក៏បានទៅនិមន្តព្រះសាស្ដាកាលបើដឹងថាព្រះបរមគ្រូទ្រង់ទទួលនិមន្តហើយ ក៏បានត្រូវត្រៀមគ្រឿងសក្ការៈទុក ដើម្បីបូជាចំពោះព្រះមុនី ។ ក្នុងកាលនោះ ព្រះឧទេនបានព្រះរាជទាន ៨ កហាបណៈឲ្យជាតម្លៃផ្កាដល់នាងសាមាវតី ជារៀងរាល់ថ្ងៃ ។ទាសីរបស់នាងសាមាវតី ឈ្មោះនាងខុជ្ជុត្តរា បានទៅកាន់សម្នាក់របស់នាយសុមនមាលាការ ទទួលទិញ

យកផ្កាមកជានិច្ច ។ ខាងក្រោយមក ក្នុងថ្ងៃមួយ នាយមាលាការបាន ពោលនឹងនាងខុជ្ជុត្តរា ដែលជាអ្នកមកក្នុងថ្ងៃនោះថា ថ្ងៃនេះ ខ្ញុំរវល់ ណាស់ ព្រោះខ្ញុំបាននិមន្តព្រះសាស្តាដើម្បីទទួលចង្ហាន់ នឹងបានបូជា ព្រះលោកនាយកដោយផ្កាដ៏ប្រសើរ ហេតុដូច្នេះ ចូរនាងរង់ចាំស្តាប់ ព្រះធម៌សិនហើយ សឹមទទួលយកផ្កាទៅ ។ នាងខុជ្ជុត្តរាទទួលថា ចាំះ បាន ។ នាយសុមនះបានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន លុះត្រាតែព្រះអង្គលែងលូកព្រះហស្តទៅក្នុងបាត្រ ព្រះលោកនាយក ព្រះអង្គក៏ទ្រង់ប្រារព្ធព្រះធម្មទេសនា ជាគ្រឿងអនុមោទនាហើយ ។ ចំណែកនាងខុជ្ជុត្តរាបានស្តាប់ធម្មកថា របស់ព្រះមហាវីរបុរសហើយ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃមុនៗ នាងបានកាន់យក កហាបណៈ ៤ កហាបណៈ ទុកសម្រាប់ខ្លួនទិញផ្កាតែ ៤ កហាបណៈ ប៉ុណ្ណោះ ។ក្នុងថ្ងៃនោះ នាងបានទិញផ្កាទាំង ៨ កហាបណៈ ។គ្រានោះ នាងសាមាវតី បានសួរចំពោះនាងខុជ្ជុត្តរានោះថា នែនាងដ៏ចម្រើន ព្រះរាជាព្រះរាជទានតម្លៃផ្កាដល់យើងជាទ្វេគុណឬ ? នាងខុជ្ជុត្តរាតបថា

បពិត្រនាងម្ចាស់ មិនមែនទេ ។ នាងសាមាវតីសួរទៀតថា កាលបើដូច្នេះ ព្រោះហេតុអ្វីបានជាមានផ្កាច្រើនយ៉ាងនេះ ? ពេលនោះ នាងខុជ្ជុត្តរាបាននិយាយប្រាប់ថា ថ្ងៃមុនៗ ខ្ញុំបានកាន់យក ៤ កហាបណៈទុកសម្រាប់ខ្លួន ទិញផ្កាតែ ៤ កហាបណៈប៉ុណ្ណោះ ។ នាងសាមាវតីបាននិយាយទៀតថា ព្រោះហេតុអ្វី ក្នុងថ្ងៃនេះនាងមិនកាន់យកដូច្នោះទៀត ? នាងខុជ្ជុត្តរាប្រាប់ថា ព្រោះការដែលខ្ញុំម្ចាស់បានស្តាប់ធម្មកថារបស់ព្រះមហាវីរៈ ហើយបានសម្រេចគុណធម៌ ទើបជាហេតុធ្វើឲ្យខ្ញុំមិនអាចកាន់កហាបណៈទាំងនោះដូចមុនទៀត ។

គ្រានោះ ព្រះនាងសាមាវតី មិនបានពោលគំរាមដល់នាងខុជ្ជុត្តរានោះថា នែមេទាសីកំណាច ហឯងចូរឲ្យកហាបណៈ ដែលហឯងកាន់យកទៅហើយអស់ប៉ុន្មានណាឲ្យអញវិញ ព្រះនាងត្រឡប់ជាពោលថា នែនាងដ៏ចម្រើន នាងចូរញ៉ាំងយើងទាំងឡាយ ឲ្យបានផឹកនូវទឹកអម្រឹតដូចនាងបានផឹកហើយដែរផង ។ ពេលនោះ នាងខុជ្ជុត្តរាពោលថា បើដូច្នោះ សូមព្រះនាងម្ចាស់ឲ្យខ្ញុំបានងូតទឹកជម្រះកាយឲ្យស្អាតសិន ។

ព្រះនាងសាមាវតី ក៏បានឲ្យនាងខុជ្ជុត្តរាងូតទឹកដោយទឹកក្រអូប ១៦ ក្អម ហើយបញ្ជាឲ្យប្រទានសំពត់សាជក សាច់ម៉ដ្តពីរផ្ទាំងដល់នាង ។ នាងខុជ្ជុត្តរានោះ បានស្លៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ប្រើគេឲ្យក្រាលអាសនៈហើយ ឲ្យនាំផ្ចិតមួយមក អង្គុយលើអាសនៈ ចាប់ផ្ចិតដ៏វិចិត្រ ហៅស្ត្រី ៥០០ នាក់មកហើយ សម្តែងធម៌ឲ្យស្ត្រីទាំងនោះបានស្តាប់ តាមន័យដែលព្រះមានជោគ ទ្រង់សម្តែងហើយនោះឯង ។ ស្ត្រីទាំងអស់នោះ កាលបានស្តាប់ធម្មកថា របស់នាងខុជ្ជុត្តរាចប់ហើយ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ស្ត្រីទាំងនោះក៏បាននាំគ្នាថ្វាយបង្គំនាងខុជ្ជុត្តរា ថែមទាំងពោលថា នែនាងដ៏ចម្រើន ចាប់តាំងពីថ្ងៃនេះតទៅ នាងកុំធ្វើការងារតទៅទៀតឡើយ នាងចូរតាំងនៅក្នុងឋានៈជាមាតា និងអាចារ្យរបស់ពួកយើងទាំងឡាយ ហើយនាងចូលទៅគាល់ព្រះសាស្តា ស្តាប់ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ មកសម្តែងឲ្យពួកយើងបានស្តាប់ផងដែរ ។ ក្នុងកាលជាខាងក្រោយមក ដោយនាងខុជ្ជុត្តរាបានតាំងនៅក្នុងសភាពបែបហ្នឹង គឺទៅស្តាប់ព្រះធម៌ជារឿយៗ

នោះ រហូតធ្វើឲ្យនាងជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ។ ព្រះបរមសាស្តា ទ្រង់ប្រកាសតែងតាំងនាងខុជ្ជុត្តរាក្នុងតំណែងជាឯតទគ្គៈថាម្នាលភិក្ខុទាំងឡាយ នាងខុជ្ជុត្តរាជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ដែលជាឧបាសិការបស់តថាគត ផ្នែកខាងពហុសូត ឬក៏សម្តែងព្រះធម៌ផងដែរ ។ ស្ត្រីទាំង ៥០០ នាក់ នោះឯង បានពោលនឹងនាងខុជ្ជុត្តរាយ៉ាងនេះថា នែនាងដ៏ចម្រើន ពួកយើងទាំងឡាយប្រាថ្នានឹងចូលទៅគាល់ព្រះភគវា សូមនាងនាំពួកខ្ញុំទាំងឡាយចូលទៅគាល់ព្រះអង្គ ដើម្បីបានជួបព្រះសាស្តា ពួកខ្ញុំនឹងបូជាព្រះសម្ពុទ្ធដោយគ្រឿងសក្ការៈទាំងឡាយមានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ។ នាងខុជ្ជុត្តរាបានពោលថាបពិត្រពួកនាងទាំងឡាយដ៏ចម្រើន ដែលឈ្មោះថា ព្រះរាជត្រកូលជារឿងលំបាក ខ្ញុំមិនអាចដើម្បីនឹងនាំពួកនាងទៅក្រៅបានទេ ។ ស្ត្រីទាំងនោះ បានពោលអង្វរទៀតថា នែនាងដ៏ចម្រើន នាងកុំធ្វើឲ្យពួកយើងវិនាសប្រយោជន៍ឡើយ សូមនាងនាំពួកខ្ញុំទាំងឡាយទៅផងចុះ ដើម្បីបានឃើញព្រះអង្គ ។ នាងខុជ្ជុត្តរា កាលបើពោលដូច្នេះហើយ

ទើបពោលណែនាំថា បើពួកនាងទាំងអស់គ្នានេះ ចង់ឃើញព្រះមុនី ហើយដែលអាចមើលឃើញព្រះភគវាបាន ដោយប្រហោងមានប្រមាណប៉ុនណា ចូរពួកនាងទាំងអស់គ្នា ចោះនូវប្រហោងជញ្ជាំងមានប្រមាណប៉ុណ្ណោះចុះ ដែលជាទីលំនៅរបស់ពួកនាងទាំងឡាយ ចូរបញ្ជាឲ្យគេនាំគ្រឿងក្រអូប និងកម្រងផ្កាជាដើមមក ហើយឈរក្នុងទីនោះៗ ចូរចាំក្រឡេកមើល ចូរលើកដៃទាំងពីរថ្វាយបង្គំ និងចូរបូជាព្រះតថាគតនៅទីនោះ ដែលស្តេចយាងចូលកាត់ទៅកាន់ផ្ទះរបស់សេដ្ឋីទាំងបីនោះចុះ ។ ស្ត្រីទាំងនោះ ក៏បាននាំគ្នាធ្វើតាមយ៉ាងនោះ បានក្រឡេកមើលព្រះភគវា ដែលស្តេចយាងទៅ និងយាងមកថ្វាយបង្គំ និងបូជាហើយ ។ ថ្ងៃមួយ ព្រះនាងមាគន្ទិយាចេញអំពីប្រាសាទរបស់ខ្លួន ធ្វើដំណើរទៅកាន់លំនៅរបស់ស្ត្រីទាំងនោះ ហើយបានឃើញប្រហោង ក្នុងបន្ទប់ទាំងឡាយនោះ បានសួរថា នេះប្រហោងអ្វី ? កាលស្ត្រីទាំងនោះមិនបានដឹងថា ព្រះនាងមាគន្ទិយានេះ ចងគំនុំជាមួយនឹងព្រះសាស្តា ទើបនាំគ្នាក្រាបបង្គំទូលតាមត្រង់ថា ដើម្បីនាំគ្នាមើលព្រះលោកនាថ

ស្តេចយាងចូលកាត់ទីនេះ ហេតុដូច្នេះ បានជាពួកយើងទាំងអស់គ្នា នាំគ្នាចោះនូវប្រហោងនេះ ដើម្បីបានឃើញ ឬបានថ្វាយបង្គំ និងបូជាព្រះសាស្តានៅក្នុងទីនេះ ។ ដោយញ៉ាំងសេចក្តីជ្រះថ្លា ក្នុងពេលដែលបានឃើញព្រះអង្គយាងមកនោះ កាលបើពោលដូច្នេះហើយ ព្រះនាងមាគន្ទិយាទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកស្រីទាំងនោះ ទ្រង់ត្រិះរិះដោយព្រះទ័យ ដែលព្រះនាងមានគំនុំថា ព្រះសមណគោតមបានមកដល់នគរនេះហើយ ឥឡូវនេះ យើងនឹងដឹងនូវអំពើដែលគួរធ្វើដល់ព្រះសមណគោតមនោះ សូម្បីស្ត្រីទាំងនេះ ក៏ជាអ្នកឧបដ្ឋាយិការបស់ព្រះសមណគោតមនោះដែរ យើងនឹងដឹងនូវអំពើដែលគួរគប្បីធ្វើដល់ស្ត្រីទាំងនេះផងដែរ កាលព្រះនាងគិតឃើញដូច្នេះហើយ ទើបទៅក្រាបទូលដល់ព្រះបាទឧទេនថា បពិត្រមហារាជ ស្ត្រីទាំង ៥០០ នាក់ព្រមទាំងព្រះនាងសាមាវតី មានបក្សពួកខាងក្រៅ ស្ត្រីទាំងនោះនឹងដាក់ព្រះជន្មព្រះអង្គ ២-៣ ថ្ងៃទៀតមិនខាន ។ ព្រះរាជាទ្រង់មិនបានជឿតាមពាក្យក្រាបទូលទាំងនោះឡើយ ដោយទ្រង់ព្រះតម្រាស់ថា ស្ត្រី

ទាំងនោះនឹងមិនធ្វើនូវអំពើបែបនោះទេ ។ សូម្បីកាលព្រះនាងមាគន្ទិយា ក្រាបទូលទៀត ក៏នៅតែទ្រង់មិនជឿដែរ ។

គ្រានោះ ព្រះនាងមាគន្ទិយា ក៏បានក្រាបទូលព្រះរាជាអង្គនោះ ដល់ទៅ ៣ ដងហើយក៏ដោយ ព្រះអង្គនៅតែមិនជឿដដែល នាងបាន ក្រាបទូលទៀតថា ប្រសិនបើព្រះអង្គមិនទ្រង់ជឿតាមពាក្យរបស់ខ្ញុំ ម្ចាស់ទេ សូមព្រះអង្គស្តេចយាងទៅលំនៅរបស់ស្ត្រីទាំងនោះហើយ ទ្រង់ពិនិត្យមើលចុះ ។ ពេលនោះ ព្រះរាជាក៏ស្តេចយាងទៅទតមើល តាមបន្ទប់ទាំងនោះមែន ក៏ស្រាប់តែបានឃើញប្រហោងបន្ទប់ទាំងនោះ ក៏ត្រាស់សួរថា ប្រហោងនេះ ជាប្រហោងអ្វី ? កាលស្ត្រីទាំងនោះ ក្រាបទូលសេចក្តីនោះហើយ ទ្រង់ក៏មិនបានពិរោធចំពោះស្ត្រីទាំងនោះ ដោយមិនបានត្រាស់អ្វីៗ សោះ បញ្ជាឲ្យបិទប្រហោងទាំងនោះហើយ ឲ្យធ្វើបង្អួចតូចៗ ក្នុងបន្ទប់ទាំងនោះៗ ឡើង ។ បានឮថា បង្អួចតូចៗ ទាំងឡាយបានកើតឡើងក្នុងកាលនោះឯង ។ ព្រះនាងមាគន្ទិយាមិនអាច ដើម្បីនឹងធ្វើអ្វីៗ ដល់ស្ត្រីទាំងនោះបាន ក៏គិតថា យើងនឹងធ្វើនូវអំពើ

ដែលគប្បីធ្វើដល់សមណៈនេះឲ្យទាល់តែបាន ។ ទើបឲ្យកហាបណៈ
ដល់អ្នកនគរ ហើយពោលថា ពួកឯង ព្រមទាំងពួកបុរសដែលជាខ្ញុំប្រុស
និងកម្មករទាំងឡាយ ចូរនាំគ្នាទៅជេរប្រទេចផ្ដាសាព្រះសមណគោតម
ដែលមកកាន់នគរនេះឲ្យរត់ចេញទៅវិញ ពួកមិច្ឆាទិដ្ឋិដែលជាអ្នក
មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ បាននាំគ្នាដើរទៅជេរប្រទេចផ្ដាសាដោយវត្ថុ
សម្រាប់ជេរ ១០ យ៉ាងថា ១- ឯងជាចោរ ២- ឯងជាបុគ្គលពាល
៣- ឯងជាមនុស្សល្ងង់ ៤- ឯងជាអូដ្ឋ ៥- ឯងជាគោ ៦- ឯងជាលា
៧- ឯងជាសត្វនរក ៨- ឯងជាសត្វតិរច្ឆាន ៩- សុគតិរបស់អ្នក
មិនមាន ១០- ឯងសង្ឃឹមបានតែទុគ្គតិម្យ៉ាងប៉ុណ្ណោះ ។ គ្រានោះ
ព្រះអានន្ទបានឮពាក្យជេរទាំងនោះហើយ បានក្រាបទូលពាក្យនេះ
ចំពោះព្រះលោកនាយកថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកនគរទាំងនេះ
បាននាំគ្នាមកជេរប្រទេចផ្ដាសាពួកយើងទាំងឡាយហើយ ហេតុដូច្នេះ
ពួកយើងទាំងឡាយនឹងទៅកាន់ទីដទៃវិញចុះ ។ លំដាប់នោះ ព្រះភគវា
ត្រាស់សួរថា ម្នាលអានន្ទ យើងទៅកាន់ទីណា ? ព្រះអានន្ទក្រាបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន ពួកយើងនឹងទៅកាន់នគរដទៃវិញចុះ ។ ព្រះមុនីត្រាស់ថា ម្នាលអានន្ទ ប្រសិនបើពួកមនុស្សនៅក្នុងក្រុង ដែលយើងទៅនោះគេជេរទៀត តើយើងទៅកាន់នគរណាទៀត ? ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់នគរដទៃមួយទៀត ។ ព្រះមានជោគត្រាស់ថា ចុះបើកាលមនុស្សក្នុងនគរនោះជេរយើងទៀត តើយើងគប្បីទៅកាន់ទីណាទៀតដែរ ? ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់នគរដទៃក្រៅអំពីនគរនោះទៀត ។ ព្រះភគវាត្រាស់ថា ម្នាលអានន្ទ កាលធ្វើយ៉ាងនេះមិនសមគួរទេ អធិករណ៍កើតឡើងក្នុងទីណា កាលអធិករណ៍នោះស្ងប់រំងាប់ហើយ ក្នុងទីនោះទើបគួរទៅកាន់ទីដទៃទៀតបាន ម្នាលអានន្ទ ពួកមនុស្សប្រភេទណាដែលមកជេរ ? ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនជនទាំងនោះ មានទាំងពួកទាសៈ និងកម្មករដែលជាអ្នកមកជេរ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតដូចជាដំរីចូលទៅកាន់សង្គ្រាមក៏ការអត់ទ្រាំចំពោះកូនសរ ដែលមកអំពីទិសទាំង ៤ រមែងជាភារៈ

របស់ដំរីដែលចូលទៅកាន់សង្គ្រាមនោះ យ៉ាងណាមិញ ដែលឈ្មោះថាការអត់ទ្រាំចំពោះពាក្យ ដែលមនុស្សទ្រុស្តសីលជាច្រើនពោលហើយ ក៏ជាភារៈរបស់តថាគតដូច្នោះដែរ កាលព្រះសាស្តាត្រាស់ដូច្នេះហើយ ទើបត្រាស់ព្រះគាថា ៣ គាថា ក្នុងពេលនោះថា

តថាគត នឹងអត់ទ្រាំចំពោះពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញ ដែលរបូតចេញមកអំពីធ្នូ ក្នុងសង្គ្រាមដូច្នោះ ព្រោះថាជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំពាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់ពាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណាទ្រាំអត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា ជាបុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី ពួកសេះអាជានេយ្យក្តី ពួកសេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅហើយ រាប់ថាជាសត្វប្រសើរបំផុត បុគ្គលដែលមានខ្លួនទូន្មានបានហើយ ជាអ្នកប្រសើរជាងសត្វទាំងអស់នោះ ។

ធម្មកថាក្នុងពេលនោះ បានជាប្រយោជន៍ដល់មហាជនជាច្រើន ដែលមកប្រជុំគ្នាក្នុងទីនោះ កាលព្រះពុទ្ធអង្គទ្រង់ត្រាស់ព្រះធម៌យ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលអានន្ទ អ្នកកុំគិតឡើយ ពួកជនទាំងនោះនឹងជេរត្រឹម ៧ ថ្ងៃទៀតប៉ុណ្ណោះ ដល់ថ្ងៃទី ៨ នឹងស្ងប់ស្ងាត់ទៅហើយ ព្រោះថា អធិករណ៍ដែលកើតឡើងដល់ព្រះពុទ្ធទាំងឡាយមិនហួស ៧ ថ្ងៃទេ ។ ព្រះនាងមាគន្ទិយាបានជួលមនុស្សឲ្យទៅជេរព្រះសាស្ដាហើយ ប៉ុន្តែមិនអាចធ្វើឲ្យព្រះសាស្ដាចៀសចេញទៅបាន ទើបត្រិះរិះទៀតថា យើងនឹងធ្វើយ៉ាងណាហ្ន៎ កាលគិតដូច្នេះហើយ បានយល់ឃើញថា ស្ត្រីទាំងនេះជាឧបដ្ឋាយិការបស់ព្រះសមណគោតមនោះ យើងនឹងធ្វើសេចក្ដីវិនាសឲ្យកើតមានដល់ស្ត្រីទាំងនោះឲ្យទាល់តែបាន ។ ថ្ងៃមួយកាលព្រះនាងមាគន្ទិយា ធ្វើការបម្រើព្រះរាជាក្នុងទីទ្រង់សោយទឹកចណ្ឌ បានបញ្ជូនដំណឹងទៅឲ្យឪពុកមាថា ខ្ញុំត្រូវការមាន់ សូមឪពុកមានាំយកមាន់ស្លាប់ ៨ មាន់រស់ ៨ មក លុះយកមកដល់ហើយចូរឈរនៅទីបំផុតនៃជណ្ដើរ ចូរបញ្ជាឲ្យមនុស្សទៅថ្វាយដំណឹងដល់ព្រះរាជាថា

ខ្ញុំនមកដល់ហើយ សូម្បីកាលព្រះរាជាត្រាស់ថា ចូរចូលមក ក៏កុំចូលទៅ ចូរបញ្ជូនមាន់រស់ ៨ ទៅមុន បញ្ជូនមាន់ស្លាប់ទៅខាងក្រោយ ហើយបានប្រទានសំណូកដល់អ្នកបម្រើដោយពាក្យថា ឯងគប្បីធ្វើតាមពាក្យរបស់យើង ។ នាយចុល្លមាគន្ទិយៈមកហើយ បានឲ្យមនុស្សទៅថ្វាយដំណឹងដល់ព្រះរាជាទ្រង់ជ្រាប កាលព្រះរាជាត្រាស់ថា ចូរចូលមក ក៏ពោលថា យើងនឹងមិនចូលទៅកាន់ទីជាទីសោយទឹកចណ្ឌរបស់ព្រះរាជា ចំណែកព្រះនាងមាគន្ទិយា បានបញ្ជូនអ្នកបម្រើទៅដោយពាក្យថា នែបា ឯងចូរទៅកាន់សម្នាក់នៃឪពុកមារបស់យើង ។ អ្នកបម្រើនោះទៅហើយ នាំមាន់រស់ ៨ ដែលនាយចុល្លមាគន្ទិយៈនោះឲ្យមកហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរោហិតបញ្ជូនបណ្ណាការមកហើយ ព្រះបាទឧទេនត្រាស់ថា ប្រពៃណាស់ សម្ភារៈកើតឡើងដល់ពួកយើងហើយ នរណាហ្ន៎ គប្បីជាអ្នកចម្អិន ? ព្រះនាងមាគន្ទិយាក្រាបទូលថា បពិត្រមហារាជ ស្ត្រី ៥០០ នាក់ ដែលមានព្រះនាងសាមាវតីជាប្រធាន ជាអ្នកមិនមានការងារធ្វើ គឺជាអ្នកនៅទំនេរ សូមព្រះអង្គបញ្ជូនកិច្ចការងារនេះ

ឲ្យដល់ស្ត្រីទាំងនោះជាអ្នកចម្អិន ហើយនាំមកថ្វាយព្រះអង្គ ។ព្រះរាជាទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ឯងចូរនាំទៅឲ្យដល់ស្ត្រីទាំងនោះគឺកុំឲ្យដល់អ្នកដទៃឲ្យសោះ ចូរសម្លាប់ហើយចម្អិនដោយខ្លួនឯង ។ អ្នកបម្រើទទួលរាជតម្រាស់ថា ព្រះករុណាថ្លៃវិសេស រួចក៏បានធ្វើតាមព្រះរាជាដែលមានព្រះរាជតម្រាស់នោះ ស្ត្រីទាំងនោះក៏បានប្រកែកថាពួកខ្ញុំមិនធ្វើបាណាតិបាតទេ អ្នកបម្រើនោះក៏បានយកសេចក្តីនោះមកក្រាបទូលដល់ព្រះរាជាវិញ ។ ព្រះនាងមាគន្ទិយាក្រាបទូលថា បពិត្រមហារាជ ព្រះអង្គឃើញទេ ឥឡូវនេះ ព្រះអង្គទ្រង់ជ្រាបការធ្វើ ឬមិនធ្វើបាណាតិបាតរបស់ស្ត្រីទាំងនោះ សូមព្រះអង្គបញ្ជាថា ស្ត្រីទាំងនោះចូរចម្អិន ហើយនាំទៅថ្វាយដល់សមណៈ ដូច្នេះវិញចុះ ព្រះអង្គ ។

គ្រានោះ ព្រះរាជាត្រាស់យ៉ាងនោះហើយ ក៏បានបញ្ជូនទៅ ។ អ្នកបម្រើនោះ បានកាន់មាន់ដែលនៅរស់នោះ ធ្វើហាក់បីដូចជាដើរទៅៗ ហើយបានឲ្យមាន់ទាំងនោះដល់បុរោហិតៗ បានយកមាន់ស្លាប់ទៅកាន់សម្នាក់របស់ស្ត្រីទាំងនោះ ថែមទាំងពោលថា ពួកនាងចូរចម្អិនមាន់

ទាំងនេះរួចហើយ នាំយកទៅថ្វាយដល់ព្រះសមណគោតម ។ ស្ត្រីទាំងនោះពោលថា ល្អហើយ ចូរឲ្យមកចុះ ព្រោះថា ការចម្អិនមាន់ស្លាប់នេះជាកិច្ចរបស់ពួកយើងពោលដូច្នេះហើយក៏ទទួលយកទុក ។ អ្នកបម្រើនោះមកកាន់សម្នាក់របស់ព្រះរាជាវិញ ព្រះរាជាបាត្រាស់សួរថា នែបាយ៉ាងម៉េចហើយកិច្ចការងារនោះ ? អ្នកបម្រើនោះក្រាបទូលថា កាលខ្ញុំព្រះអង្គគ្រាន់តែពោលថា ពួកនាងចូរចម្អិនរួចហើយ នាំទៅថ្វាយដល់ព្រះសមណគោតមប៉ុណ្ណោះ ស្ត្រីទាំងនោះក៏ប្រញាប់ប្រញាល់មកទទួលយកទៅ ។ ព្រះនាងមាគន្ទិយាក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គទតមើលចុះ ស្ត្រីទាំងនោះមិនធ្វើឲ្យដល់បុគ្គលដូចជាព្រះអង្គទេ កាលខ្ញុំព្រះអង្គទូលថា ស្ត្រីទាំងនោះមានបក្សពួកខាងក្រៅ ព្រះអង្គនៅតែមិនជឿទៀត ។ ព្រះរាជាសូម្បីទ្រង់ព្រះសណ្ដាប់នូវពាក្យនោះ ទ្រង់ក៏បានអត់សង្កត់ព្រះទ័យ គឺនៅស្ងៀមដូចដើម ។ ព្រះនាងមាគន្ទិយាគិតថា យើងគួរធ្វើយ៉ាងណាទៅទៀត ។ ក៏ក្នុងកាលនោះ ព្រះបាទឧទេនទ្រង់បានទៅសម្រាក នៅក្នុងប្រាសាទរបស់អគ្គមហេសីទាំងនោះ គឺ

ប្រាសាទរបស់ព្រះនាងសាមាវតី ១ ប្រាសាទរបស់ព្រះនាងវាសុលទត្តា ១ និងប្រាសាទរបស់ព្រះនាងមាគន្ទិយា ១ អស់ ៧ ថ្ងៃ ក្នុងប្រាសាទនីមួយៗ ។ គ្រានោះ ព្រះនាងមាគន្ទិយាដឹងថា ថ្ងៃស្អែកនេះព្រះរាជានឹងស្តេចយាងទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតី ក៏បញ្ជូនដំណឹងទៅប្រាប់ដល់ឪពុកមាថា សូមលោកឪពុកមាជ្រាប ខ្ញុំត្រូវការពស់ សូមលោកឪពុកមាដកចង្កូមពស់ទាំងអស់ ហើយបញ្ជូនមកឲ្យដល់ខ្ញុំ នាយចុលមាគន្ទិយៈធ្វើយ៉ាងនោះ រួចហើយបញ្ជូនទៅថ្វាយព្រះនាងមែន ។ ព្រះរាជាទ្រង់កាន់យកពិណហត្ថីកន្ត គឺពិណសម្រាប់ញ៉ាំងដំរីឲ្យត្រេកអរតែម្យ៉ាង ស្តេចបានយាងទៅកាន់ទីដែលព្រះអង្គប្រាថ្នានឹងទៅ ។ ពិណនោះមានប្រហោងមួយៗ ព្រះនាងមាគន្ទិយា បានយកពស់ទៅដាក់នៅក្នុងប្រហោងនោះ ហើយបិទប្រហោងដោយដុំនៃកម្រងផ្កា ពស់នោះក៏បាននៅក្នុងពិណនោះឯង អស់ ២-៣ ថ្ងៃ ក្នុងថ្ងៃដែលព្រះរាជាស្តេចយាងទៅ ព្រះនាងមាគន្ទិយាទូលថា បពិត្រព្រះសម្មតិទេព ថ្ងៃនេះ ព្រះអង្គស្តេចយាងទៅកាន់ប្រាសាទអគ្គមហេសីអង្គណា ? កាលព្រះរាជាត្រាស់

ប្រាប់ថា ទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតី នាងក៏ក្រាបទូលថា បពិត្រមហារាជ ថ្ងៃនេះ ខ្ញុំព្រះអង្គយល់សុបិនឃើញថាមិនល្អទេ បពិត្រព្រះសម្មតិទេព ព្រះអង្គមិនអាចយាងទៅកាន់ទីនោះបានទេ ។ ព្រះរាជាត្រាស់ថា យើងត្រូវតែទៅ ព្រះនាងមាគន្ទិយាហាមដល់ទៅ ៣ ដង ហើយទូលថា បើដូច្នោះ សូម្បីខ្ញុំព្រះអង្គក៏នឹងទៅជាមួយព្រះអង្គដែរ សូម្បីព្រះអង្គមិនបានជ្រាបថា នឹងមានហេតុអ្វីកើតឡើងដល់ព្រះអង្គដែរ ពោលដូច្នេះហើយ ក៏បានទៅជាមួយព្រះរាជាទាល់តែបាន ។ ព្រះរាជាទ្រទ្រង់សំពត់ផ្កាឈើ គ្រឿងក្រអូប និងអាភរណៈទាំងឡាយ ដែលពួកស្ត្រី រួមជាមួយនឹងព្រះនាងមាគន្ទិយាថ្វាយ សោយភោជនដ៏ល្អ បានដាក់ពិណទុកនៅលើក្បាលដំណេក ហើយផ្ទំលើព្រះក្រឡាបន្ទំ ។ ព្រះនាងមាគន្ទិយាធ្វើហាក់ដូចជាដើរទៅដើរមក បានយកដុំកម្រងផ្កាចេញអំពីពិណ ។ ពស់នោះបានអត់អាហារ ២-៣ ថ្ងៃមកហើយ ក៏បានលូនចេញតាមប្រហោងពិណនោះមក បញ្ចេញសំឡេងយ៉ាងខ្លាំងៗ បើកពពារដេកនៅលើព្រះទែនក្រឡាព្រះបន្ទំ ។ ព្រះនាងមាគន្ទិយា

ឃើញពស់នោះដូច្នោះហើយ ក៏ស្រែកឡើងថា បពិត្រព្រះសម្មតិទេព ទ្រង់ទុំពស់ កាលទឹងជេរព្រះរាជា និងស្ត្រីទាំងនោះថា ព្រះរាជាល្ងង់ ព្រះរាជាអង្គនេះ ជាអ្នកមិនមានបុណ្យ ជាអ្នកមិនជឿតាមពាក្យរបស់យើង សូម្បីស្ត្រីទាំងនេះ ក៏ជាមនុស្សមិនមានសិរីក្បាលរឹង ប្រៀនប្រដៅបាន ដោយកម្រ ពួកនាងឯង កាលព្រះរាជាអង្គនេះសោយទិវង្គតទៅហើយ សប្បាយឬ បើព្រះរាជានៅមានព្រះជន្ម ពួកនាងឯងរស់នៅដោយលំបាកឬ ថ្ងៃនេះ យើងបានសុបិនដ៏អាក្រក់របស់យើងហើយ ព្រះអង្គអើយ ព្រះអង្គទ្រង់មិនជឿស្តាប់តាមពាក្យរបស់ខ្ញុំព្រះអង្គ ដែលបានពោលអង្វរថា មិនគួរស្តេចយាងមកកាន់ទីនេះ ។ ព្រះបាទឧទេនបានទតឃើញពស់នោះ ទ្រង់ក៏ស្តុតព្រះទ័យចំពោះមរណៈ គឺពោរពេញទៅដោយការក្រោធខឹងចំពោះស្ត្រីទាំងនោះ ដោយគិតថា ស្ត្រីទាំងនេះបានធ្វើកម្មបែបនេះចំពោះអាត្មាអញ ហេតុអ្វីក៏អាត្មាអញមិនជឿតាមពាក្យរបស់ព្រះនាងមាគន្ទិយា ដែលជាអ្នកប្រាប់ហើយ ប្រាប់ទៀតថា ស្ត្រីទាំងនេះជាមនុស្សលោមក កាលលើកមុនពួកវា បានចោះប្រហោងទុក

នៅតាមបន្ទប់របស់ខ្លួន រៀងៗខ្លួន ហើយកាលយើងបញ្ជូនមាន់ទៅឲ្យ ក៏បញ្ជូនមាន់ត្រឡប់មកវិញទៀត ថ្ងៃនេះ ពួកវាបានយកពស់ដាក់ក្នុងក្រឡាព្រះបន្ទំ ។ ចំណែកព្រះនាងសាមាវតី ក៏បានឲ្យឱវាទដល់ស្ត្រីទាំង ៥០០ នាក់នោះថា នែនាងដ៏ចម្រើនទាំងឡាយ ទីពឹងដទៃរបស់ពួកយើងមិនមាន អ្នកទាំងឡាយចូរញ៉ាំងមេត្តាចិត្ត ឲ្យប្រព្រឹត្តទៅចំពោះព្រះរាជា ដែលជាកំពូលលើនរជន និងព្រះទេវីនៅក្នុងចិត្តខ្លួនឯង អ្នកទាំងឡាយកុំញ៉ាំងសេចក្តីក្រោធចំពោះអ្នកណាៗ ឡើយ ។ ព្រះរាជាទ្រង់កាន់យកធ្នូ ដែលមានសណ្ឋានដូចក្អកជំរី ឬស្នែងសត្វ ដែលបុរសមានកម្លាំង ១០០០ នាក់ ទើបអាចលើកបាន ទ្រង់បានឲ្យព្រះនាងសាមាវតីឈរនៅពីខាងមុខ ឲ្យស្ត្រីទាំងនោះឈរតម្រៀបគ្នាជាជួរនៅពីខាងក្រោយរបស់ព្រះនាងសាមាវតីទៅតាមលំដាប់ ហើយទ្រង់ក៏បាញ់កូនសរតម្រង់ទៅចំទ្រូងព្រះនាងសាមាវតី ។ កូនសរនោះ ត្រឡប់ជាមានមុខឆ្ពោះមកកាន់ព្រះរាជាវិញ ដែលមានសភាពបែបនេះ ដោយកម្លាំងអានុភាពមេត្តាចិត្តរបស់ព្រះនាងសាមាវតី និងពួកស្ត្រីទាំងនោះ ។

ព្រះរាជាទ្រង់ព្រះចិន្តាដូច្នេះថា កូនសរដែលយើងបាញ់ទៅហើយនេះ អាចទម្លុះនូវសិលាបាន ហេតុដូចម្តេច បានជាកូនសរនេះមានមុខធ្លោះមកតម្រង់ហឫទ័យយើងវិញ ពិតណាស់ សូម្បីកូនសរដែលមិនមានចិត្ត មិនមែនជាសត្វ មិនមែនជារបស់មានជីវិត រមែងដឹងនូវគុណរបស់ព្រះនាងសាមាវតី ខ្លួនយើងជាមនុស្ស ហេតុដូចម្តេច បានជាមិនដឹងគុណអ្វីបន្តិចបន្តួចទាល់តែសោះ ។ ព្រះរាជា ទ្រង់បោះធ្នូនោះចោល ទ្រង់បានផ្គងអញ្ជលីនៅទៀបបាទមូលនៃព្រះនាងសាមាវតី ហើយត្រាស់ថា យើងជាមនុស្សវង្វេង ជាមនុស្សល្ងង់ខ្លៅ ទិសទាំងពួងមិនប្រាកដដល់យើង នែនាងសាមាវតី នាងចូរការពារយើង មួយវិញទៀត នាងចូរជាទីពឹងរបស់យើង ព្រះនាងសាមាវតី បានស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក៏មិនបានក្រាបទូលថា បពិត្រមហារាជ ប្រពៃហើយ ព្រះអង្គចូរដល់ទូលបង្គំជាទីពឹងចុះ ប៉ុន្តែនាងបានត្រឡប់ជាក្រាបទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គដល់នូវបុគ្គលណាជាទីពឹង សូមព្រះអង្គគួរដល់បុគ្គលនោះ ជាទីពឹងដែរចុះ ។ ព្រះនាងសាមាវតីដែលជា

សាវិការបស់ព្រះសម្ពុទ្ធ លុះពោលពាក្យដូច្នេះហើយ ក៏ពោលទៀតថា

**ព្រះអង្គកុំឲ្យទ្រង់ដល់នូវខ្ញុំជាទីពឹងឡើយ ខ្ញុំព្រះអង្គដល់នូវបុគ្គលណា ជាទីពឹង បពិត្រមហារាជ បុគ្គលនោះ គឺព្រះពុទ្ធៗ នោះ ជាបុគ្គលដ៏កំពូល សូមព្រះអង្គទ្រង់ដល់នូវព្រះពុទ្ធអង្គនោះជាទីពឹងផង ទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គផង ។**

គ្រានោះ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យរបស់ព្រះនាងសាមាវតីនោះហើយ ក៏ទ្រង់ត្រាស់ថា ឥឡូវនេះ យើងខ្លាចណាស់ ហើយព្រះរាជាត្រាស់ព្រះគាថានេះថា

**យើងនេះ ជាមនុស្សវង្វេង ទិសទាំងពួងរមែងមិនប្រាកដដល់យើង នាងសាមាវតីអើយ នាងចូរគាំទ្រយើង មួយវិញទៀត នាងចូរជាទីពឹងរបស់យើង ។**

គ្រានោះ ព្រះនាងសាមាវតីក៏បានពោលហាមព្រះរាជាដោយន័យដូចមុននោះឯងទៀត កាលព្រះរាជាត្រាស់ថា បើដូច្នោះ យើងសូមដល់នាង និងព្រះលោកនាថជាទីពឹង ហើយយើងនឹងឲ្យពរដល់នាង

ដូច្នេះហើយ នាងសាមាវតីក្រាបទូលថា បពិត្រមហារាជ ពរនេះចូរជាពរដែលខ្ញុំម្ចាស់បានទទួលហើយចុះ ។ ព្រះរាជាក៏ស្ដេចយាងចូលទៅគាល់ព្រះមានជោគ ទ្រង់ដល់នូវព្រះលោកនាថជាសរណៈហើយ ទ្រង់បាននិមន្តភិក្ខុសង្ឃថ្វាយទានដល់ភិក្ខុអស់ ៧ ថ្ងៃ ដែលមានព្រះពុទ្ធជាប្រធាន ហើយទ្រង់ហៅព្រះនាងសាមាវតីមកត្រាស់ថា នាងចូរក្រោកឡើងទទួលពររបស់យើង ព្រះនាងសាមាវតីក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់មិនមានសេចក្ដីត្រូវការដោយវត្ថុទាំងឡាយ មានប្រាក់ជាដើមទេ ប៉ុន្តែសូមព្រះអង្គព្រះរាជទានពរនេះដល់ខ្ញុំម្ចាស់ គឺព្រះភគវា ព្រមទាំងភិក្ខុសង្ឃ ៥០០ រូប ឲ្យស្ដេចយាងមកកាន់ទីនេះជានិច្ច សូមព្រះអង្គទ្រង់ធ្វើដោយប្រការនេះចុះ ខ្ញុំម្ចាស់នឹងបានឱកាសស្ដាប់ព្រះធម៌ ។ ព្រះរាជាក៏ទ្រង់បានចូលទៅថ្វាយបង្គំព្រះសាស្ដា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ព្រមទាំងភិក្ខុសង្ឃទាំង ៥០០ រូប ស្ដេចយាងទៅកាន់ទីកន្លែងរបស់ព្រះនាងសាមាវតី ព្រមទាំងស្ត្រីទាំង ៥០០ នាក់នោះជានិច្ច ដើម្បីបានឱកាសថ្វាយទាន ឬស្ដាប់ព្រះធម៌ ។

គ្រានោះ ព្រះមហាវីរបុរសត្រាស់ថា មហាបពិត្រ ធម្មតាការត្រាច់ទៅក្នុងទីមួយជានិច្ច រមែងមិនសមគួរដល់ព្រះពុទ្ធទាំងឡាយទេ ។ ព្រះរាជាមានព្រះបន្ទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះអង្គចាត់ភិក្ខុមួយរូបជាអ្នកឲ្យទៅកាន់ទីនោះចុះ ។ ព្រះសាស្តា ក៏ទ្រង់បានចាត់ព្រះអានន្ទជាអ្នកឲ្យទៅកាន់ទីកន្លែងនោះ ចាប់តាំងពីពេលនោះមកព្រះអានន្ទក៏តែងតែនាំភិក្ខុ ៥០០ រូបទៅកាន់រាជត្រកូលជានិច្ច ចំណែកព្រះនាងសាមាវតី ព្រមទាំងបរិវារទាំងនោះ បានចាត់ចែងនូវចង្ហាន់បិណ្ឌបាតប្រគេនដល់ព្រះថេរៈនិងភិក្ខុដែលជាបរិវារនិមន្តទៅជាមួយនោះ ឲ្យឆាន់គ្រប់គ្រាន់ ជាពិសេស គឺបានស្តាប់ព្រះធម៌ជានិច្ចទៀតផង ។ ថ្ងៃមួយ ស្ត្រីទាំងនោះ បានស្តាប់ធម្មកថារបស់ព្រះថេរៈហើយ ក៏កើតមានសេចក្តីជ្រះថ្លា បានបូជាព្រះធម៌ដោយសំពត់ឧត្តរាសង្គៈ ៥០០ ផ្ទាំង ។ សំពត់ឧត្តរាសង្គៈមួយផ្ទាំងៗ មានតម្លៃ ៥០០ កហាបណៈ ។ ព្រះរាជាទ្រង់មិនបានឃើញសំពត់របស់ស្ត្រីទាំងនោះ សូម្បីតែមួយផ្ទាំងទើបត្រាស់សួរថា នែនាងដ៏ចម្រើនទាំងឡាយ តើសំពត់ឧត្តរាសង្គៈ

ទៅណាអស់ហើយ ? ពួកស្ត្រីទាំងនោះឆ្លើយថា ពួកខ្ញុំម្ចាស់ បានយកទៅប្រគេនដល់ព្រះអានន្ទអស់ហើយ ។ ព្រះរាជាត្រាស់ទៀតថា លោកម្ចាស់អានន្ទនោះ ទទួលយកទៅទាំងអស់ឬ ? ពួកស្ត្រីទាំងនោះឆ្លើយថា បពិត្រមហារាជ លោកម្ចាស់អានន្ទ លោកបានទទួលយកទៅទាំងអស់ ។ កាលព្រះរាជា បានឮដូច្នោះ ហើយស្ដេចក៏យាងចូលទៅរកព្រះថេរៈ ហើយត្រាស់សួរអំពីរឿង ដែលស្ត្រីទាំងនោះប្រគេនសំពត់ឧត្តរាសង្គៈ ។ ព្រះអានន្ទឆ្លើយថា មែន ពួកស្ត្រីទាំងនោះបានប្រគេនសំពត់ដល់អាត្មា ៥០០ ផ្ទាំងពិតមែន ។

ឧទេន. លោកម្ចាស់អានន្ទ នឹងយកចីវរទៅធ្វើអ្វីច្រើនដល់ម្ល៉េះ ?

អានន្ទ. អាត្មានឹងចែកដល់ពួកភិក្ខុទាំងឡាយ ដែលមានចីវរចាស់គ្រាំគ្រា ។

ឧទេន. តើលោកម្ចាស់អានន្ទ នឹងធ្វើយ៉ាងណា ចំពោះចីវរចាស់គ្រាំគ្រានោះ ?

អានន្ទ. អាត្មានឹងយកសំពត់ចីវរទាំងនោះទៅធ្វើកម្រាលគ្រែ ។

ឧទេន. លោកម្ចាស់អានន្ទ យកធ្វើអ្វីចំពោះសំពត់កម្រាលគ្រែចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់ទាំងនោះទៅធ្វើស្រោមពូក ។

ឧទេន. លោកម្ចាស់ធ្វើយ៉ាងណាចំពោះស្រោមពូកចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់ទាំងនោះទៅធ្វើជាកម្រាលផែនដី ។

ឧទេន. ចុះលោកម្ចាស់អានន្ទ នឹងធ្វើយ៉ាងណា ចំពោះសំពត់កម្រាលផែនដីចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់កម្រាលផែនដីចាស់នោះ ទៅធ្វើជាសំពត់ជូតជើង ។

ឧទេន. ចុះលោកម្ចាស់ធ្វើយ៉ាងណា ចំពោះសំពត់ជូតជើងចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់ជូតជើងចាស់នោះ ទៅធ្វើជាសំពត់ជូតធូលីវិញ ។

ឧទេន. ចុះលោកម្ចាស់យកសំពត់ជូតធូលីចាស់នោះទៅធ្វើអ្វី ?

អានន្ទ. អាត្មានឹងចិញ្ច្រាំនូវសំពត់ជូតធូលីចាស់នោះ ហើយប្រឡាក់ លាយជាមួយភក់ យកទៅបូកលាបជញ្ជាំង ។

ឧទេន. បពិត្រលោកម្ចាស់ដ៏ចម្រើន សំពត់ទាំងឡាយ ដែលទាយកប្រគេនដល់ពួកលោកម្ចាស់នេះ រមែងមិនវិនាសទៅ ព្រោះធ្វើនូវកិច្ចមានប៉ុណ្ណេះឬ ?

អានន្ទ. ថ្វាយព្រះពរមហាបពិត្រ យ៉ាងនេះឯង ។

គ្រានោះ ព្រះរាជាទ្រង់ក៏កើតសេចក្តីជ្រះថ្លាឡើង ថែមទាំងប្រើអ្នកបម្រើឲ្យនាំសំពត់ ៥០០ ផ្ទាំងដទៃមកទៀត ប្រគេនដល់ព្រះថេរៈ ។ បានឮថា ព្រះថេរៈបានទទួលសំពត់ដែលមានតម្លៃ ៥០០ កហាបណៈ ដែលព្រះរាជានាំមកប្រគេនដោយចំណែក ៥០០ អស់វារៈ ៥០០ ដង ។ បានទទួលសំពត់ដែលមានតម្លៃ ១០០០ កហាបណៈ ដែលព្រះរាជានាំយកមកប្រគេន អស់វារៈមួយសែនដង ។ សំពត់ដែលព្រះថេរៈទទួលបាន បើរាប់ថា ១-២-៣-៤-៥-១០ ដូច្នេះ រមែងរាប់មិនបាន ។ បានឮថា កាលព្រះអង្គបរិនិព្វានទៅហើយ ព្រះអានន្ទបានត្រាច់ទៅកាន់

ជម្ពូទ្វីបទាំងមូល ហើយព្រះថេរៈបានប្រគេនបាត្រ និងចីវរទាំងឡាយ ដែលជារបស់ខ្លួននោះឯង ដល់ភិក្ខុទាំងឡាយក្នុងវិហារទាំងពួង ។

ផលល្អដែលព្រះអានន្ទត្ថេរ បានទទួលការប្រគេនសំពត់យ៉ាងច្រើននេះ និងភាពជាអ្នកមានបញ្ញាច្រើនក្នុងជាតិនេះ មានរឿងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

ក្នុងជាតិមួយ ព្រះអានន្ទ បានកើតជាជាងតម្បាញ បានប្រគេនសំពត់មួយផ្ទាំងតូចប្រមាណមួយចំអាម ព្រមទាំងម្ជុលមួយដល់ព្រះបច្ចេកពុទ្ធមួយព្រះអង្គ គឺក្នុងសម័យដែលធ្វើចីវរ ។ ចំណែកព្រះអានន្ទជាអ្នកមានបញ្ញាច្រើននៅក្នុងជាតិនេះ ព្រោះផលនៃការប្រគេនម្ជុល និងការបានប្រគេនសំពត់ដល់ ៥០០ ដង ម្តងៗ ៥០០ ផ្ទាំង ព្រោះផលនៃការប្រគេនសំពត់តូចប្រមាណមួយចំអាមនោះឯង ។

រឿងរបស់ព្រះនាងសាមាវតីតទៅនេះ មានសម្តែងទុកនៅក្នុងគម្ពីរអដ្ឋកថាមនោរថបូរណី និងក្នុង **អដ្ឋកថាធម្មបទ** ក្នុងរឿងព្រះនាងសាមាវតី ដូចមានសេចក្តីថា ៖

គ្រានោះ ព្រះនាងមាគន្ទិយាគិតថា យើងធ្វើនូវកម្មណា កម្មនោះមិនបានសម្រេចទាល់តែសោះ បែរជាត្រឡប់ទៅជាប្រការដទៃវិញ យើងនឹងធ្វើយ៉ាងណាទៀតហ្ន៎ ហើយទ្រង់ត្រិះរិះថា ឧបាយដូច្នេះប្រើបាន ក្នុងកាលព្រះរាជា ស្តេចយាងទៅប្រពាតព្រះរាជឧទ្យាន ទើបទ្រង់បញ្ជូនដំណឹងទៅឲ្យដល់ចុល្លមាគន្ទិយៈថា សូមលោកឪពុកមាទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតី ឲ្យបើកឃ្លាំងសំពត់ និងឃ្លាំងប្រេងចេញហើយ ចូរយកសំពត់នោះទៅជ្រលក់ជាមួយនឹងប្រេង រួចយកទៅរុំសសរប្រាសាទរបស់ព្រះនាងសាមាវតី ឲ្យស្ត្រីទាំងអស់នោះនៅរួមគ្នាក្នុងប្រាសាទ ចូរបិទទ្វារចាក់សោពីខាងក្រៅ ហើយយកភ្លើងដុតដំណាក់នោះ រួចចៀសចេញទៅ ។ ចុល្លមាគន្ទិយៈ បានទៅកាន់ដំណាក់របស់ព្រះនាងសាមាវតី ឲ្យបើកឃ្លាំងសំពត់ និងឃ្លាំងប្រេង ហើយឲ្យយកសំពត់ជ្រលក់ប្រេង ទៅរុំព័ទ្ធសសរដំណាក់ទាំងអស់របស់ព្រះនាងសាមាវតី ។ ពេលនោះ ស្ត្រីទាំងនោះ ដែលមានព្រះនាងសាមាវតីជាប្រធាន បានចូលទៅត្រាស់សួរចុល្លមាគន្ទិយៈថា អ្នកនាំគ្នាធ្វើអ្វីនេះ ?

ចុល្លមាគន្ទិយៈក្រាបទូលថា បពិត្រព្រះនាងម្ចាស់ទាំងឡាយ ព្រះរាជាទ្រង់ត្រាស់បញ្ជាឲ្យយកសំពត់ជ្រលក់ប្រេងទាំងនេះ មករុំព័ទ្ធសសរក្នុងដំណាក់ទាំងនេះ ដើម្បីជាប្រយោជន៍ក្នុងការលម្អព្រះរាជវាំង កាលរុំព័ទ្ធសសរដំណាក់នោះរួចហើយ បានឲ្យស្ត្រីទាំងនោះ ចូលទៅក្នុងប្រាសាទបិទទ្វារចាក់សោពីខាងក្រៅ ដុតភ្លើងចាប់តាំងអំពីបន្ទប់ខាងលើចុះមក ព្រះនាងសាមាវតី កាលបានឃើញដូច្នោះហើយ បានប្រទានឱវាទដល់ពួកស្ត្រីទាំងនោះថា ក្នុងពេលពួកយើងបានត្រាច់រង្គាត់នៅក្នុងសង្សារវដ្ត ដែលរកទីបំផុតគ្មាន ពួកយើងបានត្រូវភ្លើងឆេះយ៉ាងនេះរាប់ប្រមាណមិនបាន ហេតុដូច្នេះ អ្នកទាំងឡាយ ចូរតាំងនៅក្នុងសេចក្តីមិនប្រមាទចុះ ។ កាលភ្លើងកំពុងតែឆេះប្រាសាទនោះ ស្ត្រីទាំងនោះបានធ្វើទុកក្នុងចិត្តនូវ **វេទនាបរិគ្គហកម្មដ្ឋាន** បានដល់ កម្មដ្ឋានដែលមានការកំណត់វេទនាមកជាអារម្មណ៍ អ្នកខ្លះ ក៏បានសម្រេចជាសកទាគាមី អ្នកខ្លះ ក៏បានសម្រេចអនាគាមី ក្នុងថ្ងៃនោះ ពួកស្ត្រីទាំងនោះ មិនអាចញុំាំងភ្លើងឲ្យរលត់បាន ដោយអំណាចគុណធម៌របស់ពួកនាង ដូចក្នុង

កាលលើកមុនទៀតបាន ព្រោះអានុភាពនៃអំពើកម្ម ដែលខ្លួនបានធ្វើទុកមកហើយក្នុងអតីតជាតិ ទើបធ្វើឲ្យពួកស្ត្រីទាំងនោះ ដែលមានព្រះនាងសមាវតីជាប្រធាន ឆេះក្នុងគំនរភ្លើងនោះទៅ ។

ព្រះធម្មសង្គាហកាចារ្យបានពោលទុកជាបន្តទៅទៀត តាមដែលមានសម្ដែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ ឧទាន** ដូចមានសេចក្ដីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាមជិតក្រុងកោសម្ពី ។ គ្រានោះ មានភិក្ខុជាច្រើន ក្រោយពីត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាឆាន់ភត្តរួចហើយ ទើបនាំគ្នាចូលទៅគាល់ព្រះសម្ពុទ្ធដល់ទីគង់ប្រថាប់ ថ្វាយបង្គំរួចហើយ អង្គុយក្នុងទីដ៏សមគួរ ។ បានក្រាបបង្គំទូលសួរព្រះមានជោគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រទានវរោកាស កាលព្រះបាទឧទេនស្ដេចយាងទៅប្រពាតព្រះរាជឧទ្យានក្លាម ក៏បានមានភ្លើងឆេះព្រះរាជដំណាក់របស់ស្ត្រីទាំង ៥០០ នាក់ ដែលមានព្រះនាងសាមាវតីជាប្រធាន បានស្លាប់ទៅទាំងអស់ហើយ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាទាំងនោះមានគតិទៅ

ជាយ៉ាងណា កតពខាងមុខនឹងទៅជាយ៉ាងណាដែរ ? គ្រានោះ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាឧបាសិកាទាំងនោះ ឧបាសិកាដែលជាព្រះសោតាបន្នក៏មាន ជាព្រះសកទាគាមីក៏មាន ជាព្រះអនាគាមីក៏មាន ម្នាលភិក្ខុទាំងឡាយ ឧបាសិកាទាំងអស់នោះ ដែលធ្វើកាលកិរិយានោះ មិនមែនឥតផលទេ ។ លុះព្រះលោកនាថជាក់ច្បាស់នូវសេចក្តីនោះហើយ ទ្រង់បន្លឺនូវឧទានក្នុងវេលានោះថា

សត្វលោកមានមោហៈជាចំណង ប្រាកដដូចជាមានសភាពគួរឲ្យរីករាយ បុគ្គលមានឧបក្កិលេសជាគ្រឿងចង ត្រូវងងឹត គឺអវិជ្ជារួបរឹតហើយ ប្រាកដដូចជាទៀងទាត់ សេចក្តីកង្វល់ មានរាគៈជាដើម មិនមានដល់បុគ្គលអ្នកពិចារណាឃើញច្បាស់នោះទេ ។

គ្រានោះ ព្រះមុនីត្រាស់យ៉ាងនេះហើយ ទើបទ្រង់សម្តែងធម៌ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វទាំងឡាយ ដែលត្រាច់រង្គាត់ក្នុងវដ្តៈ ជាអ្នកមិនប្រមាទ រហូតអស់កាលជានិច្ច ធ្វើតែបុញ្ញកម្មក៏មាន ជាអ្នកមានសេចក្តីប្រមាទ ធ្វើតែបាបកម្មក៏មាន ព្រោះហេតុនោះ សត្វលោក

ដែលត្រាច់រង្គាត់ទៅក្នុងវដ្តៈ ទើបសោយសុខខ្លះ ទុក្ខខ្លះជាធម្មតាទៅ ។

រឿងរបស់ព្រះបាទឧទេន ដាក់ទោសចំពោះព្រះនាងមាគន្ទិយា ព្រមជាមួយនឹងបក្សពួក ហើយក៏ជាការសម្តែងឲ្យឃើញថា អ្នកធ្វើល្អ បានល្អ អ្នកធ្វើអាក្រក់ បានអាក្រក់ តាមដែលមានសម្តែងទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **អដ្ឋកថាធម្មបទ** ដូចមានសេចក្តីថា ៖

កាលព្រះបាទឧទេន ទ្រង់បានជ្រាបដំណឹងពីរាជបុរសដែលបានរក្សាស្រ្តីទាំងនោះថា ប្រាសាទរបស់ព្រះនាងសាមាវតីត្រូវភ្លើងឆេះ សូម្បីកាលស្តេចប្រញាប់យាងទៅ ក្រោយពីជ្រាបដំណឹងភ្លាមៗ ពេលដែលព្រះអង្គស្តេចយាងទៅដល់ បានត្រាស់បញ្ជាឲ្យនាំគ្នារំលត់ភ្លើង ហើយទ្រង់ក៏កើតទុក្ខទោមនស្សយ៉ាងខ្លាំង ថែមទាំងទ្រង់ព្រះចិន្តាថា អំពើនេះ ជាអំពើរបស់នរណាហ្ន៎ ទ្រង់ពិចារណាដូច្នេះហើយ ទ្រង់ជ្រាបថា អំពើនេះ ពិតជាអំពើដែលព្រះនាងមាគន្ទិយាបញ្ជាឲ្យគេធ្វើ ទ្រង់ព្រះចិន្តាទៀតថា សូម្បីយើងគំរាមបែបណាហើយចំពោះព្រះនាងៗ ប្រាកដជាមិនប្រាប់ដដែលយើងនឹងរកឧបាយ ហើយសួរដោយសន្សឹមៗ

ទើបត្រាស់នឹងអាមាត្យទាំងឡាយថា នែអ្នកដ៏ចម្រើនទាំងឡាយ ក្នុងកាលមុនអំពីកាលនេះ យើងក្រោកឡើងហើយ ក៏ជាអ្នករង្កៀសសង្ស័យដោយជុំវិញ ព្រោះព្រះនាងសាមាវតីតែងតែស្វែងរកទោសរបស់យើងជានិច្ច ឥឡូវនេះ នាងបានស្លាប់ទៅហើយ យើងមានការត្រជាក់ចិត្តណាស់ ហើយយើងរស់នៅបានជាសុខសប្បាយទៀតផង ដោយមិនមានអ្នកមករំខាន ។ ពេលនោះ ពួកអាមាត្យទូលសួរថា បពិត្រព្រះសម្មតិទេព កម្មនេះ តើអ្នកណាហ្ន៎ជាអ្នកធ្វើ ? ព្រះរាជាត្រាស់ឆ្លើយថា អ្នកដែលធ្វើកម្មនេះ ជាអ្នកធ្វើសេចក្តីស្នេហាចំពោះយើង ឬជាទីស្រឡាញ់របស់យើង ។ គ្រានោះ ព្រះនាងមាគន្ទិយា ដែលឈរនៅក្បែរព្រះរាជាបានឮព្រះតម្រាស់យ៉ាងនោះ នាងក៏ទូលថា អ្នកដទៃ មិនអាចធ្វើបានទេបពិត្រមហារាជ កម្មនេះខ្ញុំម្ចាស់ជាអ្នកធ្វើ ខ្ញុំម្ចាស់បានបង្គាប់ឪពុកមារបស់ខ្ញុំម្ចាស់ឲ្យជាអ្នកធ្វើ ។ ព្រះរាជាត្រាស់ថា អ្នកដែលជាទីស្រឡាញ់យើងដទៃក្រៅអំពីនាង រមែងមិនមាន យើងពេញចិត្តណាស់ចំពោះនាងខ្ញុំនឹងឲ្យពរដល់ព្រះនាងៗ ចូរបញ្ជូនមនុស្សឲ្យទៅហៅពពួកញាតិរបស់

ព្រះនាងមក ព្រះនាងមាគន្ទិយា ក៏បានផ្ញើដំណឹងទៅប្រាប់ពពួកញាតិ ឲ្យបានជ្រាបថា ព្រះរាជាទ្រង់សព្វព្រះហឫទ័យ ហើយបានប្រទានពរដល់យើង សូមជនទាំងឡាយដែលជាញាតិរបស់យើង ចូរនាំគ្នាមកឲ្យលឿន ព្រោះព្រះរាជាបញ្ជាឲ្យធ្វើនូវសក្ការៈដល់ញាតិរបស់យើងទាំងឡាយ ដែលមកហើយ ។ សូម្បីពួកជនដែលមិនមែនជាញាតិរបស់ព្រះនាងមាគន្ទិយា កាលបើឮដំណឹងដូច្នោះហើយ ក៏ឲ្យនូវសំណូក ហើយពោលថា ពួកយើងជាញាតិរបស់ព្រះនាងមាគន្ទិយា រួចក៏បាននាំគ្នាមកកាន់ព្រះរាជវាំង ។ ព្រះរាជាបញ្ជាឲ្យរាជបុរសចាប់ជនទាំងអស់នោះទុក ហើយឲ្យជីករណ្ដៅ ដែលមានជម្រៅប្រមាណត្រឹមផ្ចិតនាព្រះលានហ្លួង ហើយឲ្យកប់ជនទាំងនោះ ទៅក្នុងរណ្ដៅត្រឹមផ្ចិត បញ្ជាឲ្យរោយចំបើងពីលើក្បាល ហើយដុតភ្លើង ពេលដែលក្បាលត្រូវភ្លើងឆេះរួចហើយ បញ្ជាឲ្យរាជបុរសយកនង្គ័លទៅភ្ជួរពីលើក្បាលរបស់ជនទាំងនោះ ឲ្យដាច់ជាកំណាត់តូច កំណាត់ធំ ឬជាចំណិតតូច ចំណិតធំ ។ ព្រះរាជាបញ្ជាឲ្យពន្ទះសាច់អំពីសរីរៈរបស់ព្រះនាងមាគន្ទិយា

ដោយកាំបិតដ៏មុត ហើយឲ្យទៅអាំងលើជើងក្រាន ពេលដែលឆ្អិនហើយ ត្រាស់បញ្ជាឲ្យយកសាច់ដែលអាំងឆ្អិននោះ ឲ្យព្រះនាងមាគន្ទិយាស៊ី ។

សម័យថ្ងៃមួយ ភិក្ខុទាំងឡាយ បានសន្ទនាគ្នានៅក្នុងសាលាធម្មសភាថា នែអាវុសោទាំងឡាយ សេចក្តីស្លាប់ដូច្នេះរបស់ឧបាសិកាអ្នកដល់ព្រមដោយគុណបែបនេះ មិនសមគួរទាល់តែសោះឡើយ ។ ពេលនោះ ព្រះលោកនាថ ស្តេចយាងមកដល់ ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកបានសន្ទនាគ្នាអំពីរឿងអ្វី ? ភិក្ខុទាំងឡាយនោះក្រាបទូល ពីរឿងរបស់ព្រះនាងសាមាវតី កាលព្រះអង្គជ្រាបពីរឿងសន្ទនាគ្នាដូច្នេះហើយ ព្រះសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីស្លាប់របស់ស្ត្រីទាំងនោះ ដែលមានព្រះនាងសាមាវតីជាប្រធាននោះ បើក្នុងជាតិនេះមិនគួរមែន ប៉ុន្តែថា សេចក្តីស្លាប់របស់ស្ត្រីទាំងនោះ បើសម្តែងអំពីកម្មដែលពួកនាងបានធ្វើទុកពីជាតិមុន គួរណាស់ ភិក្ខុទាំងឡាយនោះក្រាបទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន តើពួកស្ត្រីទាំងនោះធ្វើកម្មអ្វីទុកពីជាតិមុន ទើបធ្វើ

ឲ្យពួកស្ត្រីទាំងនេះទទួលផលដូច្នេះ សូមព្រះពុទ្ធអង្គទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះករុណាទាំងឡាយផង ហើយព្រះលោកនាថ ទ្រង់ត្រាស់នាំអតីតនិទានមកត្រាស់សម្តែងថា

ក្នុងអតីតកាល មានព្រះបាទព្រហ្មទត្តសោយរាជ្យនៅក្នុងក្រុងពារាណសី មានព្រះបច្ចេកពុទ្ធ ៨ រូប តែងតែនិមន្តទៅឆាន់នៅក្នុងព្រះរាជវាំងជានិច្ច ។ ស្ត្រីទាំង ៥០០ នោះ គឺបានជាអ្នកខ្វល់ខ្វាយក្នុងការបាត់បែងបម្រើព្រះបច្ចេកពុទ្ធទាំងនោះ ។ បណ្តាព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធ ៧ រូប បាននិមន្តទៅកាន់ហិមវន្តប្រទេសមុនមួយអង្គទៀត បានទៅគង់ចូលឈាននៅក្នុងគុម្ពោតស្មៅមួយកន្លែងនៅក្បែរឆ្នេរស្ទឹង ។ ថ្ងៃមួយ កាលព្រះបច្ចេកពុទ្ធនិមន្តទៅហើយ ព្រះរាជាទ្រង់បាននាំស្ត្រីទាំងនោះ ទៅដើម្បីងូតទឹកលេងក្នុងស្ទឹង ស្ត្រីទាំងនោះបានងូតទឹកលេងក្នុងស្ទឹងនោះពេញមួយថ្ងៃ ដូច្នេះ ពេលដែលឡើងពីទឹកមកវិញក៏រងា ក៏នាំគ្នារកអុសបង្កាត់ភ្លើងអាំង ដោយពោលថា នែនាងដ៏ចម្រើនទាំងឡាយ គប្បីរកមើលទីបង្កាត់ភ្លើងដើម្បីអាំង ដើរមើលចុះ

មើលឡើង ក៏បានឃើញគុម្ពោតស្មៅមួយកន្លែង ដែលដុះស៊ុបទ្រុប មានស្មៅឆាប់ ទើបនាំគ្នាទៅឈរចោមរោមទីនោះ ដុតភ្លើងឡើង ដោយសម្គាល់ថា ជាគុម្ពោតស្មៅ កាលស្មៅទាំងនោះឆេះហើយធ្លាក់ស្រុតចុះមក ស្ត្រីទាំងនោះបានឃើញព្រះបច្ចេកពុទ្ធ ក៏ពោលថា យើងវិនាសហើយៗ ព្រះបច្ចេកពុទ្ធ របស់ព្រះរាជាពួកយើងត្រូវឆេះភ្លើងនេះស្លាប់ហើយ ព្រះរាជាកាលបើទ្រង់ជ្រាបនឹងធ្វើឲ្យពួកយើងវិនាសមិនខាន ហេតុដូច្នេះ ពួកយើងនាំគ្នាដុតលោកឲ្យឆេះសុសទាំងអស់ទៅ កុំឲ្យមានសេសសល់ គ្រប់គ្នាបាននាំគ្នា ទៅយកអុសពីទីដទៃមកដាក់បន្ថែមដុតព្រះបច្ចេកពុទ្ធនោះទៀត រហូតដល់មានគំនរអុសយ៉ាងធំ នៅពីលើព្រះបច្ចេកពុទ្ធ ។ គ្រានោះ ស្ត្រីទាំងនោះ បានដុតអុសនោះឡើងហើយ នាំគ្នាចៀសចេញទៅ ដោយសម្គាល់ថា ឥឡូវនេះ ភ្លើងឆេះលោកម្ចាស់សុសអស់ហើយ ។ កាលដុតលើកមុន ពួកស្ត្រីទាំងនោះ មិនមានចេតនានឹងដុតឡើយ ដុតលើកទី ២ ទើបជាកម្មជាប់តាមមកដល់កាលឥឡូវនេះ សូម្បីជនទាំងឡាយនាំគ្នាយកអុសមួយពាន់រទេះមកដុត ក៏មិនអាចដើម្បីនឹងធ្វើ

ឲ្យព្រះបច្ចេកពុទ្ធ ដែលគង់ចូលសមាបត្តិ ឲ្យមានអាការ គឺចំហាយក្ដៅបន្តិចបន្តួចកើតបានឡើយ ។ ក្នុងថ្ងៃទី ៧ ព្រះបច្ចេកពុទ្ធក៏បានចេញពីសមាបត្តិ និមន្តទៅតាមសប្បាយ ។ ដោយកម្មនោះ ស្ត្រីទាំងនោះក្រោយអំពីអស់ជីវិតទៅ បានទៅឆេះក្នុងនរកអស់ច្រើនពាន់ឆ្នាំ ព្រោះកម្មដែលខ្លួន បានធ្វើទុកហើយនោះឯង រួចពីនរកមកកើតជាមនុស្សដោយទំនងនេះអស់ ១០០ ជាតិមកហើយ ដោយវិបាកដ៏សេសនៃកម្មនោះឯង ទើបជាតិនេះ ត្រូវគេដុតឆេះឲ្យស្លាប់ក្នុងប្រាសាទនេះទៀត ។

ថ្ងៃមួយ ភិក្ខុទាំងឡាយ បានអង្គុយសន្ទនាគ្នាក្នុងសាលាធម្មសភាថា ស្ត្រីទាំង ៥០០ នាក់ ដែលមានព្រះនាងសាមាវតីជាប្រធានត្រូវភ្លើងឆេះហើយក្នុងជំណាក់ ចំណែកពពួកញាតិរបស់ព្រះនាងមាគន្ទិយាត្រូវភ្លើងចំបើងឆេះពីខាងលើក្បាល ហើយបំបែកឲ្យបែកខ្ទេចដោយនង្គ័លដែក រីឯព្រះនាងមាគន្ទិយា ត្រូវរាជបុរសយកកាំបិតដ៏មុតមកពន្លះសាច់ជាដុំៗ រួចយកសាច់ទាំងនោះទៅអាំង ហើយឲ្យនាងស៊ីសាច់ខ្លួនឯង ក្នុងបណ្ដាជនទាំងនោះ នរណាហ្ន៎ ឈ្មោះថា រស់នៅ នរណាហ្ន៎

ឈ្មោះថា ស្លាប់ហើយ ? ព្រះភគវាស្តេចយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកអង្គុយសន្ទនាគ្នាអំពីរឿងអ្វី? ភិក្ខុទាំងឡាយនោះ បានក្រាបទូលនូវការសន្ទនាគ្នាពីរឿងរបស់ព្រះនាងសាមាវតី និងពីរឿងព្រះនាងមាគន្ទិយា កាលព្រះសម្ពុទ្ធ ទ្រង់ជ្រាបដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយប្រមាទហើយ បុគ្គលនោះ សូម្បីរស់នៅអស់ ១០០ ឆ្នាំ ក៏ឈ្មោះថាស្លាប់ហើយដោយពិត បុគ្គលណាមួយមិនប្រមាទហើយ បុគ្គលនោះ សូម្បីស្លាប់ទៅហើយ ក៏ឈ្មោះថា នៅរស់ ព្រោះដូច្នោះ ព្រះនាងមាគន្ទិយា ទោះបីរស់នៅក៏ដោយ ស្លាប់ទៅហើយក៏ដោយ ក៏ឈ្មោះថាស្លាប់ហើយដោយពិត ចំណែកស្ត្រី ៥០០ នាក់វិញ ដែលមានព្រះនាងសាមាវតីជាប្រធាន សូម្បីស្លាប់ទៅហើយ ក៏ឈ្មោះថានៅរស់ដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះថា អ្នកមិនប្រមាទហើយ ឈ្មោះថា រមែងមិនស្លាប់ ព្រោះដូច្នោះ ព្រះអង្គទ្រង់ត្រាស់សម្តែងព្រះគាថានេះថា

*សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ*

ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកជាបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ទើបស្ថិតនៅក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ ជាគោចរនៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានសេចក្តីព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។

ក្នុងព្រះគាថានេះ មានសេចក្តីអធិប្បាយរបស់ព្រះអដ្ឋកថាចារ្យក្នុងសេចក្តីខ្លះ ដើម្បីឲ្យងាយយល់ ដូចពាក្យថា សេចក្តីមិនប្រមាទរមែងមានសេចក្តីទូលំទូលាយ រួមសេចក្តីទូលំទូលាយចូលទុក ព្រោះថាព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងអស់ ដែលអាចារ្យទាំងឡាយពោលមកតែងប្រជុំចុះក្នុងសេចក្តីមិនប្រមាទនោះឯង ។ ព្រោះហេតុនោះ ព្រះមុនីទើបព្រះអង្គទ្រង់ត្រាស់សម្តែងទុកថា ម្នាលភិក្ខុទាំងឡាយ ស្នាមជើង

របស់សត្វទាំងឡាយ ដែលត្រាច់ទៅលើផែនដីទាំងអស់នោះ តែងដល់នូវការប្រជុំចុះក្នុងស្នាមជើងនៃសត្វដំរី ស្នាមជើងនៃសត្វដំរីប្រាកដជាប្រសើរជាង ស្នាមជើងនៃពពួកសត្វទាំងអស់ ព្រោះហេតុថា ស្នាមជើងនៃសត្វដំរីជាស្នាមជើងធំ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងអស់ ក៏មានសេចក្តីមិនប្រមាទជាឫសគល់ រួមប្រជុំចុះក្នុងសេចក្តីមិនប្រមាទ សេចក្តីមិនប្រមាទ ដែលតថាគតពោលថា ជាកំពូលនៃកុសលធម៌ក៏ដូច្នោះដែរ ។ សេចក្តីមិនប្រមាទនោះ កាលពោលដោយសេចក្តី បានដល់ ការនៅមិនប្រាសចាកសតិ ព្រោះពាក្យថា សេចក្តីមិនប្រមាទនេះ ជាឈ្មោះនៃសតិ ដែលបានតាំងប្រុងជានិច្ច ។ ពាក្យថា **ជាផ្លូវនៃសេចក្តីមិនស្លាប់** សំដៅដល់ព្រះនិព្វាន ដែលហៅថារបស់មិនស្លាប់ ព្រោះព្រះនិព្វាននោះ ឈ្មោះថា មិនចាស់ មិនស្លាប់ ដោយហេតុដែលមិនមានការកើតឡើង ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ត្រាស់ហៅនូវព្រះនិព្វាននោះថា **អមតៈ** ប្រែថា **មិនស្លាប់** ។ បុគ្គលទាំងឡាយរមែងបានសម្រេចអមតៈ គឺការមិនស្លាប់ដោយសេចក្តីមិនប្រមាទនេះ ។

ព្រោះហេតុនោះ សេចក្ដីមិនប្រមាទ ឈ្មោះថា **ជាគ្រឿងដល់នូវអមតៈ** មានសេចក្ដីអធិប្បាយថា ជាឧបាយ ឬជាគ្រឿងបានសម្រេចនូវធម្មជាត ដែលមិនចេះស្លាប់ ។ ពាក្យថា **សេចក្ដីប្រមាទ** បានដល់ ការស្រវឹង សេចក្ដីប្រមាទនេះ ជាឈ្មោះនៃការខ្វះសតិ សំដៅដល់ ការភ្លេចសតិ ឬវង្វេងស្មារតី ។ ពាក្យថា **ផ្លូវនៃសេចក្ដីស្លាប់** ព្រោះជាអ្នកប្រមាទ ហើយ រមែងមិនកន្លងផុតចាកការកើតទៅទៀតបាន អ្នកកើតហើយ ក៏មានការចាស់ មានការស្លាប់ ព្រោះហេតុនោះ សេចក្ដីប្រមាទ ទើប ឈ្មោះថា ជាផ្លូវនៃសេចក្ដីស្លាប់ គឺរមែងនាំគេចូលទៅរកសេចក្ដីស្លាប់ ។ ពាក្យថា **អ្នកប្រមាទហើយ** ទោះបីរស់នៅក៏ឈ្មោះថា ស្លាប់ហើយ ព្រោះ មិនផុតចាកទុក្ខ មានជាតិ គឺការកើតជាដើម ។ ចំណែកអ្នកមិនប្រមាទ ជាអ្នកធ្វើលក្ខណៈនៃសេចក្ដីមិនប្រមាទឲ្យចម្រើនហើយ ធ្វើឲ្យជាក់ច្បាស់ នូវមគ្គផលបានដោយរហ័ស រមែងមិនកើតជាត្តខ្ធទី ២ និងទី ៣ ទៀត ព្រោះហេតុនោះ បុគ្គលអ្នកមិនប្រមាទហើយ ទោះរស់នៅក្ដី ស្លាប់ទៅ ហើយក្ដី ក៏ឈ្មោះថា មិនស្លាប់ដោយពិតប្រាកដ ។ បុគ្គលណាប្រមាទ

ហើយ បុគ្គលនោះ ដូចជាបុគ្គលដែលស្លាប់ទៅហើយដែរ ដោយការដាច់ជីវិតិន្ទ្រិយ មិនមានវិញ្ញាណដូចជាកំណាត់ឈើដូច្នោះ ព្រោះជាអ្នកស្លាប់ហើយដោយ សេចក្តីស្លាប់ គឺសេចក្តីប្រមាទ ព្រោះថាចិត្តត្រឹមតែមួយដួងថា យើងនឹងឲ្យទាន នឹងរក្សាសីល នឹងធ្វើឧបោសថកម្មដូចនេះ ក៏មិនកើតឡើងដល់បុគ្គលនោះ ដែលជាពួកគ្រហស្ថ ដូចជាមនុស្សស្លាប់ហើយ ។

ចំណែកបព្វជិត ជាអ្នកប្រមាទហើយ ក៏មិនមានចិត្តត្រឹមតែមួយដួងដែលកើតឡើងថា យើងបំពេញវត្តទាំងឡាយ មានអាចរិយវត្តនិងឧបជ្ឈាយវត្ត ដែលគប្បីបដិបត្តិចំពោះឧបជ្ឈាយ៍របស់ខ្លួន យើងនឹងសមាទានធុតង្គ យើងនឹងចម្រើនភាវនា បុគ្គលទាំងនោះនឹងមានហេតុផ្សេងពីមនុស្សដែលស្លាប់ទៅហើយ ព្រោះហេតុនោះ ព្រះលោកនាថទើបទ្រង់ត្រាស់ថា បុគ្គលពួកណាប្រមាទហើយ បុគ្គលពួកនោះ ដូចជាមនុស្សស្លាប់ទៅហើយដែរ ។ ពាក្យថា **រមែងដឹងសេចក្តីផ្សេងគ្នានោះ** គឺដឹងថា ការលះចេញចាកនូវវដ្តៈ រមែងមិនមានដល់អ្នកប្រមាទ

តែមានដល់អ្នកមិនប្រមាទប៉ុណ្ណោះ ។ មានពាក្យសួរថា នរណាទៅដែលអាចដឹងនូវសេចក្តីប្លែកគ្នានោះបាន ? ឆ្លើយថា បណ្ឌិតទាំងឡាយតែងនៅក្នុងសេចក្តីមិនប្រមាទ ឬរមែងដឹងសេចក្តីប្លែកគ្នានៃសេចក្តីនោះបានដែរ ។ អធិប្បាយថា **បណ្ឌិត** គឺអ្នកប្រាជ្ញ បានដល់ អ្នកដែលមានបញ្ញា ដែលតែងតែតាំងនៅក្នុងសេចក្តីមិនប្រមាទរបស់ខ្លួនហើយធ្វើនូវសេចក្តីមិនប្រមាទឲ្យចម្រើនឡើង បណ្ឌិតទាំងនេះ រមែងដឹងហេតុដែលប្លែកគ្នានោះបាន ។ ជនជាបណ្ឌិតទាំងនោះ លុះដឹងយ៉ាងនេះហើយរមែងរីករាយ គឺជាអ្នកមានទឹកមុខញញឹម មានចិត្តរីករាយត្រេកអរក្នុងការមិនប្រមាទរបស់ខ្លួននោះ ។ ពាក្យថា **រីករាយនៅក្នុងគោចរនៃព្រះអរិយៈទាំងឡាយ** មានពាក្យអធិប្បាយថា ជនជាបណ្ឌិតទាំងនោះពេលដែលរីករាយនៅក្នុងសេចក្តីមិនប្រមាទយ៉ាងនេះ ក៏ប្រព្រឹត្តតាមសេចក្តីមិនប្រមាទនោះ ឲ្យចម្រើនក្រៃលែងឡើង ហើយឈ្មោះថាជាអ្នករីករាយ គឺជាអ្នករីករាយក្នុងពោធិបក្ខិយធម៌ទាំង ៣៧ ប្រការមានសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥

ពោជ្ឈង្គ ៧ មគ្គដែលប្រកបដោយអង្គ ៨ ប្រការ និងលោកុត្តរធម៌ ៩ ប្រការ ដែលរាប់ថាជាទីគោចរ របស់ព្រះអរិយបុគ្គលទាំងឡាយ បានដល់ ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវករបស់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនានេះចប់ មានមនុស្សជាច្រើននាក់ បានសម្រេចជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។

សេចក្តីល្អ របស់ព្រះនាងសាមាវតី ព្រោះអាស្រ័យការមានមេត្តាចិត្តនេះ មហាជនបាននាំគ្នាពោលសរសើរថា ព្រះនាងសាមាវតីទ្រង់រារាំងកូនសររបស់ព្រះរាជា ដែលទ្រង់កំពុងតែពិរោធ ដោយព្រះនាងបានផ្សាយមេត្តាចិត្តទៅដល់ព្រះរាជា តមកជាខាងក្រោយ ព្រះអង្គដែលទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់បានប្រារព្ធយកមេត្តាចិត្ត របស់ព្រះនាងសាមាវតីជាដើមហេតុ ហើយទ្រង់ប្រកាសតែងតាំងនាងទុកក្នុងតំណែងជាឯតទគ្គៈ តាមដែលមានសម្តែងនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ មេត្តាវិហារីនំ យទិទំ សាមាវតី** ម្នាលភិក្ខុទាំងឡាយ ព្រះនាងសាមាវតីជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ដែលជាឧបាសិការបស់តថាគត ផ្នែកខាងជាអ្នកនៅដោយមេត្តាចិត្ត ។

ពាក្យថា **មេត្តា** ប្រែថា សេចក្តីស្រឡាញ់ និងការអាណិតអាសូរ មានសេចក្តីថា មានសេចក្តីប្រាថ្នាចង់ឲ្យអ្នកដទៃបានសេចក្តីសុខ បានផ្សាយមេត្តាចិត្ត គិតនឹងឲ្យសត្វទាំងពួង បានសេចក្តីសុខគ្រប់គ្នា ដូចមានពាក្យផ្សាយមេត្តាថា **សព្វេ សត្តា** សត្វទាំងឡាយ ទាំងពួងដែលដល់នូវសេចក្តីទុក្ខ កើត ចាស់ ឈឺ ស្លាប់ ទាំងអស់ ។ **អវេរា ហោន្តុ** ចូរនៅជាសុខចុះ កុំមានពៀរដល់គ្នានឹងគ្នាឡើយ **អព្យាបជ្ឈា ហោន្តុ** ចូរនៅជាសុខចុះ កុំព្យាបាទបៀតបៀននូវគ្នានឹងគ្នាឡើយ ។ **អនីឃា ហោន្តុ** ចូរនៅជាសុខចុះ កុំមានសេចក្តីទុក្ខ តាមផ្លូវកាយ និងតាមផ្លូវចិត្តឡើយ ។ **សុខី អត្តានំ បរិហរន្តុ** ចូរមានសេចក្តីសុខកាយសប្បាយចិត្ត រក្សាខ្លួនឲ្យផុតចាកទុក្ខភ័យទាំង អស់ចុះ ។

អ្នកចម្រើនមេត្តាចិត្តជានិច្ច រហូតដល់ចិត្តតាំងមាំនៅក្នុងមេត្តា មានមេត្តាចិត្តជាធម៌ប្រចាំខ្លួនហើយ រមែងទទួលអានិសង្ស ៨ ប្រការ តាមដែលមានសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ នវមភាគនិបាត ក្នុងមេត្តាវគ្គ** ដូចមានសេចក្តីថា ៖

១- ដេកលក់ជាសុខ ២- ភ្ញាក់ឡើងជាសុខ ៣- មិនឃើញនូវសុបិនអាក្រក់ ៤- ជាទីស្រឡាញ់នៃពួកមនុស្ស ៥- ជាទីស្រឡាញ់នៃអមនុស្ស ៦- ពួកទេវតាតែងរក្សា ៧- ថ្នាំពិសក្តី សស្ត្រាវុធក្តី ភ្លើងក្តី មិនប៉ះពាល់នូវបុគ្គលនោះ ៨- កុសលបើមិនទាន់បានគុណវិសេសដ៏ខ្ពង់ខ្ពស់ទេ រមែងទៅកើតក្នុងព្រហ្មលោក ។

នៅមានអានិសង្សរបស់មេត្តាចិត្ត ដែលមានសម្តែងនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដែលពោលអំពីផលនៃមេត្តាចិត្តថា ៖

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប់ប្រសព្វនឹងមេត្តាចិត្ត សូម្បីមួយផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា មានឈានមិនបានលះបង់ ជាអ្នកធ្វើតាមសាសនាព្រះសាស្តា ជាអ្នកធ្វើ

តាមឱវាទព្រះសាស្តា បរិភោគចង្ហាន់អ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវមេត្តាចិត្ត សូម្បីមួយផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា មានឈានមិនបានលះបង់ ជាអ្នកធ្វើតាមសាសនាព្រះសាស្តា ជាអ្នកធ្វើតាមឱវាទព្រះសាស្តា បរិភោគចង្ហាន់អ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វីដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះនូវមេត្តាចិត្ត សូម្បីមួយផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា មានឈានមិនបានលះបង់ ជាអ្នកធ្វើតាមសាសនាព្រះសាស្តា ជាអ្នកធ្វើតាមឱវាទព្រះសាស្តា បរិភោគចង្ហាន់អ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វីដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

នៅក្នុងអដ្ឋកថាមនោរថបូរណី បានអធិប្បាយនៅត្រង់ពាក្យថាចាន់ដុំបាយរបស់អ្នកស្រុកមិនទទេបាកប្រយោជន៍ អាហារដែលអ្នកស្រុក

ប្រគេនដល់ភិក្ខុ អ្នកអប់រំដោយមេត្តាចិត្ត សូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃប៉ុណ្ណោះ ក៏ជារបស់មានផលច្រើន ឬអានិសង្សច្រើន មិនបាច់ពោលថ្វីដល់ដុំបាយ ដែលប្រគេនដល់ភិក្ខុដែលជាអ្នកអប់រំមេត្តាចិត្តឲ្យច្រើនជារឿយៗ នោះ ៕

( ជីវប្រវត្តិរបស់ព្រះនាងសាមាវតី ចប់ )

8888888888888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ឧបាសិកាឧត្តរានន្ទមាតា ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកត្រេកអរក្នុងឈាន "

ឧបាសិកាឧត្តរានន្ទមាតា ជាអ្នកមានចិត្តល្អ ដោយការឲ្យអភ័យក្នុងកំហុសរបស់អ្នកដទៃ ដែលបានធ្វើនូវអំពើអាក្រក់ចំពោះខ្លួន ដូចដែលហៅបានថា ព្រះឈ្នះមារ ដោយប្រើសេចក្តីល្អ ឈ្នះសេចក្តីអាក្រក់ នាងជាអរិយឧបាសិកា ដែលមានតំណែងជាឯតទគ្គៈ ដែលជាការរ៉ាប់រងអំពីកិត្តិគុណ ចំណេះដឹង ភាពអង់អាច និងសេចក្តីល្អ របស់នាងដែលបានធ្វើទុករួចមកហើយ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ឧបាសិកា **ឧត្តរានន្ទមាតា** មានពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

ក្នុងអតីតកាល រាប់ថយក្រោយអំពីភទ្រកប្បនេះទៅបានមួយសែនកប្ប **នាងឧត្តរា** បានកើតនៅក្នុងត្រកូលរបស់អ្នកមានធនធានម្នាក់

នៅក្នុងក្រុងហង្សវតី ដែលត្រូវនឹងពុទ្ធកាលនៃព្រះបទុមុត្តរសម្ពុទ្ធ ។ ថ្ងៃមួយ **នាងឧត្តរា** បានទៅស្ដាប់ព្រះធម៌ទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ បានឃើញព្រះអង្គប្រកាសតែងតាំងឧបាសិកាម្នាក់ ទុកក្នុងតំណែងជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងជាអ្នកត្រេកអរក្នុងឈាន កាលនាងបានឃើញដូច្នោះហើយ នាងក៏មានការពេញចិត្តក្នុងតំណែងនោះ ទើបបានធ្វើបុណ្យ ហើយតាំងចិត្តប្រាថ្នា ដើម្បីឲ្យបាននូវតំណែងនោះក្នុងកាលជាអនាគត ។ លុះនាងកុលធីតាអស់ជីវិតអំពីជាតិនោះទៅហើយ នាងបានស្លាប់កើតៗ ស្លាប់ជាមនុស្ស និងទេវតាអស់មួយសែនកប្ប ។

លុះមកដល់បច្ចុប្បន្នជាតិនេះ ដែលរាប់ថាជាជាតិចុងក្រោយរបស់នាងឧត្តរានន្ទមាតា ដែលមានជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិនេះ មានសម្ដែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **អដ្ឋកថាធម្មបទ** នៃ **កោធវគ្គ** ក្នុងរឿងរបស់នាងឧត្តរា និងក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីនៅក្នុង **គម្ពីរខុទ្ទកនិកាយ វិមានវត្ថុ** ដូចមានសេចក្ដីថា ៖

កាលព្រះមានបុណ្យប្រថាប់នៅក្នុងវត្តវេឡុវ័ន នាក្រុងរាជគ្រឹះ ទ្រង់ធ្វើភត្តកិច្ចនៅក្នុងផ្ទះរបស់នាងឧត្តរាហើយ ទ្រង់ប្រារព្ធឧបាសិកាឧត្តរា បានត្រាស់ព្រះធម៌ទេសនាប្រោសដល់មហាជន ដែលមកប្រជុំក្នុងពេលនោះ ។ ឧបាសិកាឧត្តរា ជាធីតារបស់នាយបុណ្ណៈ ចំណែកមាតារបស់នាងមិនឃើញមានប្រាកដឈ្មោះទេ ។ ឈ្មោះរបស់នាងថា **ឧត្តរា** នេះ ជាឈ្មោះដែលមាតាបិតាដាក់ឈ្មោះឲ្យតាំងអំពីកំណើតមក ។ ត្រកូលរបស់នាងឧត្តរា ជាត្រកូលក្រីក្រកម្សត់ ត្រូវទៅនៅអាស្រ័យក្នុងផ្ទះរបស់សុមនសេដ្ឋី ដោយឪពុកម្តាយរបស់នាង បានទទួលស៊ីឈ្នួលធ្វើការងារបិញ្ចឹមជីវិតរស់នៅក្នុងក្រុងរាជគ្រឹះ ក្នុងផ្ទះរបស់នាងមានគ្នា ៣ នាក់ គឺនាយបុណ្ណៈ ១ ភរិយារបស់នាយបុណ្ណៈ ១ រួមទាំងខ្លួននាងដែលជាកូនស្រី ។ ថ្ងៃមួយ ពួករាជបុរសធ្វើការស្រែកប្រកាសខ្លាំងៗ ក្នុងក្រុងរាជគ្រឹះថា អ្នកទាំងឡាយនាំគ្នាទៅលេងបុណ្យនក្ខត្តឫក្សប្រចាំឆ្នាំរហូត ៧ ថ្ងៃទាំងអស់គ្នា ។ គ្រានោះ សុមនសេដ្ឋីកាលបានឮពាក្យស្រែកប្រកាសអញ្ជើញឲ្យទៅលេងបុណ្យនក្ខត្តឫក្សដូច្នេះហើយ ទើបឲ្យហៅ

នាយបុណ្ណៈមកជួបតាំងពីព្រឹកព្រលឹម បានសួរថា នែបាបុណ្ណៈ កាលបើដល់ថ្ងៃបុណ្យនក្ខត្តឫក្ស ឬថ្ងៃឧបោសថ បរិវាររបស់ខ្ញុំទាំងអស់បាននាំគ្នាទៅលេងបុណ្យនក្ខត្តឫក្ស បាទៅលេងនឹងគេ ឬថា បាទៅធ្វើការងារ ? ទើបនាយបុណ្ណៈ ជម្រាបតបថា បាទនាយ ខ្ញុំប្រឹក្សានឹងភរិយារបស់ខ្ញុំសិន ហើយនឹងជម្រាបលោកនាយជាខាងក្រោយ កាលថាដូច្នេះហើយ គេក៏ទៅប្រាប់រឿងទាំងអស់នេះឲ្យភរិយាបានដឹង ។ ចំណែកភរិយាបានពោលនឹងបុណ្ណៈថា បង លោកសេដ្ឋីជាចៅហ្វាយនាយជាអ្នកមានអំណាចលើយើង កាលលោកសេដ្ឋីសន្ទនាជាមួយនឹងបងយ៉ាងនោះ ជារឿងមួយល្អដែរ ដូច្នេះបងកុំបោះបង់ចោលការងារធ្វើស្រែឡើយណា ។ នាយបុណ្ណៈ កាលបើប្រឹក្សាជាមួយនឹងភរិយារួចហើយ បានត្រឡប់ទៅជម្រាប ឲ្យលោកសេដ្ឋីបានជ្រាបថា បាទលោកនាយការទៅលេងនក្ខត្តឫក្ស រមែងជាភារៈរបស់លោកអ្នកមានទ្រព្យក្នុងផ្ទះរបស់ខ្ញុំ សូម្បីត្រឹមតែអង្ករដែលនឹងត្រូវប្រើប្រាស់ដាំបាយ ដើម្បីទទួលទានក្នុងថ្ងៃស្អែកនេះ នៅមិនទាន់មាននៅឡើយ ខ្ញុំមិនប្រាថ្នាដើម្បីទៅលេង

នក្ខត្តឫក្សទេ ប្រសិនបើខ្ញុំបានគោហើយ ខ្ញុំនឹងលីនង្គ័លទៅភ្ជួរស្រែវិញ ។ សុមនសេដ្ឋីពោលថា បើដូច្នោះ អ្នកចូរទទួលយកគោទៅចុះ ។ នាយបុណ្ណៈទទួលយកគោដែលមានកម្លាំងទៅភ្ជួរស្រែ ថែមទាំងបាននិយាយនឹងភរិយាខ្លួនថា នែនាងដ៏ចម្រើន អ្នកក្រុងគេនាំគ្នាទៅលេងនក្ខត្តឫក្ស ខ្លួនខ្ញុំនឹងត្រូវទៅធ្វើការស៊ីឈ្នួល ព្រោះយើងជាមនុស្សទ័លក្រ ថ្ងៃនេះនាងចូរដាំបបរលាយបន្លែពីរចំណែក ហើយនាំយកអាហារទៅឲ្យបងផង កាលគេប្រាប់ដល់ភរិយាយ៉ាងនេះហើយ គេក៏បានដើរទៅភ្ជួរស្រែបាត់ទៅ ។

ក្នុងកាលនោះ ព្រះសារីបុត្រដ៏មានអាយុ បានចូលនិរោធសមាបត្តិមករហូត ៧ ថ្ងៃហើយ ក្នុងថ្ងៃដែលលោកបានចេញពីនិរោធសមាបត្តិហើយ លោកបានប្រមើលមើលថា ថ្ងៃនេះអាត្មាអញ គប្បីទៅធ្វើសេចក្តីអនុគ្រោះដល់នរណាហ្ន៎ ពិចារណាទៅៗ ក៏បានឃើញនាយបុណ្ណៈចូលមកក្នុងសំណាញ់ញាណរបស់លោក និងបានប្រមើលទៅទៀតថា នាយបុណ្ណៈនេះ មានសទ្ធាឬទេ គេអាចធ្វើការសង្គ្រោះដល់អាត្មាអញឬទេ ហើយដឹងថា គេជាអ្នកមានសទ្ធា មានសេចក្តីអង់អាច ដែល

សមគួរនឹងធ្វើការសង្គ្រោះបាន ហើយគេប្រាកដនឹងបានទទួលសម្បត្តិយ៉ាងធំ ព្រោះបុណ្យនោះជាបច្ច័យហើយ កាលលោកគិតឃើញដូច្នេះ ទើបលោកកាន់យកបាត្រនិមន្តទៅកាន់កន្លែង ដែលបុណ្ណៈកំពុងភ្ជួរស្រែ ដែលជាវេលាស្វែងរកកិច្ចារបស់ភិក្ខុសង្ឃ ព្រះថេរៈបានទៅឈរសម្ងំ គុម្ពោតឈើមួយគុម្ពនៅក្បែរអណ្តូងទឹក គឺនៅមិនឆ្ងាយពីកន្លែងបុណ្ណៈប៉ុន្មានឡើយ ។ គ្រានោះ នាយបុណ្ណៈបានក្រឡេកឃើញព្រះធម្មសេនាបតីសារីបុត្រហើយ ទើបសម្រាកភ្ជួរស្រែ ចូលទៅរកព្រះថេរៈ ហើយថ្វាយបង្គំព្រះថេរៈ ដោយបញ្ចង្គប្រតិស្ឋាន ។ ព្រះសារីបុត្របានសួរនាយបុណ្ណៈដល់ទីកន្លែង ដែលល្មមនឹងទៅរកទឹកបាន ។ នាយបុណ្ណៈគិតថា ព្រះថេរៈគង់នឹងត្រូវការឈើស្ទន់ និងទឹកលុបមុខ ទើបគេបានធ្វើឈើស្ទន់ឲ្យជាកប្បិយៈ គឺរបស់ដែលគួរ ( សេចក្តីថា វត្ថុដែលសមគួរដល់ភិក្ខុសង្ឃប្រើប្រាស់ ) ។ ពេលនោះ ព្រះសារីបុត្រ កាលបានទទួលឈើស្ទន់ហើយ បាននាំយកបាត្រ និងសំពត់តម្រងទឹកចេញមកឲ្យនាយបុណ្ណៈ ។ នាយបុណ្ណៈគិតថា លោកម្ចាស់ប្រាកដជាត្រូវ

ការទឹកធាន់ គេបានទទួលយកបាត្រ និងសំពត់តម្រងទឹកពីព្រះថេរៈមក ក្នុងខណៈដែលព្រះថេរៈកំពុងទំពាឈើស្ទន់ គេបាននាំយកបាត្រ និង សំពត់តម្រងទឹកមករៀបចំការត្រងទឹកប្រគេនដល់ព្រះថេរៈ ។លុះព្រះ សារីបុត្រលុបមុខរួចហើយ គិតថា ផ្ទះរបស់នាយបុណ្ណៈនៅក្រោយគេ បំផុតនៃផ្ទះអ្នកដទៃ ប្រសិនបើអាត្មាទៅកន្លែងផ្ទះរបស់គេ ភរិយារបស់ នាយបុណ្ណៈ នឹងមិនបានឃើញអាត្មាអញ ដូច្នេះអាត្មាអញ ត្រូវតែនៅ រង់ចាំត្រង់ផ្លូវនេះចុះ ដរាបដល់ភរិយារបស់គេធ្វើដំណើរនាំយកអាហារ មកឲ្យដល់ប្តី កាលព្រះថេរៈគិតឃើញដូច្នេះហើយ បាននិមន្តនៅរង់ចាំ នៅក្នុងទីកន្លែងនោះឯង កាលបើព្រះថេរៈបានជ្រាបថា កាលបើភរិយា របស់នាយបុណ្ណៈដើរមកតាមផ្លូវហើយ អាត្មាអញនឹងនិមន្តឆ្ពោះទៅ កាន់ក្រុង ។ នាយបុណ្ណៈគិតសាឡើងវិញថា ក្នុងថ្ងៃដទៃៗ ព្រះថេរៈ មិនបាននិមន្តមកផ្លូវនេះ តែថ្ងៃនេះ ព្រះថេរៈបាននិមន្តមកកាន់ផ្លូវនេះ ប្រាកដជាមានបំណងដើម្បីអនុគ្រោះដល់យើង សូមឲ្យភរិយារបស់ យើងនាំយកអាហារ ដែលនឹងនាំយកមកឲ្យដល់យើងដាក់បាត្រព្រះ

ថេរៈផងចុះ ។ លំដាប់នោះ ភរិយារបស់នាយបុណ្ណៈក៏គិតថា ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស ព្រឹកឡើងបានចាត់ចែងភោជនីយាហារ តាមដែលរកបាន តាំងអំពីព្រឹកម៉្លេះ ហើយកាន់ភោជនីយាហារធ្វើដំណើរឆ្ពោះមកកន្លែងដែលស្វាមីភ្ជួរ តែនាងដើរមកតាមផ្លូវ បានជួបនឹងព្រះសារីបុត្រក្នុងរវាងផ្លូវ មុននឹងទៅដល់កន្លែងដែលស្វាមីភ្ជួរស្រែ ទើបនាងគិតថា ក្នុងថ្ងៃមុនៗ គ្រាខ្លះ កាលយើងមានទេយ្យធម៌ (របស់ប្រគេនព្រះសង្ឃ) យើងក៏មិនបានជួបលោកម្ចាស់ ។ គ្រាខ្លះ កាលបានជួបលោកម្ចាស់ ទេយ្យធម៌របស់យើងមិនមាន ថ្ងៃនេះបានជួបលោកម្ចាស់ហើយ ទាំងទេយ្យធម៌របស់យើងក៏មានដែរ យើងនឹងប្រគេនភត្តាហារនេះដល់ព្រះថេរៈមុន ហើយយើងនឹងរៀបចំធ្វើថ្មី រួចយកមកឲ្យដល់ស្វាមីរបស់យើងក្នុងពេលជាខាងក្រោយ នាងបានគិតថា លោកម្ចាស់នឹងធ្វើការអនុគ្រោះដល់យើងទេហ្ន៎ ទើបនាងធ្វើចិត្តឲ្យប្រកបដោយចេតនាទាំង ៣ កាល ហើយនាងដាក់ភោជនីយាហារចុះ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ថែមទាំងបានពិតព្រះថេរៈទៀតថា បពិត្រលោកម្ចាស់

ដ៏ចម្រើន សូមលោកម្ចាស់ កុំគិតថា ភត្តាហារនេះសៅហ្មង ឬប្រណីត សូមលោកម្ចាស់ធ្វើសេចក្តីអនុគ្រោះ ដល់ទាសៈរបស់លោកម្ចាស់ផង ។ ព្រះសារីបុត្រ ក៏បានបង្អោនបាត្រចូលទៅទទួល កាលនាងយកដៃម្ខាងទ្រភាជនៈ ដៃម្ខាងទៀត ជួសភត្តាហារដាក់ចុះទៅក្នុងបាត្របានពាក់កណ្តាល ទើបព្រះថេរៈយកដៃបិទមាត់បាត្រ ព្រមទាំងពោលថា នែនាងដ៏ចម្រើន ប៉ុណ្ណោះគ្រប់គ្រាន់ហើយ ។ ចំណែកភរិយារបស់នាយបុណ្ណៈ បានពិតថេរវាចាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ភត្តាហារត្រឹមតែមួយចំណែក ខ្ញុំព្រះករុណាមិនអាចធ្វើជាពីរចំណែកបានទេ សូមលោកម្ចាស់កុំធ្វើការសង្គ្រោះដល់ទាសៈរបស់លោកម្ចាស់ក្នុងលោកនេះអី សូមធ្វើការសង្គ្រោះក្នុងលោកខាងមុខវិញចុះ ខ្ញុំព្រះករុណាតាំងចិត្តប្រគេន មិនឲ្យមានសេសសល់ឡើយ ។ កាលនាងពោលដូច្នេះហើយ ក៏បានដាក់ភត្តាហារទាំងអស់ចុះទៅក្នុងបាត្ររបស់ព្រះថេរៈ ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យខ្ញុំព្រះករុណាផុតចាកអត្តភាព ជាអ្នករស់នៅក្រីក្រលំបាកក្នុងជាតិនេះ ដូចយ៉ាងការរស់នៅសព្វថ្ងៃនេះ និងសូមឲ្យខ្ញុំព្រះករុណា

គប្បីជាអ្នកមានចំណែកនៃធម៌ ដែលលោកម្ចាស់បានឃើញហើយ ។

គ្រានោះ ព្រះសារីបុត្រ ក៏បានធ្វើការអនុមោទនាដល់នាងថា ការប្រាថ្នារបស់នាងចូរសម្រេចយ៉ាងនោះចុះ ព្រះថេរៈក៏បានអង្គុយចុះឆាន់ភត្តាហារ ក្នុងទីកន្លែងដែលរកទឹកបានស្រួលមួយកន្លែង ក្រោយពីឆាន់រួចស្រេចហើយ ទើបព្រះថេរៈនិមន្តចៀសចេញទៅ ។ ចំណែកភរិយារបស់នាយបុណ្ណៈ ក៏បានត្រឡប់ទៅកាន់ផ្ទះវិញ ដើម្បីចាត់ចែងធ្វើភត្តាហារសម្រាប់ស្វាមីសាជាថ្មី ។ ឯនាយបុណ្ណៈ ភ្ជួរស្រែទៅបានប្រមាណកន្ទះករីស ( **១ ករីស=១២៥ ហត្ថ** ) មិនអាចទ្រាំការឃ្លានបានទើបគេដោះគោចេញ ហើយបានចូលទៅសម្រាក នៅក្រោមម្លប់នៃដើមឈើមួយ ដោយអង្គុយចាំមើលផ្លូវភរិយាដែលមកនោះ ។ ភរិយារបស់នាយបុណ្ណៈ កាលបើរៀបចំអម្ពិនរួចជាថ្មីស្រេចហើយ ក៏បានប្រញាប់ប្រញាល់កាន់ភាជនៈដាក់អាហារ ដើរទៅកន្លែងដែលស្វាមីភ្ជួរស្រែ ដើរៗ ទៅបណ្តើរនឹកក្រែងស្វាមីខឹងនឹងខ្លួន កាលនាងឃើញស្វាមីក៏គិតថា គាត់គង់តែមានការឃ្លានខ្លាំង នៅអង្គុយរង់ចាំយើង

បើគាត់សម្គុតយើង ដោយថា នាងយូរម៉្លេះ ហើយគាត់យកគល់ត្នោត វាយយើង កម្មដែលយើងធ្វើហើយ នឹងជារបស់មិនមានប្រយោជន៍ ហេតុដូច្នេះ យើងនឹងស្រែកប្រាប់ឲ្យដល់គាត់បានដឹងមុន លុះគិតឃើញ ដូច្នេះ ទើបនាងពោលថា បងថ្ងៃនេះ សូមបងតាំងចិត្តឲ្យធូរផង់មួយ ថ្ងៃចុះ កុំធ្វើកម្មដែលខ្ញុំបានធ្វើហើយ ឲ្យគ្មានប្រយោជន៍ ការពិតខ្ញុំបាន នាំយកអាហារឲ្យមកបងតាំងពីព្រលឹមម៉្លេះ ប៉ុន្តែបានដើរមកតាមផ្លូវ ក៏បានជួបព្រះធម្មសេនាបតីសារីបុត្រក្នុងវាងផ្លូវ ខ្ញុំក៏បានប្រគេនអាហារ របស់បងដល់ព្រះថេរៈទៅហើយ ខ្ញុំក៏បានត្រឡប់ទៅផ្ទះសាជាថ្មី ដើម្បី រៀបចំអម្ពិនអាហារមកឲ្យបងម្តងទៀត សូមបងញុំាងចិត្តឲ្យជ្រះថ្លាចុះ ។ នាយបុណ្ណៈសួរថា នែនាងដ៏ចម្រើន នាងបាននិយាយថាអ្វី ? កិរិយា របស់គេបាននិយាយដដែលម្តងទៀតឲ្យស្តាប់ ។ កាលនាយបុណ្ណៈ បានដឹងរឿងនោះហើយ ទើបនិយាយថា នែនាងដ៏ចម្រើន នាងបាន ប្រគេនចង្ហាន់ដែលជាចំណែករបស់ខ្ញុំដល់លោកម្ចាស់ រាប់ថា ជាការ ធ្វើអំពើល្អដោយពិត ព្រោះថា ពីព្រឹកមិញនេះ ខ្ញុំក៏បានប្រគេនឈើស្ទន់

និងទឹកខ្ញុំព្រះឱស្ឋដល់លោកម្ចាស់ដែរ ពោលហើយគេក៏មានចិត្តជ្រះថ្លាឡើង តាមពាក្យពោលប្រាប់របស់ភរិយា ។ សរុបសេចក្តីមកថា ចិត្តរបស់បុគ្គលទាំងពីរនាក់នោះ ជាអ្នកមានចិត្តនឹកគិតក្នុងផ្លូវល្អ ឬជាអ្នកមានបំណងល្អដូចគ្នា ។ បន្ទាប់អំពីនោះ នាយបុណ្ណៈបានបរិភោគអាហារដែលភរិយានាំមកឲ្យរួចស្រេចហើយ ក៏មានរាងកាយទន់អស់កម្លាំង ព្រោះបរិភោគអាហារក្នុងពេលរសៀលទៅហើយៗ គេក៏បានដាក់ក្បាលកើយលើភ្លៅរបស់ភរិយាដេកលក់ទៅ ។ គ្រានោះ កន្លែងដែលគេភ្ជួរអំពីព្រឹក បានក្លាយជាសាច់មាសសុទ្ធទាំងអស់ សូម្បីរហូតដល់ធូលីដីមើលទៅល្អស្អាតឥតខ្ចោះ ដូចជាគំនរផ្កាកណិការ ។ កាលបើនាយបុណ្ណៈបានដេកលក់ទៅមួយស្របក់ហើយ ក៏បានភ្ញាក់ឡើង ថែមទាំងបានក្រឡេកទៅឃើញអាចម៍បំណះក្លាយជាមាស ទើបនិយាយជាមួយនឹងភរិយាថា នែនាងដ៏ចម្រើន កន្លែងដែលខ្ញុំភ្ជួរហើយ ខ្ញុំឃើញជាមាសទាំងអស់ ឬថា ព្រោះខ្ញុំបរិភោគអាហារ ក្នុងវេលារសៀលពេកទៅ ធ្វើឲ្យភ្នែកខ្ញុំស្រវាំងមើលទៅមិនដឹង ឬយ៉ាងណាហ្ន៎ ។ សូម្បីភរិយា

របស់គេបាននិយាយរ៉ាប់រងថា ទីកន្លែងនោះ ខ្ញុំមើលទៅបានឃើញជាមាសដូចគ្នាដែរ ។ នាយបុណ្ណៈបានក្រោកឡើង ដើរសំដៅទៅកាន់ទីកន្លែងដែលភ្ជួររាស់នោះ ហើយចាប់យកដុំអាចម៍បំណះមួយដុំយកមកគោះនឹងយាមនង្គ័ល ក៏បានដឹងថាជាមាស ទើបគេហៅភរិយាមកប្រាប់ថា នៃនាងដ៏ចម្រើន ធម្មតាពូជដែលបុគ្គលដទៃៗ គេដាក់ចាំទុករមែងឲ្យផលដោយកាលកន្លងទៅបីខែ ឬបួនខែ តែពូជ គឺទានដែលយើងបានព្រោះ គឺប្រគេនដល់ព្រះសារីបុត្រ បានឲ្យផលហើយក្នុងថ្ងៃនេះឯង ដុំអាចម៍បំណះ សូម្បីប៉ុនផ្លែកន្ទួតព្រៃ ក៏ក្លាយជាដុំមាសទាំងអស់ ក្នុងទីកន្លែងប្រមាណមួយករីស បានក្លាយជាមាសទាំងអស់ ។ ភរិយារបស់គេសួរថា បង តើពេលនេះ ពួកយើងគប្បីធ្វើដូចម្តេច ទើបល្អ ? នាយបុណ្ណៈតបថា មាសច្រើនដល់ម្ល៉េះ យើងមិនអាចលាក់ទ្រព្យច្រើនទាំងនេះប្រើប្រាស់បាន ទើបប្រាប់ភរិយាឲ្យនៅក្នុងទីនេះសិន ចំណែកខ្លួនយកថាស ដែលដាក់អាហារដែលភរិយានាំយកមកឲ្យខ្លួន យកមកដាក់មាសពេញហើយ បាននាំយកទៅកាន់រាជត្រកូល លុះទៅដល់ទ្វាររាជវាំង

ក៏ឲ្យនាយឆ្មាំទ្វារចូលទៅក្រាបថ្វាយបង្គំទូលព្រះរាជាថា មានបុរសម្នាក់យកមាសមកថ្វាយព្រះអង្គ ។ គ្រានោះ ទើបព្រះរាជាត្រាស់ឲ្យនាយបុណ្ណៈចូលមកគាល់ បានត្រាស់សួរថា នែបាដ៏ចម្រើន អ្នកបានមាសនេះមកពីទីណា ? នាយបុណ្ណៈក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បានមកពីកន្លែងដែលខ្ញុំព្រះអង្គភ្ជួរស្រែ ពីព្រោះថា ក្នុងថ្ងៃនេះ កន្លែងដែលខ្ញុំព្រះអង្គភ្ជួរស្រែទាំងប៉ុន្មាន បានក្លាយជាមាសទាំងអស់ សូមព្រះករុណាម្ចាស់ជីវិតតម្កល់លើត្បូងជ្រាប គួរទឹងត្រាស់ឲ្យគេទៅដឹកមាសមកព្រះអង្គ ។ ទើបព្រះរាជាត្រាស់ថា អ្នកឈ្មោះអ្វី ? នាយបុណ្ណៈក្រាបបង្គំទូលថា ទូលព្រះបង្គំឈ្មោះបុណ្ណៈ ព្រះអង្គ ។ ព្រះរាជាត្រាស់សួរតទៅទៀតថា កាលពីព្រឹកមិញនេះ អ្នកបានធ្វើអ្វីខ្លះ ? នាយបុណ្ណៈក្រាបបង្គំទូលថា ព្រឹកមិញនេះ ទូលព្រះបង្គំជាខ្ញុំ បានប្រគេនឈើស្ទន់និងទឹកខ្ពុរព្រះឱស្ឋដល់ព្រះសារីបុត្រ ចំណែកភរិយារបស់ទូលព្រះបង្គំជាខ្ញុំ បានប្រគេនចង្ហាន់ ដែលនាំមកឲ្យទូលព្រះបង្គំជាខ្ញុំដល់ព្រះសារីបុត្រដូចគ្នា ព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យក្រាបបង្គំទូលហើយ

ត្រាស់ថា នែអ្នកដ៏ចម្រើន សរុបសេចក្ដីមកថា ទានដែលអ្នកបានប្រគេនដល់ព្រះសារីបុត្រ បានឲ្យផលក្នុងថ្ងៃនេះ ហើយទ្រង់ត្រាស់សួរតទៅទៀតថា អ្នកគប្បីធ្វើដូចម្ដេចក្នុងរឿងនេះ ? នាយបុណ្ណៈ ក្រាបបង្គំទូលថា បពិត្រព្រះតេជះជីវិតតម្កល់លើត្បូង សូមទ្រង់បញ្ជូនរទេះទៅដើម្បីដឹកមាសមកក្នុងព្រះនគរនេះចុះ ព្រះអង្គ ។

គ្រានោះ ព្រះរាជាមានព្រះរាជតម្រាស់ឲ្យពួករាជបុរស នាំរទេះជាច្រើនទៅកាន់កន្លែងស្រែ របស់នាយបុណ្ណៈដែលបានភ្ជួរអាចម៍បំណះក្លាយជាមាសនោះ ។ កាលពួករាជបុរសនិយាយថា មាសនេះជាព្រះរាជទ្រព្យរបស់ព្រះរាជាហើយ ចាប់ដុំមាសលើកឡើងមក ផលប្រាកដថាដុំមាសដែលពួកគេលើកឡើងមកកាន់នោះ ក៏បានក្លាយជាដុំអាចម៍បំណះដូចដើមវិញ ។ លុះហេតុការណ៍ប្រែប្រួលកើតឡើងដូច្នេះ ពួករាជបុរសទើបត្រឡប់ទៅក្រាបបង្គំទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាត្រាស់សួរថា ហេតុដែលមានដូចនេះ ពួកលោកនិយាយថាយ៉ាងណា ក្នុងខណៈដែលចាប់ដុំមាសយកមក ។ ពួករាជបុរសក្រាបបង្គំទូលថា ក្នុង

ខណៈដែលទូលបង្គំជាខ្ញុំទាំងឡាយចាប់ដុំមាសនោះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយនិយាយថា មាសនេះជាព្រះរាជទ្រព្យរបស់ព្រះរាជាព្រះករុណាថ្លៃវិសេស ។ ទើបព្រះរាជាត្រាស់ថា មាសនោះមិនមែនជាទ្រព្យរបស់យើងទេ ពួកលោកចូរត្រឡប់ទៅវិញចុះ ពេលដែលពួកលោកចាប់ដុំមាសឡើង ពួកលោកចូរនិយាយថា មាសនេះជារបស់នាយបុណ្ណៈ ។ ពួករាជបុរសបាននាំគ្នាត្រឡប់ទៅកាន់ស្រែរបស់នាយបុណ្ណៈ ហើយបាននាំគ្នាធ្វើតាមព្រះរាជបញ្ជារបស់ព្រះរាជា ដូច្នេះមាសដែលពួកគេចាប់លើកមកហើយៗ ក៏ជាមាសពិតៗ ហើយពួកគេទើបដឹកមាសទាំងអស់នោះមកគរទុកនៅត្រង់ព្រះលានហ្លួង ។ មាសទាំងអស់ ដែលពួករាជបុរសដឹកមកគរជាគំនរនោះ មានកម្ពស់ប្រមាណ ៨០ ហត្ថ ។ ព្រះរាជាមានព្រះរាជតម្រាស់ត្រាស់ឲ្យប្រជាជន ក្នុងព្រះនគរមកប្រជុំគ្នា ហើយត្រាស់សួរថា ក្នុងព្រះនគរនេះ មាននរណាមានមាសដល់ម៉្លេះខ្លះឬទេ ? ពេលនោះ ប្រជាជនក្នុងព្រះនគរក្រាបបង្គំទូលថា សូមតេជះជីវិតតម្កល់លើត្បូង មិនមាននរណាមានមាសដល់

ម៉្លេះទេ ព្រះករុណាថ្លៃវិសេស ។ ទើបព្រះរាជា ត្រាស់សួរប្រជាជនក្នុងព្រះនគរថា គួរនឹងឲ្យងារអ្វីដល់នាយបុណ្ណៈ អ្នកដែលជាម្ចាស់របស់ទ្រព្យ មានចំនួនច្រើនដល់ប៉ុណ្ណេះ ? ប្រជាជនក្រាបបង្គំទូលថា គួរតាំងងារឲ្យនាយបុណ្ណៈជាសេដ្ឋី ព្រះករុណាថ្លៃវិសេស ។ ព្រះរាជាមានព្រះរាជឱង្ការថា នាយបុណ្ណៈ លោកចូរជាសេដ្ឋីឈ្មោះថា **ពហុធនសេដ្ឋី** ( សេដ្ឋីអ្នកមានទ្រព្យច្រើន ) ហើយបានព្រះរាជទានឆត្រ ( ជាគ្រឿងសម្គាល់ភាពជាសេដ្ឋី ការកើតជាសេដ្ឋីក្នុងសម័យនោះ ព្រះរាជាទ្រង់តែងតាំងងារឲ្យ ) សម្រាប់តំណែងសេដ្ឋីដល់គេ ព្រមដោយទ្រព្យសម្បត្តិជាច្រើនទៀត ។ គ្រានោះ នាយបុណ្ណៈ បានក្រាបបង្គំទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំអាស្រ័យនៅជាមួយនឹងគេ ក្នុងត្រកូលអ្នកដទៃ អស់កាលយូរមកដល់ឥឡូវនេះ សូមព្រះតេជះជីវិតតម្កល់លើត្បូង សូមព្រះករុណា ព្រះរាជទានទីកន្លែងនៅដល់ខ្ញុំព្រះអង្គផងចុះ ព្រះករុណាថ្លៃវិសេស ។ ព្រះរាជាទ្រង់ត្រាស់អនុញ្ញាតថា ប្រសិនបើដូច្នោះ អ្នកចូរពិចារណាជ្រើសរើសមើលត្រង់

កន្លែងព្រៃមួយ ដែលតាំងនៅផ្នែកខាងត្បូងនោះ ចូរនាំយកកម្ពោតឈើនោះចេញ ហើយឲ្យគេសាងផ្ទះឡើងចុះ ត្រាស់ដូចនេះហើយ ព្រះអង្គចង្អុលប្រាប់ទីកន្លែង ដែលសាងសង់ផ្ទះរបស់សេដ្ឋីចាស់កាលពីមុន ។ បុណ្ណសេដ្ឋី បានឲ្យជាងសាងសង់ផ្ទះនៅ កន្លែងដែលព្រះរាជាប្រោសព្រះរាជទានឲ្យ បានចំណាយពេលសាងសង់ត្រឹមតែ ២-៣ ថ្ងៃប៉ុណ្ណោះ ជាងក៏ធ្វើរួចស្រេចហើយ ទើបបុណ្ណសេដ្ឋីចាត់ចែងធ្វើគេហប្បវេសន-មង្គល ( សំដៅដល់មង្គល ដែលបុគ្គលគួរធ្វើក្នុងពេលឡើងនៅផ្ទះថ្មី ឬពិធីឡើងផ្ទះថ្មី ) និងឆត្រមង្គល ( សំដៅដល់មង្គល ដែលបុគ្គលគួរធ្វើក្នុងពេលចូងឆត្រ ) ដោយធ្វើជាបុណ្យ មានការថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានជាប់គ្នា ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ដែលជាថ្ងៃក្រោយនៃការថ្វាយទាន ព្រះភគវា កាលទ្រង់ធ្វើការអនុមោទនា ទើបត្រាស់អនុបុព្វីកថា បានដល់ទានកថា ១ សីលកថា ១ សគ្គកថា ១ កាមាទីនវកថា ១ នេក្ខម្មានិសង្សកថា ១ ប្រោសដល់បុគ្គលទាំងនោះ មានបុណ្ណសេដ្ឋីជាដើម ។ ពេលដែលព្រះមានជោគត្រាស់ធម្មកថាចប់

បុណ្ណសេដ្ឋី ១ ភរិយារបស់បុណ្ណសេដ្ឋី ១ និងនាងឧត្តរាជាធីតា ១ បានជាព្រះសោតាបន្ន នៅក្នុងព្រះពុទ្ធសាសនានេះ ។ លុះក្រោយមក រាជគហសេដ្ឋីនៅនគររាជគ្រឹះ បានជ្រាបដំណឹងថា ធីតារបស់បុណ្ណសេដ្ឋី ចម្រើនវ័យធំដឹងក្តីហើយ ទើបបានទៅសុំធីតារបស់បុណ្ណសេដ្ឋី ឲ្យដល់បុត្រប្រុសរបស់ខ្លួន ។ បុណ្ណសេដ្ឋីបដិសេធថា ខ្ញុំមិនអាចលើកកូនស្រីជូនដល់លោកបានទេ ។ ទើបរាជគហសេដ្ឋី និយាយរំឭកទាមទារសងគុណថា លោកកុំនិយាយយ៉ាងនោះ លោកក៏ធ្លាប់បានអាស្រ័យនៅជាមួយនឹងខ្ញុំអស់កាលយូរដែរ ទើបបានសម្បត្តិ និងភាពជាធំកើតឡើងយ៉ាងនេះ សូម្បីតែធីតារបស់លោក ក៏លោកមិនព្រមឲ្យដល់ខ្ញុំដែរ សូមលោកឲ្យធីតារបស់លោក ដល់កូនប្រុសខ្ញុំចុះ ។ បុណ្ណសេដ្ឋី ទើបពោលតបថា លោកបានពោលដល់តែភាពជាសេដ្ឋីរបស់លោក ប៉ុណ្ណោះ លោកមិនបានដឹងថា មនុស្សយើងនឹងរស់ស្មើគ្នាយ៉ាងនេះឬ ឥឡូវនេះ ខ្ញុំអាចធ្វើបុគ្គលដូចលោកឲ្យជាទាសៈបាន តែមិនអាចធ្វើជាតិ ឬត្រកូលរបស់លោកឲ្យជាទាសៈបាន ធីតារបស់យើងជាសោតាបន្ន

ដែលថា អរិយសាវិកាឃ្លាតឆ្ងាយពីព្រះរតនត្រ័យមិនបាន ព្រោះនាង ធ្វើការបូជាដោយទ្រព្យ ដែលមានតម្លៃមួយថ្ងៃៗ ជាច្រើនកហាបណៈ រាល់ៗ ថ្ងៃ ចំណែកកូនប្រុសរបស់លោកជាមិច្ឆាទិដ្ឋិ ខ្ញុំមិនអាចលើក ធីតារបស់ខ្ញុំ ឲ្យកូនរបស់លោកបានទេ ។ គ្រានោះ កុលបុត្រទាំងឡាយ មានសេដ្ឋី និងគហបតីជាច្រើន បានមកនិយាយអង្វរបុណ្ណសេដ្ឋីថា លោកកុំទម្លាយភាពស្និទ្ធស្នាល ដែលធ្លាប់មានមកជាមួយនឹងរាជគហ-សេដ្ឋីឡើយ ។ ចំណែករាជគហសេដ្ឋី បានដឹងបំណងដែលបុណ្ណៈ ពោលបដិសេធយ៉ាងនេះហើយ ទើបប្រាប់ថា សូមលោកកុំទម្លាយ ភាពស្និទ្ធស្នាលពីមុនឲ្យសោះ ខ្ញុំនឹងឲ្យមនុស្សប្រាត់បែងផ្កា ដែលមាន តម្លៃមួយថ្ងៃៗ ២ កហាបណៈ ឲ្យដល់កូនប្រសារាល់ៗ ថ្ងៃ ។ ពេលនោះ ទើបនាយបុណ្ណសេដ្ឋី ទទួលថា ល្អហើយ គេក៏បានរៀបចំជូននាង ឧត្តរាឲ្យដល់រាជគហសេដ្ឋី ដែលក្នុងថ្ងៃនោះ ត្រូវនឹងថ្ងៃពេញបូណ៌មី ខែអាសាឍ ។

ចាប់តាំងពីកាលដែលនាងឧត្តរាទៅកាន់ត្រកូលស្វាមី នាងមិន

បានធ្វើកិច្ចអ្វី ដែលនាងធ្លាប់បានធ្វើឡើយ ថ្ងៃមួយ នាងបាននិយាយប្រាប់ស្វាមីថា ខ្ញុំធ្លាប់បានរក្សាឧបោសថប្រចាំខែ មួយខែៗ ៨ ដង ក្នុងសម័យកាល ដែលនៅក្នុងត្រកូលរបស់ខ្ញុំ ឥឡូវនេះ ប្រសិនបើបងអនុញ្ញាត ក៏ខ្ញុំនឹងអធិដ្ឋានឧបោសថសីលឡើង ។ ស្វាមីរបស់នាងមិនព្រមឲ្យនាងរក្សាឧបោសថសីលទេ ។ នាងឧត្តរាកាលបើមិនអាចធ្វើឲ្យស្វាមីអនុញ្ញាតក៏បាននៅស្ងៀម ហើយនាងគិតថា យើងនឹងរក្សាឧបោសថសីលខាងក្នុងវស្សា លុះដល់ថ្ងៃចូលវស្សា នាងក៏មិនបានឱកាសទៀត ។ ចាប់ផ្តើមពីពេលដែលនាងមករស់នៅក្នុងត្រកូលស្វាមីនាងមិនមានឱកាសដើម្បីនឹងបានចូលទៅរកភិក្ខុសង្ឃ ឬភិក្ខុនី ដើម្បីថ្វាយទាន ឬស្តាប់ព្រះធម៌ឡើយ សូម្បីនាងអង្វរ ឬធ្វើយ៉ាងណាក៏ដោយស្វាមីក៏មិនព្រមអនុញ្ញាតឲ្យដែល កាលវេលាកន្លងទៅបានប្រមាណ ២ ខែកន្លះ ទើបនាងសួរស្រីបម្រើនៅជិតដិតថា ពេលនេះ សល់ប៉ុន្មានថ្ងៃទៀតដល់ថ្ងៃចេញវស្សា ? អ្នកបម្រើស្រីតបថា ចាស នាងម្ចាស់នៅសល់តែកន្លះខែទៀតប៉ុណ្ណោះ ដល់ថ្ងៃចេញវស្សាហើយ ។ នាងឧត្តរា

ទើបបញ្ជូនដំណឹងទៅឲ្យដល់មាតាបិតារបស់នាងថា បពិត្រលោកឪពុកអ្នកម្ដាយ ខ្ញុំត្រូវលោកឪពុកអ្នកម្ដាយបញ្ជូនមករស់នៅក្នុងត្រកូលស្វាមីអ្នកជាមិច្ឆាទិដ្ឋិនេះ មិនប្រសើរឡើយ ចាប់តាំងអំពីខ្ញុំមករស់នៅក្នុងត្រកូលនេះ ខ្ញុំមិនដែលបានឱកាសធ្វើបុណ្យ សូម្បីត្រឹមតែបន្តិច ក្នុងកម្មវិធីបុណ្យផ្សេងៗ មានការឲ្យទានដល់ភិក្ខុសង្ឃជាដើមឡើយ សូមលោកឪពុកអ្នកម្ដាយបញ្ជូនប្រាក់ ១៥០០០ កហាបណៈមកឲ្យដល់ខ្ញុំផង ។ បុណ្ណសេដ្ឋី កាលបានជ្រាបដំណឹងរបស់នាងឧត្តរាដូច្នេះហើយក៏មិនសប្បាយចិត្ត ដោយគិតថា កូនស្រីរបស់យើង បានទទួលនូវសេចក្ដីទុក្ខ ទើបចាត់ចែងបញ្ជូនប្រាក់ទៅ ១៥០០០ កហាបណៈ ដោយប្រាប់ថា ក្នុងនគរនេះ មានស្រីផ្កាមាស ឈ្មោះ **នាងសិរិមា** កូនចូរនិយាយថា នាងចូរទទួលប្រាក់មួយថ្ងៃៗ ១០០០ កហាបណៈ ហើយកូនចូរចំណាយកហាបណៈទាំងនេះ ជាតម្លៃជួលនាងមក ឲ្យនាងមកធ្វើជាអ្នកបម្រើរបស់ស្វាមីកូន ចំណែកកូនវិញ ចូរធ្វើបុណ្យកុសលផ្សេងៗ ចុះ ។ ចំណែកនាងឧត្តរាកាលបានទទួលប្រាក់គ្រប់ចំនួនហើយ

ទើបឲ្យអញ្ជើញនាងសិរិមាមក ហើយប្រាប់ថា នែនាងសិរិមា ខ្ញុំរក្សាឧបោសថសីលកន្លះខែនេះ នាងចូរទទួលប្រាក់ ១៥០០០ កហាបណៈនេះ ហើយចូរបម្រើសេដ្ឋីបុត្រដែលជាស្វាមីរបស់ខ្ញុំ ក្នុងរយៈពេលកន្លះខែនេះ ។ នាងសិរិមាបានពោលរ៉ាប់រងថា ចាស បាន ។ នាងឧត្តរាក៏បាននាំនាងសិរិមាទៅកាន់សម្នាក់របស់ស្វាមី ។ កាលស្វាមីរបស់នាងឧត្តរាបានក្រឡេកឃើញនាងសិរិមា ទើបសួរថា មានរឿងអ្វីនេះ ? នាងឧត្តរាទើបប្រាប់ថា បង សូមឲ្យស្រីដែលជាសម្លាញ់របស់ខ្ញុំនេះនៅបម្រើបងជំនួសខ្ញុំបានកន្លះខែ ចំណែកខ្ញុំមានបំណងប្រាថ្នានឹងថ្វាយទាន និងស្តាប់ព្រះធម៌ទេសនា ក្នុងរយៈពេលកន្លះខែនេះ ហេតុដូច្នេះ សូមបងអនុគ្រោះដល់ខ្ញុំផង ។ គ្រានោះ ស្វាមីរបស់នាងឧត្តរា កាលបានឃើញនាងសិរិមាមានរូបស្អាតឥតខ្ចោះ ក៏កើតសេចក្តីស្រឡាញ់ ទើបនិយាយជាមួយនឹងនាងឧត្តរាថា យើងនឹងបានការរីករាយចិត្តជាមួយនឹងនាងសិរិមា ហើយបានពោលថា យើងព្រមអនុញ្ញាតឲ្យនាងរក្សាឧបោសថសីលក្នុងរយៈពេលកន្លះខែនេះចុះ ។ នាងឧត្តរាកាលបានទទួលការអនុញ្ញាត

ពីស្វាមីហើយ ទើបព្រមគ្នានឹងពួកទាសីចាត់ចែងអាហារដោយខ្លួនឯង បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រះអង្គកុំយាងទៅទីដទៃ សូមព្រះអង្គទ្រង់ទទួលភិក្ខា ក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ ក្នុងរយៈពេលកន្លះខែនេះ គ្រានាងបានទទួលការបេ្តជ្ញា របស់ព្រះមានព្រះភាគហើយ ក៏មានចិត្តត្រេកអរថា ឥឡូវនេះ យើងបានឱកាសឧបដ្ឋាកព្រះសម្មាសម្ពុទ្ធ និងបានស្តាប់ព្រះធម៌តាំងពីថ្ងៃនេះទៅ រហូតដល់ថ្ងៃបវារណា ហើយនាងបានទៅចាត់ចែងកិច្ចការគ្រប់យ៉ាង ក្នុងផ្ទះបាយធំ ទាំងបានប្រាប់ដល់ពួកទាសីថា ពួកនាងចូរដាំបបរបាយយ៉ាងនេះ ចូរចំហុយនំយ៉ាងនេះជាដើម ។

គ្រានោះ ស្វាមីរបស់នាងគិតថា ថ្ងៃស្អែកនេះជាថ្ងៃបវារណា គេបានឈរនៅត្រង់បង្អួច បែរមុខទៅខាងផ្ទះបាយធំ ពិនិត្យពិចារណាមើលដោយគិតថា នាងអន្ធពាលនោះកំពុងតែធ្វើអ្វីទៅហ្ន៎ ហើយបានក្រឡេកឃើញនាងឧត្តរា មានខ្លួនប្រឡាក់ស្រមកទៅដោយផេះ ឬមាន

ញើសហូរយ៉ាងសស្រាក់ ថែមទាំងស្រមេមស្រមាម ទៅដោយធ្យូង និងម្រែងភ្លើង ដើរធ្វើការងារច្រើនយ៉ាងនេះ ទើបគេគិតថា គួរឲ្យអាណិតស្រីអន្ធពាលនេះ ដោយមិនចេះសោយសម្បត្តិដ៏មានសិរីដូចនេះ នៅក្នុងទីលំនៅសុខស្រួល តែត្រឡប់មានចិត្តគិតត្រេកអរថា យើងនឹងឧបដ្ឋាកសមណៈក្បាលត្រងោល បានដើរខ្វល់ខ្វាយក្នុងកិច្ចការ ទើបអស់សំណើច ហើយចៀសចេញទៅ ។ កាលបើស្វាមីរបស់នាងឧត្តរាចៀសចេញទៅហើយ នាងសិរិមាដែលឈរនៅក្បែរនោះដែរ បានគិតជញ្ជឹងថា សេដ្ឋីបានសម្លឹងមើលអ្វីហ្ន៎ ទើបបានសើចចេញមកដូចនេះ ទើបនាងមើលតាមបង្អួចចុះទៅខាងក្រោម បានក្រឡេកឃើញនាងឧត្តរាហើយ គិតថា សេដ្ឋីបុត្រនេះបានសើច ព្រោះបានឃើញនាងឧត្តរានោះឯង សេចក្តីពេញចិត្តរបស់សេដ្ឋីបុត្រ នៅមានចំពោះនាងឧត្តរានៅឡើយ ។ មួយទៀត នាងសិរិមា សូម្បីថា នាងជាស្រីខាងក្រៅ មករស់នៅក្នុងផ្ទះនេះតែកន្លះខែប៉ុណ្ណោះ ដោយបានសេចក្តីសុខពីសម្បត្តិនោះ រហូតដល់ភ្លេចខ្លួនថា ខ្លួនជាស្រីខាងក្រៅ បែរជាសម្គាល់

ខ្លួនខុស ហើយគិតថា ខ្លួនជាម្ចាស់ផ្ទះនេះ ដោយនាងចងអាឃាត ចំពោះនាងឧត្តរា ដោយការប្រចណ្ឌថា យើងនឹងធ្វើឲ្យនាងឧត្តរាបាន ទទួលនូវសេចក្តីទុក្ខ ហើយនាងបានចុះចាកប្រាសាទចូលទៅផ្ទះបាយធំ ដោយនាងដើរជ្រែកចូលទៅក្នុងចន្លោះនាងទាសីទាំងឡាយ នាងបាន ចាប់យកវែកដួសខ្លាញ់ ដែលកំពុងពុះកញ្ជ្រោលនៅក្នុងខ្ទះសម្រាប់ ចៀននំ ដើរសំដៅតម្រង់ទៅរកនាងឧត្តរា ។ ឯនាងឧត្តរា កាលបាន ក្រឡេកឃើញនាងសិរិមា ដើរតម្រង់មករក ទើបផ្សាយមេត្តាចិត្ត ដល់នាងសិរិមាថា សម្លាញ់របស់យើងនេះ បានធ្វើឧបការៈដល់យើង ច្រើនណាស់ ចក្កវាឡក៏ចង្អៀត ព្រហ្មលោកក៏នៅទាប ចំណែកគុណ របស់សម្លាញ់យើងនេះធំធេងណាស់ ដោយយើងបានអាស្រ័យនឹងនាង ទើបមានឱកាសថ្វាយទាន និងស្តាប់ព្រះធម៌ ប្រសិនបើយើងមាន សេចក្តីក្រោធចំពោះនាងសិរិមា សូមឲ្យខ្លាញ់ដែលកំពុងតែក្តៅគគុក រលាកយើងចុះ តែប្រសិនបើ យើងមិនមានសេចក្តីក្រោធចំពោះនាងទេ សូមឲ្យខ្លាញ់នេះកុំរលាកយើងឡើយ ។ ខ្លាញ់ដែលកំពុងក្តៅគគុក

ដែលនាងសិរិមា បានចាក់ស្រោចទៅលើក្បាលនាងឧត្តរាប្រាកដជា ហាក់បីដូចជាទឹកត្រជាក់ ឬហាក់បីដូចជាទឹកធ្លាក់ចុះពីលើស្លឹកឈូក ដូច្នោះដែរ ។ នាងសិរិមាយល់ថា ខ្លាញ់នេះគង់នឹងត្រជាក់ ទើបយកវែកដួសខ្លាញ់ដែលកំពុងក្តៅគគុកនោះ ដាក់ឲ្យពេញវែកទៀត បានកាន់ដើរមករកនាងឧត្តរា ដោយបំណងនឹងស្រោចម្តងទៀត ។ ក្នុងខណៈនោះ ពួកទាសីរបស់នាងឧត្តរា បានឃើញនាងសិរិមាយកខ្លាញ់ស្រោចទៅលើនាងឧត្តរា ដែលជាចៅហ្វាយរបស់ខ្លួនទៀត ទើបនាំគ្នាស្រែកគំរាមឡើងព្រមគ្នាថា វ៉ឺយនាងជាមនុស្សអាក្រក់ ជាមនុស្សថោកទាប នាងចូរចៀសចេញទៅ នាងមិនគួរចាក់ខ្លាញ់ដែលកំពុងក្តៅគគុក មកលើចៅហ្វាយស្រីរបស់ពួកយើងទេ នាងបានទទួលតម្លៃឈ្នួលពីចៅហ្វាយស្រីរបស់ពួកយើង ទើបនាងមានឱកាសរស់នៅក្នុងផ្ទះនេះ តែនាងត្រឡប់ព្យាយាមធ្វើខ្លួនឯង ឲ្យដូចជាចៅហ្វាយស្រីរបស់ពួកយើង ថាហើយម្នាក់ៗ ស្ទុះក្រោកឡើងយ៉ាងរហ័សពីទីនេះខ្លះ ទីនោះខ្លះ រត់ស្រូចូលទៅបោមពោមនាងសិរិមា ដោយប្រើដៃតប់ខ្លះ វាយខ្លះ និងប្រើជើងធាក់

ឲ្យដួលចុះទៅលើផ្ទៃដី ហើយបានវាយថែមទៀត ។ ចំណែកនាងឧត្តរា មិនអាចនឹងចូលទៅហាមពួកទាសីទាំងនោះ បានទាន់ពេលវេលា តែនាងបានស្រែកហាមពួកទាសីគ្រប់គ្នា ដែលបានវាយទៅលើនាងសិរិមាឲ្យឈប់វាយទៅលើនាងសិរិមាទៀតទៅ ហើយទើបនាងសួរនាងសិរិមាថា សិរិមា តើនាងមានបំណងអ្វី ទើបនាងបានធ្វើកម្មធ្ងន់យ៉ាងនេះ ថាហើយ ទើបនាងពោលប្រៀនប្រដៅនាងសិរិមា ថែមទាំងបានងូតទឹកក្តៅឧណ្ហៗ ទាំងលាបដោយប្រេងចម្រាញ់ ១០០ ជង ឲ្យដល់នាងសិរិមាៗ ក៏មានស្មារតីដឹងខ្លួនថា ខ្លួនជាស្រីខាងក្រៅ ហើយរឭកដល់ហេតុការណ៍ដែលនាងធ្វើហើយនោះថា យើងបានចាក់ខ្លាញ់ដែលកំពុងក្តៅគគុកទៅលើនាងឧត្តរា ព្រោះហេតុតែការសើចរបស់សេដ្ឋីបុត្រ យើងបានធ្វើកម្មធ្ងន់ហើយ នាងឧត្តរាមិនបានបង្គាប់បញ្ជាឲ្យពួកនាងទាសីចាប់វាយយើងតទៅទៀត តែនាងត្រឡប់ហាមពួកទាសីទាំងអស់នោះមិនឲ្យធ្វើបាបដល់យើងទៀត សូម្បីក្នុងពេលដែលពួកទាសីគំរាមកំហែងយើង នាងបានធ្វើកម្មដែលគួរធ្វើដល់យើង ដោយការហាមមិនឲ្យពួក

ទាសីទាំងនោះ វាយយើងតទៅទៀត បើយើងមិនសូមខមាទោស ឲ្យនាងអត់ទោសដល់យើងទេ ក្បាលរបស់យើងត្រូវបែកជា ៧ ភាគ លុះនាងសិរិមាបានគិតឃើញដូច្នេះហើយ ទើបនាងក្រាបចុះទៀបបាតជើង របស់នាងឧត្តរា បានពោលសូមខមាទោសថា បពិត្រអ្នកម្ចាស់ ខ្ញុំបាន ធ្វើខុសកន្លងទៅ ព្រោះមិនបានពិចារណា សូមអ្នកម្ចាស់អត់ទោស ឲ្យដល់ខ្ញុំផងចុះ ។ នាងឧត្តរាពោលថា នែនាងសិរិមា ខ្ញុំអត់ទោស ឲ្យដល់នាងក្នុងទីនេះមិនបានទេ ខ្ញុំជាកូនមានបិតា ប្រសិនបើបិតាខ្ញុំ អត់ទោសឲ្យ ទើបខ្ញុំអត់ទោសឲ្យនាងបាន ។ ទើបនាងសិរិមាពោលថា បពិត្រអ្នកម្ចាស់ សេចក្តីនេះសូមលើកទុកសិនចុះ ខ្ញុំនឹងឲ្យបុណ្ណសេដ្ឋី ដែលជាបិតារបស់នាងម្ចាស់អត់ទោសឲ្យខ្ញុំដែរ ។ នាងឧត្តរាពោល ប្រាប់ថា នែនាងសិរិមា បុណ្ណសេដ្ឋីដែលជាបិតាបង្កើតខ្ញុំក្នុងវដ្តៈ តែកាល ព្រះបិតាអ្នកបង្កើតខ្ញុំក្នុងវិវដ្តៈ ទ្រង់អត់ទោសឲ្យខ្ញុំ ទើបអត់ទោសឲ្យនាង ។ ទើបនាងសិរិមាសួរថា បពិត្រអ្នកម្ចាស់ តើនរណាទៅដែលជាបិតាបង្កើត របស់អ្នកម្ចាស់ក្នុងវិវដ្តៈ ? នាងឧត្តរាតបថា ព្រះមុនីជាព្រះបិតាបង្កើត

ក្នុងវិវដ្ដ: ។ ទើបនាងសិរិមាពោលថា បពិត្រអ្នកម្ចាស់ ខ្ញុំមិនធ្លាប់មានការស្និទ្ធស្នាលនឹងព្រះពុទ្ធសោះឡើយ ។

គ្រានោះ នាងឧត្តរាពោលទទួលរ៉ាប់រងថា នែនាងសិរិមា ខ្ញុំជាអ្នកជួយនាង ថ្ងៃស្អែកនេះ ព្រះលោកនាយក ទ្រង់នាំភិក្ខុសង្ឃ យាងមកទីនេះ នាងចូរកាន់គ្រឿងសក្ការ: តាមតែនឹងមានមកក្នុងទីនេះ ហើយនាងចូរទៅក្រាបទូល សូមឲ្យព្រះពុទ្ធ ទ្រង់អត់ទោសឲ្យ ។នាងសិរិមាពោលតបទទួលថា ល្អហើយនាងម្ចាស់ នាងបានក្រោកឡើង ជម្រាបលានាងឧត្តរាត្រឡប់ទៅផ្ទះរបស់ខ្លួនឯង ហើយបញ្ជាស្រីបរិវារ ៥០០ នាក់ឲ្យត្រៀមខាទនីយ និងភោជនីយាហារយ៉ាងច្រើន ។ លុះព្រឹកឡើងនាងសិរិមាបានកាន់គ្រឿងសក្ការ:ដើរមកផ្ទះនាងឧត្តរា តែនាងមិនទាន់ហ៊ានចូលទៅដាក់បាត្រប្រគេនភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាននៅឡើយនាងឈរនៅស្ងៀមសិន ។ ទើបនាងឧត្តរា ទទួលយកវត្ថុទាំងអស់នោះមកចាត់ចែងឲ្យ ។ ក្នុងពេលដែលភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទ្រង់សោយភត្តាហាររួចស្រេចហើយ នាងសិរិមា ព្រមទាំងបរិវារ

បាននាំគ្នាទៅក្រាបចុះទៀប ព្រះយុគលបាទរបស់ព្រះមានព្រះភាគ ។ គ្រានោះ ព្រះសម្មាសម្ពុទ្ធត្រាស់សួរនាងសិរិមាថា នែនាងសិរិមា នាងមានកំហុសអ្វីឬ ? នាងសិរិមាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីព្រឹកម្សិលមិញនេះ ខ្ញុំបានធ្វើអំពើអាក្រក់ចំពោះអ្នកម្ចាស់ឧត្តរា តែកាលរឿងកើតឡើងដូច្នេះ អ្នកនាងម្ចាស់ឧត្តរាដែលជាសម្លាញ់របស់ខ្ញុំបាននិយាយហាមពួកទាសី ដែលធ្វើនូវអំពើអាក្រក់ដល់ខ្ញុំ អ្នកម្ចាស់ឧត្តរាបានធ្វើឧបការៈដល់ខ្ញុំដោយពិត ខ្ញុំបានរឭកនឹកគុណរបស់អ្នកម្ចាស់ឧត្តរានេះ ទើបសូមឲ្យអ្នកម្ចាស់ឧត្តរាអត់ទោសឲ្យ កាលបើដូច្នេះ អ្នកម្ចាស់ឧត្តរាប្រាប់នឹងខ្ញុំថា ប្រសិនបើព្រះពុទ្ធបិតា ទ្រង់អត់ទោសឲ្យអ្នកម្ចាស់ឧត្តរា ទើបអត់ទោសឲ្យដល់ខ្ញុំដែរ ព្រះករុណា ព្រះអង្គ ។ ពេលនោះ ទើបព្រះលោកនាថ ត្រាស់សួរនាងឧត្តរាថា នែនាងឧត្តរា យ៉ាងនោះពិតមែនឬ ? នាងឧត្តរាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ព្រះអង្គ ។ កាលពីម្សិលមិញនេះ នាងសិរិមាដែលជាសម្លាញ់របស់ខ្ញុំ បានចាក់ខ្លាញ់ដែលកំពុងតែក្តៅគគុក ស្រោចមកលើក្បាល

ខ្ញុំព្រះអង្គ ។ព្រះលោកនាយកត្រាស់សួរថា នែនាងឧត្តរា បើដូច្នោះ តើនាងគិតដូចម្តេច ? នាងឧត្តរា ក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ គិតដូច្នេះថា ចក្រវាលនេះចង្អៀត ព្រហ្មលោកក៏នៅទាប ចំណែកគុណរបស់សម្លាញ់ខ្ញុំធំធេងណាស់ ព្រោះខ្ញុំព្រះអង្គអាស្រ័យគេ ទើបបានឱកាសដើម្បីថ្វាយទាន និងស្តាប់ព្រះធម៌ជាដើម ប្រសិនបើខ្ញុំព្រះអង្គមានសេចក្តីក្រោធចំពោះនាងសិរិមា សូមឲ្យខ្លាញ់ដែលកំពុងតែក្តៅគគុកនេះរលាកខ្ញុំព្រះអង្គចុះ តែប្រសិនបើខ្ញុំព្រះអង្គមិនមានសេចក្តីក្រោធទេ ខ្លាញ់កុំរលាកខ្ញុំព្រះអង្គឡើយ ហើយខ្ញុំព្រះអង្គ ក៏បានផ្សាយនូវមេត្តាចិត្តទៅដល់នាងសិរិមានោះ ព្រះអង្គ ។ ចំណែកនាងសិរិមា បានក្រាបទូលសូមខមាទោសចំពោះព្រះមហាវីរៈ លុះព្រះមហាមុនី ទ្រង់អត់ទោសឲ្យហើយ ទើបនាងទៅសូមខមាទោសចំពោះនាងឧត្តរា ហើយនាងឧត្តរាក៏អត់ទោសឲ្យទៀត ។ ព្រះសាស្តាបានត្រាស់ឡើងថា ប្រពៃហើយៗ ឧត្តរា ការផ្ចាញ់សេចក្តីក្រោធយ៉ាងនេះគួរហើយ ធម្មតាបុគ្គលក្រោធ គប្បីផ្ចាញ់បានដោយសេចក្តីមិនក្រោធ

ផ្ចាញ់មនុស្សអសប្បុរសដោយសប្បុរស ផ្ចាញ់មនុស្សកំណាញ់បាន ដោយការឲ្យទាន ផ្ចាញ់មនុស្សនិយាយពាក្យមិនពិតដោយពាក្យពិត ជាពិសេសនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ព្រះគាថានេះថា

*បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្ដីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យទាន គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។*

ក្នុងពេលដែលព្រះមានបុណ្យ ទ្រង់សម្ដែងធម៌ទេសនានេះចប់ បានត្រាស់ធម្មកថាតទៅទៀត ដែលពោលអំពីសច្ចៈ ៤ ប្រការ គឺ **១- វចីសច្ចៈ** គឺការពិតដោយវាចា **២- សម្មតិសច្ចៈ** គឺពិតដោយសន្មត **៣- ទិដ្ឋិសច្ចៈ** គឺពិតដោយការឃើញ **៤- បរមត្ថសច្ចៈ** គឺពិតដោយបរមត្ថ កាលត្រាស់សច្ចៈទាំង ៤ ចប់ហើយ នាងឧត្តរាក៏បានតាំងនៅក្នុងព្រះសកទាគាមិផល ស្វាមី មាតាបិតារបស់ស្វាមីបានសម្រេចនូវព្រះសោតាបត្តិផល ។ ចំណែកនាងសិរិមា ព្រមទាំង

បរិវារទាំង ៥០០ នាក់ ក៏បានសម្រេចជាព្រះសោតាបន្ន ។ ក្រោយពីនាង សិរិមាបានសម្រេចជាព្រះសោតាបន្នហើយ បានក្រាបទូលនិមន្តព្រះមុនី ដើម្បីថ្វាយទានក្នុងថ្ងៃស្អែកនេះ ។

ចំណែកឧបាសិកាឧត្តរា ដែលជាអ្នកមានចិត្តពេញលេញទៅ ដោយមេត្តាចិត្ត ដែលគិតប្រាថ្នាចំពោះសេចក្តីល្អដល់អ្នកដទៃ និងអាច យកឈ្នះអំពើអាក្រក់របស់នាងសិរិមា ដោយការចូលមេត្តាឈាន (ការសម្លឹងចិត្តគិតឲ្យអ្នកដទៃបានសេចក្តីសុខ) ទើបនាងបានទទួល ការលើកតម្កើងពីព្រះវិជិតមារ ដោយកាលនោះព្រះអង្គ ទ្រង់គង់ប្រថាប់ នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ដូចមានសេចក្តីសម្តែងទុកនៅក្នុង ព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ ឈាយិនីនំ យទិទំ ឧត្តរានន្ទមាតា** ម្នាលភិក្ខុទាំងឡាយ នាងឧត្តរានន្ទមាតា ជាឯតទគ្គៈ គឺជាឧបាសិកាប្រសើរជាង ពួកឧបាសិកាអ្នកមានឈាន ស្រេចនឹងនាង ឧត្តរានន្ទមាតា ។

ភាពជាអ្នកត្រេកអរក្នុងឈានរបស់ឧបាសិកាឧត្តរា ឬមានឈ្មោះពេញថា ឧបាសិកាឧត្តរានន្ទមាតា មានរឿងជាគ្រឿងអះអាងថា នាងជាអ្នកមានចិត្តនិយមដូចនោះ សេចក្តីនៃការពិតក្នុង **គម្ពីរអង្គុត្តរនិកាយ សត្តកនិបាត** នៃ **មហាយញ្ញវគ្គទី ៥** ថា ៖

សម័យមួយ ព្រះជិនស្រី ព្រះសារីបុត្រដ៏មានអាយុ និងព្រះមហាមោគ្គល្លានដ៏មានអាយុ ត្រាច់ទៅកាន់ចារិកក្នុងទក្ខិណាគិរីជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ សម័យនោះឯង នន្ទមាតាឧបាសិកា នៅក្នុងក្រុងឈ្មោះ **វេឡុកណ្ដកៈ** ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី សូធ្យបារាយនធម៌ គឺព្រះនិព្វាន ដោយសំឡេងដ៏ពីរោះ ។ សម័យនោះឯង មហារាជឈ្មោះវេស្សវ័ណ ស្តេចចេញទៅអំពីទិសខាងជើង ទៅកាន់ទិសខាងត្បូង ដោយកិច្ចការនីមួយ ។ មហារាជ ឈ្មោះវេស្សវ័ណ បានឮនន្ទមាតាឧបាសិកា កំពុងសូធ្យបារាយនធម៌ ដោយសំឡេងដ៏ពីរោះ ក៏បង្អង់ឈរចាំស្តាប់ត្រាតែចប់ពាក្យពោល ។ លុះនន្ទមាតាឧបាសិកាសូធ្យនូវបារាយនធម៌ ដោយសំឡេងដ៏ពីរោះរួចហើយ ក៏នៅស្ងៀម ។

លំដាប់នោះ មហារាជវេស្សវ័ណ ជ្រាបច្បាស់នូវការចប់នៃកថារបស់នន្ទមាតាឧបាសិកាហើយ ក៏អនុមោទនាថា នៃនាងពីរោះណាស់ នៃនាងពីរោះណាស់ ។ នន្ទមាតាឧបាសិកាសួរថា បពិត្រព្រះអង្គមានមុខដ៏ចម្រើន ចុះអ្នកជាអ្វី ? នៃនាង ខ្ញុំជាមហារាជ ឈ្មោះវេស្សវ័ណជាប្អូននៃនាង ។ បពិត្រព្រះអង្គអ្នកមានមុខដ៏ចម្រើន ប្រពៃហើយ បើដូច្នោះធម្មបរិយាយដែលខ្ញុំពោលហើយនេះ សូមជាបណ្ណាការយ៉ាងវិសេសដល់ព្រះអង្គ ។ វេស្សវ័ណមហារាជពោលថា នៃនាងប្រពៃហើយពាក្យនោះ ចូរជាបណ្ណាការយ៉ាងវិសេសដល់ខ្ញុំចុះ ភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន មិនទាន់បានធ្វើភត្តកិច្ចក្នុងវេលាព្រឹក និងបានមកកាន់វេឡុកណ្ដកនគរក្នុងថ្ងៃស្អែក នាងចូរអង្គាសនូវភិក្ខុសង្ឃនោះ ឧទ្ទិសនូវចំណែកបុណ្យដល់ខ្ញុំផង បណ្ណាការយ៉ាងពិសេស នឹងមានដល់ខ្ញុំយ៉ាងនេះឯង ។ គ្រានោះ នន្ទមាតាឧបាសិកា លុះកាលកន្លងទៅ ក៏ប្រើបុរសម្នាក់ឲ្យចាត់ចែងខាទនីយភោជនីយាហារដ៏ឧត្ដម ក្នុងលំនៅរបស់ខ្លួន ។ លំដាប់នោះ ភិក្ខុសង្ឃ

មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន មិនទាន់ធ្វើភត្តកិច្ចក្នុងពេលព្រឹកនៅឡើយ ក៏សំដៅទៅកាន់វេឡុកណ្ដកនគរ ។ ចំណែកខាងនន្ទមាតាឧបាសិកា ក៏ហៅបុរសម្នាក់ថា នែបុរសដ៏ចម្រើន អ្នកចូរមក អ្នកចូរទៅឯអារាម ចូរក្រាបទូលនូវភត្តកាលចំពោះភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន កាលគួរហើយ ភត្តក្នុងលំនៅនៃនន្ទមាតាជាម្ចាស់ ក៏សម្រេចហើយ ។ បុរសនោះក៏ទទួលស្ដាប់នន្ទមាតាឧបាសិកាថា បាទអ្នកម្ចាស់ ហើយក៏សំដៅទៅឯអារាម ក្រាបទូលនូវកាលដល់ភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន កាលគួរហើយ ភត្តក្នុងលំនៅនៃនន្ទមាតាឧបាសិកាជាម្ចាស់ ក៏សម្រេចហើយ ។

លំដាប់នោះ ភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យចូលទៅត្រង់លំនៅដែលនន្ទមាតាឧបាសិកានៅ លុះចូលទៅដល់ហើយក៏គង់លើអាសនៈ ដែលគេក្រាលស្រេចហើយ ។ ចំណែកខាងនន្ទមាតា

ឧបាសិកា អង្គាសភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាន ជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ឧត្តមដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែហាមឃាត់ ។ នន្ទមាតាឧបាសិកា លុះកំណត់ដឹងនូវព្រះសារីបុត្រដ៏មានអាយុ កាលឆាន់រួច មានព្រះហស្តដាក់ចេញពីបាត្រហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះនន្ទមាតាឧបាសិកា អង្គុយក្នុងទីដ៏សមគួរហើយ ព្រះសារីបុត្រដ៏មានអាយុ ក៏សួរដូច្នេះថា នែនន្ទមាតា ចុះអ្នកណាប្រាប់ដំណើរមកនៃភិក្ខុសង្ឃដល់នាង ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីឯណោះ សូធ្យបារាយនធម៌ ដោយសំឡេង ( ដ៏ពីរោះ ) ហើយ នៅស្ងៀម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ស្រាប់តែមហារាជឈ្មោះវេស្សវ័ណ ដឹងច្បាស់នូវទីបំផុតនៃធម្មកថារបស់ខ្ញុំ ក៏អនុមោទនាថា នែនាងពីរោះណាស់ នែនាងពីរោះណាស់ ។ ខ្ញុំម្ចាស់សួរថា នែអ្នកមានមុខដ៏ចម្រើន ចុះអ្នកជាអ្វី ? នែនាង ខ្ញុំជាមហារាជឈ្មោះវេស្សវ័ណជាប្អូននៃនាង ។ បពិត្រព្រះអង្គមានព្រះភក្ត្រដ៏ចម្រើន ការមករបស់ព្រះអង្គប្រពៃណាស់

បើដូច្នោះ ធម្មបរិយាយដែលខ្ញុំបានពោលហើយនេះ សូមជាបណ្ណាការយ៉ាងវិសេសដល់ព្រះអង្គ ។ នៃនាង ប្រពៃហើយ ពាក្យនោះឯង សូមជាបណ្ណាការយ៉ាងវិសេសដល់ខ្ញុំ ភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន មិនទាន់ធ្វើភត្តកិច្ចក្នុងវេលាព្រឹកនៅឡើយ និមន្តមកកាន់វេឡុកណ្តកនគរ ក្នុងថ្ងៃស្អែក ចូរនាងអង្គាសភិក្ខុសង្ឃ ហើយឧទ្ទិសជូនទូវចំណែកបុណ្យដល់ខ្ញុំផង ។ បណ្ណាការយ៉ាងវិសេសនឹងមានដល់ខ្ញុំយ៉ាងនេះឯង បពិត្រលោកម្ចាស់ដ៏ចម្រើន បុណ្យក្នុងទាននេះ ( ត្រង់ពាក្យថា បុណ្យក្នុងទាន ដែលបូជាហើយ ក្នុងអដ្ឋកថាសំដៅយកចេតនា ៣ ប្រការ ) សូមឲ្យជាបុណ្យដែលខ្ញុំបូជាហើយ ដើម្បីសេចក្តីសុខដល់មហារាជឈ្មោះវេស្សវណចុះ ។ នៃនាងនន្ទមាតា អស្ចារ្យណាស់ នៃនាងនន្ទមាតា ចម្លែកណាស់ ព្រោះនាងបានចរចាក្នុងទីចំពោះមុខ ជាមួយនឹងមហារាជឈ្មោះវេស្សវណ ជាទេវបុត្រមានឫទ្ធិធំយ៉ាងនេះ មានសក្តិធំយ៉ាងនេះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត

ដែលអស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងគ្រានេះ ខ្ញុំមានកូនប្រុសម្នាក់ឈ្មោះនន្ទៈ ជាទីស្រឡាញ់ជាទីពេញចិត្តព្រះរាជាទាំងឡាយ ចាប់ទាញកំហែងកូននោះ ព្រោះហេតុនីមួយមកផ្តាច់ជីវិត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលទារកនោះ គេចាប់យកទៅហើយក្តី កំពុងចាប់ក្តី សម្លាប់ហើយក្តី កំពុងសម្លាប់ហើយក្តី បៀតបៀនហើយក្តី កំពុងបៀតបៀនក្តី ខ្ញុំម្ចាស់មិនដឹងនូវសេចក្តីប្រែប្រួលនៃចិត្តឡើយ ។ នៃនាងនន្ទមាតា អស្ចារ្យណាស់ នៃនាងនន្ទមាតាចម្លែកណាស់ កោតតែនាងជម្រះនូវហេតុត្រឹមតែការកើតឡើងនៃចិត្តបាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចម្លែកនៃខ្ញុំទេ នៅមានធម៌ឯទៀតអស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងគ្រានេះ ស្វាមីរបស់ខ្ញុំធ្វើមរណកាលទៅ ក៏ទៅកើតក្នុងកំណើតនៃយក្ខមួយ ស្វាមីរបស់ខ្ញុំនោះ សម្តែងនូវអត្តភាពដល់ខ្ញុំដូចក្នុងកាលមុន បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់មិនដឹងនូវសេចក្តីប្រែប្រួលនៃចិត្ត ដែលជាហេតុជាងនោះឡើយ ។ នៃនាងនន្ទមាតា អស្ចារ្យណាស់ នៃនាងនន្ទមាតា

ចម្លែកណាស់ កោតតែនាងជម្រះនូវហេតុត្រឹមតែការកើតឡើងនៃចិត្តបាន បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀតជាអស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំម្ចាស់នៅក្រមុំ គេនាំមកឲ្យស្វាមីកំលោះ ខ្ញុំមិនដែលប្រព្រឹត្តកន្លងដោយចិត្តទេ មិនបាច់និយាយដល់ការប្រព្រឹត្តកន្លងដោយកាយឡើយ ។ នែនន្ទមាតា អស្ចារ្យណាស់ នែនន្ទមាតា ចម្លែកណាស់ កោតតែនាងជម្រះនូវហេតុត្រឹមតែការកើតឡើងនៃចិត្តបាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនជាអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ទៀត ជាអស្ចារ្យ ចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំម្ចាស់សម្តែងខ្លួនជាឧបាសិកាឡើង មិនធ្លាប់ក្លែងប្រព្រឹត្តកន្លងនូវសិក្ខាបទណាមួយទេ ។ នែនន្ទមាតា អស្ចារ្យណាស់ នែនន្ទមាតា ចម្លែកណាស់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនជាអស្ចារ្យ ចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត ជាអស្ចារ្យ ចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ប៉ុនប៉ងជាបមកក្នុងទីនេះថា

ខ្ញុំស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ ហើយបាន ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ បីតិ និងសុខ កើតអំពី សេចក្ដីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្ក និងវិចារៈ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺ សទ្ធាមានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខ កើតអំពីសមាធិ គឺទុតិយជ្ឈាន ព្រោះវិនាសទៅនៃបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង ខ្ញុំជាអ្នកទឹករឭកដឹងច្បាស់ ទទួលនូវសុខ ដោយនាមកាយផង បានដល់នូវតតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ តែងសរសើរថា បុគ្គលមានសតិប្រកបដោយឧបេក្ខានៅជាសុខ ព្រោះ លះបង់នូវសេចក្ដីសុខផង លះបង់នូវទុក្ខផង វិនាសទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុនផង ខ្ញុំក៏បានដល់នូវចតុត្ថជ្ឈាន មានសតិ ដ៏បរិសុទ្ធដោយឧបេក្ខា មិនជាទុក្ខ មិនជាសុខ ។ នែនទ្ធមាតា អស្ចារ្យ ណាស់ នែនទ្ធមាតា ចម្លែកណាស់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនជាអស្ចារ្យ ចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត

ជាអស្ចារ្យ ចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន សំយោជនៈខាងក្រោមទាំងប្រាំណា ដែលព្រះសាស្តា ទ្រង់សម្តែងហើយ បណ្តាសំយោជនៈទាំងនោះ ខ្ញុំម្ចាស់ពិចារណាមិនឃើញនូវសំយោជនៈណាមួយក្នុងខ្លួន ដែលមិនទាន់លះបង់សោះឡើយ ។ នែននូមាតា អស្ចារ្យណាស់ នែននូមាតា ចម្លែកណាស់ ។ លំដាប់នោះ ព្រះសារីបុត្រដ៏មានអាយុ ញុំាងនន្ទមាតាឧបាសិកាឲ្យឃើញច្បាស់ ឲ្យប្រតិបត្តិតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយក្រោកចាកអាសនៈចៀសចេញទៅ ។

គុណ គឺសេចក្តីល្អ ផ្នែកខាងបរិច្ចាគទានរបស់ឧត្តរានន្ទមាតាឧបាសិកា ដែលនាងបានធ្វើហើយ ដោយចេតនាដ៏បរិសុទ្ធ ថែមទាំងបានទទួលការសរសើរពីព្រះទសពល តាមដែលមានរឿងតំណាលទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត នៃ សេក្ខបរិហានិយវគ្គ** ពោលដោយអង្គទក្ខិណាទាន ៦ ប្រការ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុង

សាវត្ថី ។ សម័យនោះឯង ឧបាសិកាជាមាតាព្រះនន្ទៈ អ្នកនៅក្នុងក្រុងវេឡុកណ្ដកៈ តម្កល់ទានប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន ។ ព្រះភគវាបានទតឃើញនន្ទមាតាឧបាសិកា អ្នកនៅក្នុងក្រុងវេឡុកណ្ដកៈ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា ដែលកំពុងតម្កល់ទានប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន លុះទតឃើញហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ នន្ទមាតាឧបាសិកា អ្នកនៅក្នុងក្រុងវេឡុកណ្ដកៈនោះកំពុងតម្កល់ទានប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានសារីបុត្រ និងមហាមោគ្គល្លានជាប្រធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះទានដែលប្រកបដោយអង្គ ៦ តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកៈទាំងឡាយមាន ៣ ។ ចុះអង្គរបស់ទាយកមាន ៣ តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ទាយកជាអ្នកមានចិត្តត្រេកអរមុនអំពីកាលឲ្យទាន ១

កំពុងតែឲ្យធ្វើចិត្តឲ្យជ្រះថ្លា ១ លុះឲ្យហើយ មានចិត្តរីករាយ ១ ។ នេះជាអង្គទាយកមាន ៣ ។ អង្គរបស់បដិគ្គាហកៈទាំងឡាយមាន ៣ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាករាគៈ ឬប្រតិបត្តិដើម្បីបន្ទោបង់រាគៈ ១ ប្រាសចាកទោសៈ ឬប្រតិបត្តិ ដើម្បីបន្ទោបង់ទោសៈ ១ ប្រាសចាកមោហៈ ឬប្រតិបត្តិ ដើម្បីបន្ទោបង់មោហៈ ១ ។ នេះជាអង្គបដិគ្គាហកៈមាន ៣ ។ អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកៈមាន ៣ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់នូវប្រមាណនៃបុណ្យ របស់ទានដែលប្រកបដោយអង្គ ៦ នេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្តីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីប្រាថ្នា ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យច្រើនប៉ុណ្ណោះបាន ។ម្នាលភិក្ខុទាំងឡាយ

ដូចបុគ្គលដែលមិនងាយកំណត់ប្រមាណនូវទឹក ក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណេះអាឡ្ហកៈក្តី ទឹកប៉ុណ្ណេះរយអាឡ្ហកៈក្តី ទឹកប៉ុណ្ណេះពាន់អាឡ្ហកៈក្តី ទឹកប៉ុណ្ណេះម៉ឺនអាឡ្ហកៈក្តីបានឡើយ ។ ដោយពិតនោះ រាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា គំនរទឹកដ៏ច្រើនប៉ុណ្ណោះបានយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់ប្រមាណនូវបុណ្យនៃទានប្រកបដោយអង្គ ៦ យ៉ាង យ៉ាងនេះថា គំនរបុណ្យគំនរកុសល ជាគ្រឿងនាំមកនូវសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសេចក្តីសុខបានឡើយ ។ ដោយពិតនោះ រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យដ៏ច្រើនប៉ុណ្ណោះបាន ក៏យ៉ាងនោះដែរ ។ គ្រាព្រះសាស្តា ទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថាថា

ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីកាលឲ្យ កំពុងឲ្យធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយ ក៏មានចិត្តត្រេកអរតាមក្រោយ នេះជា

សេចក្តីបរិបូណ៌របស់ទាន ។ បុគ្គលអ្នកប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ ជាព្រហ្មចារី មានសេចក្តីសង្រួម ឈ្មោះថា ជាខេត្តនៃទានដ៏បរិបូណ៌ដោយគុណ ។ បុគ្គលខ្វល់ខ្វាយដោយខ្លួនឯង ឲ្យទានដោយដៃរបស់ខ្លួន ។ ទាននោះជាទានមានផលច្រើន ព្រោះខ្លួនផង ព្រោះបុគ្គលដទៃផង ។ អ្នកប្រាជ្ញជាបណ្ឌិត អ្នកមានសទ្ធា មានចិត្តផុតស្រឡះចាកសេចក្តីកំណាញ់ លុះឲ្យទានយ៉ាងនេះហើយ ក៏រមែងទៅកើតក្នុងទេវលោក ជាសុខឥតមានទុក្ខ ។

នេះរាប់ថា ជាការថ្វាយទានដ៏ល្អ ដែលនាងឧត្តរានន្ទមាតាធ្វើទុកជាតួយ៉ាង ព្រោះគ្រប់អង្គទាំងអ្នកឲ្យ និងអ្នកទទួល ។

ជីវប្រវត្តិរបស់ឧត្តរាឧបាសិកា ក្រោយពីអស់ជីវិតទៅហើយ មានរឿងតំណាលទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី **ឧត្តរាវិមាន** នៅក្នុង **គម្ពីរខុទ្ទកនិកាយ វិមានវត្ថុ** ដូចមានសេចក្តីថា ៖

កាលតមក នាងឧត្តរាឧបាសិកា អ្នកជាព្រះសកទាគាមី បាន អស់ជីវិតទៅហើយ នាងបានទៅកើតក្នុងស្ថានតាវត្តិង្ស ។ គ្រានោះ ព្រះមហាមោគ្គល្លាន បាននិមន្តទៅកាន់ស្ថានតាវត្តិង្ស ថែមទាំងបានទៅ ជួបនាងឧត្តរាទេពធីតា ទើបសួរដល់បុព្វកម្ម ដែលនាងបានធ្វើទុកថា នែនាងទេពធីតា នាងមានសម្បុរល្អស្អិតនៅហើយ ញ៉ាំងទីទាំងពួង ឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹក នាងមានសម្បុរបែបនេះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគទ្រព្យទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគទ្រព្យទាំងនោះ ក៏កើតឡើងដល់នាងផង តើ ដោយហេតុអ្វី ? នែនាង ទេពធីតាមានអានុភាពច្រើន អាត្មាសួរនាង កាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ដោយហេតុអ្វី ? ទេពធីតានោះ ដែលព្រះមហាមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ដោះស្រាយនូវផលនៃកម្មនេះថា

សេចក្តីប្រណែនក្តី សេចក្តីកំណាញ់ក្តី មានះក្តី ការលើកខ្លួន

